# ព្រះពុទ្ធទ្រង់បង្រៀនអ្វី?



ធម្មទាន

លីន កុសល

ព.ស ២៥៥៥



# ព្រះពុទ្ធទ្រង់បង្រៀនអ្វី?

## ប្រែសម្រួលចេញពីសៀវភៅ

## ' What The Buddha Taught '

**Written by : Walpola Sri Rahula**

ប្រែសម្រួលដោយ : លីន កុសល

វាយអត្ថបទដោយ : កញ្ញា ជា រីណែត

បោះពុម្ពលើកទី១ : ព.ស ២៥៥៥( គ.ស ២០១១)

# អារម្ភកថា

សៀវភៅ "**ព្រះពុទ្ធទ្រង់បង្រៀនអ្វី?**" នេះ ខ្ញុំព្រះករុណាខ្ញុំបាទ បានបកប្រែនិងរៀបរៀងបន្តចេញមកពីភាសាថៃ ដែលបានបកប្រែមកពីច្បាប់ដើមជាភាសាអង់គ្លេសមានចំណងជើងថា **"What The Buddha Taught"** និពន្ធដោយព្រះភិក្ខុ**វ៉ាលប៉ូល ស្រ៊ីរាហុល**ជាជនជាតិសិរីលង្កា ហើយត្រូវបានទទួលនូវការលើកសរសើរពីមជ្ឈដ្ឋានអន្តរជាតិថាជាសៀវភៅណែនាំអំពីព្រះពុទ្ធសាសនាដ៏ល្អបំផុតមួយ មានខ្លឹមសារអធិប្បាយនូវគោលធម៌ថ្នាក់មូលដ្ឋានរបស់ព្រះពុទ្ធសាសនា ដោយការប្រើនូវពាក្យពេចន៍បែបសាមញ្ញ តែផ្តល់នូវអត្ថន័យច្បាស់លាស់ពេញលេញនិងគ្រប់ជ្រុងជ្រោយ ។

ដោយយល់ឃើញថាជាសៀវភៅដ៏ល្អនិងមានគុណតម្លៃ គួរដល់ការសិក្សាស្វែងយល់នូវព្រះធម៌ ដែលជាឱវាទទូន្មានប្រៀនប្រដៅរបស់អង្គព្រះសម្មាសម្ពុទ្ធ និងដើម្បីរួមចំណែកលើកតម្កើងនូវព្រះពុទ្ធសាសនាឱ្យកាន់តែរីកចម្រើនជាភិយ្យោភាពថែមទៀត ប្រកបព្រមដោយបំណងប្រាថ្នាចង់តបស្នងសងគុណចំពោះលោកឪពុកនិងលោកគ្រូ ដែលលោកទាំងពីរបានធ្វើមរណកាលអស់រយៈពេលជាយូរឆ្នាំមកហើយ ក៏ដូចជាដើម្បីជូនជាមហាកុសលចំពោះលោកយាយរបស់ខ្ញុំ ដែលលោកកាន់តែ

មានវ័យជរាជាលំដាប់ផងនោះ ទើបខ្ញុំសម្រេចចិត្តប្រែនិងរៀបរៀងសៀវភៅនេះឡើង ដើម្បីញុំាងជាប្រយោជន៍ឱ្យដល់ខេមរជនទូទៅ ។

សម្រាប់ការប្រែនិងរៀបរៀងនេះទៀតសោត ខ្ញុំព្រះករុណាខ្ញុំបាទបានព្យាយាមជ្រើសរើសប្រើនូវពាក្យពេចន៍ សំនួនវោហារ ភាសាសាមញ្ញ ដើម្បីងាយស្រួលដល់លោកអ្នកអាន[១] ទូទៅ( សិស្ស និស្សិត មន្ត្រីរាជការ ព្រះសង្ឃ...) ។ ដោយហេតុថាខ្ញុំព្រះករុណាខ្ញុំបាទដែលជាអ្នកប្រែនិងរៀបរៀង មានក្តីប្រាថ្នាយ៉ាងខ្លាំងក្លាក្នុងការធ្វើឱ្យសៀវភៅនេះ អាចផ្សព្វផ្សាយទៅបានយ៉ាងទូលំទូលាយគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងសង្គម ត្បិតថាតាមរយៈការសង្កេតរបស់ខ្ញុំផ្ទាល់គឺតែងប្រទះឃើញថា ភាគច្រើននៃប្រជាពលរដ្ឋខ្មែរដែលជាអ្នកមានជំនឿលើព្រះពុទ្ធសាសនា មានការយល់ដឹងតិចតួចណាស់ទាក់ទងទៅនឹងព្រះធម៌ ដែលជាឱវាទទូន្មានប្រៀនប្រដៅរបស់អង្គព្រះសម្មាសម្ពុទ្ធ( បើទុកណាជាពួកគេអះអាងថាខ្លួនជាពុទ្ធសាសនិកជនក៏ដោយ) ទាំងនេះគឺបណ្តាលមកពីបច្ច័យជាច្រើនយ៉ាង ហើយមួយនៅក្នុងចំណោមនោះគឺទាក់ទងផ្ទាល់ទៅនឹងការប្រើប្រាស់ភាសានៅក្នុងការផ្សព្វផ្សាយ ដែលស្ទើរតែទាំងអស់នៃគម្ពីរសៀវភៅឬអត្ថបទដែលស្តីអំពីព្រះពុទ្ធសាសនា បើទុកណាជា

[១] ក្នុងទីនេះសំដៅដល់អ្នកសិក្សាគឺអ្នកសិក្សាសៀវភៅនេះ ដ្បិតថាព្រះធម៌បុគ្គលគប្បីសិក្សាឱ្យបានយល់ច្បាស់ ហើយបដិបត្តិតាម មិនមែនគ្រាន់តែអានប៉ុណ្ណោះទេ ។

បានបកប្រែជាភាសាខ្មែរហើយក៏ដោយចុះ ក៏គង់នៅមានលាយឡំដោយពាក្យបាលីជាច្រើន ជាហេតុនាំឱ្យមានការលំបាកសម្រាប់អ្នកដែលចង់សិក្សាស្វែងយល់អំពីព្រះពុទ្ធសាសនា ហើយដែលមិនសូវមានចំណេះដឹងផ្នែកភាសាបាលី(ពិសេសយុវជន យុវនារីសម័យថ្មី)។ អ្វីដែលខ្ញុំព្រះករុណាខ្ញុំបាទបានរៀបរាប់មកនេះ គឺមិនមែនមានន័យថាមិនគួរប្រើនូវភាសាបាលីនោះឡើយ ព្រោះថាតាមពិតទៅគឺមានតែភាសាបាលីប៉ុណ្ណោះដែលអាចរក្សាទុកនូវព្រះពុទ្ធវចនៈរបស់អង្គព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងបាន[២]។ វិការដែលព្យាយាមប្រើនូវភាសាសាមញ្ញនេះ គឺគ្រាន់តែចង់ធ្វើឱ្យមនុស្សភាគច្រើនអាចយល់សេចក្តីបាន។ ដោយឡែកពាក្យមួយចំនួនក៏គង់នៅរក្សាជាភាសាបាលីដដែល ដោយមានពន្យល់អត្ថន័យរបស់ពាក្យនៅក្នុងបទានុក្រម ដែលលោកអ្នកអាចបើកមើលបាននៅផ្នែកខាងចុងនៃសៀវភៅនេះ។

---

[២] ព្រោះថាភាសាបាលីជាភាសាតែមួយគត់ ដែលធ្វើឱ្យមានការឯកភាពគ្នា រវាងប្រទេសដែលប្រកាន់យកនូវព្រះពុទ្ធសាសនាតាមបែបថេរវាទ មានដូចជាប្រទេសកម្ពុជា ឡាវ ថៃ ភូមា និងស្រីលង្កាជាដើម។ ដោយហេតុថាប្រសិនណាជាប្រទេសទាំងនេះ រក្សានូវព្រះពុទ្ធវចនៈដែលជាឱវាទទូន្មានប្រៀនប្រដៅរបស់អង្គព្រះសម្មាសម្ពុទ្ធ ទៅតាមភាសាជាតិរៀងៗខ្លួនវិញនោះ ក៏នឹងធ្វើឱ្យមានការខ្វែងគំនិតគ្នាទៅតាមអត្ថន័យនៃភាសាជាតិនិមួយៗនោះ (ក្នុងករណីដែលភាសាជាតិនិមួយៗមានការកែប្រែ) ជាក់ជាមិនខាន។

ហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំព្រះករុណាខ្ញុំបាទដែលជាអ្នកប្រែនិងរៀបរៀងសង្ឃឹមថា ពុទ្ធបរិស័ទទាំងឡាយដែលជាអ្នកមានចំណេះដឹងជ្រៅជ្រះនឹងមិនកើតការថ្នាំងថ្នាក់ថា ហេតុអ្វីខ្ញុំព្រះករុណាខ្ញុំបាទត្រូវពន្យល់ សូម្បីតែពាក្យដែលងាយស្រួលផងនោះ ត្បិតថាវាគឺមិនងាយស្រួលសោះឡើយ សម្រាប់អ្នកដែលមិនចេះភាសាបាលី( តើមានមនុស្សប៉ុន្មានលាននាក់ ដែលនៅមិនទាន់យល់អំពីអត្ថន័យដ៏ពិតប្រាកដនៃពាក្យថាវេទនា កម្ម វិបាក ឬសូម្បីតែពាក្យថាវិញ្ញាណនោះ?) ។

សម្រាប់អវសាននៃអារម្ភកថានេះ ខ្ញុំព្រះករុណាខ្ញុំបាទដែលជាអ្នកប្រែនិងរៀបរៀង រីករាយនឹងទទួលយកនូវមតិរិះគន់ ក៏ដូចជាយោបល់ណែនាំផ្សេងៗ ដែលកើតចេញពីកំហុសឆ្គងឬចំណុចខ្វះខាតដោយអចេតនាណាមួយ ពីសំណាក់លោកអ្នកចេះដឹងទាំងឡាយដោយក្តីគោរព ។

**"យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ "**

**"សភាវៈទាំងឡាយណា មានការកើត (ជាធម្មតា)**

**សភាវៈទាំងឡាយនោះ រមែងមានការរលត់ទៅវិញ (ជាធម្មតា)"**

១២.១៥នាទីអធ្រាត ថ្ងៃព្រហស្បតិ៍ ១រោច ខែកត្តិក

នាសរទរដូវ ព.ស២៥៥២( ១៣វិច្ឆិកា២០០៨)

**លីន កុសល**

# ឧទ្ទិសកថា

វិកុសលទាំងឡាយណា ដែលកើតចេញពីសេចក្តីព្យាយាមប្រឹងប្រែង ក្នុងការញុាំងសៀវភៅនេះឱ្យសម្រេចចេញជារូបរាងឡើង ខ្ញុំសូមជូនក៏ដូចជាឧទ្ទិសនូវកុសលទាំងឡាយនោះចំពោះ

- ព្រះតេជគុណស៊ាយ( អតីតព្រះគ្រូចៅអធិការវត្ត"ព្រះឥន្ទ្រទេព") និងជាអ្នកផ្តល់កំណើតក្នុងព្រះពុទ្ធសាសនាដល់រូបខ្ញុំ
- ព្រះតេជគុណ សោម ព្រះគ្រូចៅអធិការវត្តព្រះវិហារហ្លួង និងជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ
- លោកតាឧបាសក ចាន់ លិយកា
- លោកយាយឧបាសិកា ប្រាក់ លីន
- លោកឪពុក ប្រាក់ ចាន់ណា និង អ្នកម្តាយ សូ ម៉ានី
- អ៊ំប្រុស ហែម សារិន និង អ៊ំស្រី ជា គឹមអេង
- អ៊ំប្រុស ប្រាក់ ប៊ុនរិទ្ធ និង អ៊ំស្រី ចាន់ ម៉ាលី
- បងប្រុសជាទីគោរពរបស់ខ្ញុំ
- ញាតិកាទាំងប្រាំពីរសន្តានរបស់ខ្ញុំ
- លោកអ្នកទាំងឡាយដែលមានសេចក្តីល្អចំពោះខ្ញុំ( អ្នកដែលស្រលាញ់ខ្ញុំ)

- លោកអ្នកទាំងឡាយដែលប្រទូស្តរាយចំពោះខ្ញុំ( អ្នកដែលស្អប់ខ្ញុំ)

- អ្នកដែលបានអាននិងសិក្សាសៀវភៅនេះ

- សាសនិកជនគ្រប់សាសនាទាំងអស់ក្នុងលោក

- សព្វសត្វទាំងឡាយដែលធ្លាក់ទៅក្នុងអន្លង់នៃការកើតចាស់ ឈឺស្លាប់ និងសេចក្តីទុក្ខសោកផ្សេងៗ

សូមអ្នកទាំងឡាយទាំងអស់នោះ បានទទួលនូវចំណែកនៃមហាកុសលនេះស្មើៗគ្នា ហើយសូមឱ្យអ្នកទាំងឡាយនោះ បានដល់នូវសេចក្តីសុខដែលប្រកបដោយសន្តិ ទាំងជាអ្នកមាននូវមេត្តាចិត្តចំពោះគ្នានឹងគ្នាផងចុះ ។

 លលល✴ឥឥឥ

សូមឱ្យសច្ចធម៌ប្រាកដច្បាស់ដល់សត្វទាំងឡាយ

សូមសត្វទាំងឡាយជាអ្នកមាននូវមេត្តាចិត្តចំពោះគ្នានឹងគ្នា

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**


- អារម្ភកថា ........................................................ ២
- ឧទ្ទិសកថា ........................................................ ៦
- ព្រះពុទ្ធអង្គ ........................................................ ១៤

**ជំពូក១**

- ទស្សនគតិរបស់ពុទ្ធសាសនិកបុគ្គល .............................. ១៨
- កាលាមសូត្រ ........................................................ ២១
- សេចក្តីសង្ស័យ ........................................................ ២៤
- ខន្តិធម្ម ........................................................ ២៧
- ព្រះពុទ្ធសាសនាជាសាសនាឬជាទស្សនវិជ្ជា ..................... ៣១
- នារោងជាងស្ទូនឆ្នាំង ................................................ ៣៤
- សទ្ធា(ជំនឿ) ........................................................ ៣៧
- វិធីរក្សាសច្ចៈ ........................................................ ៤៣
- ទ្រង់ឧបមាព្រះធម៌ដូចទៅនឹងក្បូន ................................ ៤៤
- ទ្រង់ប្រៀបធៀបព្រះធម៌ជាមួយនឹងស្លឹកឈើក្នុងដៃ ......... ៤៨

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**


- ចំណោទទិដ្ឋិ( ទស្សនវិជ្ជា) .......................................... ៥០

**ជំពូក២**

- អរិយសច្ចៈ៤ .......................................................... ៥៧
- អរិយសច្ចៈប្រការទី១ : ទុក្ខ ....................................... ៥៨
- ព្រះពុទ្ធសាសនាមិនមែនជាសាសនានៃការយល់ឃើញ ...... ៥៩
- ពេទ្យដ៏ឆ្លាត .......................................................... ៦០
- ឥស្សរភាពនៅលើឥស្សរភាព ....................................... ៦៣
- តាមលំនាំនៃការពិត ................................................ ៦៥
- ខន្ធ ៥ ................................................................. ៦៩
- សុន្ទរភាពជានិរន្តរ៍ .................................................. ៨៥

**ជំពូក៣**

- អរិយសច្ចៈប្រការទី២ៈសមុទ័យ( ហេតុដែលនាំឱ្យកើតទុក្ខ) ៨៨
- អាហារតាមទ្រឹស្តីព្រះពុទ្ធសាសនា ................................ ៩២
- កម្មជាអ្វី? ............................................................ ៩៤
- ច្បាប់វដ្តចក្រ ........................................................ ១០០

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**

**ជំពូក៤**

- អរិយសច្ចៈប្រការទី៣ ៖ និរោធ(ការរំលត់ទុក្ខ)............... ១០២
- ភាសាមនុស្សភាសាធម៌ ............................................ ១០២
- និយមន័យរបស់និព្វាន ............................................ ១០៥
- មាគ៌ាឆ្ពោះទៅកាន់និព្វាន ........................................ ១០៩
- និព្វានហើយទៅណា? ............................................ ១១៤
- បរមត្ថបញ្ហា ...................................................... ១១៧
- បរមសុខក្នុងបច្ចុប្បន្ន ............................................ ១១៩
- មិនមានអ្វីនៅនានិព្វាន .......................................... ១២១

**ជំពូក៥**

- អរិយសច្ចៈប្រការទី៤ ៖ មគ្គ(ផ្លូវនាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ) ១២៤
- គុណសម្បត្តិរបស់មនុស្សដែលគ្រប់លក្ខណៈ .................... ១២៧
- អង្គប្រកបផ្នែកសីល .............................................. ១២៩
- អង្គប្រកបផ្នែកសមាធិ ............................................ ១៣២
- អង្គប្រកបផ្នែកបញ្ញា .............................................. ១៣៦

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**

- សរុបអរិយសច្ចៈ៤ .................................................. ១៣៩

**ជំពូក៦**

- ជំនឿរឿងអត្តា ........................................................ ១៤១
- ប្រភពនៃក្តីទុក្ខសោកក្នុងលោក .................................... ១៤២
- មនុស្សបង្កើតព្រះជាម្ចាស់ ........................................... ១៤៣
- ធម៌បញ្ច្រាសលោកិយ ................................................ ១៤៤
- វិភាគខន្ធ៥ ............................................................. ១៤៦
- សភាវៈដែលកើតព្រោះហេតុ( បដិច្ចសមុប្បាទ) .............. ១៤៧
- គន្លងនៃវដ្តៈ ........................................................... ១៥០
- សច្ចៈ២ប្រការ ......................................................... ១៥៣
- អ្នកស្វែងរក ........................................................... ១៥៤
- ខ្លាចនូវអ្វីដែលមិនគួរខ្លាច ........................................... ១៥៦
- វិភាគន័យក្នុងព្រះធម្មបទ ........................................... ១៥៩
- អលគទ្ទូបមសូត្រ ..................................................... ១៦១

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**

- អធិប្បាយអំពី "ខ្លួនជាទីពឹងរបស់ខ្លួន" .......................... ១៦៣
- មហាបរិនិព្វានសូត្រ ................................................ ១៦៥
- អត្តានៅឯណា? ........................................................ ១៦៩
- វិធីឆ្លើយសំនួររបស់ព្រះពុទ្ធជាម្ចាស់ .............................. ១៧២
- គោលជំហរដ៏ត្រឹមត្រូវ ................................................ ១៧៥

**ជំពូក៧**

- កម្មដ្ឋាន ឬ ការអប់រំចិត្ត( ភាវនា) .............................. ១៧៨
- ការចម្រើនកម្មដ្ឋាន .................................................. ១៧៩
- ប្រភេទនៃកម្មដ្ឋាន .................................................... ១៨០
- សតិបដ្ឋានសូត្រ ........................................................ ១៨៣
- អានាបាណស្សតិកម្មដ្ឋាន ............................................ ១៨៤
- វិធីរំលត់កំហឹង ........................................................ ១៨៩
- ឧបសគ្គរារាំងផ្លូវចិត្ត .................................................. ១៩១
- អង្គបញ្ញាជាគ្រឿងត្រាស់ដឹង ........................................ ១៩២

# មាតិការឿង

**ឧទ្ទេសបទ** **ទំព័រ**

**ជំពូក៨**


- ព្រះពុទ្ធសាសនាជាមួយលោកបច្ចុប្បន្ន .......................... ១៩៦
- ធម្មៈសម្រាប់មនុស្សគ្រប់ឋានៈ .................................... ១៩៧
- គោលធមិសម្រាប់ភាពជាពុទ្ធសាសនិកបុគ្គល.................. ២០១
- សង្គ្រាម និងសន្តិភាព ................................................ ២០៤
- ផ្លូវនៃសន្តិភាព ......................................................... ២០៦
- បទានុក្រម ............................................................ ២០៩


ឈឈឈ✲ឥឥឥ

# ព្រះពុទ្ធអង្គ

## THE BUDDHA

ព្រះពុទ្ធអង្គទ្រង់មានព្រះនាមដើមថា **"សិទ្ធត្ថ"**[៣] (សំស្ក្រឹតហៅថាសិទ្ធាថ៌) និងព្រះនាមដោយគោត្ត(ត្រកូល)ថា **"គោតម"** (សំស្ក្រឹតថាគៅតម)។ ព្រះអង្គទ្រង់គង់ប្រថាប់ នៅក្នុងប្រទេសឥណ្ឌា ភាគខាងជើងក្នុងសតវត្សរ៍ទី៦មុនគ្រិស្តសករាជ។ ព្រះរាជបិតារបស់ទ្រង់មានព្រះនាមថា**សុទ្ធោទនៈ** ជាក្សត្រនៃនគរសាក្យ(បច្ចុប្បន្នស្ថិតនៅក្នុងប្រទេសនេប៉ាល់)។ ព្រះរាជមាតារបស់ព្រះអង្គទ្រង់ព្រះនាមថា**សិរីមហាមាយា។**

យោងទៅតាមប្រពៃណីនាយុគសម័យនោះ ព្រះអង្គទ្រង់បានរៀបអភិសេកទាំងដែលទ្រង់នៅមានវ័យក្មេងនៅឡើយ ពោលគឺនៅព្រះជន្ម១៦ព្រះវស្សាជាមួយនឹងព្រះនាង**យសោធរាពិម្ពា** ដែលមានសម្រស់ស្រស់ស្អាតនិងពោរពេញទៅដោយស្វាមីភក្តិរកស្រីប្រដូចគ្មាន។ ព្រះសិទ្ធត្ថទ្រង់គង់ប្រថាប់នៅក្នុងព្រះរាជវាំងរបស់ព្រះអង្គ ព្រមជាមួយស្រីស្នំនិងរាជបរិវារ ដែលនៅរង់ចាំគាល់បំរើនិងបំពេញទៅតាមគ្រប់តម្រូវការរបស់ព្រះអង្គ។ ប៉ុន្តែដោយនឹកស្មានមិនដល់ ព្រះអង្គទ្រង់បានជួបប្រទះនូវសច្ចធម៌នៃជីវិត និងសេចក្តីទុក្ខរបស់មនុស្សជាតិ(សត្វ

---

[៣] អានថា"សិត-ធ័ត" ឬ "សិត-ធ័ត-ថៈ" ន័យថាអ្នកញុំាងប្រយោជន៍គ្រប់យ៉ាងឱ្យសម្រេច ឬអ្នកសម្រេចប្រយោជន៍បានតាមបំណង។

លោក) ទើបសម្រេចព្រះទ័យដែលនឹងរកដំណោះស្រាយ ពោលគឺផ្លូវដែលអាចរួចចាកផុតអំពីសេចក្ដីទុក្ខ ដែលមាននៅក្នុងលោក[៤] យើងនេះ។ ក្នុងព្រះជន្មាយុ២៩ព្រះវស្សា មិនយូរប៉ុន្មានបន្ទាប់ពីការប្រសូត្រនៃព្រះរាជបុត្រាមួយព្រះអង្គគត់របស់ព្រះអង្គ គឺព្រះរាជកុមារ**រាហុល** ព្រះអង្គទ្រង់បានចាកចោលអាណាចក្ររបស់ព្រះអង្គ ហើយទៅទ្រង់ផ្នួសជាបព្វជិត(ឥសី) ដើម្បីស្វែងរកផ្លូវរំលត់ទុក្ខ។

អស់រយៈពេល៦ឆ្នាំ ដែលព្រះឥសីគោតមបានធ្វើដំណើរត្រាច់ចរទៅតាមតំបន់ផ្សេងៗនៃជ្រលងទន្លេគង្គា ទ្រង់បានជួបប្រទះជាមួយគណាចារ្យផ្នែកសាសនា ដែលមានឈ្មោះបោះសំឡេងជាច្រើន។ ព្រះអង្គទ្រង់បានសិក្សានិងបដិបត្តិតាមបែបផែន ព្រមទាំងវិធីសាស្ត្រផ្សេងៗរបស់គ្រូទាំងនោះ ដោយទ្រង់ថែមទាំងបានដាក់ព្រះកាយទទួលយកនូវវត្តបដិបត្តិបែបទុក្ករកិរិយា[៥] ដ៏សែនតឹងតែងក្រៃលែង។ ប៉ុន្តែវត្តបដិបត្តិព្រមទាំងបែបផែនក៏ដូចជាវិធីសាស្ត្ររបស់សាសនាទាំងនោះ មិនបានធ្វើឱ្យព្រះអង្គទ្រង់ពេញព្រះទ័យឡើយ(ដោយទ្រង់យល់ឃើញថាមិនមែន

---

[៤] លោកក្នុងទីនេះ គឺសំដៅទៅដល់លោកទាំងអស់ ទោះក្នុងឬក្រៅចក្រវាលក៏ដោយ។

[៥] អំពើដែលបុគ្គលធ្វើបានដោយលំបាកឬដោយកម្រ ពោលគឺការធ្វើខ្លួនឱ្យលំបាកមានដូចជាការបង្អត់អាហារ ឬការមិនដេកជាដើម ដោយមានជំនឿថានឹងធ្វើខ្លួនគេឱ្យបរិសុទ្ធ ឬបានទទួលនូវការពេញចិត្តពីព្រះជាម្ចាស់ ឬពីអាទិទេពអង្គណាមួយ។

ជាផ្លូវដែលអាចនាំបុគ្គល ឱ្យរួចចាកផុតពីសេចក្តីទុក្ខបាន) ។ ដូចនោះទើបទ្រង់លះបង់ចោលនូវសាសនាទាំងឡាយដែលមានមកអំពីមុន រួមទាំងវិធីសាស្ត្រនៃសាសនាទាំងនោះ ហើយធ្វើដំណើរទៅតាមផ្លូវរបស់ព្រះអង្គផ្ទាល់ ។ បន្ទាប់ពីនោះមករហូតដល់យប់មួយ ព្រះអង្គទ្រង់បានប្រថាប់គង់នៅក្រោមដើមឈើមួយ( ចាប់ពីពេលនោះមកក៏ត្រូវបានគេហៅថា "ដើមពោធិ៍" ឬមានន័យថាដើមឈើនៃការត្រាស់ដឹង) ។ ស្ថិតក្នុងរាត្រីនោះឯងដែលព្រះអង្គទ្រង់សម្រេចបាននូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ត្រាស់ដឹងនូវលោកុត្តរធម៌ក្នុងព្រះជន្មាយុ៣៥ព្រះវស្សា ដែលបន្ទាប់ពីនោះមកព្រះអង្គត្រូវបានគេស្គាល់ក្នុងព្រះនាមថា "ព្រះពុទ្ធជាម្ចាស់ " ឬ "ព្រះអ្នកត្រាស់ដឹង"( នូវសេចក្តីពិត) ។

បន្ទាប់អំពីការត្រាស់ដឹងរបស់ព្រះអង្គហើយ ព្រះពុទ្ធជាម្ចាស់ក៏បានទ្រង់ប្រទាននូវបឋមទេសនាដល់បញ្ចវគ្គិយ៍ ដែលជាមិត្តរួមបដិបត្តិធម៌មកជាមួយព្រះអង្គតាំងតែពីគ្រាដំបូង នាឧទ្យានក្តាន់ស្ថិតក្នុង**ព្រៃឥសិបតនៈ**( បច្ចុប្បន្នស្ថិតនៅក្នុងតំបន់សារនាថរបស់ឥណ្ឌា) ជិតនគរពារាណសី ។ រាប់តាំងអំពីនោះមកអស់រយៈពេល៤៥ព្រះវស្សា ព្រះអង្គទ្រង់បានទេសនាទូន្មានមនុស្សប្រុសស្រីគ្រប់ជាន់ថ្នាក់រួមមាន ក្សត្រព្រាហ្មណ៍ មន្ត្រីរាជការ គហបតី ពាណិជ្ជករ កសិករ អ្នកសុំទាន បព្វជិតចោរ ដោយទ្រង់ពុំបានរើសមុខឬបែងចែកវណ្ណៈជាន់ថ្នាក់ក្នុងចំណោម

ជនទាំងនោះឡើយ ។ ព្រះអង្គទ្រង់មិនទទួលស្គាល់ផងដែរនូវភាពខុសប្លែកគ្នានៃវណ្ណៈ ក៏ដូចជាការបែងចែកក្រុមជននៅក្នុងសង្គម ។ ចំពោះមាគ៌ាដែលព្រះអង្គទ្រង់ទូន្មាននោះ គឺទ្រង់បើកទទួលមនុស្សគ្រប់ៗគ្នាដែលស្ម័គ្រចិត្តទទួលយកនូវឱវាទទូន្មានរបស់ព្រះអង្គ ដោយពុំមានការបង្ខិតបង្ខំអ្វីឡើយ ។

លុះព្រះជន្មាយុគម្រប់៨០ព្រះវស្សា ព្រះពុទ្ធអង្គក៏ទ្រង់រំលត់ខន្ធបរិនិព្វាននៅនា**នគរកុសិនារា**( បច្ចុប្បន្ននៅក្នុងតំបន់ឧត្តរប្រដេសរបស់ឥណ្ឌា) ។

បច្ចុប្បន្ននេះព្រះពុទ្ធសាសនាត្រូវបានគោរពនិងប្រកាន់ខ្ជាប់ នៅក្នុងបណ្ដាប្រទេសជាច្រើនដូចជា ស៊ីរីលង្កា កម្ពុជា ភូមា ថៃ ឡាវ វៀតណាម ទីបេតិ៍ ចិន ជប៉ុន ម៉ុងហ្គោលី កូរ៉េ កោះហ្វរម៉ូហ្សា( តៃវ៉ាន់) តំបន់ខ្លះនៃប្រទេសឥណ្ឌា ប៉ាគីស្ថាន នេប៉ាល់ ព្រមទាំងសហភាពសូវៀត ( រុស្ស៊ី) ផងដែរ ។

ពុទ្ធសាសនិកជនទូទាំងពិភពលោក មានចំនួនសរុបច្រើនជាង ៥០០លាននាក់( អំឡុងទសវត្សរ៍ទី៥០) ។

ଓଓଓଓ✵ଚଚଚଚ

# ជំពូក១

# ទស្សនគតិរបស់ពុទ្ធសាសនិកបុគ្គល

ក្នុងចំណោមសាស្ដានៃសាសនាទាំងឡាយ ព្រះពុទ្ធជាម្ចាស់ (ប្រសិនបើព្រមឱ្យយើងហៅព្រះអង្គថាជាសាស្ដា អ្នកបង្កើតសាសនាទៅតាមអត្ថន័យរបស់ស័ព្ទ ដែលយើងនិយមនាំគ្នាយល់ឃើញនោះ) ទ្រង់ជាសាស្ដាមួយព្រះអង្គគត់ប៉ុណ្ណោះ ដែលមិនបានអាងព្រះអង្គថាជាអ្វីផ្សេងក្រៅតែពីជាមនុស្សធម្មតាហើយបរិសុទ្ធ។ សាស្ដាទាំងឡាយដទៃ បើមិនមែនជាព្រះជាម្ចាស់ដោយខ្លួនឯង ក៏ជាអវតាររបស់ព្រះជាម្ចាស់តាមរូបភាពផ្សេងៗ ឬមិនដូច្នោះទេក៏ជាអ្នកដែលព្រះជាម្ចាស់បញ្ជូនមក។ ដោយឡែកព្រះពុទ្ធជាម្ចាស់ មិនត្រឹមតែជាមនុស្សធម្មតាប៉ុណ្ណោះទេ តែទ្រង់ថែមទាំងមិនអាងទៅដល់ការដែលព្រះអង្គបានទទួល នូវការជំរុញពីអាទិទេពអង្គណាមួយ ឬពីអំណាចវិសេសខាងក្រៅណាមួយនោះឡើយ។ ព្រះអង្គទ្រង់ចាត់ទុកថា ការត្រាស់ដឹងក៏ដូចជាការសម្រេចបានគ្រប់បែបយ៉ាងរបស់ព្រះអង្គ ជាការព្យាយាមរបស់មនុស្ស ជាសតិបញ្ញារបស់មនុស្ស ហើយជាពិសេសមនុស្សប៉ុណ្ណោះ ដែលអាចក្លាយជាព្រះពុទ្ធបាន។ មនុស្សគ្រប់គ្នាមានសក្ដានុភាព(អំណាចផ្ទាល់ខ្លួន) ដែលអាចធ្វើឱ្យខ្លួនគេក្លាយទៅជាព្រះពុទ្ធបានដោយខ្លួនឯង បើប្រសិនណាជាគេប្រាថ្នាយ៉ាង

ដូច្នោះ ហើយធ្វើនូវសេចក្តីព្យាយាម ។ ហេតុដូច្នេះយើងអាចនឹងហៅព្រះពុទ្ធជាម្ចាស់ថាជាកំពូលមនុស្សក៏បាន ដ្បិតថាព្រះអង្គទ្រង់មានភាពជាមនុស្សយ៉ាងពេញលេញនៅក្នុងព្រះវរកាយរបស់ទ្រង់ រហូតដល់ទៅថាក្នុងសម័យក្រោយៗមក ព្រះអង្គបានទទួលនូវការគោរពយ៉ាងខ្លាំងក្លាពីសំណាក់មនុស្សទូទៅ ប្រដូចទៅនឹងមនុស្សវិសេស (Super-human) ។

តាមគោលការណ៍នៃព្រះពុទ្ធសាសនា **ឋានៈរបស់មនុស្សជាឋានៈដែលខ្ពង់ខ្ពស់បំផុត។ មនុស្សជាម្ចាស់របស់ខ្លួនឯង ហើយមិនមានព្រះជាម្ចាស់ឬអាទិទេពឯណានិមួយ ដែលនឹងមកសម្រេចជោគវាសនារបស់មនុស្សបានឡើយ** ។ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ថា "**ខ្លួនជាទីពឹងរបស់ខ្លួន ពុំមានអ្នកដទៃណា ជាទីពឹងរបស់ខ្លួនបានឡើយ**" ។ ព្រះអង្គជានិច្ចជាកាល ទ្រង់ដាស់តឿនដល់សាវ័កទាំងឡាយរបស់ព្រះអង្គ ឱ្យចេះពឹងខ្លួនឯង និងមិនឱ្យស្វែងរកទីពឹងឬផ្តេកផ្តួលទៅលើបុគ្គលណាមួយផ្សេងទៀតឡើយ[៦] ។ ព្រះអង្គទ្រង់ត្រាស់ទូន្មានផ្ចុងផ្តើមនិងជំរុញ ក៏ដូចជាលើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗ ធ្វើនូវសេចក្តីចម្រើន( អភិវឌ្ឍ)ឱ្យដល់ខ្លួន និងការរួចចាកផុតពីសេចក្តីទុក្ខរបស់ពួកគេឱ្យបានសម្រេច ត្បិតថាមនុស្សមានថាមពល ដែលអាចរំដោះខ្លួនគេផ្ទាល់ពីសំយោជន៍ទាំងឡាយបាន ។

[៦] មានន័យថាមិនឱ្យធ្វើការផ្តេកផ្តួលទៅលើព្រេងវាសនា ឬមានជំនឿទៅលើការបន់ស្រន់បួងសួង ដើម្បីឱ្យទេវតាឬអាទិទេពណា មកជួយខ្លួននោះឡើយ ។

ព្រះអង្គទ្រង់ត្រាស់ថា "អ្នកទាំងឡាយគួរធ្វើនូវកិច្ចរបស់ខ្លួន ព្រោះថាតថាគតទាំងឡាយគ្រាន់តែជាអ្នកចង្អុលបង្ហាញផ្លូវប៉ុណ្ណោះ"។ ប្រសិនបើព្រះពុទ្ធជាម្ចាស់ទ្រង់បានទទួលនូវការតាំងព្រះនាមថាជា "ព្រះជួយលាងបាប"មែននោះ ក៏ប្រហែលជានៅក្នុងន័យដែលថា ព្រះអង្គបានទ្រង់ស្វែងរកឃើញនូវព្រះធម៌ និងទ្រង់ចង្អុលមាគ៌ាឆ្ពោះទៅកាន់ការរំលត់ទុក្ខគឺព្រះនិព្វានប៉ុណ្ណោះ ប៉ុន្តែយើងចាំបាច់ត្រូវតែបដិបត្តិតាមមាគ៌ានោះដោយខ្លួនយើងផ្ទាល់។ ផ្អែកលើគោលការណ៍នៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗនេះឯងហើយ ដែលព្រះពុទ្ធជាម្ចាស់បានអនុញ្ញាតឱ្យសាវ័ករបស់ព្រះអង្គមានឥស្សរភាព ដូចមានសម្តែងទុកនៅក្នុងមហាបរិនិព្វានសូត្រដែលព្រះអង្គទ្រង់ត្រាស់ថា "ព្រះអង្គមិនធ្លាប់ទ្រង់ព្រះតម្រិះដែលនឹងគ្រប់គ្រងគណៈសង្ឃឡើយ ទាំងមិនទ្រង់ប្រាថ្នាឱ្យគណៈសង្ឃពឹងពាក់អាស្រ័យ(ផ្តេកផ្តួលលើ)ព្រះអង្គផងដែរ"។ ព្រះអង្គទ្រង់ត្រាស់ថា មិនមានគោលធម៌ខាងក្នុង នៅក្នុងពាក្យទូន្មានរបស់ព្រះអង្គឡើយ គឺថាមិនមានអ្វីលាក់ទុកនៅក្នុងដៃរបស់គ្រូ(អាចរិយមុដ្ឋិ) ឬនិយាយម្យ៉ាងទៀតថា មិនមានអ្វីលាក់ទុកនៅក្នុងដៃអាវ(គ្មានអ្វីបិទបាំង)។

សេរីភាពខាងការគិត ដែលព្រះពុទ្ធបរមគ្រូទ្រង់បានអនុញ្ញាតមកនេះ ពុំមាននរណាធ្លាប់បានឮមកអំពីមុនឡើយ ក្នុងប្រវត្តិសាស្ត្រនៃសាសនាទាំងឡាយ។ សេរីភាពនេះគឺជាតម្រូវការដ៏ចាំបាច់ ព្រោះព្រះពុទ្ធ

បរមគ្រូទ្រង់បានត្រាស់ទូន្មានទុកថា **"សេចក្តីបរិសុទ្ធរបស់មនុស្ស ត្រូវអាស្រ័យការធ្វើឱ្យជាក់ច្បាស់នូវសច្ចធម៌ដោយខ្លួនឯងផ្ទាល់ មិនមែនអាស្រ័យទៅលើការអាណិតអាសូរពីព្រះជាម្ចាស់អង្គណា ដើម្បីជារង្វាន់សម្រាប់ការប្រព្រឹត្តដ៏ល្អ និងមានសេចក្តីស្មោះត្រង់ចំពោះព្រះអង្គ ឬពីអំណាចខាងក្រៅណាមួយនោះក៏ទេដែរ"** ។

## កាលាមសូត្រ

សម័យមួយ ព្រះបរមសាស្តាស្តេចយាងទៅកាន់និគមមួយកន្លែងដែលមានឈ្មោះថាកេសបុត្តៈស្ថិតក្នុងដែនកោសល ។ អ្នកនិគមនេះត្រូវបានគេស្គាល់ជាទូទៅដោយឈ្មោះថាកាលាមៈ ។ ពេលបានដំណឹងថាព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងនិគមរបស់ខ្លួន អ្នកស្រុកកាលាមៈទាំងឡាយក៏នាំគ្នាចូលទៅក្រាបបង្គំគាល់ហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន! មានសមណៈនិងព្រាហ្មណ៍ពួកខ្លះ ដែលបានមកកាន់កេសបុត្តនិគម ។ សមណៈព្រាហ្មណ៍ទាំងឡាយនោះ អធិប្បាយនិងលើកសរសើរពាក្យទូន្មានរបស់ខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះ ហើយមាក់ងាយដល់ពាក្យទូន្មានរបស់បុគ្គលដទៃ ។ តមកក៏មានសមណៈព្រាហ្មណ៍ពួកដទៃទៀតមកដល់ ។ សមណៈព្រាហ្មណ៍ទាំងនោះក៏ដូចគ្នា ម្នាក់ៗសុទ្ធសឹងអធិប្បាយនិងលើកតម្កើងនូវឱវាទទូន្មានរបស់ខ្លួនតែរៀងៗ ហើយមើល

ងាយមើលថោករិះគន់ឱវាទទូន្មានរបស់បុគ្គលដទៃ។ បពិត្រព្រះអង្គដ៏ចម្រើន! ពួកទូលព្រះបង្គំទាំងឡាយ មានសេចក្ដីសង្ស័យនិងស្ទាក់ស្ទើរនៅក្នុងចិត្តជានិច្ចថា ក្នុងចំណោមសមណៈព្រាហ្មណ៍ដ៏គួរឱ្យគោរពទាំងឡាយនោះ នរណាទៅហ្ន៎! ពោលនូវពាក្យពិត ហើយនរណាដែលពោលនូវពាក្យមិនពិត?"។

លំដាប់នោះឯងព្រះបរមសាស្ដា បានទ្រង់ប្រទាននូវឱវាទណែនាំដ៏ល្អឯក ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃសាសនាទាំងឡាយ ដល់កាលាមជនទាំងឡាយនោះថា "ប្រពៃហើយ! កាលាមជនទាំងឡាយ។ ជាការសមគួរដែលអ្នកទាំងឡាយមានក្ដីសង្ស័យ មានភាពឃ្លេងឃ្លោងចិត្ត ព្រោះក្ដីសង្ស័យដូចពោលមកនេះ កើតឡើងក្នុងរឿងដែលគួរសង្ស័យ។ ម្នាលកាលាមជនទាំងឡាយ! ចូរអ្នកទាំងឡាយពិចារណាយ៉ាងដូច្នេះថា

១. កុំជឿដោយការនិយាយរៀបរាប់

២. កុំជឿដោយការនិទានតៗគ្នា

៣. កុំជឿដោយការល្បីតៗគ្នា( ពាក្យចចាមអារ៉ាម)

៤. កុំជឿដោយអាងគម្ពីរ( តម្រា)

៥. កុំជឿដោយការប្រកាន់នូវគោលការណ៍តក្កវិទ្យានិងសន្និដ្ឋាន

៦. កុំជឿដោយការពិចារណានូវអាការខាងក្រៅ

៧. កុំជឿតាមការចូលចិត្ត ក្នុងគំនិតដែលកើតចេញពីការស្មាន របស់ខ្លួន

៨. កុំជឿដោយឃើញថា គួរនឹងប្រព្រឹត្តទៅបាន

៩. កុំជឿដោយគ្រាន់តែគិតថា អ្នកនេះជាគ្រូរបស់យើង

“ម្នាលកាលាមជនទាំងឡាយ! ពេលណាដែលអ្នកទាំងឡាយដឹងច្បាស់ដោយខ្លួនឯងថា ធម៌(សភាវៈ)ទាំងឡាយណាជាអកុសល ប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ពេលនោះចូរអ្នកទាំងឡាយលះបង់ចោលនូវធម៌ទាំងនោះ ហើយពេលណាអ្នកទាំងឡាយដឹងច្បាស់ដោយខ្លួនឯងថា ធម៌ទាំងឡាយណាជាកុសល ជាធម៌ដ៏ប្រពៃ ប្រព្រឹត្តទៅដើម្បីសេចក្ដីចម្រើន ពេលនោះអ្នកទាំងឡាយគប្បីទទួលយកនូវធម៌ទាំងឡាយនោះ ហើយបដិបត្តិតាមធម៌ទាំងឡាយនោះចុះ”។

បន្ទាប់មកព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់បន្ថែមលើនោះទៀត គឺព្រះអង្គទ្រង់ត្រាស់ប្រាប់ដល់ភិក្ខុទាំងឡាយថា ព្រះសាវ័កទាំងឡាយគួរនឹងពិចារណាត្រួតពិនិត្យ សូម្បីតែចំពោះអង្គព្រះតថាគតផ្ទាល់ ដើម្បីឱ្យព្រះសាវ័កទាំងឡាយមាននូវទំនុកចិត្តពេញទី នៅក្នុងគុណតម្លៃដ៏ពិតប្រាកដរបស់អង្គព្រះសាស្ដា ដែលខ្លួនប្រព្រឹត្តបដិបត្តិតាម។

# សេចក្តីសង្ស័យ

តាមទ្រឹស្តីព្រះពុទ្ធសាសនា សេចក្តីសង្ស័យ(វិចិកិច្ឆា)ជានីវរណៈមួយ ក្នុងចំណោមនីវរណៈទាំង៥ប្រការ ដែលជាឧបសគ្គរារាំងមិនឱ្យបុគ្គលយល់ច្បាស់នូវសច្ចធម៌ ទាំងរារាំងដល់ការរីកចម្រើនផ្នែកបញ្ញាស្មារតី(ឬទប់ស្កាត់នូវរាល់ការរីកចម្រើនផ្នែកផ្លូវចិត្តទាំងអស់)។ យ៉ាងណាក៏ដោយចុះ ការសង្ស័យមិនមែនបាប ព្រោះមិនមានក្រឹត្យក្រមនៃជំនឿណាមួយស្តីអំពីបាប ទាក់ទងទៅនឹងរឿងសេចក្តីសង្ស័យនៅក្នុងព្រះពុទ្ធសាសនាឡើយ។ តាមការពិតពុំមានបាបនៅក្នុងព្រះពុទ្ធសាសនាតាមដែលយើងនាំគ្នាយល់ដូចនៅក្នុងសាសនាមួយចំនួនឡើយ។ ឫសគល់នៃអំពើអាក្រក់ទាំងឡាយទាំងពួង គឺបណ្តាលមកពីអវិជ្ជានិងមិច្ឆាទិដ្ឋិ។ ប៉ុន្តែក៏ជាការពិតដែលមិនអាចនឹងបដិសេធបានថា ដរាបណាដែលនៅមានការសង្ស័យ ភាពឃ្លេងឃ្លោងចិត្តនិងភាពស្ទាក់ស្ទើរចិត្ត ភាពរីកចម្រើនក៏នឹងមិនមានដរាបនោះ។ ហើយក៏ជាការពិតដែលមិនអាចនឹងបដិសេធបានដូចគ្នាថា ចាំបាច់ត្រូវតែមានការសង្ស័យ ដរាបណាបុគ្គលនៅមិនទាន់យល់ឬឃើញយ៉ាងច្បាស់។ តែក្នុងការដែលនឹងរីកចម្រើនទៅមុខបាននោះ ជាការចាំបាច់ណាស់ដែល នឹងត្រូវកម្ចាត់បង់នូវការសង្ស័យ

ឱ្យបានជាមុនសិន ។ វិការដែលនឹងកម្ចាត់បង់នូវការសង្ស័យបាននោះ ចាំបាច់បុគ្គលត្រូវតែឃើញច្បាស់ដោយខ្លួនឯង ។

ជាការមិនត្រឹមត្រូវឡើយក្នុងការនិយាយថា "បុគ្គលមិនគួរសង្ស័យ" ឬ "បុគ្គលគួរជឿ" ។ **គ្រាន់តែនិយាយថា "ខ្ញុំជឿ" មិនមែនមានន័យថា អ្នកយល់និងមើលឃើញហើយនោះទេ** ។ ប្រៀបដូចជាពេលដែលកូនសិស្សដោះស្រាយនូវបញ្ហាគណិតវិទ្យា គេនឹងមកដល់ដំណាក់កាលមួយ ដែលខ្លួនគេផ្ទាល់មិនដឹងគួរធ្វើយ៉ាងណាបន្តទៅទៀត ហើយជាដំណាក់កាលដែលគេកើតការសង្ស័យនិងមិនប្រាកដក្នុងចិត្ត ។ ដរាបណាដែលគេនៅមានការសង្ស័យនោះនៅឡើយ គេនឹងមិនអាចធ្វើបន្តទៅមុខទៀតបានឡើយ ។ ផ្ទុយទៅវិញ បើគេចង់បន្តធ្វើទៅមុខទៀតបាននោះ គេចាំបាច់ត្រូវតែកម្ចាត់បង់នូវការសង្ស័យនោះជាមុនសិន ហើយផ្លូវក្នុងការកម្ចាត់បង់នូវក្តីសង្ស័យ ដែលមានត្រឹមតែការនិយាយថា "ខ្ញុំជឿ" ឬ "ខ្ញុំមិនសង្ស័យ" ប្រាកដជាមិនអាចដោះស្រាយនូវបញ្ហាទាំងនោះបានឡើយ ។ **ការបង្ខាប់ខ្លួនឯងឱ្យព្រមទទួលយកអ្វី ដោយប្រាសចាកនូវការយល់ច្បាស់នោះ គឺជាការបោកបញ្ឆោតខ្លួនឯង មិនមែនជារឿងនៃការយល់ដឹង ឬក៏សតិបញ្ញាអ្វីឡើយ** ។

ព្រះពុទ្ធជាម្ចាស់ជានិច្ចជាកាល ទ្រង់មានព្រះបំណងយ៉ាងខ្លាំងក្លាក្នុងការកម្ចាត់បង់នូវរាល់សេចក្តីសង្ស័យ (របស់សត្វលោក) ។ សូម្បីមុន

ការបរិនិព្វានរបស់ព្រះអង្គៗក៏បានទ្រង់សំណូមពរដល់សាវ័កទាំងឡាយជាច្រើនលើកច្រើនសាឱ្យទូលសួរព្រះអង្គ ប្រសិនបើសាវ័កទាំងនោះមានមន្ទិល ទាក់ទងទៅនឹងឱវាទទូន្មានរបស់ព្រះអង្គ(ព្រះធម៌) ដើម្បីជៀសវាងនូវការក្តៅក្រហាយស្តាយក្រោយថា ខ្លួនមិនអាចដោះស្រាយរាល់ការសង្ស័យទាំងឡាយឱ្យច្បាស់លាស់បាន ទាំងដែលព្រះដ៏មានព្រះភាគទ្រង់គង់ព្រះជន្មនៅឡើយ ប៉ុន្តែព្រះសាវ័កទាំងឡាយក៏នាំគ្នានៅស្ងៀម។ ព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់បានត្រាស់នៅក្នុងគ្រានោះ ជាព្រះពុទ្ធដីកាដែលគួរឱ្យចាប់ចិត្តយ៉ាងក្រៃលែង គឺព្រះអង្គទ្រង់ត្រាស់ថា"ប្រសិនបើព្រោះតែការគោរពចំពោះតថាគត ទើបធ្វើឱ្យអ្នកទាំងឡាយមិនហ៊ានសួរអ្វីនោះក៏សូមឱ្យភិក្ខុមួយអង្គក្នុងចំណោមពួកអ្នក ប្រាប់ដល់មិត្តសម្លាញ់របស់ខ្លួនចុះ(គឺសុំឱ្យភិក្ខុ១អង្គប្រាប់ដល់មិត្តរបស់ខ្លួន ដើម្បីឱ្យសួរនូវបញ្ហាជំនួសខ្លួន)"។

# ខន្តិធម៌

មិនចំពោះតែឥស្សរភាពផ្នែកគំនិតប៉ុណ្ណោះទេ ដែលនាំឱ្យមានការចម្លែកនៅក្នុងចិត្ត ដល់អ្នកសិក្សាប្រវត្តិសាស្ត្រសាសនាទាំងឡាយ សូម្បីតែអធ្យាស្រ័យដ៏ទូលំទូលាយ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រទានទុកមក ក៏ធ្វើឱ្យកើតនូវការចម្លែកក្នុងចិត្តយ៉ាងខ្លាំងណាស់ដែរ ។

សម័យមួយនាស្រុកនាលន្ទា គហបតីអ្នកមានឈ្មោះល្បីល្បាញ និងមានទ្រព្យស្តុកស្តម្ភម្នាក់មាននាមថា**ឧបាលី** ជាមនុស្សដែលអ្នកផងទូទៅស្គាល់ថា ជាសាវ័កផ្នែកគ្រហស្ថរបស់**និគ្រន្ថនាដបុត្រ**( មហាវីរៈ) ។ គាត់ត្រូវបានព្រះមហាវីរៈបញ្ជូនឱ្យទៅគាល់ព្រះពុទ្ធជាម្ចាស់ ដោយមានរៀបគំរោងទុកជាមុន ពោលគឺឱ្យយកឈ្នះ( ផ្ចាញ់) ព្រះពុទ្ធជាម្ចាស់ដោយការទូលសួរដេញដោលនូវបញ្ហាមួយចំនួន ទាក់ទងទៅនឹងទ្រឹស្តីរឿងកម្ម ដោយហេតុថា ទស្សនៈរបស់ព្រះសាស្តានៅក្នុងរឿងកម្ម មានលក្ខណៈខុសប្លែកពីទស្សនៈរបស់មហាវីរៈ ។ ផ្ទុយស្រលះពីការស្មាន នៅចុងបញ្ចប់នៃការចោទឆ្លើយគ្នា ឧបាលីកើតមាននូវជំនឿយ៉ាងមុតមាំថា ទស្សនៈរបស់ព្រះពុទ្ធជាម្ចាស់ត្រឹមត្រូវ រីឯទស្សនៈរបស់គ្រូខ្លួនជាទស្សនៈមិនត្រឹមត្រូវ ។ ហេតុដូច្នោះហើយ ទើបឧបាលីទូលអង្វករសុំឱ្យព្រះពុទ្ធជាម្ចាស់ទទួលខ្លួនជាឧបាសកម្នាក់ក្នុងចំណោមឧបាសកទាំងឡាយ ប៉ុន្តែព្រះសក្យ

មុនីបានទ្រង់ត្រាស់ប្រាប់ដល់ឧបាលី ឱ្យពិចារណារឿងនោះសាជាថ្មី ហើយមិនឱ្យឆាប់សម្រេចចិត្តព្រោះថា "ការពិចារណាដោយហ្មត់ចត់និងត្រឹមត្រូវជាការល្អ សម្រាប់មនុស្សដែលមានកេរ្តិ៍ឈ្មោះដូចជារូបអ្នក"។ ពេលឧបាលីសម្តែងនូវបំណងប្រាថ្នារបស់ខ្លួនម្តងទៀត ព្រះសម្មាសម្ពុទ្ធក៏បានទ្រង់សុំឱ្យឧបាលីនោះ គោរពឧបត្ថម្ភអាចារ្យ(គ្រូ)សាសនាចាស់របស់ខ្លួនតទៅទៀត ដូចដែលខ្លួនបានធ្វើកន្លងមក។ នៅសតវត្សរ៍ទី៣មុនគ្រិស្តសករាជ ព្រះចៅចក្រពត្តិដ៏ល្បីរន្ទឺរបស់ឥណ្ឌាព្រះនាមថាអសោក ទ្រង់ជាអ្នកគោរពនូវព្រះពុទ្ធសាសនា ជាអ្នកបដិបត្តិតាមគោលការណ៍អត់ឱននិងយោគយល់អធ្យាស្រ័យគ្នា ដែលជាឱវាទទូន្មានរបស់ព្រះសម្មាសម្ពុទ្ធទ្រង់បានលើកតម្កើងនិងឧបត្ថម្ភទំនុកបម្រុងគ្រប់សាសនាទាំងអស់ នៅក្នុងអាណាចក្រដ៏ធំធេងរបស់ព្រះអង្គ។ នៅក្នុងសេចក្តីប្រកាសព្រះរាជឱង្ការច្បាប់មួយរបស់ព្រះអង្គ ដែលត្រូវបានចារឹកនៅលើផែនសិលាហើយដែលត្រូវបានគេរក្សាទុករហូតមកដល់សព្វថ្ងៃនេះ ព្រះចៅចក្រពត្តិអង្គនោះបានទ្រង់ប្រកាសយ៉ាងដូច្នេះថា "បុគ្គលមិនគួរលើកសរសើរចំពោះសាសនារបស់ខ្លួនតែម្យ៉ាង ហើយបន្ទុះបង្អាប់សាសនារបស់បុគ្គលដទៃ។ តែផ្ទុយទៅវិញ បុគ្គលគួរសរសើរសាសនារបស់បុគ្គលដទៃផងដែរដោយអាស្រ័យហេតុផលណាមួយ។ ពេលធ្វើបានយ៉ាងដូច្នេះ បុគ្គលរមែងឈ្មោះថាជួយសាសនារបស់ខ្លួនឯងឱ្យចម្រើនលូតលាស់ផង ហើយឈ្មោះ

ថាឱ្យនូវការស្រលាញ់រាប់អានដល់សាសនាដទៃផងដែរ ។ ប៉ុន្តែប្រសិនបើធ្វើផ្ទុយពីនេះ ក៏ឈ្មោះថាជីករណ្តៅកប់សាសនារបស់ខ្លួនឯង ទាំងឈ្មោះថាធ្វើអន្តរាយឱ្យដល់សាសនាដទៃផងដែរ ។ បុគ្គលណាក៏ដោយដែលលើកសរសើរសាសនារបស់ខ្លួន ហើយប្រមាថមាក់ងាយសាសនាទាំងឡាយឯទៀត គេរមែងធ្វើយ៉ាងដូច្នោះព្រោះអាស្រ័យនូវភក្តីភាពចំពោះសាសនារបស់ខ្លួនដោយគំនិតថា "យើងនឹងលើកតម្កើងសាសនារបស់យើង" ។ តែផ្ទុយស្រលះទៅនឹងគំនិតយ៉ាងដូច្នោះរបស់គេ គេឈ្មោះថាបំផ្លាញនូវសាសនារបស់ខ្លួនឯងខ្លាំងឡើង ។ ដូច្នេះការស្រុះស្រួលគ្នានេះឯង ទើបជាការល្អ ។ **សូមឱ្យអ្នករាល់គ្នាចូរស្តាប់ និងចូរជាអ្នកពេញចិត្តនឹងស្តាប់ នូវធម៌ដែលអ្នកដទៃគេគោរពផងចុះ"** ។

គប្បីនឹងពោលបន្ថែមទុកនៅក្នុងទីនេះផងដែរថា ទឹកចិត្តយោគយល់អធ្យាស្រ័យដែលកើតមកពីការយល់ចិត្តយល់ថ្លើមគ្នានេះ គួរតែត្រូវបានគេនាំយកមកប្រើនៅក្នុងពេលបច្ចុប្បន្ននេះ(ជាពិសេសសម្រាប់សង្គមកម្ពុជា) មិនចំពោះតែអ្វីដែលទាក់ទងទៅនឹងសាសនាប៉ុណ្ណោះទេ ប៉ុន្តែគួរប្រើសម្រាប់ដោះស្រាយនូវរាល់ករណីផ្សេងៗទាំងឡាយផងដែរ ។

ទឹកចិត្តនៃការអធ្យាស្រ័យអត់ឱននិងការយោគយល់គ្នានេះ ជាខមួយនៃឧត្តមគតិដែលបានរក្សាទុកយ៉ាងល្អបំផុត ក្នុងវប្បធម៌និងអរិយធម៌របស់ព្រះពុទ្ធសាសនាតាំងពីគ្រាដំបូងមកម្ល៉េះ ។ ហើយទាំងនេះឯងជា

ហេតុផលដែលថា ហេតុអ្វីទើបមិនមានសូម្បីតែឧទាហរណ៍មួយ ស្តីអំពីការជិះជាន់គំរាមកំហែង ឬក៏ការបង្ហូរឈាមសូម្បីមួយតំណក់ ក្នុងការធ្វើឱ្យប្រជាជនផ្លាស់ប្តូរចិត្ត ត្រលប់មកគោរពរាប់អានព្រះពុទ្ធសាសនា ក៏ដូចជាការផ្សព្វផ្សាយនូវព្រះពុទ្ធសាសនា ក្នុងប្រវត្តិសាស្ត្រដ៏យូរអង្វែងជាង ២៥០០ឆ្នាំកន្លងមកនេះ ដែលព្រះពុទ្ធសាសនាបានផ្សព្វផ្សាយទៅយ៉ាងសន្តិទូទាំងផ្ទៃផែនដីនៃទ្វីបអាស៊ី ដោយមានសាសនិកជនក្នុងបច្ចុប្បន្ននេះច្រើនជាង៥០០លាននាក់( អំឡុងឆ្នាំ១៩៥០) ។

**ការប្រើអំពើហិង្សា( ហិង្សធម្ម) តាមរូបភាពណាមួយ ទោះស្ថិតក្រោមហេតុផលណាក៏ដោយ រមែងជាការប្រឆាំងទៅនឹងឱវាទទូន្មានប្រៀនប្រដៅរបស់អង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ យ៉ាងមិនអាចប្រកែកបាន ។**

# ព្រះពុទ្ធសាសនាជាសាសនាឬជាទស្សនវិជ្ជា?

ជារឿយៗដែលតែងតែមានមនុស្សចោទសួរថា ព្រះពុទ្ធសាសនាជាសាសនា(Religion) ឬជាទស្សនវិជ្ជា(Philosophy)? ។ វាមិនសំខាន់ទេដែលអ្នកនឹងហៅព្រះពុទ្ធសាសនាថាជាអ្វី ព្រះពុទ្ធសាសនាក៏នៅតែជាខ្លួនរបស់ខ្លួនឯង( នៅតែជាព្រះពុទ្ធសាសនា) ។ មិនថាអ្នកនឹងដាក់ផ្លាកឈ្មោះអ្វីឱ្យព្រះពុទ្ធសាសនា ផ្លាកឈ្មោះនោះគឺមិនសំខាន់អ្វីឡើយ ។ សូម្បីតែឈ្មោះថា"ព្រះពុទ្ធសាសនា" ដែលយើងបានហៅសំដៅទៅដល់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ក៏មានសារៈសំខាន់តិចតួចណាស់( ប្រសិនបើប្រៀបធៀបទៅនឹងខ្លឹមសារ នៃឱវាទទូន្មានរបស់ព្រះអង្គ) ។

ឈ្មោះដែលបុគ្គលបានឱ្យដល់ព្រះពុទ្ធសាសនា ជាឈ្មោះដែលមិនសំខាន់

**ឈ្មោះនោះសំខាន់ប៉ុណ្ណា អ្វីដែលយើងហៅថាជាផ្កាកុលាប**
**គង់មានក្លិនក្រអូបដូចគ្នា ទោះដោយឈ្មោះអ្វីក៏ដោយ**

ក្នុងលំនាំដូចគ្នានេះ សច្ចធម៌ក៏មិនចាំបាច់ត្រូវមានឈ្មោះ ដ្បិតថាសច្ចធម៌មិនមែនជារបស់ព្រះពុទ្ធ ព្រះយេស៊ូ ព្រះព្រហ្ម ព្រះសិវៈ ទាំងមិនមែនជារបស់ព្រះអាល់ឡាហ៏ ឬរបស់អាទិទេពអង្គណាមួយឡើយ ។

វាមិនមែនជារឿងផ្តាច់មុខរបស់នរណាម្នាក់ឡើយ។ ផ្លាកបែងចែកបក្សពួកនេះឯង ដែលជាឧបសគ្គរារាំងដល់ការយល់ច្បាស់នូវសច្ចធម៌ដោយឥស្សរៈ។ ផ្ទុយទៅវិញ វាត្រលប់ជាបង្កឱ្យកើតនូវអគតិ ដែលជាអន្តរាយដល់ចិត្តគំនិតរបស់មនុស្ស។

អ្វីដែលពោលមកខាងលើនេះជាការពិត មិនចំពោះតែក្នុងរឿងសតិបញ្ញានិងផ្នែកចិត្តគំនិតប៉ុណ្ណោះទេ តែក៏ជាការពិតនៅក្នុងរឿងសម្ព័ន្ធភាព រវាងមនុស្សនិងមនុស្សផងដែរ។ ឧទាហរណ៍ដូចជាពេលដែលយើងបានជួបនឹងមនុស្សម្នាក់ យើងមិនគ្រាន់តែមើលគេក្នុងឋានៈដែលគេជាមនុស្សម្នាក់ប៉ុណ្ណោះទេ តែយើងនៅបានដាក់ឈ្មោះឱ្យគេថែមទៀតផង ដូចជាចិន ជប៉ុន អង់គ្លេស បារាំងជាដើម ហើយមានអារម្មណ៍ចំពោះគេយ៉ាងពេញទៅដោយអគតិជាច្រើន ដែលជាប់មកជាមួយនឹងផ្លាកឈ្មោះនោះក្នុងចិត្តគំនិតរបស់យើង ទាំងដែលការពិតគេអាចនឹងជាអ្នកដែលប្រាសចាកនូវលក្ខណៈទាំងឡាយ ដែលយើងបានដាក់ឱ្យគេនោះក៏ថាបាន។

មនុស្សទាំងឡាយចូលចិត្តដាក់ឈ្មោះ សម្រាប់បែងចែកបក្សពួកគ្នា ហើយពួកគេទៅឆ្ងាយរហូតដល់ថ្នាក់ថា យកឈ្មោះទាំងនោះមកដាក់ឱ្យដល់លក្ខណសម្បត្តិឬអារម្មណ៍របស់មនុស្ស ដែលជារបស់សាមញ្ញសម្រាប់មនុស្សគ្រប់គ្នា។ ហេតុដូច្នេះឯង ទើបមានការនាំគ្នានិយាយទៅ

ដល់ការបំពេញទាន( ការឱ្យ) តាមបែបផ្សេងៗ ។ ឧទាហរណ៍ដូចជាការបំពេញទានបែបពុទ្ធ ឬការបំពេញទានបែបគ្រិស្ត ហើយនាំគ្នាមាក់ងាយដល់ការបំពេញទានប្រភេទដទៃៗ ។ តាមពិតទៅការបំពេញទាននោះមិនមែនជារបស់និកាយណាមួយឡើយ ។ ការបំពេញទានមិនមែនជារបស់គ្រិស្ត មិនមែនរបស់ពុទ្ធ ហិណ្ឌូ ឬមូស្លីម ដូចគ្នាទៅនឹងការស្រលាញ់របស់មាតាដែលមានចំពោះកូនរបស់ខ្លួន ក៏មិនមែនជារបស់ពុទ្ធឬគ្រិស្តពោលគឺវាជាសេចក្ដីស្រលាញ់របស់មាតានោះឯង ។ លក្ខណសម្បត្តិនិងអារម្មណ៍របស់មនុស្សដូចជាការស្រលាញ់ ការអាណិតអាសូរ ក្ដីមេត្តា ការអត់ធ្មត់ ការយោគយល់អធ្យាស្រ័យ សេចក្ដីប្រាថ្នា ការខឹងក្រោធ ការស្អប់ខ្ពើម ការព្យាបាទ ការច្រណែន សេចក្ដីលោភលន់ អវិជ្ជា ឬមានះជាដើម មិនចាំបាច់ត្រូវដាក់ឈ្មោះ ព្រោះវាមិនបានចំណុះដោយផ្ទាល់ទៅលើសាសនាណាមួយឡើយ ។

សម្រាប់អ្នកស្វែងរកសច្ចធម៌ វាមិនសំខាន់ថាគោលគំនិតនោះមានប្រភពមកពីណាឡើយ ព្រោះថាតាមការពិតទៅការយល់ច្បាស់នូវសច្ចធម៌ មិនចាំបាច់ដែលនឹងត្រូវដឹងថា ពាក្យទូន្មាននោះមានប្រភពមកពីព្រះពុទ្ធជាម្ចាស់ឬពីបុគ្គលណាមួយឡើយ ។ អ្វីដែលជាសារៈសំខាន់បំផុតនោះក៏គឺការឃើញនិងយល់ច្បាស់ ទៅតាមធាតុពិតនៃសភាវៈនោះៗ ។ មានរឿងដ៏សំខាន់មួយ នៅក្នុងមជ្ឈិមនិកាយ( ព្រះសូត្រទី១៤០) ដែល

ជាឧទាហរណ៍គាំទ្រនូវការអធិប្បាយខាងលើនេះ ។

## នារោងជាងស្មូនឆ្នាំង

សម័យមួយព្រះបរមសាស្តា ទ្រង់ញុាំងរាត្រីឱ្យកន្លងផុតទៅ នៅក្នុងរោងរបស់ជាងស្មូនឆ្នាំង ។ នៅក្នុងរោងរបស់ជាងស្មូនឆ្នាំងនោះឯង មានសមណៈកំលោះម្នាក់ បានមកដល់ទីនោះមុនព្រះអង្គ ប៉ុន្តែលោកមិនបានស្គាល់ព្រះពុទ្ធអង្គថាជានរណាឡើយ ។ ព្រះពុទ្ធអង្គទ្រង់សង្កេតមើលសមណៈរូបនោះហើយមានព្រះតម្រិះថា "លក្ខណៈឫកពារបស់សមណៈកំលោះនេះគួរជាទីពេញចិត្តនៃមនុស្សផងទាំងឡាយ ។ ជាការល្អប្រសិនបើយើងសួររឿង ដែលទាក់ទងនឹងខ្លួនគេខ្លះ" ។ ដូចនោះទើបព្រះពុទ្ធអង្គត្រាស់សួរទៅលោកថា "ម្នាលភិក្ខុ! អ្នកបានចេញចាកផ្ទះបួសនៅក្នុងនាមរបស់បុគ្គលណា ហើយនរណាជាគ្រូរបស់អ្នក ឬថាអ្នកចូលចិត្តធម៌របស់អ្នកណា?" ។ សមណៈកំលោះអង្គនោះក្រាបទូលថា "ម្នាលអាវុសោ! មានក្សត្រមួយព្រះអង្គបានចេញចាកសាក្យត្រកូលមកបួសជាសមណៈ មានកិត្តិស័ព្ទល្បីរន្ទឺខ្ចរខ្ចាយទៅក្នុងទិសទាំងពួងថា ព្រះអង្គជាព្រះអរហន្ត ជាព្រះសម្មាសម្ពុទ្ធ ។ ក្នុងនាមព្រះដ៏មានព្រះភាគនោះឯងហើយ ទើបខ្ញុំចេញបួស ។ ព្រះអង្គទ្រង់ជាសាស្តារបស់ខ្ញុំ ហើយខ្ញុំចូលចិត្តលទ្ធិ( ធម៌ ) របស់ព្រះអង្គ" ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរបន្តថា "ព្រះដ៏

មានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ឥលូវនេះទ្រង់ប្រថាប់គង់នៅឯណា?"។ សមណៈកំលោះក្រាបទូលថា "សម្លាញ់នៅនាផែនដីភាគខាងជើងឯណោះ មាននគរមួយឈ្មោះថាសាវត្ថី។ នាទីនោះឯង ដែលព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់ប្រថាប់នៅ"។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សួរទៀតថា "លោកធ្លាប់បានឃើញព្រះពុទ្ធអង្គទេ ហើយលោកអាចស្គាល់ព្រះអង្គទេ ប្រសិនបើលោកបានជួបនឹងទ្រង់?"។ សមណៈនោះទូលតបថា "ខ្ញុំព្រះករុណាមិនធ្លាប់បានឃើញព្រះអង្គឡើយ ហើយក៏ប្រហែលនឹងមិនស្គាល់ព្រះអង្គដែរ ប្រសិនបើបានជួបនឹងទ្រង់"។ ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបច្បាស់ក្នុងព្រះទ័យថា ក្នុងនាមព្រះអង្គនេះឯងហើយ ដែលសមណៈកំលោះរូបនេះបានចេញបួស ដោយទ្រង់មិនបានបង្ហើបប្រាប់ថា ព្រះអង្គនឹងព្រះសម្មាសម្ពុទ្ធអង្គនោះគឺជាបុគ្គលតែមួយនោះឡើយ ប៉ុន្តែទ្រង់ត្រាស់ថា "ម្នាលភិក្ខុ! យើងនឹងសម្តែងធម៌ដល់អ្នក ចូរអ្នកតាំងចិត្តស្តាប់ដោយគោរពចុះ"។ សមណៈកំលោះទទួលពាក្យព្រះអង្គដោយវាចាថា "សម្តែងចុះសម្លាញ់"។

លំដាប់នោះឯងព្រះពុទ្ធជាម្ចាស់ បានទ្រង់ប្រទាននូវព្រះសូត្រដែលសម្តែងពីសច្ចៈដ៏ល្អឯកមួយ ដល់សមណៈកំលោះរូបនោះ(ខ្លឹមសារនៃព្រះសូត្រនេះ នឹងបង្ហាញជូននៅទំព័រខាងមុខ)។

លុះចប់ព្រះសូត្រនោះឯង ទើបសមណៈកំលោះដែលមានឈ្មោះ

ថាបុក្កុសាតិដឹងច្បាស់នៅក្នុងចិត្តថា បុគ្គលដែលនិយាយជាមួយខ្លួនអម្បាញ់មិញ ការពិតក៏គឺជាព្រះពុទ្ធអង្គហ្នឹងឯង។ ដូច្នោះហើយ ទើបលោកក្រោកឈរឡើង ហើយដើរចូលមករកព្រះពុទ្ធជាម្ចាស់ ក្រាបចុះទៀបទៅនឹងព្រះបាទរបស់ព្រះបរមសាស្តា ទូលសូមខមាទោសក្នុងការដែលហៅព្រះអង្គថា "សម្លាញ់" ដោយមិនបានដឹងខ្លួន។ បន្ទាប់មកលោកក៏បានទូលសូមឱ្យព្រះពុទ្ធអង្គប្រទាននូវឧបសម្បទា(បំបួស) និងព្រមទទួលលោកឱ្យចូលទៅក្នុងគណៈសង្ឃ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សួរទៅលោកថា "មានបាត្រនិងចីវរគ្រប់គ្រាន់ហើយឬនៅ?" (ព្រះភិក្ខុចាំបាច់ត្រូវមានត្រៃចីវរនិងបាត្រសម្រាប់សុំអាហារ)។ ពេលបុក្កុសាតិទូលតបដោយពាក្យបដិសេធ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា "តថាគតនឹងមិនផ្តល់នូវឧបសម្ប័ទដល់បុគ្គលណា វៀរលែងតែគេមានបាត្រនិងចីវរគ្រប់គ្រាន់ហើយប៉ុណ្ណោះ"។ ហេតុដូច្នោះឯង ទើបបុក្កុសាតិក្រាបបង្គំលាព្រះពុទ្ធអង្គចេញទៅខាងក្រៅដើម្បីស្វែងរកបាត្រនិងចីវរ តែជាអកុសលលោកត្រូវបានគោជល់របួតដល់នូវមរណៈ។

តមកពេលដំណឹងដ៏គួរឱ្យសោកសៅនេះ បានផ្សព្វផ្សាយមកដល់ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់បានប្រកាសថាបុក្កុសាតិជាបណ្ឌិត ជាអ្នកបានឃើញច្បាស់ហើយនូវសច្ចធម៌ និងបានសម្រេចនូវអនាគាមិផល ក្នុងការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន។ ហើយទ្រង់ប្រកាសថាបុក្កុសាតិកើត

ហើយនៅក្នុងភព ដែលលោកនឹងបានសម្រេចជាព្រះអរហន្ត(នៅពេលខាងមុខ) ហើយនៅទីបំផុតលោកក៏នឹងនិព្វាន ទាំងមិនត្រលប់មកកាន់លោកនេះទៀតឡើយ។

តាមរយៈរឿងនេះ គឺបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ពេលបុក្កុសាតិស្តាប់ព្រះពុទ្ធអង្គទ្រង់មានព្រះពុទ្ធដីកា ហើយយល់ច្បាស់នូវឱវាទរបស់ព្រះពុទ្ធអង្គនោះ លោកមិនបានទាំងដឹងផងថា នរណាកំពុងនិយាយជាមួយលោក ឬថានោះជាពាក្យទូន្មានរបស់នរណា ប៉ុន្តែលោកក៏បានយល់ច្បាស់ហើយនូវសច្ចធម៌(បើថ្នាំល្អរោគក៏នឹងជា មិនចាំបាច់ត្រូវដឹងថានរណាផ្សំថ្នាំនោះ ឬថាថ្នាំនោះមកពីទីណាឡើយ)។

## សទ្ធា(ជំនឿ)

សាសនាស្ទើរតែទាំងអស់ ត្រូវបានបង្កើតឡើងមកដោយអាស្រ័យសទ្ធា ដែលមើលទៅហាក់ដូចជាសទ្ធាដែលប្រាសចាកការយល់ច្បាស់។ ដោយឡែកព្រះពុទ្ធសាសនាវិញ គឺសង្កត់ធ្ងន់ទៅលើការឃើញយ៉ាងប្រត្យក្ស ការដឹង ការយល់ នឹងថាសង្កត់ធ្ងន់ទៅលើសទ្ធានោះគឺមិនមែនឡើយ។ បើទោះណាជាថាក្នុងគម្ពីរព្រះពុទ្ធសាសនា មានពាក្យថា "សទ្ធា"(សំស្ក្រឹតថា ស្រទ្ធា) ដែលប្រែតាមធម្មតាថាទំនុកចិត្តឬជំនឿ (Faith or Belief) តែការពិតសទ្ធានៅក្នុងទីនេះ គឺមិនមែនជាជំនឿឬ

ទំនុកចិត្ត ដែលប្រាសចាកតួបញ្ហានោះឡើយ គ្រាន់តែថាសទ្ធារបស់ពុទ្ធសាសនិកជនបានដល់ការប្រាកដក្នុងចិត្ត(បូករួមជាមួយនឹងយោនិសោមនសិការ) ដែលកើតចេញពីការជឿជាក់ទៅលើព្រះពុទ្ធសាសនា ក៏ដូចជាការប្រើតាមធម្មតានៅក្នុងគម្ពីរផ្សេងៗប៉ុណ្ណោះ។

ពិតមែនហើយ យើងទទួលស្គាល់ថាពាក្យ"សទ្ធា"នេះ មានចំណែកជាFaith(ភាពស្មោះត្រង់)ខ្លះដែរ ក្នុងន័យដែលពាក្យសទ្ធានេះសំដៅទៅដល់ស្វាមីភក្តិចំពោះព្រះពុទ្ធជាម្ចាស់ ចំពោះព្រះធម៌(ពុទ្ធោវាទ) និងចំពោះព្រះសង្ឃ។

បើនិយាយទៅតាមទស្សនៈរបស់ព្រះថេរៈអសង្គៈ ដែលជាទស្សនវិទូដ៏ល្បីល្បាញរបស់ព្រះពុទ្ធសាសនា(មហាយាន) ក្នុងកំឡុងពុទ្ធសតវត្សរ៍ទី១0នោះ សទ្ធាមានលក្ខណៈ៣ប្រការគឺ

១. ការជឿជាក់យ៉ាងមុតមាំនិងឥតងាករេថា សភាវៈណាមួយនោះមានពិតហើយតាំងនៅពិត

- Full and firm conviction that a thing is

២. សេចក្តីពេញចិត្តទៅលើលក្ខណៈសម្បត្តិ ដែលល្អប្រពៃ

- Serene joy at good qualities

៣. ក្តីស្រមើស្រមៃឬការប្រាថ្នា ដែលនឹងទទួលបានជោគជ័យទៅតាមគោលដៅ ដែលបានរំពឹងទុក

- Aspiration or wish to achieve an object in view

ទោះជាយ៉ាងណាក៏ដោយចុះ សទ្ធាឬជំនឿដែលយើងបានដឹង ដូចនៅក្នុងសាសនាផ្សេងៗនោះ មានការពាក់ព័ន្ធតិចខ្លាំងណាស់ជាមួយនឹងព្រះពុទ្ធសាសនា។

**បញ្ហារឿងជំនឿកើតឡើង នៅពេលដែលបុគ្គលមិនបានឃើញច្បាស់ ប៉ុន្តែផ្ទុយទៅវិញ ក្នុងខណៈដែលអ្នកឃើញច្បាស់នូវបញ្ហា រឿងជំនឿក៏នឹងអស់ទៅដោយឯកឯង។** ប្រសិនបើខ្ញុំប្រាប់អ្នកថា ខ្ញុំមានកែវមណី១គ្រាប់នៅក្នុងដៃរបស់ខ្ញុំ បញ្ហារឿងជំនឿនឹងកើតឡើង ព្រោះអ្នកមិនបានឃើញកែវមណីនោះដោយផ្ទាល់ភ្នែក។ ប៉ុន្តែប្រសិនបើខ្ញុំលាដៃរបស់ខ្ញុំចេញ ហើយឱ្យអ្នកឃើញកែវមណី ម្តងនេះអ្នកក៏នឹងឃើញដោយផ្ទាល់ភ្នែករបស់អ្នក បញ្ហារឿងជំនឿក៏មិនកើតឡើង ដូចមាននៅក្នុងខ្លឹមសារនៃគម្ពីរព្រះពុទ្ធសាសនាតាំងពីបុរាណថា "ឃើញច្បាស់ប្រៀបដូចបុគ្គលឃើញ នូវកែវមណីនៅលើបាតដៃ"។

សាវ័កមួយអង្គរបស់ព្រះពុទ្ធជាម្ចាស់ មាននាមថា**មុសីលៈ** បានប្រាប់ដល់ភិក្ខុអង្គឯទៀតថា "ម្នាលលោកសវិដ្ឋៈ! ខ្ញុំដឹងនិងជ្រាបច្បាស់ថា ការរលត់ទៅនៃភពគឺនិព្វាន(Nirvana) មិនចាំបាច់អាស្រ័យការមានភាពស្មោះត្រង់ សទ្ធាឬការជឿ ដោយមិនបាច់មានការចូលចិត្ត ឬការទោរទន់ចិត្ត ដោយមិនបាច់និយាយរ៉ាយរ៉ាប់ប្រាប់ ឬដោយការនិយាយតៗគ្នា ដោយមិនបាច់ពិចារណារកហេតុផល ដោយមិនបាច់មានការពេញចិត្ត

ដែលកើតចេញពីការសន្និដ្ឋាន"។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ! តថាគតពោលថា ការកម្ចាត់បង់នូវកិលេសនិងអាសវៈ គឺសម្រាប់បុគ្គលអ្នកដឹងនិងអ្នកឃើញ នឹងថាសម្រាប់បុគ្គលអ្នកមិនដឹងមិនឃើញនោះ គឺមិនមែនឡើយ"**។

រឿងដែលទាក់ទងទៅនឹងការដឹងហើយនិងការយល់នេះ រមែងចោទជាបញ្ហាជានិច្ច។ ដោយឡែករឿងជំនឿគឺមិនមែនជាបញ្ហាសោះឡើយ ត្បិតថាឱវាទទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ មានលក្ខណៈពិសេសគឺជា**ឯហិបស្សិកោ** ប្រែថា**អញ្ជើញឱ្យមកមើលតែមិនមែនឱ្យមកជឿនោះទេ (ន័យថាឱ្យមកពិសោធត្រួតពិនិត្យឬសាកល្បងបាន តែជឿឬមិនជឿគឺជាការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ)**។ គ្រប់ខ្លឹមសារដែលបានប្រើនៅក្នុងគម្ពីរព្រះពុទ្ធសាសនា អះអាងទៅដល់បុគ្គលដែលបានធ្វើឱ្យជាក់ច្បាស់នូវសច្ចធម៌ រមែងប្រើពាក្យយ៉ាងដូច្នេះថា "ចក្ខុឃើញច្បាស់នូវធម៌(ធម្មចក្ខុ) ដែលប្រាសចាកធុលីនិងមន្ទិល បានកើតឡើងហើយ។ គេបានឃើញច្បាស់ហើយនូវសច្ចធម៌ បានដល់នូវសច្ចធម៌ បានដឹងនូវសច្ចធម៌ បានចាក់ធ្លុះនូវសច្ចធម៌ បានឆ្លងផុតចាកការសង្ស័យ ជាអ្នកប្រាសចាកការញាប់ញ័រ គេបានឃើញច្បាស់នូវសច្ចធម៌ តាមសេចក្តីពិត(យថាភូតំ)ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះ"។

ពេលអាងទៅដល់ការត្រាស់ដឹងរបស់ព្រះអង្គផ្ទាល់ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង(អាលោកៈ)កើតឡើងហើយ"។ ជារឿងការមើលឃើញដោយអាស្រ័យញាណ(ញាណទស្សន) ឬបញ្ញា មិនមែនជាការមើលឃើញដោយអាស្រ័យសទ្ធានោះឡើយ ។

អ្វីដែលបានពោលមកទាំងប៉ុន្មាននេះ រឹតតែបង្ហាញនូវប្រត្យក្សភាពខ្លាំងឡើងថែមទៀត នៅសម័យដែលលទ្ធិសាសនាព្រាហ្មណ៍ ព្យាយាមអូសទាញមនុស្សឱ្យមានជំនឿយ៉ាងខ្ជះខ្ជិធមិ ហើយឱ្យព្រមទទួលយកនូវអ្វីដែលជាការបដិបត្តិតៗគ្នាមក ព្រមទាំងប្រើអំណាចក្នុងការចង្អុលកំណត់ថា លទ្ធិសាសនារបស់ខ្លួនប៉ុណ្ណោះដែលពិត ។

សម័យមួយ ពួកព្រាហ្មណ៍ដែលប្រកបទៅដោយការសិក្សាច្រើន និងមានឈ្មោះល្បីល្បាញមួយក្រុម បានចូលទៅគាល់ព្រះពុទ្ធជាម្ចាស់ ហើយបានសន្ទនាចោទឆ្លើយជាមួយនឹងព្រះអង្គ អស់រយៈពេលយ៉ាងយូរ ។ ម្នាក់ក្នុងចំណោមនោះ ជាមាណពអាយុ១៦ឆ្នាំមាននាមថា **កាបឋិកៈ** ជាអ្នកដែលបានទទួលការជ្រើសរើសពីពពួកព្រាហ្មណ៍ទាំងនោះថា ជាអ្នកដែលមានសតិបញ្ញាឆ្លាតវាងវៃ ពិបាកក្នុងការរកអ្នកដទៃឯណាមកប្រៀបផ្ទឹមបាន បានចោទជាសំណួរទៅកាន់ព្រះពុទ្ធជាម្ចាស់ថា "បពិត្រព្រះគោតមដ៏ចម្រើន! មានគម្ពីរដ៏សក្តិសិទ្ធិរបស់ពួកព្រាហ្មណ៍

តាំងពីបុរាណ ដែលត្រូវបានគេរក្សាត១គ្នាមកដោយមុខបាឋ(ដោយការទន្ទេញមាត់) ដោយមិនមានបាត់វគ្គណាមួយឡើយ។ ទាក់ទងទៅនឹងគម្ពីរទាំងនោះ ពួកព្រាហ្មណ៍ទាំងឡាយបានសម្រេចមតិជាឯកច្ឆន្ទថា "រឿងនេះប៉ុណ្ណោះដែលពិត រឿងដទៃគឺមិនពិតទាំងអស់"។ ចុះចំណែកព្រះគោតមដ៏ចម្រើនវិញ តើទ្រង់យល់ឃើញយ៉ាងណាដែរ ទាក់ទងជាមួយនឹងរឿងទាំងនេះ?"។

លំដាប់នោះឯង ព្រះពុទ្ធអង្គទ្រង់ត្រាស់តបទៅវិញថា "ម្នាលព្រាហ្មណ៍! ក្នុងបណ្តាព្រាហ្មណ៍ទាំងឡាយនោះ មានព្រាហ្មណ៍ណាម្នាក់ទេដែលអះអាងថា ខ្លួនដឹងនិងឃើញយ៉ាងប្រត្យក្សថា សភាវៈនេះប៉ុណ្ណោះដែលពិត សភាវៈទាំងឡាយដទៃគឺមិនពិតទាំងអស់?"។ ដោយភាពជាមនុស្សស្មោះត្រង់ ទើបមាណពនោះក្រាបបង្គំទូលថា "មិនមានទេក្រាបទូល"។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សួរតទៅទៀតថា "ចុះមានអាចារ្យ(គ្រូ)ណាម្នាក់ទេ? ឬអាចារ្យរបស់អាចារ្យរបស់ព្រាហ្មណ៍ទាំងនោះរាប់ថយក្រោយ៧តំណ ឬសូម្បីតែនរណាម្នាក់ក្នុងចំណោមអ្នករចនាគម្ពីរពីបុរាណមកមានទេ ដែលអួតអាងថាខ្លួនដឹងនិងឃើញថាសភាវៈនេះប៉ុណ្ណោះដែលពិត សភាវៈទាំងឡាយដទៃគឺមិនពិតទាំងអស់?"។ មាណពនោះទូលថា "មិនមានទេក្រាបទូល"។ ទើបព្រះពុទ្ធអង្គត្រាស់ថា "ម្តងនេះវាក៏មិនខុសអ្វីទៅនឹងជួររបស់មនុស្សខ្វាក់ភ្នែក។ ម្នាក់ៗក៏តោងជាប់ជាមួយ

អ្នកដែលនៅខាងមុខខ្លួន។ អ្នកនៅខាងមុខក៏មើលមិនឃើញ អ្នកកណ្តាលក៏មើលមិនឃើញ អ្នកក្រោយក៏មើលមិនឃើញដូចគ្នា។ ដោយន័យនេះទើបតថាគតមានទស្សនៈថា សភាពរបស់ព្រាហ្មណ៍ទាំងឡាយនោះ គឺប្រដូចទៅនឹងសភាពរបស់មនុស្សខ្វាក់យ៉ាងដូច្នោះឯង"។ លំដាប់នោះឯង ព្រះពុទ្ធជាម្ចាស់បានទ្រង់ប្រទាននូវព្រះឱវាទ ដែលមានខ្លឹមសារយ៉ាងសំខាន់ក្រៃលែង ដល់ពពួកព្រាហ្មណ៍ទាំងនោះថា "មិនមែនជាការសមគួរឡើយ សម្រាប់បណ្ឌិតអ្នកទ្រទ្រង់(រក្សា)នូវសច្ចៈ ដែលនឹងសម្រេចនូវការយល់ឃើញថា រឿងនេះប៉ុណ្ណោះដែលពិត រឿងដទៃគឺមិនពិតទាំងអស់"។

## វិធីរក្សាសច្ចៈ

ពេលមាណពនោះ ទូលសុំឱ្យព្រះអង្គអធិប្បាយនូវគោលគំនិតក្នុងការទ្រទ្រង់ឬរក្សាសច្ចៈនោះ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា "បុគ្គលម្នាក់មានការប្រកាន់យកនូវជំនឿមួយរបស់ខ្លួន។ ប្រសិនបើគេពោលថា "នេះជាជំនឿរបស់ខ្ញុំ"។ ត្រឹមប៉ុណ្ណេះ គេឈ្មោះថានៅរក្សាបាននូវសច្ចៈ។ តែផ្អែកទៅលើជំនឿនោះ គេមិនគប្បីឈានទៅដល់ការសរុបយ៉ាងដាច់អហង្កាថា "រឿងនេះប៉ុណ្ណោះដែលពិត រឿងដទៃគឺមិនពិតទាំងអស់"។ និយាយម្យ៉ាងទៀតថា បុគ្គលអាចនឹងជឿនូវអ្វីដែលគេចូលចិត្ត ហើយគេ

ក៏អាចផងដែរក្នុងការពោលថា "ខ្ញុំជឿរឿងនេះ"។ ត្រឹមប៉ុណ្ណោះ គេឈ្មោះថានៅគោរពសច្ចៈ។ ផ្ទុយទៅវិញ ដោយអាស្រ័យត្រឹមតែការជឿឬសទ្ធារបស់គេ គេមិនគប្បីនិយាយថា រឿងដែលគេជឿប៉ុណ្ណោះទើបជាការពិត រឿងដទៃគឺមិនពិតទាំងអស់ "។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា "ការប្រកាន់មាំទៅលើអ្វីមួយ (ការយល់ឃើញណាមួយ) ហើយមាក់ងាយអ្វីដទៃ(ទស្សនះដទៃ)ថាជារឿងថោកទាប ទង្វើបែបនេះបណ្ឌិតទាំងឡាយចាត់ទុកថា ជាសំយោជន៏ម្យ៉ាង "។

## ទ្រង់ឧបមាព្រះធម៌ដូចនៅនឹងក្បូន

សម័យមួយ ព្រះពុទ្ធជាម្ចាស់ទ្រង់អធិប្បាយ អំពីគោលការណ៏នៃហេតុនិងផលដល់សាវ័ករបស់ព្រះអង្គ ដោយសាវ័កទាំងឡាយនោះក្រាបទូលថា បានឃើញនិងបានយល់នូវហេតុផលទាំងនោះយ៉ាងជាក់ច្បាស់ដូច្នោះមែន។ គ្រានោះឯង ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! សូម្បីទិដ្ឋិទាំងឡាយនេះ ដែលបរិសុទ្ធនិងប្រាកដច្បាស់ដល់ម្ល៉េះក៏ដោយ។ បើអ្នកទាំងឡាយនៅប្រកាន់មាំនូវទិដ្ឋិទាំងឡាយនេះ នៅបណ្ដោយចិត្តឱ្យពាក់ព័ន្ធជាមួយ នៅឃើញថាជារបស់ដែលមានតម្លៃទាំងនៅជាប់ជំពាក់ជាមួយវានៅឡើយនោះ។ អ្នកទាំងឡាយក៏នឹងមិន

យល់ទេថា ព្រះធម៌គឺប្រៀបបីដូចជាក្បូន ដែលជាវត្ថុប្រើសម្រាប់ចម្លងពោលគឺមិនមែនសម្រាប់ប្រកាន់មាំនោះទេ ” ។

ក្នុងទីងទៀត ព្រះពុទ្ធអង្គក៏បានទ្រង់អធិប្បាយនូវឧបមាដ៏ល្អឯកនេះ ហើយដែលនៅក្នុងខឧបមានោះ ព្រះពុទ្ធជាម្ចាស់ទ្រង់បានធ្វើការប្រៀបធៀបពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គ( ព្រះធម៌) ថា ប្រៀបបីដូចជាក្បូនសម្រាប់ឆ្លងទឹក មិនមែនសម្រាប់ជាប់ជំពាក់ ហើយលីលើស្មាទៅជាមួយនោះឡើយ ។

“ម្នាលភិក្ខុទាំងឡាយ! ឧបមាថាមានបុរសម្នាក់កំពុងធ្វើដំណើរ ហើយគេបានធ្វើដំណើរមកដល់ អាងទឹកដ៏ធំល្វឹងល្វើយមួយ ។ ត្រើយខាងនេះ ពោរពេញទៅដោយអន្តរាយផ្សេងៗ ប៉ុន្តែត្រើយម្ខាងទៀត ជាទីក្សេមក្សាន្តប្រាសចាកអន្តរាយ ។ មិនមានទូកសម្រាប់ឆ្លងទៅកាន់ត្រើយដែលជាទីក្សេមក្សាន្តនិងប្រាសចាកអន្តរាយ ហើយក៏មិនមានស្ពានណាមួយសម្រាប់ឆ្លងឡើយ ។ ហេតុដូច្នេះទើបបុរសនោះ រំពឹងក្នុងចិត្តថា “ផ្ទៃសាគរនេះ ពិតជាធំល្វឹងល្វើយណាស់ ។ ត្រើយខាងនេះ ក៏ពេញទៅដោយអន្តរាយផ្សេងៗ ។ ដោយឡែកត្រើយខាងនោះ ជាទីក្សេមក្សាន្តប្រាសចាកអន្តរាយទាំងពួង ។ មិនមានទូកសម្រាប់ឆ្លងទៅត្រើយនាយ ទាំងមិនមានស្ពាន ដែលអាចឆ្លងទៅត្រើយនាយនោះបានផងដែរ ។ ហេតុដូច្នេះប្រហែលជាការប្រសើរ ប្រសិនបើយើងនឹងប្រមូលរួបរួមស្មៅ មែកឈើ

និងស្លឹកឈើដើម្បីធ្វើជាក្បូន ហើយដោយអាស្រ័យក្បូននោះឯង យើងនឹងឆ្លងទៅត្រើយខាងនោះបានយ៉ាងមានសុវត្ថិភាព ដោយប្រើដៃហើយនិងជើងរបស់យើងផ្ទាល់"។ "ម្នាលភិក្ខុទាំងឡាយ! គិតដូច្នោះហើយទើបបុរសនោះព្យាយាមប្រមូលរួបរួមស្មៅ ឈើ មែកឈើនិងស្លឹកឈើដើម្បីធ្វើក្បូន ហើយដោយអាស្រ័យក្បូននោះ គេបានឆ្លងទៅកាន់ត្រើយម្ខាងទៀតដោយសុវត្ថិភាព ដោយប្រើដៃនិងជើងរបស់គេផ្ទាល់។ បន្ទាប់ពីបានឆ្លងទៅដល់ត្រើយម្ខាងទៀតហើយ បុរសនោះគិតថា "ក្បូននេះបានជួយយើងច្រើនណាស់ ហើយដោយជំនួយរបស់ក្បូននេះ ទើបយើងអាចឆ្លងមកបានយ៉ាងមានសុវត្ថិភាព ដោយអាស្រ័យដៃនិងជើងរបស់យើងផ្ទាល់។ វាពិតជាការប្រសើរ ប្រសិនបើយើងទូលក្បូននេះនៅលើសិរសា ឬយកទៅជាមួយយើង នៅគ្រប់ទីដែលយើងទៅ"។

"ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយគិតឃើញយ៉ាងដូចម្ដេច ប្រសិនបើបុរសម្នាក់នោះធ្វើដោយលំនាំយ៉ាងដូច្នេះ គេឈ្មោះថាធ្វើត្រឹមត្រូវឬទេជាមួយនឹងក្បូននោះ?" ពេលភិក្ខុទាំងនោះក្រាបទូលថា "មិនត្រឹមត្រូវទេព្រះអង្គ"។ ទើបព្រះអង្គទ្រង់ត្រាស់ថា "ចុះដោយអាស្រ័យនូវវិធីណាមួយ ទើបគេឈ្មោះថាបដិបត្តិបានយ៉ាងត្រឹមត្រូវ ចំពោះក្បូននោះ បន្ទាប់ពីបានឆ្លងទៅដល់ត្រើយម្ខាងទៀតហើយ"? ឧទាហរណ៍ថា បុរសនោះនឹកគិតយ៉ាងដូច្នេះថា "ក្បូននេះបានជួយយើងច្រើនណាស់

ហើយដោយជំនួយរបស់ក្បូននេះ ទើបយើងអាចឆ្លងមកបានយ៉ាងមានសុវត្ថិភាព ដោយអាស្រ័យដៃនិងជើងរបស់យើងផ្ទាល់។ វាប្រហែលជាការប្រសើរ ប្រសិនបើយើងកើយក្បូននេះទុកនឹងច្រាំងនៅទីនេះ ឬចតវាទុកឱ្យអណ្តែតទឹក ហើយទៅតាមផ្លូវដែលយើងត្រូវទៅ ទោះទីណាក៏ដោយ"។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយគិតឃើញយ៉ាងដូចម្តេច ប្រសិនបើបុរសម្នាក់នោះ ធ្វើដោយលំនាំយ៉ាងដូច្នេះ? គេឈ្មោះថាធ្វើត្រឹមត្រូវឬទេជាមួយនឹងក្បូននោះ?"។ ភិក្ខុទាំងនោះទូលតបថា "ត្រឹមត្រូវហើយក្រាបទូល"។

"ម្នាលភិក្ខុទាំងឡាយ! ក្នុងលំនាំដូចគ្នានេះដែរ តថាគតបានបង្រៀនគោលធម៌ដែលស្រដៀងទៅនឹងក្បូន ពោលគឺក្បូននោះសម្រាប់ប្រើឆ្លងទឹក មិនមែនសម្រាប់កាន់យកទៅយ៉ាងណាមុំញ។ ធម៌ទាំងឡាយណា ដែលតថាគតបានសម្តែងហើយដល់អ្នកទាំងឡាយ គឺប្រព្រឹត្តទៅដើម្បីការធ្វើឱ្យជាក់ច្បាស់នូវទីបំផុតនៃសេចក្តីទុក្ខ មិនមែនសម្រាប់ប្រកាន់មាំក៏យ៉ាងនោះដែរ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយដែលយល់ហើយថា ព្រះធម៌ស្រដៀងទៅនឹងក្បូន គប្បីលះបង់ចោលនូវការប្រកាន់មាំចំពោះអ្វីៗទាំងឡាយ(ធម៌) ចាំបាច់និយាយថ្វីទៅដល់ការលះបង់នូវអំពើមិនល្អទាំងឡាយ(អធម៌)នោះ"។

តាមរយៈការប្រៀបធៀបនេះ បានបង្ហាញឱ្យយើងឃើញយ៉ាង

ច្បាស់ថា ឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ គឺមានគោលដៅនាំមនុស្ស ឆ្ពោះទៅកាន់សេចក្តីសុខ សុវត្ថិភាព ភាពស្ងប់ ភាពត្រជាក់ត្រជុំ ព្រមទាំងកម្ចាត់បង់បាន នូវសេចក្តីទុក្ខទាំងឡាយទាំងពួង នៅក្នុងលោក (ព្រះនិព្វាន)។ ព្រះពុទ្ធអង្គមិនបានទ្រង់ត្រាស់រឿងទាំងឡាយ ដោយគ្រាន់តែដើម្បីតបស្នងទៅនឹងការចង់ដឹងចង់ឃើញ ទៅតាមសតិបញ្ញា របស់មនុស្ស ឬដើម្បីអួតអាងអំពីព្រះប្រាជ្ញាញាណនោះឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ព្រះអង្គទ្រង់ជាសាស្តាដែលជាអ្នកបដិបត្តិ (ត្រាស់យ៉ាងណាធ្វើយ៉ាងនោះ) ហើយទ្រង់ត្រាស់ទូន្មានចំពោះតែអ្វីទាំងឡាយ ដែលនាំមកនូវសេចក្តីសុខនិងសេចក្តីស្ងប់ ដល់សត្វលោកទាំងឡាយប៉ុណ្ណោះ។

## ទ្រង់ប្រៀបធៀបព្រះធម៌ជាមួយនឹងស្លឹកឈើក្នុងដៃ

គ្រាមួយព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រថាប់គង់នៅនាព្រៃមួយ ស្ថិតក្នុងនគរកោសម្ពី(បច្ចុប្បន្ននៅជិតស្រុកអាឡាហាក់បាដ Allahabad)។ ពេលនោះឯង ព្រះអង្គទ្រង់បានចាប់យកនូវស្លឹកឈើមួយចំនួនមកទុកក្នុងព្រះហត្ថ ហើយត្រាស់សួរទៅកាន់ព្រះសាវ័កទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយគិតឃើញយ៉ាងដូចម្តេច រវាងស្លឹកឈើដែលនៅក្នុងដៃរបស់តថាគត ជាមួយនឹងស្លឹកឈើដែលនៅក្នុងព្រៃនេះ។ តើស្លឹកឈើណា ដែលមានចំនួនច្រើនជាង?"។

"បពិត្រព្រះអង្គដ៏ចម្រើន! ស្លឹកឈើដែលនៅក្នុងព្រះហត្ថរបស់ព្រះអង្គតិចជាងច្រើនណាស់ បើប្រៀបធៀបទៅនឹងស្លឹកឈើដែលមាននៅក្នុងព្រៃនេះ"

"ម្នាលភិក្ខុទាំងឡាយ! ដូចគ្នានេះដែរ ក្នុងបណ្ដាអ្វីដែលតថាគតបានត្រាស់ដឹងហើយនោះ តថាគតបានប្រាប់ដល់អ្នកទាំងឡាយ ត្រឹមបន្តិចបន្តួចប៉ុណ្ណោះ រីឯអ្វីដែលតថាគតមិនបានប្រាប់ដល់អ្នកទាំងឡាយនោះ គឺមានច្រើនលើសលន់។ ហើយព្រោះហេតុអ្វីទៅ ទើបតថាគតមិនប្រាប់រឿងទាំងនោះដល់អ្នកទាំងឡាយ? ព្រោះថារឿងទាំងនោះឯងមិនមានប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីការកម្ចាត់បង់នូវសេចក្ដីទុក្ខ។ នេះឯងហើយគឺហេតុផលដែលថា ហេតុអ្វីទើបតថាគតមិនប្រាប់នូវរឿងទាំងនោះដល់អ្នកទាំងឡាយ"

ជាការគ្មានប្រយោជន៍សោះឡើយ សម្រាប់ពួកយើងទាំងឡាយ ក្នុងការដែលត្រូវនាំគ្នាមកគិតនូវអ្វី ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបហើយ តែមិនបានទ្រង់ត្រាស់ប្រាប់ដល់ពួកយើងទាំងឡាយនោះ។ លំនាំដូចគ្នានេះឯង អ្នកប្រាជ្ញមួយចំនួនធ្លាប់ធ្វើរួចមកហើយ ដោយមិនបានទទួលនូវលទ្ធផលអ្វីទាំងអស់។

ព្រះពុទ្ធជាម្ចាស់ទ្រង់មិនចាប់អារម្មណ៍ ក្នុងការរវែកញែកបកស្រាយនូវបញ្ហាទស្សនវិជ្ជាដែលមិនចាំបាច់ ដែលសុទ្ធសឹងជារឿងកើត

ចេញពីការសន្និដ្ឋាន ហើយថែមទាំងបង្កឱ្យកើតបញ្ហានៃការគិតរវើរវាយថែមទៀតផង។ ព្រះពុទ្ធអង្គទ្រង់ចាត់ទុកថា បញ្ហានៃទស្សនវិជ្ជាទាំងនោះជាព្រៃនៃទិដ្ឋិ។ ក្នុងខណៈដែលនៅមានមនុស្សជាច្រើន ក៏ដូចជាសាវ័កមួយចំនួនរបស់ព្រះអង្គ មិនយល់ច្បាស់នូវគោលជំហរនេះរបស់ព្រះអង្គឡើយ ព្រោះថាមានឧទាហរណ៍របស់លោកម្នាក់ក្នុងចំណោមពុទ្ធសាវ័កទាំងឡាយមានឈ្មោះថា**មាលុងក្យបុត្រ** ហើយគឺលោកអង្គនេះឯងដែលបានតាំងនូវសំនួរ១០ខ ទាក់ទងទៅនឹងបញ្ហាទស្សនវិជ្ជាទូលសួរចំពោះព្រះពុទ្ធជាម្ចាស់ឱ្យទ្រង់ឆ្លើយ។

## ចំណោទទិដ្ឋិ(ទស្សនវិជ្ជា)

ថ្ងៃមួយភិក្ខុមាលុងក្យបុត្រចេញពីការបដិបត្តិកម្មដ្ឋាន នាវេលាសាយ័ណ្ហសម័យ។ បន្ទាប់មក លោកបានចូលទៅគាល់ព្រះពុទ្ធជាម្ចាស់ថ្វាយនូវអភិវាទន៍ចំពោះព្រះអង្គ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរមួយទើបក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចម្រើន! វេលាដែលខ្ញុំព្រះអង្គកំពុងអង្គុយពិចារណាតែម្នាក់ឯង។ គំនិតមួយបានផុសឡើងដល់ខ្ញុំព្រះអង្គថា "មានបញ្ហាមួយចំនួនដែលព្រះអង្គទ្រង់មិនទាន់បានអធិប្បាយទ្រង់បដិសេធហើយនិងទ្រង់លះបង់ហើយ។ បញ្ហាទាំងនោះគឺ

១. លោកស្ថិតនៅទៀងទាត់ឬ?
   - Is the universe eternal?

២. លោកមិនស្ថិតនៅទៀងទាត់ឬ?

- Is it not eternal?

៣. លោកមានទីបំផុតឬ?

- Is the universe finite or

៤. ឬថាលោកគ្មានទីបំផុត?

- Is it infinite?

៥. ជីវៈគឺតែមួយជាមួយនឹងសរីរៈឬ? (ស្លាប់ហើយសូន្យឬ?)

- Is soul the same as body or

៦. ជីវៈនិងសរីរៈគឺដាច់ចេញពីគ្នាឬ? (ផ្សេងពីគ្នាឬ?)

- Is soul one thing and body another thing?

៧. ព្រះអរហន្តទាំងឡាយនៅមាន បន្ទាប់អំពីការបរិនិព្វានហើយឬ?

- Does the Arahanta exist after death or

៨. ឬថាព្រះអរហន្តទាំងឡាយមិនមាន បន្ទាប់អំពីការបរិនិព្វានហើយនោះ?

- Does the Arahanta not exist after death or

៩. ព្រះអរហន្តទាំងឡាយ ទាំងមាននៅផង និងមិនមាននៅផងក្នុងពេលជាមួយគ្នា បន្ទាប់អំពីបរិនិព្វានហើយឬ?

- Does the Arahanta both (at the same time) exist and not exist after death or

១០. ឬថាព្រះអរហន្តទាំងមាននៅក៏មិនមែន ទាំងមិនមាននៅក៏មិនមែន ក្នុងពេលជាមួយគ្នាឬ?

- Does the Arahanta both (at the same time) not exist

and not exist after death?

បញ្ហាទាំងនេះ ព្រះពុទ្ធជាម្ចាស់មិនបានទ្រង់អធិប្បាយដល់យើង។ អាការបែបនេះមិនធ្វើឱ្យយើងពេញចិត្តឡើយ។ យើងមិនជ្រួតជ្រាបច្បាស់នូវគោលជំហររបស់ព្រះអង្គ។ យើងនឹងចូលទៅគាល់ព្រះពុទ្ធអង្គ ហើយទូលសួរព្រះអង្គទាក់ទងជាមួយនឹងបញ្ហាទាំងនេះ។ ប្រសិនបើព្រះដ៏មានព្រះភាគទ្រង់អធិប្បាយនូវបញ្ហាទាំងនេះដល់យើងនោះ យើងក៏នឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌ ជាមួយព្រះអង្គបន្តទៅទៀត។ ផ្ទុយទៅវិញ ប្រសិនបើព្រះអង្គមិនទ្រង់អធិប្បាយនូវបញ្ហាទាំងនេះដល់យើងទេនោះ យើងក៏នឹងសឹកហើយចាកចេញទៅ។ បើព្រះដ៏មានព្រះភាគទ្រង់ជ្រាបថាលោកនេះទៀងឬមិនទៀង ក៏សុំឱ្យព្រះអង្គទ្រង់អធិប្បាយដល់យើងទៅតាមការពិតនោះ។ ប៉ុន្តែបើព្រះអង្គមិនទ្រង់ជ្រាបថា លោកនេះទៀងឬមិនទៀងជាដើមនោះ ក៏ជាការស្មោះត្រង់សម្រាប់អ្នកដែលមិនដឹង ក្នុងការនិយាយថា "ខ្ញុំមិនដឹង! ខ្ញុំមិនឃើញ!"។

ចម្លើយរបស់ព្រះពុទ្ធជាម្ចាស់ចំពោះមាលុងក្យបុត្រនោះ គួរនឹងបានជាប្រយោជន៍ឱ្យដល់មនុស្សទាំងឡាយជាច្រើនលាននាក់ក្នុងលោកបច្ចុប្បន្ននេះ ដែលកំពុងតែប្រើនូវពេលវេលាដ៏មានតម្លៃរបស់ខ្លួន ឱ្យអស់ទៅដោយឥតប្រយោជន៍ ជាមួយនឹងបញ្ហាអភិទស្សនវិជ្ជាយ៉ាងដូច្នេះ ហើយក៏កំពុងតែរំខានដល់សេចក្តីស្ងប់ផ្លូវចិត្តរបស់ខ្លួនដោយមិនចាំបាច់។

"ម្នាលមាលុង្ក្យបុត្រ! តថាគតធ្លាប់ប្រាប់ដល់អ្នកខ្លះទេថា "មកចុះមាលុង្ក្យបុត្រ! មកប្រព្រឹត្តព្រហ្មចរិយធម៌ជាមួយតថាគត តថាគតនឹងអធិប្បាយបញ្ហាទាំងនេះដល់អ្នក"

ភិក្ខុមាលុង្ក្យបុត្រក្រាបទូលថា "មិនធ្លាប់ទេក្រាបទូល"។ គ្រានោះឯង ព្រះពុទ្ធអង្គទ្រង់ត្រាស់បន្តថា "សូម្បីខ្លួនអ្នកផ្ទាល់ក៏ដោយ តើអ្នកធ្លាប់ប្រាប់ដល់តថាគតខ្លះទេថា "បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌ជាមួយព្រះអង្គ ហើយព្រះអង្គនឹងទ្រង់អធិប្បាយនូវបញ្ហាទាំងនេះដល់ខ្ញុំព្រះអង្គ"។ លោកក្រាបទូលថា "មិនធ្លាប់ឡើយក្រាបទូល"។

"ម្នាលមាលុង្ក្យបុត្រ! សូម្បីក្នុងខណៈនេះ តថាគតក៏មិនប្រាប់អ្នកថា "មកចុះមាលុង្ក្យបុត្រ! មកប្រព្រឹត្តនូវព្រហ្មចរិយធម៌ជាមួយតថាគត តថាគតនឹងអធិប្បាយនូវបញ្ហាទាំងនេះដល់អ្នក" ហើយខ្លួនអ្នកផ្ទាល់ក៏មិនបានប្រាប់តថាគតដូចគ្នាថា "បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌ជាមួយព្រះអង្គ ហើយព្រះអង្គនឹងទ្រង់អធិប្បាយនូវបញ្ហាទាំងនេះដល់ខ្ញុំព្រះអង្គ" ដោយហេតុទាំងនេះ គឺខ្លួនអ្នកផ្ទាល់ជាមនុស្សល្ងង់ ។តើនរណាបដិសេធនរណា?"

"ម្នាលមាលុង្ក្យបុត្រ! ប្រសិនបើមានបុគ្គលណាម្នាក់ពោលថា "ខ្ញុំនឹងមិនប្រព្រឹត្តព្រហ្មចរិយធម៌ជាមួយនឹងព្រះដ៏មានព្រះភាគ លុះណា

តែព្រះអង្គទ្រង់អធិប្បាយនូវបញ្ហាទាំងនេះដល់ខ្ញុំជាមុនសិន"។ បុគ្គលនោះក៏ប្រហែលជានឹងស្លាប់ ទាំងដែលតថាគតនៅមិនទាន់ឆ្លើយបញ្ហាទាំងនេះនៅឡើយ"

"ម្នាលមាលុង្យបុត្រ! ឧបមាថា បុរសម្នាក់ត្រូវគេបាញ់ឱ្យរបួសដោយសារព្រួញ ដែលលាបទៅដោយថ្នាំពិស។ ខណៈនោះឯង ញាតិមិត្តសាលោហិតទាំងឡាយរបស់គេ បាននាំគេទៅរកពេទ្យ។ ឧទាហរណ៍ថាគ្រានោះបុរសនោះពោលថា "ខ្ញុំនឹងមិនព្រមឱ្យពេទ្យដកព្រួញនេះចេញដរាបណាខ្ញុំមិនទាន់បានដឹងជាមុនថា នរណាជាអ្នកបាញ់ខ្ញុំ ជាក្សត្រ(អ្នកគ្រប់គ្រងរដ្ឋ) ឬព្រាហ្មណ៏(អ្នកបួស) ឬវៃស្សៈ(ពាណិជ្ជករឬកសិករ) ឬពួកសូទ្រៈ(កម្មករឬទាសករ)។ ឈ្មោះនិងគោត្ត(ត្រកូល)របស់គេយ៉ាងដូចម្តេច។ គេជាមនុស្សខ្ពស់ឬទាប ធាត់ឬស្គម ពណ៌សម្បុររបស់គេខ្មៅឬត្នោត ឬពណ៌មាស បុរសនោះមកពីភូមិស្រុកឬនិគមណា។ ខ្ញុំនឹងមិនព្រមឱ្យគេដកសរនេះចេញជាដាច់ខាត ដរាបណាខ្ញុំមិនទាន់ដឹងច្បាស់អំពីប្រភេទរបស់ធ្នូដែលប្រើបាញ់ខ្ញុំ ប្រភេទរបស់ខ្សែធ្នូ ប្រភេទរបស់ព្រួញ ប្រភេទរបស់រោមសត្វ ដែលជាប់នៅនឹងកន្ទុយរបស់ព្រួញនោះ ឬថាក្បាលព្រួញធ្វើអំពីវត្ថុអ្វីជាដើម"។ ម្នាលមាលុង្យបុត្រ! បុរសនោះក៏ប្រហែលជានឹងស្លាប់ ទាំងដែលមិនទាន់បានដឹងនូវរឿងទាំងនេះ។ ក្នុងន័យដូចគ្នានេះឯង ប្រសិនបើបុគ្គលណាម្នាក់ពោលថា "ខ្ញុំនឹងមិនប្រព្រឹត្ត

ព្រហ្មចរិយធម៌ជាមួយនឹងព្រះដ៏មានព្រះភាគ ដរាបណាព្រះអង្គមិនទ្រង់តបនូវបញ្ហាទាំងនេះដូចជាថា លោកទៀងឬមិនទៀងជាដើម គេក៏ប្រហែលជានឹងស្លាប់ ទាំងដែលតថាគតនៅមិនបានអធិប្បាយនូវបញ្ហាទាំងនេះ”

លំដាប់នោះឯងព្រះសក្យមុនី ទ្រង់បានអធិប្បាយដល់មាលុងក្យបុត្រនោះយ៉ាងដូច្នេះថា “ជីវិតព្រហ្មចរិយធម៌ មិនអាស្រ័យទៅលើទិដ្ឋិទាំងនោះឡើយ ។ មិនថាបុគ្គលនឹងមានទិដ្ឋិយ៉ាងដូចម្ដេចក៏ដោយចុះទាក់ទងទៅនឹងបញ្ហាទាំងនេះ គេក៏នៅតែមានការកើត ចាស់ ឈឺ ស្លាប់ មានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ ភាពទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តជាដើម(ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស និងឧបាយាសៈ...) ។ តថាគតប្រកាសនូវការរំលត់ទៅនៃសភាវៈទាំងនេះ(គឺព្រះនិព្វាន) ក្នុងជាតិបច្ចុប្បន្ននេះតែម្ដង ។ ព្រោះហេតុដូច្នេះ មាលុងក្យបុត្រចូរចាំទុកថា រឿងដែលតថាគតបានអធិប្បាយហើយ ក៏ជារឿងដែលតថាគតបានអធិប្បាយហើយ ។ ដោយឡែកអ្វីដែលតថាគតនៅមិនទាន់បានអធិប្បាយ ក៏នឹងនៅតែជាអ្វីដែលតថាគតមិនអធិប្បាយ ។ ចុះតើអ្វីទៅជារឿងដែលតថាគតនៅមិនទាន់បានអធិប្បាយ? នោះក៏គឺថាលោកនេះទៀងឬទេជាដើម(បានដល់ទិដ្ឋិទាំង១០ប្រការ) ។ ហេតុអ្វីទៅមាលុងក្យបុត្រ ទើបតថាគតមិន

អធិប្បាយនូវបញ្ហាទាំងនេះ? ព្រោះថាវាមិនមានប្រយោជន៍ វាមិនពាក់ព័ន្ធគ្នាជាមូលដ្ឋានទៅនឹងជីវិតព្រហ្មចរិយធម៌ ទាំងមិនប្រព្រឹត្តទៅដើម្បីការរំលត់ទុក្ខ ដើម្បីការកម្ចាត់បង់នូវកិលេស ដើម្បីការដឹងដ៏ក្រៃលែង និងដើម្បីសេចក្តីស្ងប់។ នេះហើយគឺហេតុផលដែលថា ហេតុអ្វីទើបតថាគតមិនអធិប្បាយដល់ពួកអ្នក ទាក់ទិនជាមួយនឹងបញ្ហាទាំងនេះ"។

"ម្នាលមាលុង្យបុត្រ! ក៏អ្វីទៅដែលតថាគតបានអធិប្បាយហើយ? តថាគតបានអធិប្បាយដល់រឿងទុក្ខ ហេតុដែលនាំឱ្យកើតទុក្ខ និងផ្លូវដែលនាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ។ ម្នាលមាលុង្យបុត្រ! ហេតុអ្វីទើបតថាគតអធិប្បាយនូវបញ្ហាទាំងនេះ ព្រោះថាវាមានប្រយោជន៍ មានមូលដ្ឋានទាក់ទងគ្នាទៅនឹងជីវិតព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីរលាស់ខ្លួនចេញចាកទុក្ខ ដើម្បីការកម្ចាត់បង់នូវកិលេស ដើម្បីការដឹងដ៏ក្រៃលែង និងដើម្បីសេចក្តីស្ងប់(ព្រះនិព្វាន) ហេតុនេះឯងទើបតថាគតអធិប្បាយនូវបញ្ហាទាំងនេះ"

សូមឱ្យយើងទាំងអស់គ្នា មកពិចារណាដល់អរិយសច្ចៈ៤ ដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់អធិប្បាយ ដល់ភិក្ខុមាលុង្យបុត្រ។

ឲឲឲ*៚៚៚

# ជំពូក២

## អរិយសច្ចៈ៤

ធម៌ដែលជាបេះដូង នៃឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ គឺ អរិយសច្ចៈ៤នេះឯង(ចត្តារិអរិយសច្ចានិ)។ អរិយសច្ចៈទាំង៤ប្រការនេះ ព្រះពុទ្ធអង្គទ្រង់បានសម្តែងជាលើកដំបូងបំផុត(បឋមទេសនា) ដល់**ភិក្ខុបញ្ចវគ្គីយ៍** បន្ទាប់អំពីការត្រាស់ដឹងរបស់ព្រះអង្គ នៅឯព្រៃ**ឥសិបតនៈ** (បច្ចុប្បន្នហៅថាសារនាថ)ជិតក្រុងពារាណសី។ ក្នុងព្រះធម្មទេសនាកណ្ឌនេះ(ដូចដែលមានចារឹកទុកនៅក្នុងគម្ពីរតាំងពីបុរាណមក) ព្រះពុទ្ធអង្គទ្រង់បានសម្តែងនូវអរិយសច្ចៈ៤ប្រការនេះ ដោយសង្ខេបប៉ុណ្ណោះ។ ដោយឡែកក្នុងគម្ពីរព្រះពុទ្ធសាសនាជំនាន់ដំបូងៗបំផុត មានជាច្រើនកន្លែងដែលបានអធិប្បាយនូវអរិយសច្ចៈទាំង៤ប្រការនេះ ម្តងហើយម្តងទៀតព្រមជាមួយនឹងសេចក្តីពិស្តារជាអនេកបរិយាយ។ បើយើងសិក្សាអំពីអរិយសច្ចៈទាំង៤ប្រការនេះ ដោយអាស្រ័យពាក្យអធិប្បាយនិងព័ស្តុតាងអះអាងតាមរយៈគម្ពីរទាំងនោះ យើងក៏នឹងទទួលបាននូវរឿងរ៉ាវដ៏ល្អនិងត្រឹមត្រូវ នៃឱវាទទូន្មានដែលជាខ្លឹមសារពិតៗរបស់ព្រះពុទ្ធអង្គ ស្របតាមគម្ពីរដែលមានមកតាំងពីបុរាណ។

អរិយសច្ចៈទាំង៤ប្រការនេះរួមមានៈ

១. ទុក្ខ

២. សមុទ័យ　:　ការកើតឡើង ឬហេតុដែលនាំឱ្យកើតទុក្ខ

៣. និរោធ　:　ការរំលត់ទុក្ខ

៤. មគ្គ　:　ផ្លូវសំរាប់នាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ

## អរិយសច្ចៈប្រការទី១ "ទុក្ខ"

អរិយសច្ចៈប្រការទីមួយ(ទុក្ខអរិយសច្ចៈ)។ ជាទូទៅអ្នកប្រាជ្ញភាគច្រើននាំគ្នាប្រែថា "ការពិតដ៏ប្រសើរនៃទុក្ខ" ហើយនាំគ្នាពន្យល់សេចក្តីថា ជីវិតសត្វលោកតាមទ្រឹស្តីព្រះពុទ្ធសាសនា មិនមានអ្វីផ្សេងក្រៅអំពីទុក្ខនិងការឈឺចាប់ប៉ុណ្ណោះ។ ទាំងការបកប្រែនិងការពន្យល់ទាំងនេះ ហាក់មិនគួរឱ្យពេញចិត្តបន្តិចណាសោះឡើយ។ ផ្ទុយទៅវិញវាថែមទាំងអាចនាំទៅដល់ការយល់ខុស ព្រោះបណ្តាលមកពីការបកប្រែយ៉ាងងាយៗ និងការដាក់កម្រិតអត្ថន័យខ្លឹមសាររបស់ពាក្យ ក៏ដូចជាការពន្យល់បែបសើៗនេះឯង ដែលធ្វើឱ្យមនុស្សទាំងឡាយកើតការយល់ខុសថា ព្រះពុទ្ធសាសនាជាសាសនាប្រភេទទុទិដ្ឋិនិយម។

# ព្រះពុទ្ធសាសនាមិនមែនជាសាសនានៃការយល់ឃើញ

មុននឹងចូលទៅដល់ការបកស្រាយ នូវអរិយសច្ចៈប្រការទីមួយ ស្តីអំពីទុក្ខនោះ ជំហានដំបូងយើងគប្បីស្វែងយល់ឱ្យបានច្បាស់ជាមុនថា ព្រះពុទ្ធសាសនាមិនមែនជាសាសនាប្រភេទទុទិដ្ឋិនិយម(មើលលោកក្នុងផ្លូវអាក្រក់) ឬសុទិដ្ឋិនិយម(មើលលោកក្នុងផ្លូវល្អ)នោះឡើយ។ ប្រសិនបើឱ្យប្រដូចទៅនឹងអ្វីម្យ៉ាងវិញនោះ ព្រះពុទ្ធសាសនាក៏គឺជាសាសនាប្រភេទសច្ចនិយម ព្រោះព្រះពុទ្ធសាសនាប្រកាន់យកនូវគោលជំហរទៅតាមសេចក្តីពិត។ ព្រះពុទ្ធសាសនាសម្លឹងមើលសភាវៈទាំងឡាយទៅតាមសេចក្តីពិត(យថាភូតំ) ពោលគឺមិនបានបញ្ចុះបញ្ចូលឱ្យអ្នកមានជីវិតរស់នៅបែបខុសឆ្គង ក្នុងលក្ខណៈស្រមើស្រមៃទៅដល់សួគ៌វិមានរបស់មនុស្សល្ងង់ខ្លៅ ក៏ដូចជាមិនធ្វើឱ្យអ្នកភ័យខ្លាចនិងកើតទុក្ខ តាមរយៈបាបកម្មផ្សេងៗដែលអ្នកនឹកគិតដោយខ្លួនឯង។ ព្រះពុទ្ធសាសនាបង្រៀនអ្នកយ៉ាងត្រង់ទៅត្រង់មកនិងតាមសេចក្តីពិតថាអ្នកជាអ្វី ហើយលោកជុំវិញអ្នកគឺអ្វី និងចង្អុលបង្ហាញផ្លូវឆ្ពោះទៅកាន់សេរីភាព សន្តិភាព សេចក្តីស្ងប់និងសេចក្តីសុខយ៉ាងពេញលេញដល់អ្នក។

# ពេទ្យដ៏ឆ្លាត

ពេទ្យម្នាក់អាចនឹងនិយាយហួសពីការពិតថា រោគដែលអ្នកជំងឺកំពុងមាននោះជារោគធ្ងន់ធ្ងរ ដោយបានធ្វើឱ្យអ្នកជំងឺបាត់បង់អស់នូវក្តីសង្ឃឹម។ ក្នុងខណៈដែលពេទ្យម្នាក់ទៀត អាចនឹងនិយាយចេញមកតាមបែបមនុស្សល្ងង់ថា អ្នកជំងឺមិនមានជំងឺអ្វី ហើយថាមិនចាំបាច់ត្រូវទទួលនូវការព្យាបាលក៏បាន។ វិធីទាំងនេះមិនខុសអ្វីទៅនឹងការបោកបញ្ឆោតអ្នកជំងឺ ក្នុងផ្លូវខុសនោះឡើយ។ អ្នកអាចហៅពេទ្យទី១ថា ជាមនុស្សមើលពិភពលោកក្នុងផ្លូវអាក្រក់ និងពេទ្យទី២ថាជាមនុស្សមើលពិភពលោកក្នុងផ្លូវល្អ។ យ៉ាងណាក៏ដោយចុះ ពេទ្យទាំងពីរនេះមានគ្រោះថ្នាក់ប្រហាក់ប្រហែលគ្នា។ ចំណែកឯពេទ្យទី៣ វិនិច្ឆ័យអាការរបស់រោគបានយ៉ាងត្រឹមត្រូវ យល់អំពីសមុដ្ឋាន(ដើមហេតុ)និងលក្ខណៈរបស់រោគមើលឃើញយ៉ាងជាក់ច្បាស់ថាជំងឺអាចព្យាបាលបាន ហើយបានចាប់ផ្តើមដំណើរការព្យាបាលដោយសេចក្តីអង់អាចក្លាហាន។ ដោយវិធីបែបនេះប៉ុណ្ណោះ ទើបអាចជួយអ្នកជំងឺឱ្យជាសះស្បើយបាន។ ព្រះពុទ្ធអង្គទ្រង់ប្រៀបប្រដូចទៅនឹងពេទ្យចុងក្រោយនេះ ព្រះអង្គទ្រង់ជាវេជ្ជបណ្ឌិតដ៏ឈ្លាសវៃ ហើយពោរពេញទៅដោយចំណេះដឹងនិងសមត្ថភាព ក្នុងការព្យាបាលជំងឺរបស់សត្វលោក (ភិសក្ក ឬវៃស្យគុរុ)។

ពិតមែនហើយ ពាក្យបាលីថាទុក្ខ(សំស្ក្រឹតថាទុះខ) តាមដែលយើងនិយមនាំគ្នាប្រើជាទូទៅនោះ គឺសំដៅដល់សេចក្តីទុក្ខ សេចក្តីក្តៅក្រហាយ សេចក្តីសោក ផ្ទុយគ្នាទៅនឹងពាក្យថាសុខ ដែលមានន័យថាសេចក្តីសុខ សេចក្តីសប្បាយ។ ដោយឡែកពាក្យថាទុក្ខ នៅក្នុងអរិយសច្ចៈប្រការទី១ ដែលបង្ហាញអំពីទស្សនៈរបស់ព្រះពុទ្ធជាម្ចាស់នេះ គឺមានអត្ថន័យជ្រាលជ្រៅនិងគ្របដណ្តប់បានយ៉ាងទូលំទូលាយ លើសពីអ្វីដែលយើងនាំគ្នាយល់ឃើញនោះទៅទៀត។ ដូចដែលត្រូវបានទទួលស្គាល់ហើយថាពាក្យថា"ទុក្ខ" នៅក្នុងអរិយសច្ចៈប្រការទីមួយនេះ គឺប្រាកដណាស់មានអត្ថន័យបែបសាមញ្ញៗថា "សេចក្តីទុក្ខ"។ តែក្រៅអំពីសេចក្តីទុក្ខនេះហើយនោះ អត្ថន័យដ៏ពិតប្រាកដដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់សំដៅទៅដល់ពាក្យថា"ទុក្ខ"នេះ ក៏នៅមានរួមបញ្ចូលទៅដល់សភាវៈផ្សេងៗ ដែលជ្រាលជ្រៅល្អិតសុខុមជាងនេះទៅទៀត ដូចជាភាពខ្វះខាត ភាពមិនទៀងទាត់ ភាពទទេស្អាត ភាពគ្មានខ្លឹមសារ។ល។

ដូចនេះទើបជាការពិបាកណាស់ ក្នុងការរកពាក្យណាមួយ(ត្រឹមមួយពាក្យ) ដែលអាចគ្របដណ្តប់នូវអត្ថន័យខ្លឹមសារទាំងអស់ របស់ពាក្យថា"ទុក្ខ" ដែលជាអរិយសច្ចៈខទីមួយនេះបានយ៉ាងត្រឹមត្រូវ។ ហេតុដូច្នេះ ការរក្សាស័ព្ទនេះឱ្យនៅដដែល ដោយមិនចាំបាច់ប្រែទើបជាការប្រសើរ ជាជាងការផ្តល់នូវអត្ថន័យមិនគ្រប់ជ្រុងជ្រោយនិងខុសឆ្គង

ដោយការប្រែនូវពាក្យនេះឯងយ៉ាងងាយៗថា"សេចក្តីទុក្ខ" ឬ "សេចក្តីក្តៅក្រហាយ" យ៉ាងនេះជាដើម។

ព្រះពុទ្ធជាម្ចាស់មិនបានទ្រង់បដិសេធ នូវសេចក្តីសុខក្នុងជីវិតក្នុងខណៈដែលព្រះអង្គទ្រង់ត្រាស់ថា មានសេចក្តីទុក្ខនោះឡើយ។ ផ្ទុយទៅវិញ ទ្រង់ទទួលស្គាល់នូវសេចក្តីសុខទៅតាមរូបភាពផ្សេងៗ ទាំងសេចក្តីសុខខាងផ្នែកផ្លូវកាយ(សេចក្តីសុខផ្នែកវត្ថុឬអាមិសសុខ) និងសេចក្តីសុខផ្នែកផ្លូវចិត្ត ក៏ដូចជាសេចក្តីសុខរបស់គ្រហស្ថ និងសេចក្តីសុខរបស់បព្វជិត។ ក្នុងអង្គុត្តរនិកាយ ដែលជានិកាយមួយក្នុងចំណោមនិកាយជាន់ដើមទាំង៥ មានព្រះបាលីដែលបានប្រមូលរួបរួមទុក នូវព្រះសូត្រផ្សេងៗរបស់ព្រះពុទ្ធជាម្ចាស់នោះ បានធ្វើការបែងចែកនូវសេចក្តីសុខចេញជាច្រើនប្រភេទដូចជា សេចក្តីសុខនៅក្នុងការគ្រប់គ្រងផ្ទះសម្បែង(ការរស់នៅយ៉ាងសុខសាន្តជាមួយក្រុមគ្រួសារ) សេចក្តីសុខនៅក្នុងជីវិតជាបព្វជិត(សេចក្តីសុខនៅក្នុងជីវភាពជាអ្នកបួស) សេចក្តីសុខនៅក្នុងផ្លូវកាម សេចក្តីសុខដែលកើតពីការប្រកាន់មាំ សេចក្តីសុខផ្លូវកាយ និងសេចក្តីសុខផ្លូវចិត្តជាដើម ហើយដែលសេចក្តីសុខទាំងនោះសុទ្ធសឹងតែត្រូវបានចាត់បញ្ចូលទៅក្នុងពាក្យថា"ទុក្ខ"នេះទាំងអស់។

# ឥស្សរភាពនៅលើឥស្សរភាព

សូម្បីតែសភាវៈដ៏បរិសុទ្ធផូរផង់នៃធ្យាន(ការចូលសមាធិ) ដែលសម្រេចបានដោយការប្រតិបត្តិនូវសមាធិជាន់ខ្ពស់ និងបានធ្វើឱ្យមានឥស្សរភាពពីស្រមោលងងឹតនៃសេចក្តីទុក្ខ ដែលមិនលាយឡំទៅដោយអាមិស(សេចក្តីសុខដែលមិនអាស្រ័យនូវវត្ថុខាងក្រៅ)ក្តី។ សភាវៈនៃធ្យាន(ឈាន)ដែលផុតចាកវេទនា ទាំងដែលជាទុក្ខ(ទុក្ខវេទនា)និងវេទនាដែលជាសុខ(សុខវេទនា) សល់នៅតែឧបេក្ខានិងសម្បជញ្ញៈក្តី។ សូម្បីតែសភាវៈដែលប្រសើរយ៉ាងនេះក្តី ក៏នៅតែត្រូវបានរួមបញ្ចូលទៅក្នុងពាក្យថា"ទុក្ខ"។ មានព្រះសូត្រមួយនៅក្នុងមជ្ឈិមនិកាយ បន្ទាប់ពីទ្រង់បានត្រាស់សរសើរនូវសេចក្តីសុខផ្លូវចិត្ត ដែលកើតពីធ្យានទាំងនេះហើយនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ធ្យានទាំងនេះមានសភាពមិនទៀងជាទុក្ខ មានការប្រែប្រួល(អនិច្ចា ទុក្ខា វិបរិណាមធម្មា)"។ យើងសង្កេតឃើញថា ទ្រង់ប្រើពាក្យថា"ទុក្ខ"យ៉ាងច្បាស់ៗ។ វាជាទុក្ខ មិនមែនព្រោះមានសេចក្តីទុក្ខ ដូចនៅក្នុងន័យដែលយើងនាំគ្នាយល់នោះទេ តែព្រោះថា"**សភាវៈណាមិនទៀង សភាវៈនោះជាទុក្ខ (យំ អនិច្ចំ តំ ទុក្ខំ)**"។

ព្រះពុទ្ធអង្គទ្រង់ជាអ្នកសច្ចនិយម ហើយជាអ្នកសម្លឹងសភាវៈ

ផ្សេងៗទៅតាមសេចក្ដីពិត។ ពេលត្រាស់ទៅដល់ជីវិតនិងកាមសុខ ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលគប្បីយល់ឱ្យបានច្បាស់នូវលក្ខណៈ៣ប្រការនេះគឺ

១. ការស្រលាញ់ពេញចិត្ត ឬការភ្លើតភ្លើន (អស្សាទ)

២. ទោស អន្តរាយ ឬការមិនពេញចិត្ត (អាទីនវ)

៣. ការរួចផុត ឬការរលាស់ចោល (និស្សរណ)

ឧទាហរណ៍ថា ពេលឃើញមនុស្សជាទីស្រលាញ់ មានមន្តស្នេហ៍និងសម្រស់ទាក់ទាញ អ្នកក៏ចូលចិត្តគេ(ឬនាង) កើតការជំពាក់ចិត្តឈ្លក់វង្វេងជាមួយការដែលបានឃើញបុគ្គលនោះញឹកញាប់ មានសេចក្ដីសុខនិងសេចក្ដីពេញចិត្ត ដែលកើតចេញដោយអាស្រ័យមានបុគ្គលនោះជាទីតាំង(ជាហេតុ)។ នេះគឺជាការជាប់ជំពាក់ ដែលជារឿងពិតនៅក្នុងជីវិតរបស់មនុស្ស។ ការជាប់ជំពាក់ឬការភ្លើតភ្លើនទាំងអម្បាលម៉ាននេះ សុទ្ធតែជារឿងដែលមិនឋិតថេរ ដូចគ្នាទៅនឹងបុគ្គលដែលអ្នកស្រលាញ់ ទាំងមន្តស្នេហ៍និងសម្រស់ទាក់ទាញរបស់គេ(ឬរបស់នាង) ក៏សុទ្ធសឹងតែជារឿងដែលមិនឋិតថេរទាំងអស់។ ពេលស្ថានភាពមានការប្រែប្រួលទៅក្ដី ពេលអ្នកមិនបានឃើញបុគ្គលនោះក្ដី ពេលអ្នកត្រូវព្រាត់ប្រាសចាកពីបុគ្គលជាទីស្រលាញ់ពេញចិត្ត ឬពីការភ្លើតភ្លើនទាំងឡាយនោះក្ដី អ្នកនឹងមានអារម្មណ៍សោកសៅខូចចិត្ត រហូតអាចក្លាយទៅជាមនុស្សមិនមាន

ហេតុផល បាត់បង់សតិឬជួនកាលអាចឈានដល់ថ្នាក់ធ្វើអ្វីបែបល្ងង់ខ្លៅក៏សឹងមាន។ នេះហើយគឺសភាពដែលជាទោស មិនគួរឱ្យពេញចិត្តនិងជាអន្តរាយ(អាទីនវ)។ ទាំងអស់នេះ សុទ្ធសឹងតែជារឿងពិត ដែលយើងអាចប្រទះឃើញបាន នៅក្នុងជីវិតប្រចាំថ្ងៃ។ ប្រសិនបើអ្នកមិនប្រកាន់មាំជាមួយបុគ្គលនោះក្តី បើអ្នកមិនជាប់ជំពាក់ទៅនឹងបុគ្គលនោះជាស្ថាពរក្តី នោះអ្នកនឹងបានដល់នូវឥស្សរភាព ពោលគឺការរួចចាកផុតយ៉ាងពិតប្រាកដ(និស្សរណ)។ លក្ខណៈទាំង៣នេះគឺជាសេចក្តីពិត ដែលទាក់ទងទៅនឹងការភ្លើតភ្លើន និងសេចក្តីត្រេកត្រអាលទាំងអស់នៅក្នុងជីវិត។

## តាមលំនាំនៃការពិត

តាមរយៈការពិតខាងលើនេះ អាចជាខអះអាងបង្ហាញឱ្យឃើញបានយ៉ាងច្បាស់ថា មិនមែនជាបញ្ហាក្នុងការសម្លឹងមើលពិភពលោក ក្នុងផ្លូវល្អឬផ្លូវអាក្រក់នោះឡើយ។ ផ្ទុយទៅវិញ គឺជាការអះអាងថា យើងចាំបាច់ត្រូវពិចារណាទៅដល់សេចក្តីសុខ សេចក្តីទុក្ខនិងសេចក្តីសោកសៅរបស់ជីវិត រួមទាំងការរួចផុតពីសេចក្តីទុក្ខនិងសេចក្តីសោកសៅទាំងនោះផងដែរ ដើម្បីឱ្យយើងអាចយល់ពីជីវិតបានយ៉ាងជាក់ច្បាស់ និងទៅតាមសេចក្តីពិត ហើយគឺមានតែអាស្រ័យដោយវិធីនេះប៉ុណ្ណោះ ទើបឥស្សរភាពដ៏ពិតប្រាកដមួយនឹងអាចកើតឡើងបាន។ ចំពោះបញ្ហាខនេះ

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! សមណៈព្រាហ្មណ៍ទាំងឡាយណា ប្រសិនបើមិនយល់ច្បាស់តាមសេចក្តីពិតយ៉ាងដូច្នេះថា ការភ្លើតភ្លើននៅក្នុងកាមគុណទាំងឡាយគឺជាការភ្លើតភ្លើន ការមិនពេញចិត្តនៅក្នុងកាមគុណគឺជាការមិនពេញចិត្ត ការរលាស់ខ្លួនចេញចាកកាមគុណគឺជាការរលាស់ខ្លួន ពេលនោះក៏មិនអាចទៅរួច ដែលសមណៈព្រាហ្មណ៍ទាំងនោះ នឹងយល់ច្បាស់ដោយខ្លួនឯងនូវកាមគុណបានយ៉ាងពេញលេញ ហើយក៏មិនអាចទៅរួចផងដែរ ដែលសមណៈព្រាហ្មណ៍ទាំងនោះ នឹងបង្រៀនអ្នកដទៃឱ្យឆ្ពោះទៅកាន់គោលដៅនោះបាន ទាំងមិនអាចទៅរួចសម្រាប់បុគ្គលទាំងឡាយ ដែលជាអ្នកបដិបត្តិតាមឱវាទទូន្មានរបស់សមណៈព្រាហ្មណ៍ទាំងនោះ នឹងអាចយល់ជាក់ច្បាស់នៅក្នុងកាមតណ្ហាបាន។ ម្នាលភិក្ខុទាំងឡាយ! ផ្ទុយទៅវិញ ប្រសិនបើសមណៈព្រាហ្មណ៍ទាំងឡាយណា យល់ច្បាស់ទៅតាមសភាវៈពិតយ៉ាងដូច្នេះថា ការភ្លើតភ្លើននៅក្នុងកាមតណ្ហាគឺជាការភ្លើតភ្លើន ការមិនពេញចិត្តនៅក្នុងកាមតណ្ហាជាការមិនពេញចិត្ត ការរលាស់ខ្លួនចេញចាកកាមតណ្ហា គឺជាការរលាស់ខ្លួនចេញចាកកាមតណ្ហា ពេលនោះក៏គប្បីនឹងប្រព្រឹត្តទៅបានដែលសមណៈព្រាហ្មណ៍ទាំងនោះ នឹងយល់ច្បាស់នូវកាមតណ្ហាបានដោយខ្លួនឯង ទាំងអាចប្រព្រឹត្តទៅបានដែលសមណៈព្រាហ្មណ៍ទាំងឡាយនោះ នឹងអាចបង្រៀនអ្នកដទៃឱ្យឆ្ពោះទៅកាន់គោលដៅនោះ

ហើយក៏អាចប្រព្រឹត្តទៅបានផងដែរ ដែលបុគ្គលអ្នកបដិបត្តិតាមឱវាទទូន្មានរបស់សមណៈព្រាហ្មណ៏ទាំងនោះ នឹងយល់បានយ៉ាងជាក់ច្បាស់អំពីកាមតណ្ហា"។

ទស្សនៈដែលទាក់ទងជាមួយនឹងរឿងទុក្ខនេះ យើងអាចសម្លឹងមើលបាន៣លក្ខណៈគឺ :

១. ទុក្ខ ក្នុងន័យដែលជាសេចក្តីទុក្ខវេទនាធម្មតា (ទុក្ខ-ទុក្ខ)

២. ទុក្ខ ក្នុងន័យដែលកើតចេញពីការប្រែប្រួលផ្លាស់ប្តូរ (វិបរិណាម-ទុក្ខ)

៣. ទុក្ខ ក្នុងន័យដែលជាសភាវៈមានហេតុបច្ច័យទាក់ទងគ្នា (សង្ខារ-ទុក្ខ)

សេចក្តីទុក្ខគ្រប់យ៉ាងនៅក្នុងជីវិត ដូចជាការកើត ចាស់ ឈឺ ស្លាប់ ការជួបប្រទះឬត្រូវទ្បោមព័ទ្ធទៅដោយរបស់មិនជាទីស្រលាញ់ ការព្រាត់ប្រាសពីបុគ្គលឬពីអ្វីដែលខ្លួនស្រលាញ់ ការមិនបាននូវអ្វីដែលខ្លួនប្រាថ្នា សេចក្តីសោកសៅ សេចក្តីខ្សឹកខ្សួល សេចក្តីចង្អៀតចង្អល់ចិត្ត សេចក្តីទុក្ខ ទាំងខាងផ្នែកផ្លូវកាយនិងផ្លូវចិត្តគ្រប់រូបបែប ដែលយើងទទួលស្គាល់ជាទូទៅថា ជាទុក្ខវេទនាឬថាជាសេចក្តីលំបាក ក៏សុទ្ធសឹងរួមបញ្ចូលនៅក្នុងទុក្ខ ក្នុងន័យដែលជាសេចក្តីទុក្ខធម្មតា (ទុក្ខ-ទុក្ខ)។

ការសោយនូវអារម្មណ៏ដែលជាសុខ ក៏ដូចជាហេតុដែលនាំឱ្យ

កើតមាននូវសេចក្តីសុខ គឺសុទ្ធតែជាសភាវៈមិនទៀងទាត់ឋិតថេរ។ វារមែងផ្លាស់ប្តូរទៅឆាប់រហ័សខ្លះយឺតខ្លះ ហើយពេលដែលវាផ្លាស់ប្តូរក៏បង្កឱ្យកើតនូវសេចក្តីឈឺចាប់ឬសេចក្តីទុក្ខ។ ការប្រែប្រួលទាំងអស់នេះរួមនៅក្នុងទុក្ខ ក្នុងន័យដែលកើតឡើងព្រោះការប្រែប្រួលផ្លាស់ប្តូរ(វិបរិណាមទុក្ខ)។

ការដែលនឹងយល់នូវសេចក្តីទុក្ខទាំងពីរខាងដើមនេះ គឺជារឿងងាយ។ មិនមាននរណាបដិសេធនូវសេចក្តីទុក្ខក្នុងលំនាំខាងលើនេះ នៃអរិយសច្ចៈប្រការទីមួយឡើយ ត្បិតថាវាជារឿងដែលមនុស្សទូទៅដឹងច្បាស់ ព្រោះវាងាយក្នុងការយល់ ហើយវាក៏ជារឿងធម្មតា ដែលយើងរាល់គ្នាតែងជួបប្រទះ នៅក្នុងជីវិតប្រចាំថ្ងៃថែមទៀតផង។ ដោយឡែកលក្ខណៈទីពារបស់សេចក្តីទុក្ខ ក្នុងន័យជាសភាវៈដែលកើតឡើងព្រោះអាស្រ័យបច្ច័យតាក់តែង(សង្ខារទុក្ខ) មានលក្ខណៈជាបរមត្ថធម៌ដ៏សំខាន់បំផុតរបស់អរិយសច្ចៈប្រការទីមួយនេះ ដែលចាំបាច់ទាមទារឱ្យមានការអធិប្បាយរើកញែកយ៉ាងត្រឹមត្រូវ ជាមួយនឹងអ្វីដែលយើងនាំគ្នាចាត់ទុកថាជាសត្វ បុគ្គលឬតួខ្លួន។

តាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនា អ្វីដែលយើងនាំគ្នាហៅថាជាសត្វ បុគ្គលឬតួខ្លួន ការពិតទៅគឺគ្រាន់តែជាការរួមបញ្ចូលគ្នា នៃថាមពលទាំងខាងផ្នែករាងកាយនិងចិត្តគំនិត ដែលតែងតែផ្លាស់ប្តូរប្រែប្រួល

ឥតឈប់ឈរ ហើយដែលអាចញែកចេញបានជា៥កងឬ៥ក្រុម(បញ្ចក្ខន្ធ)។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "**និយាយដោយខ្លី ឧបាទានក្ខន្ធ៥ជាទុក្ខ**"។ ក្នុងទីឯទៀត ព្រះអង្គទ្រង់កំណត់ន័យនៃពាក្យថា"ទុក្ខ" ដោយសំដៅដល់ខន្ធ៥យ៉ាងច្បាស់ថា "ម្នាលភិក្ខុទាំងឡាយ! អ្វីទៅគឺជាទុក្ខ? គួរនិយាយបានតែម្តងថា គឺឧបានទានក្ខន្ធ៥ហ្នឹងឯង(ជាទុក្ខ)"។

គប្បីយល់ឱ្យបានច្បាស់ថា ទុក្ខនិងខន្ធ៥មិនមែនជាសភាវៈ ដែលខុសប្លែកពីគ្នានោះទេ ប៉ុន្តែគឺខន្ធ៥នេះឯងហើយដែលជាតួទុក្ខ។ ប្រសិនបើយើងមានខសង្កេតមួយចំនួនទាក់ទងទៅនឹងខន្ធ៥ ដែលរួមគ្នាបង្កើតបានជាសភាវៈ ដែលយើងនាំគ្នាហៅថា"សត្វ" យើងនឹងយល់ពីចំណុចនេះបានកាន់តែច្បាស់ខ្លាំងឡើងថែមទៀត ដូច្នេះចំណោទនៅក្នុងទីនេះ ក៏គឺថា "តើអ្វីទៅជាខន្ធ៥?"។

## ខន្ធ៥

ខន្ធដំបូងគឺរូបក្ខន្ធ។ ពាក្យថារូបក្ខន្ធនេះ គឺរួមយកធាតុទាំង៤ដែលជារូបធាតុដើម(ចត្តារិ មហាភូតានិ) ពោលគឺទឹក ដី ភ្លើងនិងខ្យល់ បូករួមទាំងធាតុដែលអាស្រ័យ(ឧបាទាយរូប) នូវរូបទាំង៤នេះផងដែរ។ ពាក្យថា"ឧបាទាយរូប"របស់ធាតុទាំង៤នេះ គឺសំដៅរួមយកនូវឥន្ទ្រិយវត្ថុទាំង៥យ៉ាងរបស់យើងផងដែរ បានដល់ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ

ជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយ រីឯវត្ថុដែលជាទីតបស្នងខាងក្រៅ នៃឥន្ទ្រិយទាំងនោះរួមមានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ(ការប៉ះពាល់)។ គំនិតការយល់ឃើញឬទស្សនៈ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការនឹកគិត ខាងផ្នែកផ្លូវចិត្ត(ធម្មាយតនៈ)មួយចំនួនក្តី រូបគ្រប់ប្រភេទទាំងខាងក្នុងនិងខាងក្រៅក្តី ទាំងនេះសុទ្ធតែរួមបញ្ចូលនៅក្នុងរូបក្ខន្ធ។

ខន្ធក្រុមទី២គឺវេទនាក្ខន្ធ។ ក្រុមនេះរួមយកវេទនាទាំងអស់របស់យើង ទាំងដែលជាសុខវេទនា ទុក្ខវេទនាឬឧបេក្ខាវេទនា ដែលកើតឡើងដោយអាស្រ័យការប៉ះទង្គិចគ្នារវាងអាយតនៈខាងក្នុង(មានចក្ខុជាដើម) ជាមួយនឹងអាយតនៈខាងក្រៅ(មានរូបជាដើម)។ វេទនាទាំងនេះមាន៦ប្រភេទគឺ

១. វេទនាដែលកើតឡើងដោយការប៉ះទង្គិចរវាងចក្ខុនឹងរូប (ការសោយនូវអារម្មណ៍ដោយអាស្រ័យរូប)

២. វេទនាដែលកើតឡើងដោយការប៉ះទង្គិចរវាងត្រចៀកនឹងសំឡេង(ការសោយនូវអារម្មណ៍ដោយអាស្រ័យសំឡេង)

៣. វេទនាដែលកើតឡើងដោយការប៉ះទង្គិចរវាងច្រមុះនឹងក្លិន (ការសោយនូវអារម្មណ៍ដោយអាស្រ័យក្លិន)

៤. វេទនាដែលកើតឡើងដោយការប៉ះទង្គិចរវាងអណ្តាតនឹងរស(ការសោយនូវអារម្មណ៍ដោយអាស្រ័យរស)

៥. វេទនាដែលកើតឡើងដោយការប៉ះទង្គិចរវាងកាយនឹង ផោដ្ឋព្វៈ( ការសោយនូវអារម្មណ៍ដោយអាស្រ័យផោដ្ឋព្វៈ)

៦. វេទនាដែលកើតឡើងដោយចិត្ត( ជាឥន្ទ្រិយទី៦នៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា) ជាមួយអារម្មណ៍ដែលកើតនឹងចិត្តឬការគិត។ ការឃើញនូវវេទនាទាំងអស់ ទាំងដែលកើតពីប្រសាទពាល់ត្រូវនឹងផ្លូវចិត្តសុទ្ធសឹងរួមនៅក្នុងខន្ធ( ទី២) នេះ។

ការនិយាយទៅដល់អ្វីដែលយើងហៅថាចិត្ត( មនោ) ទៅតាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនា អាចនឹងមានប្រយោជន៍នៅក្នុងទីនេះ។ គប្បីយល់ឱ្យបានច្បាស់ថា ចិត្តមិនមែនជាតួវិញ្ញាណ( ខ្មោច ព្រាយ បិសាច) ដែលផ្ទុយស្រលះទៅនឹងវត្ថុ ហើយក៏គប្បីចងចាំទុកផងដែរថា ព្រះពុទ្ធសាសនាមិនទទួលស្គាល់រឿងវិញ្ញាណ( ព្រលឹង) ដូចដែលសាសនាទាំងឡាយទទួលស្គាល់នោះឡើយ។ មនោ( ចិត្ត) គ្រាន់តែជាឥន្ទ្រិយឬអាយតនៈ ដូចភ្នែកនិងត្រចៀកដែរ។ ចិត្តនេះអាចរក្សាឬធ្វើឱ្យចម្រើនបាន ដូចទៅនឹងឥន្ទ្រិយដទៃផងដែរ ហើយព្រះពុទ្ធអង្គក៏បានត្រាស់អំពីគុណប្រយោជន៍ នៃការគ្រប់គ្រងនិងការសង្រួមនូវឥន្ទ្រិយទាំង៦នេះជារឿយៗ។ ភាពខុសប្លែកគ្នារវាងភ្នែកនិងចិត្ត ក្នុងឋានៈដែលជាឥន្ទ្រិយដូចគ្នានោះនៅត្រង់ថា ភ្នែកទទួលដឹងនូវសភាពរបស់ពណ៌និងរូបដែលឃើញ ដោយឡែកចិត្តទទួលដឹងនូវសភាពនៃការគិត ការយល់ឃើញនិងធម្មារម្មណ៍

ទាំងឡាយ។ យើងអាចនឹងទទួលដឹងនូវសភាពផ្សេងៗនៃសភាវៈខាងក្រៅ ដោយប្រសាទដែលខុសប្លែកពីគ្នា។ យើងមិនអាចនឹងបានឮពណ៌ ប៉ុន្តែយើងអាចឃើញវាបាន ដូចគ្នានេះដែរ យើងមិនអាចនឹងឃើញសំឡេង ប៉ុន្តែយើងក៏អាចឮវាបាន។ ដោយអាស្រ័យបសាទរូបទាំង៥យ៉ាងរបស់យើងគឺភ្នែក ត្រចៀក ច្រមុះ អណ្តាតនិងកាយ យើងអាចទទួលដឹងត្រឹមលោកនៃរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដូចដែលបានរៀបរាប់មកនេះ ប៉ុន្តែរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ទាំងអស់នេះឆ្លុះបញ្ចាំងឱ្យយើងឃើញត្រឹមផ្នែកខ្លះនៃលោកប៉ុណ្ណោះ មិនមែនលោកទាំងអស់នោះទេ(សភាវធម៌ទាំងអស់)។ ចុះអ្វីទៅជាលោកនៃការនឹកគិតផ្សេងៗ? ទាំងទស្សនៈនិងការគិតឃើញ ក៏ជាចំណែកមួយរបស់លោកដូចគ្នា ប៉ុន្តែការគិតទាំងនោះ បុគ្គលមិនអាចទទួលដឹងបានដោយផ្ទាល់តាមរយៈបសាទសម្ផស្សទាំង៥ ពោលគឺមិនអាចនឹងកើតឡើងតាមផ្លូវឥន្ទ្រិយមានភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយបានឡើយ។ ទោះជាយ៉ាងដូច្នេះក្តី វាក៏អាចនឹងកើតឡើងបានតាមឥន្ទ្រិយដទៃ នោះក៏គឺចិត្ត(មនោ)។

ទុកណាជាការគិត ការយល់ឃើញ មិនអាចនឹងកើតឡើងបានដោយអាស្រ័យប្រសាទទាំង៥ក៏ដោយចុះ ក៏វាមិនអាចត្រូវបានញែកផ្តាច់ចេញទាំងស្រុង ពីសភាពដែលអាចទទួលដឹងបានដោយប្រសាទឥន្ទ្រិយ

ទាំង៥។ តាមពិតទៅ ការគិតនិងការយល់ឃើញទាំងនោះ ក៏នៅតែត្រូវអាស្រ័យនិងមានការដឹងតាមប្រសាទឥន្ទ្រិយទាំង៥ជាបច្ច័យ។ យើងអាចឃើញច្បាស់ជាឧទាហរណ៍បាន តាមរយៈមនុស្សដែលពិការភ្នែកពីកំណើត គេមិនអាចនឹងមានការគិតឃើញ ទាក់ទងជាមួយនឹងពណ៌បាន វៀរលែងតែសំឡេងដែលគេអាចដឹងបាន ដោយអាស្រ័យឥន្ទ្រិយគឺត្រចៀកប៉ុណ្ណោះ។ ការគិត ការយល់ឃើញ ដែលប្រកបជាចំណែកមួយរបស់លោក កើតឡើងតាមរយៈបសាទសម្ផស្ស មានបសាទសម្ផស្សជាបច្ច័យឱ្យកើតឡើង ហើយទទួលដឹងបានតាមផ្លូវចិត្ត។ ដូចនេះទើបចិត្ត (មនោ) ត្រូវបានចាត់បញ្ចូលថាជាឥន្ទ្រិយមួយ ដូចភ្នែកនិងត្រចៀកដែរ។

ខន្ធទីពក្នុងទីនេះគឺសញ្ញាក្ខន្ធ។ ដូចវេទនាក្ខន្ធដែរ ក្នុងលក្ខណៈដែលសញ្ញាត្រូវបានបែងចែកជា៦ប្រភេទ ដែលកើតឡើងតាមរយៈការពាក់ព័ន្ធរវាងឥន្ទ្រិយក្នុងទាំង៦(ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត) ជាមួយនឹងវត្ថុខាងក្រៅទាំង៦(រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍)។ សញ្ញាទាំងនេះក៏មិនខុសអ្វីទៅនឹងវេទនា គឺកើតឡើងដោយអាស្រ័យការប៉ះទង្គិចគ្នា រវាងអាយតនៈខាងក្នុង៦ជាមួយនឹងអាយតនៈខាងក្រៅ៦ ហើយគឺតួសញ្ញានេះឯងដែលជាអ្នកចាំនូវរឿងរ៉ាវផ្សេងៗ ទាំងដែលជារូបធម៌និងនាមធម៌។

ខន្ធប្រការទី៤បានដល់សង្ខារក្ខន្ធ។ ខន្ធក្រុមនេះរួមយកទង្វើដែលសចេញពីចេតនាទាំងអស់ទាំងល្អនិងអាក្រក់ ហើយអ្វីដែលយើងស្គាល់ថា"កម្ម" ក៏រួមបញ្ចូលនៅក្នុងខន្ធនេះផងដែរ។ គប្បីចាំពាក្យកំណត់ន័យសេចក្តី ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថា"**ម្នាលភិក្ខុទាំងឡាយ! តថាគតពោលចេតនាថាជាតួកម្ម**"។ ព្រោះមានការតាំងចិត្ត ទើបបុគ្គលធ្វើកម្មទាំងផ្លូវកាយ វាចានិងចិត្ត។ ចេតនាជាតួបង្កើតចិត្ត គឺធ្វើឱ្យចិត្តមានចលនា។ កិច្ចរបស់ចេតនា គឺបញ្ជាឱ្យចិត្តប្រព្រឹត្តទៅទាំងក្នុងផ្លូវល្អ ផ្លូវអាក្រក់ឬផ្លូវអព្យាក្រឹត្យ។ ចេតនា(សង្ខារ)ក៏ដូចទៅនឹងវេទនានិងសញ្ញាគឺមាន៦ប្រភេទ ដែលកើតឡើងពីការពាក់ព័ន្ធរវាងឥន្ទ្រិយ(អាយតនៈ)ខាងក្នុងទាំង៦ ជាមួយនឹងសភាវៈខាងក្រៅដែលមកប៉ះទង្គិច(ទាំងដែលជារូបធម៌និងនាមធម៌)។ វេទនានិងសញ្ញាមិនមែនជាការធ្វើដែលប្រកបដោយចេតនា ព្រោះទាំងវេទនានិងសញ្ញាមិនសាងវិបាក(ផលរបស់កម្ម)ផ្ទុយទៅវិញ គឺមានតែតួកម្មដែលប្រកបដោយចេតនាប៉ុណ្ណោះ ដែលអាចសាងផលកម្មបាន ។ ឧទាហរណ៍ដូចជាការចាប់អារម្មណ៍(មនសិការ) ការតាំងចិត្ត(ឆន្ទៈ) ការដំកល់ចិត្តមាំ(អធិមោក្ខ) ការជឿជាក់(សទ្ធា) ការសង្រួមចិត្ត(សមាធិ) ការដឹងច្បាស់(បញ្ញា) ការព្យាយាម(វិរិយៈ) សេចក្តីត្រេកត្រអាល(រាគៈ) ការស្អប់ខ្ពើម(បដិឃៈ) ភាពល្ងង់ខ្លៅ(អវិជ្ជា) ការប្រកាន់ខ្លួន(មានះ) ការប្រកាន់ថាមានតួខ្លួន(សក្កាយទិដ្ឋិ)

ជាដើម ។ និយាយជារួមចេតសិកធម៌មាន៥២ដួង រួមគ្នាបង្កើតបានជាសង្ខារក្ខន្ធ ។

ខន្ធទី៥ដែលជាខន្ធចុងក្រោយនោះគឺវិញ្ញាណក្ខន្ធ ។ វិញ្ញាណ( ការដឹងច្បាស់នូវអារម្មណ៍) ជាផលនៃការតបស្នង ដែលមានឥន្ទ្រិយទាំង៦ (ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត) ជាទីតាំង និងមានហេតុប្រាកដខាងក្រៅ ដែលទាក់ទងគ្នាទាំង៦ប្រការ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍) ជាគ្រឿងទទួល( ជាអារម្មណ៍) ។ ឧទាហរណ៍ដូចជាចក្ខុវិញ្ញាណ មានភ្នែកជាទីតាំង ហើយមានរូបជាគ្រឿងទទួល មនោវិញ្ញាណមានចិត្ត( មនោ) ជាទីតាំង មានធម្មារម្មណ៍គឺការនឹកគិតជាគ្រឿងទទួល( នូវអារម្មណ៍) ។ ដូចនេះទើបវិញ្ញាណ ទាក់ទងជាមួយនឹងឥន្ទ្រិយ (ឬអាយតនៈ) ផ្សេងៗ ដោយប្រការដូចដែលបានរៀបរាប់មកនេះ ។ វិញ្ញាណក៏ដូចទៅនឹងវេទនា សញ្ញានិងសង្ខារគឺមាន៦ប្រការ ដែលមានទំនាក់ទំនងរវាងអាយតនៈខាងក្នុង៦ ជាមួយនឹងអាយតនៈខាងក្រៅ៦ ។

គប្បីយល់ឱ្យបានច្បាស់ថា វិញ្ញាណមិនបានចាំវត្ថុ( អារម្មណ៍) ពោលគឺវិញ្ញាណគ្រាន់តែជាការដឹងច្បាស់មួយប្រភេទ គឺដឹងច្បាស់ពីការតាំងនៅរបស់អារម្មណ៍ ។ ឧទាហរណ៍ពេលភ្នែកប៉ះជាមួយពណ៌ ដូចយ៉ាងពណ៌ក្រហម ចក្ខុវិញ្ញាណក៏កើតឡើង ដែលគ្រាន់តែជាការដឹងច្បាស់នូវលក្ខណៈរបស់ពណ៌ ប៉ុន្តែវិញ្ញាណមិនបានចាំវាថាជាពណ៌ក្រហម ព្រោះ

មិនមានការចាំនៅក្នុងខន្ធនេះឡើយ ផ្ទុយទៅវិញគឺសញ្ញា(ខន្ធទីពដូចបានពោលមកហើយ)ទៅវិញទេ ដែលចាំបានថាវាគឺជាពណ៌ក្រហម។ ពាក្យថាចក្ខុវិញ្ញាណ គឺជាការសម្ដែងចេញនូវទស្សនៈដែលកំណត់យកនូវផ្នត់គំនិតមួយ ដែលយើងប្រើទៅតាមភាសាធម្មតាថា "ការឃើញ"។ ការឃើញមិនមែនមានន័យថាជាការចាំបាននោះទេ ដូចនេះវិញ្ញាណឯទៀតៗក៏មានន័យ(លក្ខណៈ)ដូចគ្នានេះដែរ។

សូមគូសបញ្ជាក់ត្រង់នេះបន្តិចថា តាមទស្សនៈព្រះពុទ្ធសាសនាគឺមិនមានវិញ្ញាណដែលឋិតថេរមិនប្រែប្រួល ហើយដែលយើងនាំគ្នាហៅថាខ្លួន(Self) ព្រលឹង(Soul) ឬអត្តា(Ego) ដែលផ្ទុយទៅនឹងវត្ថុរូប(រូបធម៌)នោះឡើយ។ មួយវិញទៀត ក៏មិនគួរចាត់ទុកវិញ្ញាណថាប្រៀបដូចជាខ្មោច ព្រាយ បិសាច ក្នុងសភាពដែលផ្ទុយទៅនឹងវត្ថុរូបនោះដែរ។ ចំណុចនេះចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់ ព្រោះមានមតិមួយចំនួនយល់ខុសថា វិញ្ញាណជាប្រភេទមួយរបស់អាត្មន ហើយអមតវិញ្ញាណ(វិញ្ញាណដែលមិនចេះស្លាប់)ត្រាច់ចរទៅ ប្រដូចទៅនឹងអ្វីដែលគង់នៅអស់កាលជានិច្ច ហើយដែលត្រូវបានបន្តភ្ជាប់ តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន។

សាវ័ករបស់ព្រះពុទ្ធជាម្ចាស់មួយអង្គមាននាមថា"សាតិ" បានប្រកាន់មាំថាព្រះបរមសាស្ដាបានទូន្មានយ៉ាងដូច្នេះថា "គឺវិញ្ញាណមួយដូង

នេះឯង ដែលកើតថ្មីហើយត្រាច់ចរទៅ"។ ពេលព្រះពុទ្ធជាម្ចាស់ត្រាស់សួរលោកថា"ដែលថាវិញ្ញាណនោះ គឺសំដៅទៅដល់អ្វី?"។ ចម្លើយរបស់សាតិភិក្ខុគឺដូចទៅនឹងការយល់ឃើញពីដំបូងរបស់លោកថា "វិញ្ញាណក៏គឺអ្វីដែលអាចសម្តែងចេញមកបាន ទទួលដឹងនូវអារម្មណ៍ ទទួលផលរបស់កម្មល្អនិងអាក្រក់ អាចតាំងនៅទីនេះនិងទីនោះបាន"។ ព្រះបរមសាស្តាទ្រង់បដិសេធថា "ម្នាលមោឃបុរស! អ្នកបានស្តាប់យើងប្រកាសនូវធម៌លំនាំនេះដល់នរណា? យើង(តថាគត)បានអធិប្បាយហើយ ដោយន័យជាអនេកមែនទេថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ ការកើតឡើងរបស់វិញ្ញាណដែលប្រាសចាកបច្ច័យ គឺមិនមានឡើយ"។ បន្ទាប់មកព្រះពុទ្ធអង្គក៏បានទ្រង់បន្តនូវការអធិប្បាយអំពីវិញ្ញាណ ដោយសេចក្តីពិស្តារថា វិញ្ញាណមានឈ្មោះទៅតាមបច្ច័យ ដែលវាអាស្រ័យកើតឡើង ពោលគឺបើអាស្រ័យរូបនិងភ្នែកវិញ្ញាណកើតឡើង វិញ្ញាណនេះមានឈ្មោះថាចក្ខុវិញ្ញាណ អាស្រ័យត្រចៀកជាមួយសំឡេងវិញ្ញាណកើតឡើង វិញ្ញាណនេះមានឈ្មោះថាសោតវិញ្ញាណ។ អាស្រ័យច្រមុះនិងក្លិនវិញ្ញាណកើតឡើង វិញ្ញាណនេះមានឈ្មោះថាឃានវិញ្ញាណ អាស្រ័យអណ្តាតនិងរសវិញ្ញាណកើតឡើង វិញ្ញាណនេះមានឈ្មោះថាជិវ្ហាវិញ្ញាណ។ អាស្រ័យរាងកាយនិងផោដ្ឋព្វៈវិញ្ញាណកើតឡើង វិញ្ញាណនេះមានឈ្មោះថាកាយ

វិញ្ញាណ។ អាស្រ័យចិត្តនិងធម្មារម្មណ៍(អារម្មណ៍ផ្សេងៗ)វិញ្ញាណកើតឡើង យើងហៅវិញ្ញាណនេះថាមនោវិញ្ញាណ។

លំដាប់បន្តមកទៀត ព្រះពុទ្ធជាម្ចាស់បានទ្រង់អធិប្បាយ ដោយការលើកជាឧទាហរណ៍ថា ភ្លើងមានឈ្មោះទៅតាមវត្ថុដែលវាឆេះ ភ្លើងដែលឆេះអុស យើងក៏ហៅវាថាភ្លើងអុស ភ្លើងដែលឆេះចំបើង យើងក៏ហៅវាថាភ្លើងចំបើងយ៉ាងណាមិញ វិញ្ញាណក៏មានឈ្មោះទៅតាមបច្ច័យដែលវាអាស្រ័យកើតឡើងយ៉ាងនោះដែរ។

ស្របទៅនឹងន័យនេះឯង ព្រះពុទ្ធឃោសាចារ្យដែលជាអដ្ឋកថាចារ្យ(គ្រូនៃគម្ពីរអដ្ឋកថា)ដ៏ល្បីល្បាញ បានអធិប្បាយទុកមកយ៉ាងដូច្នេះថា "ភ្លើងដែលឆេះព្រោះអុស នឹងឆេះបានចំពោះតែពេលដែលមានចំណីភ្លើង(អុស) ហើយនឹងរលត់ទៅវិញនៅទីនោះនោះឯង នៅពេលចំណីអុសមិនមាន ដែលជាយ៉ាងដូច្នេះត្បិតថាបច្ច័យបានផ្លាស់ប្តូរទៅ ប៉ុន្តែ(ភ្លើង)នឹងមិនឆ្លងទៅកាន់ចំណីផ្សេងៗដទៃទៀតជាដើម។ ក្នុងលំនាំដូចគ្នានេះឯង វិញ្ញាណដែលកើតព្រោះអាស្រ័យភ្នែកជាមួយរូប កើតឡើងតាមទ្វារនិងបសាទសម្ផស្ស(មានភ្នែកជាដើម) ក៏ចំពោះតែពេលដែលមានបច្ច័យពោលគឺភ្នែកបូករូប បូកពន្លឺ បូកមនសិការប៉ុណ្ណោះ ហើយនឹងរលត់ទៅវិញនៅក្នុងទីនោះៗ ពេលដែលបច្ច័យនៅក្នុងទីនោះមិនមានតទៅទៀត ដែលជាយ៉ាងដូច្នេះក៏ព្រោះថាបច្ច័យបានផ្លាស់ប្តូរទៅ តែ

(វិញ្ញាណ) នឹងមិនឆ្លងទៅកាន់ត្រចៀកជាដើម ហើយក្លាយជាសោតវិញ្ញាណ...”។

ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាស ដោយពាក្យពេចន៍ដ៏ច្បាស់លាស់ថា វិញ្ញាណ អាស្រ័យរូប វេទនា សញ្ញា និងសង្ខារទាំងឡាយ ហើយវាមិនអាចតាំងនៅបានដោយប្រាសចាកសភាវៈ មានរូបជាដើមនោះបានឡើយ។ ព្រះអង្គទ្រង់ត្រាស់ថា “វិញ្ញាណអាចនឹងតាំងនៅបាន ដោយអាស្រ័យមានរូបជាឧបាយ(រូបុបាយំ) មានរូបជាអារម្មណ៍(រូបារម្មណំ) មានរូបជាទីតាំង(រូបបទិដ្ឋំ) និងប្រកបជាមួយអារម្មណ៍ដែលគួរឱ្យពេញចិត្ត វារមែងចម្រើនលូតលាស់ធំធាត់ ឬវិញ្ញាណអាចតាំងនៅបាន ដោយមានវេទនាជាឧបាយ... មានសញ្ញាជាឧបាយ... មានសង្ខារជាឧបាយ ជាអារម្មណ៍ ជាទីតាំង ហើយពេលប្រសព្វជាមួយនឹងអារម្មណ៍ដែលគួរឱ្យពេញចិត្ត វារមែងចម្រើនលូតលាស់ធំធាត់”។

“ប្រសិនបើមានបុគ្គលណាមួយពោលថា យើងនឹងសម្ដែងអំពីការមក ការទៅ ការរលត់ ការកើតឡើង ការចម្រើន ការវិវឌ្ឍ និងការរីកធំធាត់របស់វិញ្ញាណ ញែកផ្ដាច់ចេញពីរូប វេទនា សញ្ញានិងសង្ខារ បុគ្គលម្នាក់នោះឈ្មោះថា បាននឹងកំពុងនិយាយទៅដល់អ្វី ដែលមិនមានប្រាកដ(មិនពិត)”។

សរុបមកបញ្ចក្ខន្ធ ដែលយើងនាំគ្នាហៅថាជាសត្វ ជាបុគ្គល ឬថាជាតួខ្លួន ការពិតទៅវាគ្រាន់តែជាឈ្មោះ ដែលត្រូវបានមនុស្សសន្មត ឡើងដើម្បីប្រើសម្រាប់ហៅ ការរួមបញ្ចូលគ្នានៃខន្ធទាំង៥នេះប៉ុណ្ណោះ។ ខន្ធទាំង៥នេះជាសភាវៈមិនទៀតទាត់ ហើយទាំងអស់តែងតែផ្លាស់ប្តូរ ជានិច្ច។ **សភាវៈណាមិនទៀង សភាវៈនោះជាទុក្ខ(យំ អនិច្ចំ តំ ទុក្ខំ)**។ នេះគឺអត្ថន័យដ៏ពិតប្រាកដ នៃព្រះពុទ្ធវចនៈដែលថា "និយាយដោយខ្លី ឧបាទានក្ខន្ធ៥ជាទុក្ខ"។

ខន្ធ៥នេះមិនមែនជាសភាវៈតែមួយជាមួយគ្នា សម្រាប់ខណៈ ដែលតភ្ជាប់គ្នាពីរខណៈនោះទេ។ ក្នុងន័យនេះ A(ទី១)គឺមិនមែនជាA (ទី២)នោះទេ។ ឧបាទានក្ខន្ធ៥ស្ថិតនៅក្នុងដំណើរនៃការកើតឡើង និង ការរលត់ទៅនៃខណៈជាច្រើន។

**"ម្នាលព្រាហ្មណ៍! វាប្រៀបដូចទឹកដែលហូរធ្លាក់ពីលើភ្នំ ហូរ ឆ្ងាយហើយលឿន នាំយកអ្វីៗគ្រប់យ៉ាងទៅព្រមគ្នាជាមួយនឹងទឹកនោះ មិនមានខណៈ(មិនមានការឈប់ជាបណ្តោះអាសន្នណាមួយ ក្នុងខណៈ កំពុងហូរធ្លាក់មកនោះ) មិនមានច្រំដែល មិនមានជាលើកទីពីរនៅពេល ដែលវាឈប់ហូរ ប៉ុន្តែវាហូរទៅនិងហូរបន្តទៅរឿយៗ។ ព្រាហ្មណ៍! ជីវិត មនុស្សក៏ដូច្នោះដែរ ប្រៀបដូចទឹកដែលហូរធ្លាក់ពីលើភ្នំ"**។

មួយវិញទៀតដូចដែលព្រះពុទ្ធអង្គ ធ្លាប់បានត្រាស់ទៅកាន់ព្រះរដ្ឋបាលថា **"ម្នាលរដ្ឋបាល! លោកទាំងមូលស្ថិតនៅក្នុងដំណើរដែលហូរជានិច្ច និងជាសភាវៈដែលមិនឋិតថេរ"**។

សភាវៈមួយរលត់ ក៏ជាបច្ច័យឱ្យកើតសភាវៈមួយបន្តទៀត ក្នុងលំនាំនៃហេតុនិងផល។ មិនមានអ្វីដែលមិនប្រែប្រួល នៅក្នុងសភាវៈទាំងនេះនោះឡើយ ទាំងមិនមានអ្វីនៅពីក្រោយបាតុភូតទាំងនោះ ដែលយើងអាចហៅបានថាជាបុគ្គល ជាសភាវៈឬជាអត្តា ដែលទៀងទាត់ឋិតថេរ។ មកដល់ត្រង់ចំណុចនេះ គ្រប់គ្នានឹងយល់ស្របថារូប វេទនា សញ្ញា សង្ខារ ឬវិញ្ញាណ គឺមិនអាចហៅបានយ៉ាងពិតប្រាកដថា ជាខ្លួនយើងសោះឡើយ តែពេលដែលខន្ធទាំងនោះទាំងដែលជារូបនិងនាម អាស្រ័យនូវគ្នានឹងគ្នាធ្វើការរួមគ្នាប្រដូចទៅនឹងគ្រឿងយន្ត ដែលមានទាំងរាងកាយនិងចិត្តគំនិត(ប៉ុណ្ណោះ) យើងក៏មានការគិតថា"ជាខ្លួនយើង" កើតឡើងមក។ វាគ្រាន់តែជាការគិតដែលខុស ជាសង្ខារក្ខន្ធដែលមិនមែនជាអ្វីដទៃ ក្រៅតែពីជាសភាវធម៌មួយក្នុងចំណោមសង្ខារ(ចេតសិក)៥២ ប្រភេទរបស់ខន្ធទី៤(សង្ខារក្ខន្ធ) ដែលយើងបានអធិប្បាយរួចមកហើយ មានឈ្មោះថាសក្កាយទិដ្ឋិ(ទិដ្ឋិដែលយល់ឃើញថាមានតួខ្លួន)។

រួមខន្ធទាំង៥ចូលជាមួយគ្នា ជាអ្វីដែលយើងនាំគ្នាហៅជាទូទៅថាសត្វនេះ គឺជាទុក្ខ(សង្ខារទុក្ខ)។ ការពិតទៅ មិនមានអ្វីដទៃដែលជា

សត្វ ជាបុគ្គលឬជាខ្លួនយើង នៅពីក្រោយខន្ធទាំង៥ ដែលជាអ្នកសោយនូវទុក្ខនោះឡើយ ដូចដែលព្រះពុទ្ធឃោសាចារ្យបានពោលទុកថា "មានត្រឹមទុក្ខប៉ុណ្ណោះដែលតាំងនៅ តែអ្នកសោយទុក្ខមិនមាន។ ការធ្វើអំពើមានប្រាកដ តែមិនប្រាកដនូវអ្នកធ្វើអំពើ។ មិនមានអ្នកធ្វើចលនាដែលមិនធ្វើចលនា នៅពីក្រោយនៃការធ្វើចលនានោះឡើយ គ្រប់យ៉ាងវាគ្រាន់តែជាចលនាប៉ុណ្ណោះ"។ **មិនមែនជាការត្រឹមត្រូវឡើយដែលនឹងនិយាយថា ជីវិតកំពុងធ្វើចលនា ត្បិតថាជីវិតគឺជាចលនាហ្នឹងឯង។** ជីវិតនិងចលនា មិនមែនជាសភាវៈពីរដែលដាច់ចេញពីគ្នា ឬពោលម្យ៉ាងទៀតថា មិនមានអ្នកគិតនៅពីក្រោយនៃការគិត ពោលគឺការគិតនោះឯងជាអ្នកគិត បើអ្នកឈប់គិត ក៏នឹងមិនមានអ្នកគិតដែលត្រូវបានរកឃើញ។ ដោយយោងទៅតាមការបកស្រាយទាំងអម្បាលម៉ាននេះ(ខ្ញុំសង្ឃឹមថា) អ្នកប្រហែលជាមិនធ្លាក់ទៅក្នុងគំនិតដែលថា ហេតុអ្វីទើបទស្សនៈរបស់ព្រះពុទ្ធសាសនា មានលក្ខណៈជាបដិបក្ខទៅនឹងទ្រឹស្តីរបស់វិទ្យាសាស្ត្រដែលថា "ខ្ញុំគិត ព្រោះហេតុដូច្នេះទើបមានខ្ញុំ"។

ម្តងនេះអាចនឹងមានជាសំណួរចោទឡើងថា "តើជីវិត(ជាតិដំបូងបំផុត) មានចំណុចចាប់ផ្តើមតាំងពីពេលណា?"។ ផ្អែកតាមគោលធម៌របស់ព្រះពុទ្ធជាម្ចាស់ ចំណុចចាប់ផ្តើមនៃដំណើរជីវិតរបស់សត្វ ជារឿងដែលបុគ្គលមិនអាចដឹងបាន។ អ្នកដែលជឿថាព្រះជាម្ចាស់ជាអ្នកបង្កើត

ជីវិត អាចនឹងប្លែកក្នុងចិត្តសម្រាប់ចម្លើយនេះ(របស់ព្រះពុទ្ធជាម្ចាស់) ប៉ុន្តែប្រសិនបើយើងសួរទៅគេវិញថា "ចុះតើអ្វីទៅជាចំណុចចាប់ផ្ដើមរបស់ព្រះជាម្ចាស់នោះ?"។ គេនឹងឆ្លើយមកវិញភ្លាមដោយមិនស្ទាក់ស្ទើរថា "ព្រះជាម្ចាស់គ្មានចំណុចចាប់ផ្ដើម" ហើយគេក៏នឹងមិនប្លែកក្នុងចិត្តចំពោះចម្លើយរបស់គេឡើយ។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា

"ម្នាលភិក្ខុទាំងឡាយ! សង្សារវដ្ដនេះមានទីបំផុត ដែលបុគ្គលមិនអាចឃើញបាន។ ការចាប់ផ្ដើមដំបូងបំផុតរបស់ពពួកសត្វ ដែលត្រាច់ទៅដោយជុំវិញ(វិលវល់កើតស្លាប់) ត្រូវគ្របដណ្ដប់ដោយអវិជ្ជានិងតណ្ហាសវៈរួបរឹតទុក មិនអាចប្រាកដឱ្យដឹងបាន"។ បន្ថែមលើនោះទៅទៀត ពេលត្រាស់ទៅដល់អវិជ្ជា ដែលជាដើមហេតុដ៏សំខាន់នៃដំណើរត្រាច់ទៅរបស់ជីវិត(សត្វលោក) ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ចំណុចចាប់ផ្ដើមរបស់អវិជ្ជា មិនប្រាកដក្នុងលំនាំដែលអាចអះអាងបានថា មិនមានអវិជ្ជាមុនពេលបច្ចុប្បន្ន"។ ដូច្នេះទើបមិនអាចទៅរួចដែលនឹងនិយាយថា មិនមានជីវិតមុនពេលបច្ចុប្បន្ន។

នេះគឺខ្លឹមសារដោយសង្ខេប របស់អរិយសច្ចៈស្ដីអំពីទុក្ខ។ ជាការចាំបាច់ក្រៃលែង ក្នុងការយល់នូវអរិយសច្ចៈប្រការដំបូងនេះឱ្យបានច្បាស់ ព្រោះដូចដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ទុកថា **"បុគ្គលដែលឃើញទុក្ខ**

**រមែងឃើញហេតុដែលនាំឱ្យកើតទុក្ខ ការរលត់ទៅនៃទុក្ខ និងផ្លូវដែលនាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ**"។

ប្រការដែលបានពោលមកទាំងប៉ុន្មាននេះ មិនបានធ្វើឱ្យជីវិតរបស់ពុទ្ធសាសនិកជនពេញទៅដោយសេចក្តីទុក្ខ ឬពេញទៅដោយសេចក្តីសោក ដូចដែលមនុស្សមួយចំនួន(អពុទ្ធិបុគ្គល) ធ្វើការវាយតម្លៃយ៉ាងខុសឆ្គងនោះឡើយ។ ផ្ទុយទៅវិញ ពុទ្ធសាសនិកបុគ្គល(ដ៏ពិតប្រាកដ) ជាអ្នកដែលមានសេចក្តីសុខបំផុត ក្នុងបណ្តាអ្នកដែលមានជីវិតរស់នៅ។ គេមិនមាននូវការភ័យខ្លាចឬក្តីកង្វល់ ហើយជាអ្នកដែលមានសេចក្តីស្ងប់និងសេចក្តីរីករាយ ទាំងមិនជាមនុស្សដែលត្រូវទុក្ខគ្របដណ្តប់បាន ឬមានការភ័យតក់ស្លុតព្រោះអាស្រ័យការប្រែប្រួលផ្លាស់ប្តូរ ឬហាយនភាព(សេចក្តីវិនាសសាបសូន្យ) ត្បិតថាគេឃើញសភាវៈគ្រប់យ៉ាងទៅតាមសេចក្តីពិត។ ព្រះពុទ្ធអង្គមិនធ្លាប់ជាអ្នកសោកសៅ ឬមិនស្រស់ថ្លាដល់ម្តងណាឡើយ ព្រះអង្គបានទទួលនូវការលើកសរសើរ ដោយបុគ្គលរួមជំនាន់ជាមួយព្រះអង្គជាច្រើន(រួមទាំងមេដឹកនាំសាសនាដទៃទៀត) ថាជាអ្នកមានព្រះភ័ក្ត្រ ពេញទៅដោយភាពស្រស់ថ្លា(ស្នាមញញឹម)ជានិច្ច (មិហិតបុព្វង្គមា)។ សូម្បីក្នុងសិល្បៈគំនូរនិងបដិមាកម្មផ្នែកព្រះពុទ្ធសាសនា រូបរបស់ព្រះពុទ្ធជាម្ចាស់រមែងបង្កប់ទៅដោយសេចក្តីសុខលើព្រះភ័ក្ត្រ មានភាពត្រជាក់ត្រជុំ សេចក្តីស្ងប់និងមហាករុណា មិនមាន

លក្ខណៈដែលបង្ហាញឱ្យឃើញពីសេចក្ដីទុក្ខ សេចក្ដីសោកសៅឬការឈឺចាប់ ដែលយើងអាចប្រទះឃើញបាននោះឡើយ ។ សិល្បៈនិងស្ថាបត្យកម្មផ្នែកព្រះពុទ្ធសាសនាដូចជាព្រះវិហារជាដើម ក៏មិនដែលផ្ដល់នូវអារម្មណ៍ ដែលពោរពេញទៅដោយភាពមួហ្មងឬសោកសៅ ។ ផ្ទុយទៅវិញ គឺបានបង្កើតនូវបរិយាកាសនៃសេចក្ដីស្ងប់ និងពេញទៅដោយសេចក្ដីរំភើបរីករាយ ។

## សុទ្ធរភាពជានិរន្តរ៍

ទោះបីជាមានទុក្ខនៅក្នុងជីវិត ប៉ុន្តែពុទ្ធសាសនិកបុគ្គលក៏មិនសោកសៅចំពោះរឿងនោះៗ ទាំងមិនខឹងឬថ្នាំងថ្នាក់ចំពោះសេចក្ដីទុក្ខនោះឡើយ ។ តាមទស្សនៈរបស់ព្រះពុទ្ធសាសនា ចំណុចដ៏អាក្រក់មួយក្នុងចំណោមអំពើអាក្រក់ជាមូលដ្ឋាននៅក្នុងជីវិត គឺការថ្នាំងថ្នាក់ឬការខឹងក្រោធ ។ ការថ្នាំងថ្នាក់(បដិឃៈ) បានដល់ចេតនាអាក្រក់ចំពោះសត្វទាំងឡាយ ចំពោះសេចក្ដីទុក្ខទាំងអស់ និងចំពោះសភាវៈដែលទាក់ទងជាមួយនឹងសេចក្ដីទុក្ខ ។ តួនាទីរបស់វា គឺបង្កើតនូវទីតាំងនៃសេចក្ដីទុក្ខ ក៏ដូចជាការប្រព្រឹត្តនូវទង្វើមិនគួរគប្បីទាំងឡាយ ។ ដូចនេះទើបជាការខុសដែលចិត្តមិនអត់ធន់ចំពោះសេចក្ដីទុក្ខ ត្បិតថាការមិនអត់ធន់ឬការខឹងក្រោធចំពោះសេចក្ដីទុក្ខ គឺមិនអាចកម្ចាត់នូវសេចក្ដីទុក្ខបានឡើយ ។

ផ្ទុយទៅវិញ វាកាន់តែបន្ថែមនូវភាពស្មុគស្មាញឡើងថែមមួយកម្រិតទៀត។ វាជាការបំប៉ោងនូវស្ថានការណ៍ ដែលអាក្រក់ស្រាប់ទៅហើយនោះ ឱ្យកាន់តែអាក្រក់ខ្លាំងឡើងថែមទៀត។ ហេតុដូច្នេះការដែលប្រសើរបំផុត ក៏គឺមិនខឹងឬមិនថ្នាំងថ្នាក់ ហើយព្យាយាមស្វែងយល់នូវបញ្ហាដែលនាំឱ្យកើតទុក្ខថា វាកើតឡើងមកបានយ៉ាងដូចម្តេច និងរំលត់វាទៅវិញបានយ៉ាងដូចម្តេច បន្ទាប់មកក៏ធ្វើការងារដោយសេចក្តីអត់ធន់ដោយបញ្ញា ដោយការតាំងចិត្តដ៏មុតមាំនិងដោយអស់ពីសមត្ថភាព។

មានគម្ពីរចាស់ៗចំនួន២គឺថេរគាថានិងថេរីគាថា ដែលរួបរួមនូវពាក្យឧទានប្រកបដោយសោមនស្ស នៃបណ្តាសាវ័កទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់ទាំងបុរសនិងស្ត្រី ដែលលោកទាំងនោះសុទ្ធសឹងជាអ្នកប្រទះនូវសន្តិនិងសេចក្តីសុខក្នុងជីវិត ដោយអាស្រ័យឱវាទទូន្មានរបស់ព្រះអង្គ។ គ្រាមួយព្រះបាទបសេនទិកោសលបានទូលព្រះអង្គថា សាវ័កទាំងឡាយរបស់ព្រះអង្គជាអ្នករីករាយសប្បាយចិត្ត( ហដ្ឋបហដ្ឋ) មានបីតិប្រាមោទ្យ( ឧទគ្គុទគ្គ) នៅជាសុខសំរាន្តជាមួយជីវិតផ្លូវធម៌( អភិរតរូប) មានឥន្ទ្រិយស្រស់ថ្លា( បីណិតិន្ទ្រិយ) ប្រាសចាកភាពខ្វល់ខ្វាយ( អប្បោសុក្ក) ត្រជាក់( បណ្ណលោម) ស្ងប់រម្ងាប់( បរទវុត្ត) និងមានចិត្តភ្លឺស្វាង( ទាំងដែលបរិភោគអាហារត្រឹមមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ) មិនដូចសាវ័ករបស់សាសនាដទៃ ដែលជាអ្នកល្ហិតល្ហៃ គ្រោកគ្រាត ស្លេក ស្លាំង

និងមិនគួរឱ្យទាក់ភ្នែកទាក់ចិត្តសោះឡើយ ។ បន្ទាប់មកព្រះបាទបសេនទិកោសលទ្រង់ក្រាបទូលបន្ថែមទៀតថា ព្រះអង្គទ្រង់ជឿថាព្រះសាវ័កទាំងឡាយ ដែលមានលក្ខណសម្បត្តិពេញលេញបរិបូរយ៉ាងដូច្នេះ ក៏អាស្រ័យមកពីការពិតដែលថា "ព្រះគុណម្ចាស់ទាំងឡាយនេះ បានដឹងច្បាស់នូវគុណវិសេសដទៃក្រៃលែងជាងកាលមុន ក្នុងសាសនារបស់ព្រះដ៏មានបុណ្យយ៉ាងពិតប្រាកដ" ។

ព្រះពុទ្ធសាសនាជាបដិបក្ខចំពោះចិត្ត ដែលមានលក្ខណៈសោកសៅ តក់ស្លុត ខូចចិត្តនិងស្រងូតស្រងាត់ ដែលត្រូវបានចាត់ទុកថាជានីវរណធម៌(ជាសត្រូវ) ចំពោះការត្រាស់ដឹងនូវសច្ចធម៌ ពោលដោយន័យមួយទៀតគឺគួរចងចាំទុកក្នុងចិត្តថា សេចក្ដីរីករាយដែលប្រកបដោយអំណរ(បីតិ) ជាលក្ខណៈដ៏ល្អមួយក្នុងចំណោមពោជ្ឈង្គ៧(ធម៌ជាអង្គនៃការត្រាស់ដឹង) ដែលជាគុណសម្បត្តិដ៏សំខាន់ និងគួរបណ្ដុះឱ្យកើតមានឡើង ដើម្បីការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន(ទីបំផុតនៃសេចក្ដីទុក្ខ) ។

ឲឲឲ✵៚៚៚

# ជំពូក៣

## អរិយសច្ចៈប្រការទី២

## សមុទ័យ "ហេតុដែលនាំឱ្យកើតទុក្ខ"

អរិយសច្ចៈប្រការទី២នេះ គឺសម្តែងអំពីការកើតឡើងឬប្រភព នៃសេចក្តីទុក្ខ(ទុក្ខសមុទយ អរិយសច្ច)។ និយមន័យដែលគេនិយមប្រើ និងស្គាល់ច្បាស់ជាទូទៅរបស់អរិយសច្ចៈប្រការទី២នេះ ដូចមានប្រាកដ នៅក្នុងទីជាច្រើននៅក្នុងគម្ពីរបុរាណមានសេចក្តីថា

**"ចំណង់នេះឯង(សេចក្តីស្រេកឃ្លាន តណ្ហា) ដែលបង្កើតឱ្យមាន ជាតិកំណើតនិងការអន្ទោលវិលវល់កើត ចាស់ ឈឺ ស្លាប់ គ្មានទីបញ្ចប់ ហើយដែលត្រូវបានចងភ្ជាប់ ជាមួយនឹងកាមរាគៈ(សេចក្តីប្រាថ្នា)ដ៏ខ្លាំង ក្លា"**។ "តណ្ហា"នេះត្រូវបានបែងចែកចេញជា៣ប្រភេទគឺ

១. កាមតណ្ហា សេចក្តីប្រាថ្នានៅក្នុងកាម បានដល់ការស្រលាញ់ ឬការជាប់ជំពាក់នៅក្នុងបញ្ចកាមគុណ(រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ)។

២. ភវតណ្ហា ចំណង់ឬតម្រេកនៅក្នុងភព(ភាពជានេះជានោះ) គឺការប្រាថ្នាចង់ឱ្យខ្លួនក្លាយទៅជាយ៉ាងនេះឬយ៉ាងនោះ ហើយជាប់ជំពាក់ ទៅនឹងសភាវៈដែលស្ថិតនៅជុំវិញខ្លួន ដែលធ្វើឱ្យសត្វលោកមិនអាចរើ ខ្លួនចេញចាកសង្សារវដ្តបាន។

៣. វិភវតណ្ហា សេចក្ដីប្រាថ្នាមិនចង់ឱ្យខ្លួនក្លាយទៅជានេះ ជានោះ ឬការថ្នាំងថ្នាក់ទៅនឹងសភាវៈទាំងឡាយដែលនៅជុំវិញខ្លួន។

សេចក្ដីស្រេកឃ្លាន សេចក្ដីត្រូវការ សេចក្ដីលោភលន់ដែលស្ដែងចេញមកតាមផ្លូវផ្សេងៗនេះឯង ដែលបង្កឱ្យកើតជាសេចក្ដីទុក្ខគ្រប់បែបយ៉ាង និងការវិលវល់កើតស្លាប់(មិនចេះចប់)របស់សត្វលោកផងទាំងឡាយ តែថាទាំងសេចក្ដីស្រេកឃ្លាន សេចក្ដីត្រូវការនិងសេចក្ដីលោភលន់ជាដើមនេះ មិនមែនជាមូលហេតុដំបូងនៃសេចក្ដីទុក្ខនោះឡើយ ព្រោះថាគ្រប់សភាវៈទាំងអស់ មានសម្ព័ន្ធភាពទៅវិញទៅមកនិងអាស្រ័យនូវគ្នានឹងគ្នាកើតឡើង សូម្បីតែចំណង់ស្រេកឃ្លានគឺតណ្ហានេះ ដែលត្រូវបានចាត់ទុកថាជាមូលហេតុឬជាប្រភពនៃសេចក្ដីទុក្ខ ក៏នៅតែត្រូវអាស្រ័យសភាវៈដទៃគឺវេទនាទើបកើតឡើងមកបាន។ វេទនាកើតឡើងព្រោះអាស្រ័យការប៉ះទង្គិចគ្នា(ផស្សៈ)។ ការប៉ះទង្គិចគ្នា(ផស្សៈ)នឹងអាចកើតឡើងបាន ព្រោះអាស្រ័យនូវអាយតនៈ។ អាយតនៈនឹងកើតឡើងបាន ដោយអាស្រ័យនាមរូប...។ ដំណើរយ៉ាងដូច្នេះឯងចេះតែប្រព្រឹត្តទៅជាប់មិនដាច់(ជាវដ្ដចក្រ) ពោលគឺជាច្បាប់នៃការអាស្រ័យនូវគ្នានឹងគ្នាកើតឡើង(បដិច្ចសមុប្បាទ) ដែលនឹងរៀបរាប់ដូចតទៅនេះ។

តណ្ហាគឺការប្រាថ្នាចង់បាន មិនមែនជាមូលហេតុដំបូងឬថាជាមូលហេតុតែមួយ នៃការកើតឡើងរបស់ទុក្ខ តែជាមូលហេតុដែលប្រាកដ

ច្បាស់ ជាមូលហេតុចម្បង និងជាមូលហេតុសំខាន់លើសមូលហេតុដទៃ។ ដោយហេតុនេះទើបក្នុងគម្ពីរភាសាបាលីជាន់ដើមខ្លះ បានផ្តល់នូវអត្ថន័យរបស់សមុទ័យឬប្រភពកើតឡើងនៃទុក្ខ ដោយរួមយកទាំងកិលេសនិងសាសវៈទាំងឡាយដទៃ(កិលេសសាសវធម្ម)បញ្ចូលជាមួយផង ក្រៅអំពីតណ្ហាគឺចំណង់ក្នុងរឿងផ្សេងៗ ដែលតែងតែត្រូវបានលើកយកមកនិយាយជាលំដាប់ដំបូងៗជានិច្ច។ ការចង្អុលបញ្ជាក់សម្រាប់ករណីចាំបាច់ត្រឹមប៉ុណ្ណេះ ក៏ប្រហែលជាល្មមនឹងអាចឱ្យយល់បាន ប្រសិនបើនៅចាំបានថាតណ្ហានេះមានការយល់ខុសនៅក្នុងតួខ្លួន ដែលកើតចេញពីអវិជ្ជាជាចំណុចកណ្តាល។

ពាក្យថា"តណ្ហា"នៅក្នុងទីនេះ មិនមែនសំដៅត្រឹមតែទៅលើការប្រាថ្នាចង់បាននិងការប្រកាន់មាំនៅក្នុងកាមសុខ ក្នុងទ្រព្យសម្បត្តិ ក្នុងអំណាចនិងកិត្តិយស ឬកេរ្តិ៍ឈ្មោះជាដើមប៉ុណ្ណោះទេ ប៉ុន្តែគឺសំដៅរួមទៅដល់ការប្រាថ្នាចង់បាននិងការប្រកាន់មាំនូវគំនិត ឧត្តមគតិ ទស្សនៈ ទ្រឹស្តី ការយល់ដឹងនិងជំនឿទៀតផង។ បើយោងទៅតាមការរំរែកញែករបស់ព្រះពុទ្ធជាម្ចាស់ ភាពក្តៅក្រហាយនិងភាពវឹកវរទាំងឡាយទាំងពួងនៅក្នុងលោក រាប់តាំងពីការឈ្លោះទាស់ទែងគ្នាបន្តិចបន្តួចរវាងបុគ្គលនិងបុគ្គល រហូតដល់មហាសង្គ្រាមរវាងប្រទេសនិមួយៗ សុទ្ធសឹងកើតចេញពីការប្រាថ្នាចង់បានគឺតណ្ហា ដែលឃើញដល់ប្រយោជន៍ផ្ទាល់ខ្លួននេះឯង។

តាមរយៈទស្សនៈខាងលើនេះ គឺបានចង្អុលបង្ហាញឱ្យឃើញថា បញ្ហាផ្នែកនយោបាយ ក៏ដូចជាបញ្ហាសង្គមទាំងឡាយ សុទ្ធសឹងតែមានឫសគល់ចេញមកអំពីការប្រាថ្នាចង់បាន(មិនចេះស្កប់ស្កល់) ប្រកបដោយភាពអាត្មានិយមនេះទាំងអស់។ បណ្ដារដ្ឋបុរស(មេដឹកនាំ)ទាំងឡាយ ដែលបាននាំគ្នាព្យាយាមដោះស្រាយបញ្ហាទំនាស់រវាងជាតិនិមួយៗ និងធ្វើការចរចាដើម្បីបញ្ចប់សង្គ្រាមហើយកសាងសន្តិភាពនោះ វាគ្រាន់តែជាការកែបញ្ហាសើៗ តាមលំនាំលក្ខណៈបែបនយោបាយនិងសង្គមប៉ុណ្ណោះឯងនៅមិនបានចូលទៅដល់ឫសគល់ដ៏ពិតប្រាកដនៃបញ្ហា សមដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ដល់ព្រះរដ្ឋបាលថា **"លោកទាំងមូលខ្វះខាតជានិច្ចមិនចេះស្កប់ ទាំងជាទាសករនៃតណ្ហា(តណ្ហាទាសោ)"**។

មនុស្សគ្រប់គ្នាប្រហែលជានឹងទទួលស្គាល់ថា រាល់បណ្ដាអំពើអាក្រក់ទាំងឡាយនៅក្នុងលោក សុទ្ធតែកើតចេញមកអំពីការប្រាថ្នាចង់បានដោយអាត្មានិយមនេះទាំងអស់។ ប្រការនេះមិនពិបាកយល់ឡើយ ប៉ុន្តែប្រការដែលថាតើការប្រាថ្នាចង់បានគឺតណ្ហា ជាតួបង្កឱ្យកើតជាតិថ្មីនិងភពថ្មី(បោនោភវិកា)បានយ៉ាងដូចម្ដេចនោះ ទើបជាបញ្ហាដែលលំបាកក្នុងការយល់ ។ ព្រោះហេតុដូច្នេះទើបនៅក្នុងទីនេះ ត្រូវចាំបាច់ទាមទារឱ្យមានការអធិប្បាយវែកញែក ក្នុងផ្នែកទ្រឹស្ដីដ៏ជ្រាលជ្រៅរបស់អរិយសច្ចៈប្រការទី២ ផ្គួបព្រមទៅជាមួយផ្នែកទ្រឹស្ដីរបស់អរិយសច្ចៈ

ប្រការទី១ ហើយចាំបាច់ផងដែរដែលត្រូវអធិប្បាយទៅដល់ទ្រឹស្តីរបស់កម្មនិងការវិលវល់កើតស្លាប់។

## អាហារតាមទ្រឹស្តីព្រះពុទ្ធសាសនា

តាមគោលការណ៍របស់ព្រះពុទ្ធសាសនា អាហារមាន៤ប្រភេទ ក្នុងលក្ខណៈដែលជាមូលហេតុឬជាបច្ច័យ ដែលចាំបាច់សម្រាប់ទ្រទ្រង់ជីវិតនិងការបន្តនូវដំណើរជាប់មិនដាច់(វិលវល់កើតស្លាប់) របស់ពពួកសត្វទាំងឡាយគឺ

១. អាហារគឺវត្ថុទូទៅ(កពលិង្ការាហារ)

២. អាហារគឺការប៉ះទង្គិចគ្នារវាងអាយតនៈខាងក្នុង(រួមទាំងចិត្ត)ជាមួយអាយតនៈខាងក្រៅ(ផស្សាហារ)

៣. ការដឹងច្បាស់ (វិញ្ញាណាហារ)

៤. ចេតនាឬការតម្កល់ចិត្តមាំ (មនោសញ្ចេតនាហារ)

ក្នុងអាហារទាំង៤ប្រភេទនេះ អាហារចុងក្រោយគឺមនោសញ្ចេតនាហារបានដល់ការតាំងចិត្តយ៉ាងមុតមាំ ដែលនឹងមានជីវិតមានភព(ការចង់ក្លាយទៅជានេះឬជានោះ) មានជាតិ(ការកើត) មានការបន្តភ្ជាប់ និងមានក្រៃលែងឡើងថែមទៀត។ ការតម្កល់ចិត្តមាំដូច្នេះឯង ដែលជាអ្នកបង្កើតឫសគល់នៃការតាំងនៅ(បញ្ចក្ខន្ធ) ក្នុងភាពជានេះជានោះនិងការ

បន្តភ្ជាប់។ វាជាកម្លាំងរុញច្រានឱ្យឈានទៅធ្វើកម្មល្អឬកម្មអាក្រក់បាន (កុសលាកុសលកម្ម)។ ការតាំងចិត្តមាំនេះគឺជាតួចេតនា ដូចដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់ថា "ពេលបុគ្គលយល់នូវអាហារគឺចេតនា ហើយក៏រមែងឈ្មោះថាយល់នូវតណ្ហាទាំង៣យ៉ាងផងដែរ"។ ដូចនេះពាក្យថាតណ្ហា ចេតនា មនោសញ្ចេតនានិងកម្ម សុទ្ធសឹងមានអត្ថន័យដូចគ្នាពោលគឺសំដៅដល់ការប្រាថ្នាចង់បាន ការតាំងចិត្តមាំដែលចង់ឱ្យខ្លួនក្លាយទៅជាយ៉ាងនេះឬជាយ៉ាងនោះ ដែលនឹងឱ្យកើតថ្មីឬដែលនឹងឱ្យមានច្រើនឡើង ដែលនឹងចម្រើនធំធាត់ខ្លាំងឡើង ដែលនឹងសន្សំច្រើនឡើង។ ចំណង់ទាំងនេះឯង គឺជាមូលហេតុរបស់ការកើតឡើងនៃសេចក្តីទុក្ខ ស្ថិតនៅក្នុងសង្ខារក្ខន្ធ ដែលជាខន្ធមួយក្នុងចំណោមខន្ធទាំង៥(បញ្ចក្ខន្ធ) ប្រកបឡើងជាសត្វជាបុគ្គល។ ខនេះជាចំណុចមួយដែលមានសារៈសំខាន់ហើយជាខ្លឹមសារដ៏ពិតប្រាកដនៃឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់។

ព្រោះហេតុដូច្នេះ យើងចាំបាច់ត្រូវកត់សំគាល់និងចងចាំឱ្យបានច្បាស់ថាមូលហេតុនៃការកើតឡើងរបស់ទុក្ខគឺស្ថិតនៅក្នុងតួទុក្ខនោះឯង នឹងថាកើតមកអំពីខាងក្រៅនោះគឺមិនមែនឡើយ។ នៅក្នុងលំនាំដូចគ្នានេះទៀតសោត ក៏ចាំបាច់ត្រូវតែចងចាំឱ្យបានច្បាស់ផងដែរថា មូលហេតុឬប្រភពរបស់ការរំលត់ទៅនៃសេចក្តីទុក្ខឬការកម្ចាត់ទុក្ខនោះ ក៏ស្ថិតនៅក្នុងតួទុក្ខនោះឯងដូចគ្នា នឹងថាមកពីខាងក្រៅណាមួយនោះក៏ទេដែរ។

ទាំងនេះគឺអត្ថន័យបានមកពីព្រះសូត្រមួយ ដែលតែងតែជួបប្រទះជាញឹកញាប់ក្នុងគម្ពីរព្រះបាលីដើមថា "យំ កិញ្ចិ សមុទយ ធម្មំ សព្វន្តំ និរោធធម្មំ" ដែលមានសេចក្តីជាភាសាខ្មែរថា **"សភាវៈទាំងឡាយណាដែលមានការកើតឡើងហើយ(ជាធម្មតា) សភាវៈទាំងឡាយនោះរមែងមានការរលត់ទៅវិញ(ជាធម្មតា)"**។ បុគ្គល សត្វ វត្ថុ ឬសភាវៈណាមួយប្រសិនបើនៅក្នុងខ្លួនរបស់វា មានសារជាតិនៃការកើតឡើងជាធម្មតា មានការតាំងឡើងជាធម្មតា។ បុគ្គល សត្វ វត្ថុឬសភាវៈនោះៗនៅក្នុងខ្លួនរបស់វាផ្ទាល់ ក៏មានសារជាតិនៃការបែកធ្លាយទៅវិញជាធម្មតា(ចំណុចនេះនឹងលើកមកអធិប្បាយម្តងទៀត នៅពេលនិយាយដល់អរិយសច្ចៈខទី៣គឺនិរោធ)។

## កម្មជាអ្វី?

ម្តងនេះយើងចូលមកដល់ការបកស្រាយ អំពីពាក្យថា "កម្ម"។ ពាក្យថា"កម្ម"ក្នុងភាសាបាលីប្រែដោយព្យញ្ជនៈ(ប្រែតាមរូបស័ព្ទ)ថា "ការធ្វើ" ឬ "ទង្វើ" ។ ដោយឡែកក្នុងទ្រឹស្តីកម្មរបស់ព្រះពុទ្ធសាសនា គឺមានន័យសំដៅតែទៅលើការធ្វើដែលប្រកបដោយចេតនាប៉ុណ្ណោះ មិនបានសំដៅទៅដល់ការធ្វើគ្រប់យ៉ាង ទាំងមិនបានសំដៅទៅដល់ផលរបស់កម្ម ដូចដែលមនុស្សជាច្រើននាំគ្នាប្រើយ៉ាងខុសឆ្គងនោះឡើយ ត្បិតថា

ផលរបស់កម្មហៅថា"ផល" ឬវិបាករបស់កម្ម(កម្មផលឬកម្មវិបាក) ។

ចេតនាអាចនឹងល្អឬអាក្រក់ក៏ថាបាន ដូចគ្នាទៅនឹងតណ្ហាដែលមានទាំងល្អនិងអាក្រក់ ដូចនេះទើបកម្មអាចមានទាំងល្អនិងអាក្រក់។ កម្មល្អ(កុសលកម្ម)រមែងឱ្យផលល្អ រីឯកម្មអាក្រក់(អកុសលកម្ម)រមែងឱ្យនូវផលអាក្រក់។ តណ្ហា ចេតនា កម្ម មិនថាល្អឬអាក្រក់រមែងមានកម្លាំងមួយ៉ាងជាផល គឺកម្លាំងដែលធ្វើឱ្យកើតមានការអន្ទោលទៅមកដែលសំដៅដល់ការអន្ទោលទៅមក ទាំងនៅក្នុងផ្នែកល្អនិងផ្នែកអាក្រក់(សុគតិនិងទុគតិ)។ និយាយមួយ៉ាងទៀតថា មិនថាកម្មដែលបុគ្គលបានធ្វើហើយ ជាកម្មល្អឬអាក្រក់ក៏ដោយចុះ សុទ្ធតែស្ថិតនៅក្នុងវដ្តចក្រនៃការអន្ទោលវិលវល់កើតស្លាប់(សង្សារវដ្ត)ទាំងអស់។ ដោយឡែកព្រះអរហន្ត ទោះបីថាលោកបានធ្វើនូវកម្ម(អំពើ)ក៏ពិតមែន តែលោកក៏មិនបានសន្សំនូវកម្ម ព្រោះលោករួចផុតពីការប្រកាន់មាំនៅក្នុងតួខ្លួន(បញ្ចក្ខន្ធ) ផុតចាកពីតណ្ហាដែលនឹងធ្វើឱ្យកើតនូវការអន្ទោលវិលវល់ ផុតចាកកិលេសអាសវៈទាំងឡាយទាំងពួង(កិលេសសាសវធម្ម)។ ព្រោះហេតុដូច្នេះ ទើបមិនមានការកើតថ្មីសម្រាប់លោក។

ទ្រឹស្តីកម្មនេះ ចាំបាច់មិនត្រូវឱ្យមានការយល់ច្រឡំជំពាក់វាក់វិនទៅនឹងអ្វីដែលយើងនាំគ្នាហៅថា"យុត្តិធម៌ផ្នែកសីលធម៌" ឬ "ការផ្តល់នូវគុណនិងទោស"។ ផ្នត់គំនិតដែលទាក់ទងជាមួយយុត្តិធម៌ផ្នែកសីលធម៌

ឬការឱ្យនូវគុណនិងទោសនេះ កើតចេញពីជំនឿដែលថាមានបុគ្គលវិសេសគឺព្រះជាម្ចាស់ ចាំធ្វើតួនាទីជំនុំជម្រះ ជាអ្នកបញ្ញត្តក្រឹត្យក្រមទាំងជាអ្នកសម្រេចថាអ្វីត្រូវអ្វីខុស។ ទ្រឹស្តីកម្មជាទ្រឹស្តីដែលនិយាយអំពីហេតុនិងផល ជាទ្រឹស្តីស្តីអំពីកិរិយានិងបដិកិរិយា ជាច្បាប់ធម្មជាតិ ហើយដែលមិនមានការពាក់ព័ន្ធជាមួយនឹងផ្នត់គំនិតស្តីអំពី"យុត្តិធម៌" ឬ "ការផ្តល់នូវគុណនិងទោស" ដោយប្រការណាមួយនោះឡើយ។ ការធ្វើដែលប្រកបដោយចេតនាគ្រប់ប្រភេទ នឹងឱ្យផលឬវិបាករបស់វាត្រលប់មកវិញ បើជាកម្មល្អនឹងឱ្យមកនូវផលល្អ តែបើជាកម្មអាក្រក់ក៏នឹងឱ្យមកវិញនូវផលអាក្រក់ វាមិនមែនជា"យុត្តិធម៌" ឬ "ការផ្តល់នូវគុណនិងទោស" ពីសំណាក់អាទិទេពអង្គណាមួយ ឬពីអំណាចវិសេសណាមួយដែលរង់ចាំជំនុំជម្រះ នូវរាល់ទង្វើរបស់អ្នកនោះឡើយ ប៉ុន្តែវាប្រព្រឹត្តទៅតាមច្បាប់របស់ធម្មជាតិ និងជាច្បាប់នៅក្នុងខ្លួនរបស់វាផ្ទាល់។ រឿងនេះគឺមិនពិបាកយល់ឡើយ តែរឿងដែលពិបាកយល់នោះគឺថា ផ្អែកតាមទ្រឹស្តីកម្មនេះ តើផលរបស់កម្មដែលធ្វើដោយការតាំងចិត្ត(មានចេតនា) អាចតភ្ជាប់ទៅដល់ជីវិតបន្ទាប់អំពីសេចក្តីស្លាប់បានយ៉ាងដូចម្តេច? នៅក្នុងទីនេះនឹងអធិប្បាយអំពីសេចក្តីស្លាប់ តាមគោលការណ៍របស់ព្រះពុទ្ធសាសនា គ្រាន់ជាមូលដ្ឋានចំណេះដឹង សម្រាប់ត្រិះរិះពិចារណាដូចតទៅ

ដូចយើងជ្រាបស្រាប់ហើយ(ដូចបានអធិប្បាយរួចមកហើយ)ថា

អ្វីដែលយើងនាំគ្នាហៅថាជាសត្វ ជាបុគ្គលនោះ គឺមិនមានអ្វីផ្សេងឡើយ ក្រៅតែពីការរួមបញ្ចូលគ្នារបស់កម្លាំងឬថាមពល ទាំងខាងផ្នែករាងកាយនិងចិត្តគំនិត ហើយអ្វីដែលយើងនាំគ្នាហៅថាសេចក្តីស្លាប់នោះ គឺសំដៅទៅដល់ការឈប់ធ្វើការរបស់រាងកាយ។ ដូច្នេះសួរថាតើកម្លាំងឬថាមពលទាំងឡាយ នឹងឈប់ទៅព្រមគ្នាជាមួយនឹងការឈប់ធ្វើការរបស់រាងកាយមែនឬ? ទ្រឹស្តីព្រះពុទ្ធសាសនាឆ្លើយថា "មិនមែនយ៉ាងដូច្នោះឡើយ"។ ការតាំងចិត្ត ការប៉ុនប៉ង សេចក្តីត្រេកត្រអាល សេចក្តីស្រេកឃ្លានក្នុងការប្រាថ្នាឱ្យខ្លួន ក្លាយទៅជាយ៉ាងនេះឬយ៉ាងនោះ ការជាប់ជំពាក់ទៅលើអ្វីមួយ ការចង់ឱ្យមានដំណើរបន្ត សេចក្តីប្រាថ្នាដ៏ក្រៃលែងទាំងនេះ ជាកម្លាំងដ៏មហាសាលដែលរុញច្រានគ្រប់ជីវិត គ្រប់សភាវៈ ឬសូម្បីតែលោកទាំងមូលឱ្យធ្លាក់ទៅក្នុងអំណាចនៃច្បាប់វដ្តចក្រ វាជាកម្លាំងដ៏មហិមាបំផុត ជាកម្លាំងដ៏មហាសាលបំផុតក្នុងលោក។ តាមគោលការណ៍របស់ព្រះពុទ្ធសាសនា(តាមច្បាប់ធម្មជាតិ) កម្លាំងដែលថានេះមិនបានឈប់ព្រមទៅជាមួយនឹង ការឈប់ធ្វើការរបស់រាងកាយ(គឺសេចក្តីស្លាប់)នោះឡើយ តែវាបានបន្តទៅប្រាកដខ្លួននៅក្នុងរូបមួយដទៃផ្សេងទៀត ដោយបង្កឱ្យមាននូវជាតិកំណើតថ្មី ឬដែលយើងនាំគ្នាហៅថាការកើតថ្មី(ការកើតម្តងទៀត)។

មកដល់ត្រង់ចំណុចនេះ មានសំណួរមួយសួរថាប្រសិនបើបុគ្គល

មិនមានភាពទៀតទាត់ ឋិតថេរឬមានខ្លឹមសារ ដូចជាតួខ្លួនឬវិញ្ញាណ (អាត្ម័ន) ហើយអ្វីទៅដែលអាចទៅចាប់កំណើតថ្មី បន្ទាប់អំពីការស្លាប់ទៅហើយនោះ? មុននឹងបកស្រាយអំពីជីវិតក្រោយការស្លាប់នោះ សូមឱ្យមកពិចារណាជាមួយគ្នាសិនថា ជីវិតនេះគឺជាអ្វី? ហើយជីវិតនេះបន្តភ្ជាប់មកដល់បច្ចុប្បន្នបានយ៉ាងដូចម្តេច? អ្វីដែលយើងហៅថាជាជីវិតនោះ ដូចដែលបានបញ្ជាក់មកជាហូរហែថា ក៏គឺជាការរួមបញ្ចូលគ្នារបស់ខន្ធ៥ ដែលសំដៅទៅដល់ការរួបរួមគ្នារបស់កម្លាំង ទាំងខាងផ្នែករាងកាយនិងចិត្តគំនិត។ ខន្ធ៥នេះរមែងមានការប្រែប្រួលផ្លាស់ប្តូរជានិច្ច មិនស្ថិតនៅដូចដើមសូម្បីមួយខណៈ មានការកើតនិងស្លាប់ទៅគ្រប់ខណៈ "ម្នាលភិក្ខុ! ពេលខន្ធទាំងឡាយ កើតចាស់និងស្លាប់ទៅគ្រប់ខណៈ អ្នកក៏កើតចាស់និងស្លាប់(ទៅគ្រប់ខណៈផងដែរ)"។ ដោយហេតុនេះ សូម្បីតែនៅក្នុងអំឡុងពេលកំពុងមានជីវិតរស់នៅក្នុងខណៈនេះ យើងក៏កើតនិងស្លាប់គ្រប់ខណៈ[៧] តែយើងក៏នៅអាចបន្តជីវិតទៅបាន។ បើយើងអាចយល់បានថា ជីវិតនេះយើងអាចបន្តទៅបានដោយប្រាសរូបធាតុដែល

---

[៧] ជាការពិតដែលថា ជីវិតរបស់សត្វលោកមានការកើតនិងស្លាប់ទៅនៅគ្រប់ខណៈ ទាំងដែលជារូបធម៌និងនាមធម៌ ត្បិតថារាល់កោសិកាទាំងឡាយ នៅក្នុងខ្លួនរបស់មនុស្សសត្វរមែងកើតឡើងថ្មី និងជម្រុះចោលនូវកោសិកាចាស់ឥតឈប់ឈរ ដូចគ្នាទៅនឹងអារម្មណ៍ឬការនឹកគិតផ្សេងៗ ដែលតែងតែកើតរលត់ៗ(ខណៈចិត្តមួយកើតឡើងហើយក៏រលត់ទៅវិញ ទាំងជាបច្ច័យឱ្យកើតនូវខណៈចិត្តបន្តៗមកទៀត) បន្តគ្នាជាខ្សែវដ្តៈមួយដែលគ្មានទីបញ្ចប់។

ឋិតថេរដូចជាអត្តាឬវិញ្ញាណ រឿងអ្វីដែលយើងនឹងមិន អាចយល់បានថា កម្លាំងឬថាមពលទាំងនោះអាចស្ថិតនៅតទៅទៀតបាន ដោយប្រាសចាក អត្តាឬវិញ្ញាណគាំទ្រ បន្ទាប់ពីរាងកាយបានឈប់ធ្វើការទៅហើយនោះ? ខណៈពេលដែលរាងកាយនេះមិនអាចធ្វើការបានតទៅទៀតនោះ ថាមពលទាំងឡាយមិនបានស្លាប់ព្រមទៅជាមួយនឹងវានោះទេ។ ប៉ុន្តែផ្ទុយទៅវិញ ថាមពលទាំងនោះនៅបានបន្តទៅគ្រប់គ្រងរូបដទៃទៀត ដែលយើងហៅថាជាជីវិតមួយផ្សេងទៀត។ ក្នុងខ្លួនរបស់ទារកឥន្ទ្រិយផ្សេងៗទាំងឡាយ ទាំងរាងកាយ ខួរក្បាល និងសតិបញ្ញា នៅទន់ខ្សោយមិនរឹងមាំពេញលេញ តែឥន្ទ្រិយទាំងនោះក៏មាននូវសក្តានុពលភាពខាងក្នុងរបស់វា ដែលនឹងធ្វើឱ្យកើតការចម្រើនធំធាត់ ក្លាយជាមនុស្សពេញវ័យដោយបរិបូរបាន។ ថាមពលទាំងរាងកាយនិងចិត្តគំនិតដែលប្រកបគ្នាជាបុគ្គលក៏ដូចគ្នា មានកម្លាំងផ្ទាល់របស់វាដែលនឹងអាចឱ្យវាទៅចាប់យកនូវរូបថ្មី ហើយសន្សឹមៗលូតលាស់និងរួបរួមកម្លាំងឡើងមកសាជាថ្មីរហូតចាស់ក្លាបាន។

# ច្បាប់វដ្តចក្រ

អាស្រ័យដោយមិនមានសភាវៈឋិតថេរទៀតទាត់យ៉ាងដូច្នេះ ទើបមិនមានអ្វីដែលបញ្ជូនតគ្នា ពីខណៈមួយទៅកាន់ខណៈមួយទៀត ។ ប្រាកដណាស់ថាមិនមានសភាវៈ ដែលឋិតថេរឬគង់វង្សឥតប្រែប្រួល ដែលអាចឆ្លងឬផ្ទេរពីជីវិតមួយ ទៅកាន់ជីវិតមួយផ្សេងទៀតបានឡើយ ។ វាគ្រាន់តែជាការតភ្ជាប់ ដែលប្រព្រឹត្តទៅយ៉ាងជាប់លាប់មិនដាច់រយៈ ហើយមានការប្រែប្រួលគ្រប់ខណៈ ។ តាមពិតទៅទំនាក់ទំនងទាំងនេះ គ្រាន់តែជាការធ្វើចលនាប៉ុណ្ណោះ ឧបមាដូចអណ្តាតភ្លើងដែលឆេះពេញមួយយប់ នឹងថាជាអណ្តាតភ្លើងតែមួយក៏មិនមែន ហើយនឹងថាជាអណ្តាតភ្លើងថ្មី ក៏រឹតតែមិនមែនទៅទៀត ។ ទារកដែលធំធាត់ក្លាយជាមនុស្សចាស់អាយុ៦០ឆ្នាំ នឹងថាបុរសអាយុ៦០ឆ្នាំម្នាក់នេះ ជាមនុស្សតែម្នាក់ជាមួយនឹងទារកនោះក៏មិនមែន ហើយនឹងថាជាមនុស្សដទៃ ក៏រឹងរឹតតែមិនមែនទៅទៀត( ន ច សោ ន ច អញ្ញោ) ។ វាជាការបន្តភ្ជាប់របស់ខ្សែសម្ព័ន្ធភាពមួយ ។ ភាពខុសប្លែកគ្នារវាងការកើតនិងការស្លាប់ប្រព្រឹត្តទៅត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ ពោលគឺខណៈចិត្តចុងក្រោយបំផុតនៅក្នុងជីវិតនេះ ជាអ្នកតភ្ជាប់ឱ្យដល់ខណៈចិត្តដំបូង ក្នុងអ្វីដែលយើងហៅថាជីវិតជាតិក្រោយ ដែលតាមពិតទៅគឺជាការបន្តភ្ជាប់នៃខ្សែ

សម្ព័ន្ធភាពតែមួយប៉ុណ្ណោះឯង។ ក្នុងអំឡុងពេលដែលយើងមានជីវិតនៅក្នុងលោកនេះក៏ដូចគ្នា ខណៈចិត្តមួយតភ្ជាប់ឱ្យដល់ខណៈចិត្តបន្ទាប់ៗឯទៀត។ ដូច្នេះតាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនា បញ្ហាទាក់ទងជាមួយជីវិតក្រោយពីការស្លាប់នេះ មិនមែនជារឿងអាថ៌កំបាំងឬជារឿងធំដុំអ្វីនោះឡើយ ហើយពុទ្ធសាសនិកជនទៀតសោតក៏មិនបានព្រួយបារម្ភខ្វល់ចិត្តជាមួយនឹងបញ្ហាទាំងនេះដែរ(មិនខ្វល់ថាស្លាប់ហើយកើតទៀតឬអត់នោះទេ)។ ដរាបណានៅមានតណ្ហា ដែលធ្វើឱ្យមានដំណើរនៃការអន្ទោលវិលវល់(សង្សារ) ការកើត ចាស់ ឈឺ ស្លាប់ ក៏នឹងនៅតែមានការប្រព្រឹត្តទៅដរាបនោះ។ ដំណើរនៃការអន្ទោលវិលវល់នេះ នឹងអាចបញ្ឈប់ទៅបាន លុះណាតែថាមពលរុញច្រានរបស់វាគឺតណ្ហា ត្រូវបានកាត់ផ្តាច់ទាំងស្រុងដោយបញ្ញា ដែលមើលឃើញនូវសច្ចធម៌ គឺនិរវាណៈ(ព្រះនិព្វាន)។

ឲឲឲ✳ឲឲឲ

# ជំពូក ៤

# អរិយសច្ចះ ប្រការទី៣

# និរោធ : ការរំលត់ទុក្ខ

អរិយសច្ចៈប្រការទី៣ គឺការរួចរំដោះ ការដាក់ចុះ(ទុក្ខ) ការមានឥស្សរភាពពីសេចក្ដីទុក្ខ ចាកវដ្ដនៃទុក្ខ ហៅថាអរិយសច្ចៈនៃការរំលត់ទុក្ខ(ទុក្ខនិរោធអរិយសច្ចៈ) បានដល់ព្រះនិព្វាន ដែលត្រូវបានគេស្គាល់យ៉ាងទូលំទូលាយ នៅក្នុងស័ព្ទរបស់ភាសាសំស្ក្រឹតថា"និរវាណៈ" (Nirvana)។ ការដែលនឹងកម្ចាត់ទុក្ខឱ្យបានជ្រះស្រឡះនោះ បុគ្គលចាំបាច់ត្រូវកម្ចាត់ឫសគល់នៃសេចក្ដីទុក្ខ(តណ្ហា) ដូចដែលបានពោលរួចមកហើយនៅខាងដើមអោយបានជាមុនសិន ហេតុដូច្នេះហើយទើបនិរវាណៈអាចហៅបានម្យ៉ាងទៀតថា"តណ្ហក្ខយ" ដែលមានន័យថាការអស់ទៅនៃតណ្ហា។

## ភាសាមនុស្សភាសាធម៌

ម្ដងនេះអ្នកអាចនឹងសួរថា ចុះអ្វីទៅគឺនិរវាណៈនោះ? មានសៀវភៅជាច្រើនដែលគេបាននាំគ្នាសរសេរ ដើម្បីឆ្លើយតបទៅនឹងបញ្ហាមួយនេះ តែចម្លើយនៅក្នុងសៀវភៅទាំងនោះ រឹតតែមានច្រើនប៉ុណ្ណាក៏រឹងរឹតតែធ្វើឱ្យមានចម្ងល់ខ្លាំងឡើងប៉ុណ្ណោះ ជាជាងការផ្ដល់នូវ

ប្រត្យក្សភាពទាក់ទងទៅនឹងរឿងនេះ។ ការប្រើពាក្យពេចន៍ផ្សេងៗមក អធិប្បាយ ដោយផ្អែកទៅតាមគោលការណ៍នៃហេតុនិងផលតែម្យ៉ាង នោះ ពិតណាស់គឺមិនអាចឆ្លើយតបនូវបញ្ហានេះ បានយ៉ាងត្រឹមត្រូវពេញ លេញ និងគួរឱ្យពេញចិត្តបាននោះឡើយ ព្រោះថាភាសាមនុស្សមានភាព អត្តខាត់ មិនល្មមដែលនឹងអាចនាំយកមកសម្តែង អំពីភាពពិតប្រាកដនៃ បរមសច្ចៈឬបរមត្ថសច្ចៈ គឺនិរវាណៈនេះបានឡើយ។ ភាសាត្រូវបាន មនុស្សបង្កើតឡើងមកប្រើ ដើម្បីអធិប្បាយអំពីសភាវៈឬផ្ទត់គំនិត ផ្សេងៗ ដែលអាចពាល់ត្រូវនិងទទួលដឹងបាន ដោយអាយតនៈទាំង៦ (ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត)។ ដោយឡែកភាពពិត នៅក្នុងផ្លូវលោកុត្តរដូចយ៉ាងនិរវាណៈនេះ គឺមានលក្ខណៈផ្សេងគ្នា ដូច្នេះ ទើបយើងមិនអាចរកពាក្យពេចន៍ណាមួយ មកអធិប្បាយបទពិសោធ ប្រភេទនេះបានឡើយ ដូចគ្នាទៅនឹងអណ្តើកដែលមិនអាចរកពាក្យពេចន៍ ណាមួយនៅក្នុងភាសារបស់ត្រី មកអធិប្បាយសភាពរបស់ផែនដី ដែល ជារូបធាតុរឹងឱ្យល្មមនឹងត្រីអាចយល់បាន។ ដំណើររបស់រឿងនេះគឺថា អណ្តើកបានប្រាប់ទៅកាន់ត្រី ដែលជាមិត្តសម្លាញ់របស់ខ្លួនថា ខ្លួនទើប នឹងធ្វើដំណើរត្រលប់ពីដីគោកមកកាន់សមុទ្រវិញ។ "អញ្ចឹង ហ៎!" ត្រី និយាយ "សម្លាញ់ប្រហែលជាចង់និយាយថា សម្លាញ់ទើបត្រលប់ពីហែល នៅលើដីគោកមកមែនទេ?" ចំណែកអណ្តើកក៏ព្យាយាមអធិប្បាយថា

នៅលើផែនដីនោះ គេមិនប្រើវិធីហែលនោះទេ ព្រោះផែនដីជារូបធាតុរឹង ទើបគេប្រើវិធីដើរនៅលើផែនដីជំនួសឱ្យការហែល តែត្រីក៏នៅតែប្រកែក អះអាងថា សភាពដែលជាសភាវៈរឹង(ផែនដី) ដូចដែលអណ្ដើកថានោះ ប្រហែលជាមិនមាននោះទេ វាច្បាស់ជារូបធាតុរាវ ដូចទឹកក្នុងសមុទ្រនេះ ដែលអាចមុជងើបនិងហែលទៅមកបាន។ ពាក្យពេចន៍ផ្សេងៗវាគ្រាន់តែ ជាសញ្ញាណ សម្រាប់ប្រើជំនួសឱ្យសភាវៈឬផ្នត់គំនិតផ្សេងៗ ដែលយើង ធ្លាប់ដឹងមកហើយ(ប៉ុណ្ណោះ) ហើយសញ្ញាណទាំងនោះទៀតសោត គឺមិនអាចជាអ្នកបញ្ជូនប្រាប់ នូវលក្ខណៈដ៏ពិតប្រាកដ នៃបរមសច្ចៈបាន ឡើយ។ ភាសាជាសភាវៈមួយ៉ាង ដែលពេលខ្លះអាចនឹងធ្វើឱ្យយល់ភ្លាំង ភ្លាត់ទៅបាននៅក្នុងរឿងសច្ចៈ ហេតុនេះទើបមានពាក្យពោលនៅក្នុង ការតារសូត្រថា "បុគ្គលឆោតល្ងង់រមែងជាប់ជំពាក់នៅក្នុងពាក្យពេចន៍ ឧបមាដូចដំរីដែលជាប់ផុង នៅក្នុងភក់យ៉ាងដូច្នោះដែរ"។

ទោះជាយ៉ាងណាក្ដី យើងក៏នៅតែមិនមានផ្លូវផ្សេង ដែលអាច ជៀសផុតពីការចាំបាច់ត្រូវប្រើភាសាមកអធិប្បាយដដែល។ តែប្រសិន បើនិរវាណៈនេះ យើងប្រើស័ព្ទវិជ្ជមានផ្សេងៗមកជួយអធិប្បាយ ដែល ទោះបីថាស័ព្ទវិជ្ជមានផ្សេងៗទាំងនោះ នឹងជួយឱ្យយើងយល់នូវ និរវាណៈបានយ៉ាងងាយស្រួលនិងឆាប់រហ័សក៏ពិតមែន តែអ្វីដែលយើង យល់នោះ អាចនឹងផ្ទុយពីការពិតក៏ថាបាន។ ដូចនេះទើបជាទូទៅ

និរវាណៈត្រូវបានអធិប្បាយ ដោយការប្រើនូវស័ព្ទអវិជ្ជមាន(បដិសេធ) ដូចជា តណ្ហក្ខយ(ការអស់ទៅនៃតណ្ហា) អសង្ខត(មិនមានបច្ច័យតាក់តែង មិនប្រព្រឹត្តទៅតាមល័ក្ខខ័ណ្ឌ) និព្វាន(ការរំលត់)។

## និយមន័យរបស់និព្វាន

ម្តងនេះយើងសាកល្បងមកពិចារណាពីនិយមន័យ និងពាក្យអត្ថាធិប្បាយអំពីនិរវាណៈ តាមដែលមានប្រាកដនៅក្នុងគម្ពីរភាសាបាលីជាន់ដើមផ្សេងៗវិញម្តង។

"និរវាណៈគឺការរលត់ទៅនៃចំណង់(តណ្ហា) ការលះបង់នូវចំណង់ ការរលាស់ចោលនូវចំណង់ ការអស់ទៅនៃចំណង់ ការដាក់ចុះនូវចំណង់"

"គឺការស្ងប់រម្ងាប់ទៅនៃសង្ខតធម៌ទាំងពួង ការលះចោលនូវកិលេសទាំងពួង ការដកគាស់ចោលនូវឫសគល់នៃចំណង់ ការផ្តាច់បង់ចោលនូវចំណង់គឺនិព្វាន"

"ម្នាលភិក្ខុទាំងឡាយ! អសង្ខតធម៌(និរវាណៈ)ជាអ្វី? ម្នាលភិក្ខុទាំងឡាយ! គឺការរលត់ទៅនៃសេចក្តីត្រេកត្រអាល(រាគក្ខយោ) ការអស់ទៅនៃទោសៈ(ទោសក្ខយោ) ការអស់ទៅនៃសេចក្តីវង្វេង(មោហក្ខយោ)។ ម្នាលភិក្ខុទាំងឡាយ! នេះឯងហើយហៅថា

អសង្ខតធម៌ (និព្វាន)"

"ម្នាលរាធៈ! ការអស់ទៅនៃចំណង់ (តណ្ហក្ខយោ) គឺនិព្វាន"

"ម្នាលភិក្ខុទាំងឡាយ! ក្នុងចំណោមធម៌ដែលមានបច្ច័យតាក់តែង (សភាវៈដែលកើតឡើងព្រោះអាស្រ័យហេតុ) ឬមិនមានបច្ច័យតាក់តែងទាំងឡាយ ការប្រាសចាកនូវភាពត្រេកត្រអាល(វិរាគៈ) ចាត់ថាជាកំពូលនៃធម៌ទាំងពួង។ វិរាគៈក៏គឺការមានឥស្សរភាពពីមានះ ការបំបាត់បង់នូវចំណង់ ការដកចេញនូវការប្រកាន់មាំ ការកាត់ផ្តាច់នូវវដ្តៈ ការអស់ទៅនៃតណ្ហា ការរំលត់(កិលេស) គឺនិព្វាន"។

ពេលបរិព្វាជកម្នាក់សួរព្រះសារីបុត្រ អគ្គសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ថា"និព្វានគឺអ្វី?" ចម្លើយរបស់ព្រះសារីបុត្រ ក៏មានលក្ខណៈដូចទៅនឹងនិយាមនៃអសង្ខតធម៌ ដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ទុកនោះថា "ការរលត់ទៅនៃសេចក្តីត្រេកត្រអាល ការរលត់ទៅនៃការខឹងក្រោធ ការរលត់ទៅនៃសេចក្តីវង្វេង"។

"ការលះបង់ចោល ឬការកម្ចាត់បង់នូវតណ្ហានិងការពេញចិត្តនៅក្នុងឧបាទានក្ខន្ធ៥ គឺការរំលត់ទុក្ខ"

"ការរលត់ទៅនៃវដ្តៈ និងធម៌ដែលនាំឱ្យក្លាយទៅជាយ៉ាងនេះ ឬយ៉ាងនោះបានគឺនិព្វាន"

ក្រៅពីនោះព្រះពុទ្ធជាម្ចាស់ ទ្រង់នៅបានត្រាស់ទៅដល់និរវាណៈ ថា "ម្នាលភិក្ខុទាំងឡាយ! សភាវៈដែលមិនកើត មិនចាស់ និងដែលបច្ច័យតាក់តែងមិនបាន(មិនមានបច្ច័យតាក់តែង)នោះមានពិត។ ប្រសិនបើសភាវៈដែលមិនកើត មិនចាស់ និងដែលមិនមានបច្ច័យតាក់តែងមិនមានទេនោះ ក៏នឹងមិនមានការរលាស់ខ្លួនចេញចាកសភាវៈ ដែលកើត ចាស់ ឈឺ ស្លាប់ និងដែលមានបច្ច័យតាក់តែងនោះឡើយ តែព្រោះមានសភាវៈដែលមិនកើត មិនចាស់ និងដែលមិនមានបច្ច័យតាក់តែងនោះឯង ទើបមានការរលាស់ខ្លួនចេញចាកសភាវៈដែលកើត ចាស់ ឈឺ ស្លាប់ហើយដែលមានបច្ច័យតាក់តែង"។

"ទីដែលមិនមានធាតុ៤គឺ ទឹក ដី ភ្លើង និងខ្យល់ មិនមានបណ្តោយ មិនមានទទឹង មិនមានភាពហ្មត់ចត់ មិនមានភាពគ្រោកគ្រាត អំពើល្អនិងអាក្រក់ នាមនិងរូប បានត្រូវកម្ចាត់បង់ទៅទាំងអស់ មិនមានលោកនេះ មិនមានលោកខាងមុខ មិនមានការមក មិនមានការទៅ មិនមានការស្លាប់ មិនមានការកើត មិនមានអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ គឺព្រះនិព្វាន"។

ដោយហេតុដែលនិរវាណៈ មានការអធិប្បាយដោយស័ព្ទបដិសេធ(អវិជ្ជមាន)ដូច្នេះ ទើបធ្វើឱ្យមនុស្សជាច្រើន មានការយល់ខុសថា និរវាណៈជាសភាពអវិជ្ជមាន ហើយជាសភាវៈដែលសម្តែងទៅដល់

ការបំផ្លាញអត្តា(ខ្លួន)។ តាមពិតទៅ និរវាណៈគឺមិនបានបំផ្លាញអត្តាសោះឡើយ ព្រោះថាមិនមានអត្តាដែលនឹងឱ្យបំផ្លាញ ប៉ុន្តែប្រសិនបើចាត់ទុកថាជាការបំផ្លាញមែននោះ ក៏ប្រហែលជាការបំផ្លាញនូវមោហៈ(សេចក្តីល្ងង់) ដែលជាការបំផ្លាញនូវការយល់ខុស ទាក់ទងជាមួយនឹងអត្តាទៅវិញទេ។

វាពិតជាមិនត្រឹមត្រូវសោះឡើយ ដែលនឹងនិយាយថា និរវាណៈជាសភាវៈមិនមាន(សូន្យ) ឬថាជាសភាវៈដែលមានពិត។ គំនិតថា "មិនមាន"(អវិជ្ជមាន) និង"មាន"(វិជ្ជមាន) នេះគឺវាគ្រាន់តែជាការប្រើនៅក្នុងលក្ខណៈប្រៀបធៀប ដែលស្ថិតនៅក្នុងក្របខ័ណ្ឌទ្វេភាព(ជាគូៗ) ប៉ុណ្ណោះ។ ស័ព្ទផ្សេងៗទាំងនេះ មិនអាចនាំមកប្រើជាមួយ"និរវាណៈ" ដែលជាបរមត្ថសច្ចៈ ហើយដែលស្ថិតនៅលើទ្វេភាព គឺការប្រៀបធៀបនោះបានឡើយ។ ពាក្យពេចន៍បដិសេធ(អវិជ្ជមាន) ក៏មិនមែនសុទ្ធតែមានន័យទៅដល់ សភាវៈដែលនិយាយអំពី"ភាពមិនមាន"ជានិច្ចនោះដែរ។ ដូចយ៉ាងពាក្យថា"មានសុខភាពល្អ" ក្នុងភាសាបាលីឬសំស្ក្រឹតថា "អារោគយា"ដែលជាពាក្យបដិសេធ មានអត្ថន័យដោយរូបស័ព្ទថា "ការមិនមានរោគ" ដូច្នេះពាក្យថា"អារោគយា"នេះ មិនមែនជាសភាវៈអវិជ្ជមានឡើយ ដូចគ្នាទៅនឹងពាក្យថា"ការមិនស្លាប់" (ស្របទៅនឹងពាក្យសំស្ក្រឹតថា អម្រឹតឬបាលីថាអមតៈ) ដែលជាវេវចនស័ព្ទរបស់

និរវាណៈដូចគ្នា ជាពាក្យក្នុងលក្ខណៈបដិសេធ តែក៏មិនមែនមានន័យថា ការមិនស្លាប់ជាសភាវៈអវិជ្ជមានឡើយ ។ ពាក្យន័យដូចមួយទៀតរបស់ និរវាណៈ គឺការរួចស្រឡះ(បាលីថាមុត្តិឬសំស្ក្រឹតថាមុក្តិ) ។ ពាក្យនេះ ប្រហែលជាគ្មាននរណានិយាយថា ការរួចស្រឡះជាភាពមិនមាន (អវិជ្ជមាន)នោះឡើយ ត្បិតថាការរួចស្រឡះ គឺសំដៅទៅដល់ការមាន ឥស្សរភាពពីអ្វីដែលជាឧបសគ្គ ដែលមានដំណើរទៅនៅក្នុងផ្លូវអាក្រក់ ក៏ដូចជាប្រព្រឹត្តទៅក្នុងផ្លូវអវិជ្ជមាន ម្ល៉ោះហើយពាក្យថា"ការរួចស្រឡះ" មិនមែនជាសភាវៈបដិសេធនោះឡើយ ។ ហេតុដូច្នេះ និរវាណៈ មុត្តិ វិមុត្តិ និរោធ ឬនិព្វាន បានដល់ការរួចផុតពីអំពើអាក្រក់ទាំងពួង ជាការ រួចផុតពីលោភៈ(សេចក្តីលោភ) ទោសៈ(ការខឹងក្រោធ) មោហៈ (សេចក្តីវង្វេង) ជាការរួចផុតពីអ្វីៗគ្រប់យ៉ាង ពីទ្វិភាវៈ(ទ្វេភាព) ពីការ ប្រៀបធៀប ពីកាលៈនិងពីទេសៈ ។

## មាគ៌ាឆ្ពោះទៅកាន់និព្វាន

គំនិតដែលថានិរវាណៈជាបរមត្ថសច្ចៈនេះ យើងអាចប្រទះឃើញ នៅក្នុងធាតុវិភង្គសូត្រ(សូត្រទី១៤០)នៃគម្ពីរមជ្ឈិមនិកាយ ហើយព្រះ សូត្រដ៏សំខាន់នេះ ព្រះពុទ្ធជាម្ចាស់បានទ្រង់សម្តែងដល់បុក្កុសាតិ(ធ្លាប់ ពោលរួចមកហើយនៅខាងដើម)ដែលជាមនុស្សឆ្លាតឈ្លាស ហើយដែល

ព្រះអង្គទ្រង់បានជួបនៅឯផ្ទះជាងស្មូនឆ្នាំង ក្នុងរាត្រីដ៏ស្ងប់ស្ងាត់មួយ ។ ខ្លឹមសារនៃព្រះសូត្រនេះ មានដូចតទៅនេះ

មនុស្សប្រកបឡើងមកដោយធាតុ៦គឺបឋវីធាតុ(ដី) អាបោធាតុ (ទឹក) តេជោធាតុ(ភ្លើង) វាយោធាតុ(ខ្យល់) អាកាសធាតុនិងវិញ្ញាណធាតុ តែលុះញែកធាតុទាំងនោះចេញពីគ្នាទៅ ក៏មិនមាននៅសល់អ្វីដែលយើងអាចនឹងហៅថា "របស់យើង" "ខ្លួនយើង" ឬថាជា "អត្តារបស់យើង" ដឹងត្រឹមតែថាវិញ្ញាណធាតុទាំងនោះ កើតឡើងមកបានយ៉ាងដូចម្តេច និងរលត់ទៅវិញយ៉ាងដូចម្តេចប៉ុណ្ណោះ ។ ដោយអាស្រ័យនូវការដឹងច្បាស់យ៉ាងដូច្នេះ ចិត្តរបស់បុគ្គលរមែងប្រាសចាកនូវតម្រេក បន្ទាប់មកក៏ប្រទះតែសេចក្តីស្ងប់ដ៏បរិសុទ្ធ(ឧបេក្ខា) ដែលអាចនាំទៅដល់ការត្រាស់ដឹង នូវសភាវៈដ៏ល្អប្រសើរខ្ពង់ខ្ពស់ខាងផ្នែកផ្លូវចិត្ត ហើយនិងដឹងថាសេចក្តីស្ងប់ដ៏បរិសុទ្ធនេះ នឹងតាំងនៅបានអស់រយៈពេលយ៉ាងយូរ តែប្រសិនបើបុគ្គលនោះមានគំនិតថា "បើយើងនាំយកសេចក្តីស្ងប់ ដែលបរិសុទ្ធស្អាតផូរផង់នេះ ទៅទុកនៅក្នុងភាវៈនៃអាកាសធាតុ ដែលមិនមានដែនកំណត់(អាកាសនញ្ចាយតនៈ) ហើយចម្រើនចិត្តឱ្យស្របជាមួយសភាវៈនោះ នោះឯងគឺការតាក់តែងផ្នែកផ្លូវចិត្ត(សង្ខតំ) ។ ប្រសិនបើយើងនាំយកសេចក្តីស្ងប់ដែលបរិសុទ្ធស្អាតផូរផង់នេះ ទៅទុកនៅក្នុងភាវៈនៃវិញ្ញាណធាតុដែលមិនមានដែនកំណត់(វិញ្ញាណញ្ចាយតនៈ)... ក្នុងភាវៈ

នៃភាពមិនមានអ្វី( អាកិញ្ចញ្ញាយតនៈ) ឬក្នុងភាវៈនៃនេវសញ្ញានាសញ្ញាយតនៈ ហើយចម្រើនចិត្តឱ្យស្របជាមួយនឹងសភាវៈនោះ នោះឯងគឺការតាក់តែងផ្នែកផ្លូវចិត្ត"។ បន្ទាប់ពីនោះបុគ្គលនោះ ក៏នឹងមិនសាងឬតាក់តែងចិត្តឱ្យមានសន្តតិ( ការបន្តភ្ជាប់) និងការកើតថ្មី( ភវ) ឬការបំផ្លាញ (វិភវ)។ ពេលមិនសាងឬមិនតាក់តែងចិត្ត ឱ្យមានសន្តតិនិងការកើតថ្មី ឬការបំផ្លាញហើយនោះ ក៏នឹងមិនជាប់ជំពាក់ជាមួយសភាវៈទាំងឡាយក្នុងលោក។ ពេលមិនមានការជាប់ជំពាក់យ៉ាងដូច្នេះ ក៏នឹងមិនមានសេចក្តីប្រាថ្នា ពេលមិនមានសេចក្តីប្រាថ្នា ក៏នឹងមានតែសេចក្តីស្ងប់រម្ងាប់យ៉ាងពេញលេញបរិបូរ( ជាការរលត់នៅខាងក្នុង ឬដែលភាសាបាលីពោលថា បច្ចត្តំយេវ បរិនិព្វាយាតិ) បន្ទាប់មកក៏នឹងដឹងថា "គ្មានការកើតទៀត មានជីវិតរស់នៅយ៉ាងបរិសុទ្ធ អ្វីដែលគួរធ្វើក៏បានធ្វើហើយ មិនមានអ្វីដែលត្រូវធ្វើតទៅទៀត" ។ តមកពេលបុគ្គលនោះសោយសុខវេទនា ទុក្ខវេទនាឬឧបេក្ខាវេទនា ក៏នឹងដឹងច្បាស់ថានោះជាសភាវធម៌ មិនទៀង ទាត់ឋិតថេរ មិនកើតនូវការប្រកាន់មាំ មិនមានអារម្មណ៍ស្លុងទៅតាមវេទនានោះៗ មិនថានឹងមានវេទនាប្រភេទណាកើតឡើង ក៏នឹងសោយនូវវេទនាទាំងនោះ ដោយការមិនប្រកាន់មាំ(វិសំយុត្តោ) ដឹងច្បាស់ថា វេទនាទាំងឡាយទាំងពួងនោះនឹងស្ងប់រម្ងាប់ទៅបាន ពេលរាងកាយបែកធ្លាយ( ស្លាប់) ប្រៀបដូចអណ្តាតភ្លើងចង្កៀង ដែលរលត់ពេលអស់ប្រេង

និងប្រឆេះយ៉ាងដូច្នោះដែរ ។

"ម្នាលភិក្ខុ! ដោយហេតុនេះ បុគ្គលដែលមានគុណសម្បត្តិដូច្នេះ រមែងជាអ្នកដែលប្រកបទៅដោយឧត្តមបញ្ញា ព្រោះថាការដឹងច្បាស់ពីការរលត់ទៅនៃទុក្ខទាំងពួងនោះ គឺជាអរិយបញ្ញាដ៏ឧត្តម" ។

"ការរួចស្រឡះរបស់បុគ្គល ដែលមានឫសគល់ចេញមកពីការឃើញច្បាស់នូវសច្ចៈនេះ ជាការរួចស្រឡះដែលមិនញាប់ញ័រ ។ ម្នាលភិក្ខុ! សភាវៈណាដែលមិនពិត(មោសធម្ម) គឺជាសភាវៈដែលបោកបញ្ឆោត សភាវៈដែលពិត(អមោសធម្ម)គឺព្រះនិព្វាន ជាការពិតដ៏ប្រសើរ(បរមសច្ច) ។ ម្នាលភិក្ខុ! ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណសម្បត្តិយ៉ាងនេះ ឈ្មោះថាជាអ្នកដែលប្រកបដោយបរមសច្ចៈ ដោយអាស្រ័យការយល់ច្បាស់នូវអរិយសច្ចៈដ៏កំពូល(បរមអរិយសច្ច) គឺព្រះនិព្វាន ដែលជាសភាវៈពិត" ។

ក្នុងទីឯទៀត ព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ប្រើពាក្យ"សច្ចៈ" ជំនួសឱ្យពាក្យ"និព្វាន"ថា "យើងនឹងបង្រៀនសច្ចៈ និងផ្លូវឆ្ពោះទៅកាន់សច្ចៈដល់អ្នក" សច្ចៈក្នុងទីនេះគឺសំដៅដល់និរវាណៈ យ៉ាងពិតប្រាកដ ។

ចុះអ្វីទៅជាបរមសច្ចៈ? បរមសច្ចៈនៅក្នុងផ្លូវព្រះពុទ្ធសាសនាមានន័យយ៉ាងដូច្នេះថា ពុំមានសភាវៈណាមួយនៅក្នុងលោក ដែលមានលក្ខណៈពេញលេញបរិបូរ(Not perfect) ។ អ្វីៗគ្រប់យ៉ាងមានការប្រា

ស្រ័យនូវគ្នានឹងគ្នា មានឥទ្ធិពលទៅវិញទៅមក មិនទៀងទាត់ឋិតថេរ។ មិនមានសភាវៈដែលជាខ្លឹមសារដូចជា អត្តា វិញ្ញាណឬអាត្ម័ន ដែលមិនមានការផ្លាស់ប្តូរ ទៀងទាត់ឋិតថេរ ហើយពេញលេញបរិបូរនោះទេ មិនថានៅក្នុងរាងកាយឬក្រៅរាងកាយ ទាំងនេះគឺបរមសច្ចៈ។

សច្ចៈរមែងមិនប្រព្រឹត្តទៅនៅក្នុងផ្លូវអវិជ្ជមាន ទោះបីជាមានមនុស្សនាំគ្នានិយាយថា សច្ចៈក្នុងផ្លូវអវិជ្ជមានក៏ដោយចុះ។ ការធ្វើឱ្យជាក់ច្បាស់នូវសច្ចៈនេះ ពោលគឺការឃើញច្បាស់នូវសភាវៈទាំងឡាយទៅតាមសេចក្តីពិត(យថាភូតំ) ដោយប្រាសចាកមាយាឬអវិជ្ជា បានដល់ការអស់ទៅនៃតម្រេក(តណ្ហក្ខយ) និងការរលត់ទៅ(និរោធ)នៃទុក្ខ គឺជានិរវាណៈ។

ជាការមិនត្រឹមត្រូវប៉ុន្មានឡើយ ដែលគិតថានិរវាណៈជាផលតាមធម្មជាតិ របស់ការរលត់ទៅនៃតណ្ហា ត្បិតថានិរវាណៈមិនមែនជាផលនៃអ្វីមួយឡើយ។ បើនិរវាណៈជាផលនៃសភាវៈណាមួយនោះ និរវាណៈក៏នឹងជាផលដែលកើតមកពីហេតុ ជាសង្ខតៈ(មានបច្ច័យតាក់តែង)ដែលត្រូវតាក់តែងឡើងនិងប្រព្រឹត្តទៅតាមក្រឹត្យក្រម។ និរវាណៈមិនមែនជាហេតុទាំងមិនមែនជាផល ព្រោះជាអ្វីដែលស្ថិតនៅលើហេតុនិងផល។ សច្ចធម៌មិនមែនជាផល ហើយក៏មិនមែនជាវិបាក ដែលមិនត្រូវបានតាក់តែងឡើងមក ដូចជាសភាវៈផ្លូវចិត្តដ៏សុខុម មានឈានឬ

សមាធិជាដើមនោះឡើយ ។ ការពិតក៏គឺការពិត និរវាណៈក៏គឺនិរវាណៈ មានរឿងមួយប៉ុណ្ណោះដែលអ្នកគួរធ្វើក៏គឺ ការដឹងច្បាស់ឃើញច្បាស់នូវនិរវាណៈ តែនិរវាណៈមិនមែនជាផលនៃមាគ៌ានោះឡើយ ប្រៀបដូចពេលអ្នកធ្វើដំណើរតាមផ្លូវឡើងភ្នំ ភ្នំក៏មិនមែនជាផលឬជាវិបាករបស់ផ្លូវនោះ ឬពេលអ្នកឃើញពន្លឺអ្វីមួយ ពន្លឺនោះក៏មិនមែនជាផលនៃភ្នែករបស់អ្នកនោះឡើយ ។

## និព្វានហើយទៅណា?

តែងតែមានមនុស្សសួរជានិច្ចថា ក្រោយពីនិរវាណៈហើយ តើនឹងមានអ្វីកើតឡើង? សំនួរនេះគឺមិនត្រឹមត្រូវទាល់តែសោះ ព្រោះថានិរវាណៈជាបរមសច្ចៈ ហើយពេលដែលជាបរមសច្ចៈដូច្នេះ ក៏មិនមានអ្វីទៀតឡើយបន្ទាប់ពីនិរវាណៈ ។ ភិក្ខុមួយរូបមាននាមថារាធៈ បានទូលសួរនូវបញ្ហាតាមរូបបែបមួយផ្សេងទៀតដល់ព្រះពុទ្ធអង្គថា "បពិត្រព្រះអង្គដ៏ចម្រើន! អ្វីទៅគឺគោលបំណង(គោលដៅ)របស់និរវាណៈ?"។ បានជាសួរដូច្នេះ ព្រោះលោកគិតថាប្រហែលជាមានអ្វីម្យ៉ាង បន្ទាប់អំពីនិរវាណៈ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់តបថា "ម្នាលរាធៈ! សំនួរនេះមិនត្រឹមត្រូវឡើយ(មិនចំបញ្ហា) បុគ្គលដែលប្រព្រឹត្តនូវព្រហ្មចរិយធម៌ មាននិរវាណៈជាវត្ថុបំណង ជាគោលដៅដ៏ខ្ពង់ខ្ពស់បំផុត" ។

មានឃ្លាខ្លះដែលមនុស្សជាច្រើននាំគ្នាប្រើ ទាំងដែលមិនត្រឹមត្រូវសោះឡើយដូចយ៉ាង"ព្រះពុទ្ធជាម្ចាស់ស្តេចយាងចូលកាន់និរវាណៈ ឬបរិនិរវាណៈ បន្ទាប់ពីទ្រង់អស់ព្រះជន្មហើយ" ដែលតាមរយៈឃ្លាទាំងនេះ បានបង្កឱ្យមានការភាន់ច្រឡំ ទាក់ទិនទៅនឹងនិរវាណៈ។ ពេលអ្នកបានឮឃ្លាថា"ព្រះពុទ្ធជាម្ចាស់ស្តេចយាងចូលកាន់និរវាណៈឬបរិនិរវាណៈ"ដូច្នេះ អ្នកអាចនឹងនឹកគិតថា និរវាណៈជាសភាវៈ ជាអាណាចក្រ ឬជាអ្វីម្យ៉ាង ដែលមានលក្ខណៈជានេះជានោះ ហើយក៏ព្យាយាមស្រមើស្រមៃ ដល់ការចូលទៅកាន់និរវាណៈ ក្នុងលក្ខណៈនៃអារម្មណ៍ដែលកើតចេញពីពាក្យថា "ជានេះឬជានោះ" តាមដែលអ្នកធ្លាប់ដឹងមក។ ឃ្លាដែលប្រើថា "ស្តេចយាងចូលកាន់ព្រះនិព្វាន"នេះ គឺមិនស្របទៅនឹងគម្ពីរជាន់ដើម ព្រោះនៅក្នុងគម្ពីរជាន់ដើម មិនមានពាក្យដូចដែលថា "ការចូលកាន់និរវាណៈក្រោយការស្លាប់" មានតែពាក្យថា "បរិនិព្វុតោ" ដែលប្រើក្នុងន័យថាស្លាប់ សម្រាប់ព្រះពុទ្ធជាម្ចាស់ឬព្រះអរហន្ត ដែលជាអ្នកដឹងច្បាស់នូវនិរវាណៈ តែមិនមែនសំដៅដល់"ការចូលកាន់និរវាណៈ"។ ពាក្យថា "បរិនិព្វុតោ"សំដៅដល់ការ ចេញផុតស្រឡះ(ពីតណ្ហាជាគ្រឿងទាក់ទាក់) ការរំលត់(តណ្ហា) ការរលាស់ចោល(នូវបញ្ចក្ខន្ធ) ព្រោះថាព្រះពុទ្ធជាម្ចាស់ឬព្រះអរហន្ត មិនបានត្រលប់មកកើតទៀតឡើយ បន្ទាប់អំពីសេចក្តីស្លាប់ទៅហើយនោះ។

នៅមានសំនួរមួយទៀតថា "មានអ្វីកើតឡើងជាមួយនឹងព្រះពុទ្ធជាម្ចាស់ឬព្រះអរហន្ត បន្ទាប់ពីលោកអស់ជីវិត ឬបរិនិព្វានទៅហើយនោះ?"។ សំនួរនេះចាត់ចូលទៅក្នុងប្រភេទសំនួរ ដែលមិនអាចឆ្លើយបាន(អវយាកត) សូម្បីពេលព្រះពុទ្ធជាម្ចាស់ត្រាស់ទៅដល់បញ្ហានេះ ក៏ទ្រង់ត្រាស់ថាមិនមានពាក្យពេចន៍ណាមួយក្នុងភាសារបស់មនុស្ស ដែលអាចនឹងនាំមកសម្តែងបានថា មានអ្វីកើតឡើងដល់ព្រះអរហន្ត បន្ទាប់ពីលោកអស់ជីវិតទៅនោះ។ ពេលព្រះអង្គឆ្លើយសំនួររបស់វច្ឆបរិព្វាជក ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ពាក្យផ្សេងៗដូចជា"កើត" ឬ "មិនកើត" មិនអាចនាំមកប្រើក្នុងករណីរបស់ព្រះអរហន្តបានឡើយ ព្រោះថាសភាវៈផ្សេងៗដូចជារូប វេទនា សញ្ញា សង្ខារនិងវិញ្ញាណ ដែលជាសភាវៈពាក់ព័ន្ធទៅនឹងពាក្យផ្សេងៗដូចជា"កើត" និង "មិនកើត" បានត្រូវបំផ្លាញនិងត្រូវកម្ចាត់ចោល ដោយឥតមានសេសសល់ ហើយនឹងមិនកើតឡើងទៀតក្រោយពេលដែលព្រះអរហន្តបានស្លាប់ទៅ(បរិនិព្វាន)។

ព្រះអរហន្តក្រោយពេលស្លាប់ តែងតែត្រូវប្រៀបប្រដូចទៅនឹងភ្លើងដែលរលត់ នៅពេលដែលអស់អុស ឬដូចភ្លើងចង្កៀងដែលរលត់ពេលដែលអស់ប្រេងនិងប្រឆេះយ៉ាងដូច្នោះដែរ។ រឿងនេះចាំបាច់ត្រូវយល់ឱ្យបានច្បាស់ ដោយប្រាសចាកនូវភាពមន្ទិលថា អ្វីដែលប្រៀបប្រដូចនឹងអណ្តាតភ្លើងដែលរលត់ទៅនោះ មិនមែនជានិរវាណៈ(និព្វាន)

នោះឡើយ តែជាតួបុគ្គលដែលប្រកបទៅដោយខន្ធ៥ ដែលជាអ្នកដឹងច្បាស់ឃើញច្បាស់នូវនិរវាណៈ។ បានជាត្រូវលើកយកមកបញ្ជាក់យ៉ាងដូច្នេះ ព្រោះមានមនុស្សជាច្រើន(រួមទាំងអ្នកប្រាជ្ញមួយចំនួនផង) នៅយល់និងបកស្រាយខុសថា ជាការប្រៀបធៀបជាមួយនិរវាណៈ។ តាមពិតនិរវាណៈមិនអាចប្រៀបធៀបបាន ជាមួយនឹងភ្លើងឬអណ្តាតភ្លើងដែលរលត់ទៅនោះបានឡើយ។

## បរមត្ថបញ្ហា

សំនួរមួយទៀត ដែលគេរមែងសួរដែរនោះគឺថា ប្រសិនបើមិនមានតួខ្លួន មិនមានអាត្មន ហើយនរណាទៅដែលជាអ្នកឃើញច្បាស់នូវនិរវាណៈ?

មុននឹងនិយាយទៅដល់និរវាណៈជាបន្តទៀត សូមចោទជាសំនួរមួយសិនថា "នរណាជាអ្នកគិត ប្រសិនបើមិនមានតួខ្លួន?"។ ដូចដែលយើងបានដឹងនៅខាងដើមរួចមកហើយថា ការគិតនោះឯងជាអ្នកគិត មិនមានអ្នកគិតនៅពីក្រោយការគិតនោះឡើយ។ ក្នុងលំនាំដូចគ្នានេះដែរ តួបញ្ញាដែលដឹងច្បាស់នោះឯង ដែលជាអ្នកដឹងច្បាស់ មិនមានអត្តាដទៃនៅពីក្រោយការដឹងច្បាស់នោះទេ។ ក្នុងជំពូកដែលនិយាយអំពីការកើតឡើងនៃទុក្ខ យើងបានឃើញហើយថា អ្វីក៏ដោយមិនថាជាសត្វ ជាបុគ្គល

ជាវត្ថុឬជាសភាវៈ ប្រសិនបើមានការកើតឡើងជាធម្មតា រមែងមានធម្មជាតិនៃការរលត់ទៅវិញជាធម្មតា ទុក្ខ សង្សារ ឬការអន្ទោលវិលវល់ កើត ចាស់ ឈឺស្លាប់ មានការកើតឡើងជាធម្មតា តោងមានការរលត់ទៅវិញជាធម្មតា។ ទុក្ខកើតឡើងព្រោះតណ្ហា ហើយរលត់ទៅវិញព្រោះបញ្ញា តណ្ហានិងបញ្ញាទាំង២យ៉ាងនេះមាននៅក្នុងខន្ធ៥ តាមដែលបានសម្ដែងរួចមកហើយនៅខាងដើម។

ដោយហេតុនេះ បច្ច័យរបស់ការកើតឡើង និងបច្ច័យរបស់ការរលត់ទៅនៃតណ្ហានិងបញ្ញាមាននៅក្នុងខន្ធ៥ នេះគឺអត្ថន័យដ៏ពិតប្រាកដរបស់ព្រះពុទ្ធវចនៈដ៏សំខាន់ដែលទ្រង់ត្រាស់ថា "ក្នុងរាងកាយនេះឯងហើយ ដែលយើងបញ្ញត្តថាលោក ការកើតឡើងរបស់លោក ការរលត់ទៅនៃលោក និងផ្លូវនាំឆ្ពោះទៅកាន់ការរលត់ទៅនៃលោក"។ ចំណុចនេះបានបញ្ជាក់ឱ្យយើងឃើញយ៉ាងច្បាស់ថា អរិយសច្ចៈ៤បុគ្គលអាចរកឃើញបាននៅក្នុងខន្ធ៥ គឺខាងក្នុងរាងកាយរបស់យើងនេះឯងតែម្ដង។ (ពាក្យថា "លោក" ក្នុងពុទ្ធវចនៈបទនេះទ្រង់ប្រើជំនួសពាក្យថា "ទុក្ខ") ក្រៅពីនោះក៏នៅមានន័យថា មិនមានអំណាចខាងក្រៅណាមួយ (ព្រះជាម្ចាស់ឬអាទិទេព) ដែលជាអ្នកសាង ការកើតនិងការរលត់ទៅនៃសេចក្ដីទុក្ខ។

ពេលបានចម្រើនទៅតាមអរិយសច្ចៈប្រការទី៤ (ដែលនឹងពោលនៅខាងមុខនេះ) ក៏នឹងធ្វើឱ្យមើលឃើញនូវអាថ៌កំបាំងរបស់ជីវិត ឃើញការពិតជាក់ស្តែងនៃសភាវៈទាំងឡាយតាមសេចក្តីពិត ។ ពេលបានឃើញភាពអាថ៌កំបាំង និងបានមើលឃើញនូវសច្ចធម៌ហើយនោះ កម្លាំងទាំងពួងដែលជាអ្នកបង្កឱ្យកើតការតភ្ជាប់ (សន្តតិ) របស់សង្សារព្រោះអវិជ្ជាក៏នឹងស្ងប់រម្ងាប់ ហើយមិនអាចសាងសង្ខារបានតទៅទៀត ព្រោះមិនមានអវិជ្ជា មិនមានតម្រេក ដែលនឹងធ្វើឱ្យមានសន្តតិបន្តទៅទៀត ដូចគ្នាទៅនឹងរោគផ្លូវចិត្ត ដែលអាចព្យាបាលឱ្យជាបាន នៅពេលដែលអ្នកជម្ងឺបានយល់ច្បាស់នូវសមុដ្ឋាន (ហេតុដែលនាំឱ្យកើត) ឬពីភាពអាថ៌កំបាំងរបស់វាបានហើយនោះ ។

## បរមសុខក្នុងបច្ចុប្បន្ន

ស្ទើរគ្រប់សាសនាទាំងអស់ បរមធម៌(Summum bonum) អាចសម្រេចបានបន្ទាប់ពីស្លាប់ហើយប៉ុណ្ណោះ ។ ដោយឡែកនិរវាណៈ បុគ្គលអាចធ្វើឱ្យសម្រេចបាន ក្នុងខណៈដែលកំពុងមានជីវិតរស់នៅ ដោយមិនចាំបាច់ថាត្រូវរង់ចាំឱ្យអ្នកស្លាប់ជាមុនសិន ទើបសម្រេចបាននោះឡើយ ។

អ្នកដែលដឹងច្បាស់ឃើញច្បាស់ នូវសច្ចៈគឺនិរវាណៈនេះ រមែងជាបុគ្គលដែលមានសេចក្តីសុខបំផុតក្នុងលោក ជាអ្នកដែលមានឥស្សរភាពពីកិលេសនិងអាសវៈទាំងពួង និងពីការក្តៅក្រហាយចិត្តទាំងឡាយដែលជាតួបង្កឱ្យកើតទុក្ខ ជាអ្នកដែលមានសុខភាពផ្លូវចិត្តល្អ មិននឹកស្តាយអតីតកាល មិនរំពឹងគិតទៅដល់អនាគត មានជីវិតរស់នៅតែជាមួយនឹងខណៈបច្ចុប្បន្នតែម្យ៉ាងគត់ ជាអ្នកមើលឃើញនូវអាថ៌កំបាំងរបស់ធម្មជាតិ ហើយរីករាយជាមួយសភាវៈទាំងឡាយ ដោយចិត្តដែលបរិសុទ្ធផូរផង់ប្រាសចាកនូវគំនិតថា អហង្ការ(ខ្លួនយើង) មមង្ការ(របស់យើង) ជាអ្នករីករាយសោមនស្សជាមួយជីវិតដែលបរិសុទ្ធ ជាអ្នកសង្រួមឥន្ទ្រិយ មិនមាននូវការខ្វល់ខ្វាយ មានតែសេចក្តីស្ងប់(សន្តិ)។ នៅពេលដែលមិនមានសេចក្តីលោភ សេចក្តីក្រោធនិងសេចក្តីវង្វេង មិនមានការប្រកាន់ខ្លួន និងសេចក្តីមួហ្មងទាំងឡាយទាំងពួងដូច្នេះ ក៏រមែងជាអ្នកបរិសុទ្ធសុភាពរាបសា មានសេចក្តីស្រលាញ់ឱ្យដល់មនុស្សគ្រប់គ្នា មានក្តីមេត្តា ករុណា មានការយល់ចិត្ត យល់ថ្លើមអ្នកដទៃ និងមានចិត្តទូលាយជួយអ្នកដទៃដោយក្តីបរិសុទ្ធចិត្ត ត្បិតថាមិនបានគិតទៅដល់ខ្លួនឯងជាទីតាំង ជាអ្នកមិនបានទទួលផលប្រយោជន៍ពីអ្វីមួយឡើយ មិនបានសន្សំអ្វី មិនសន្សំសូម្បីតែគុណសម្បត្តិគឺសេចក្តីល្អ ព្រោះថាជាអ្នកមានឥស្សរៈពី

ការយល់ខុសនៅក្នុងខ្លួនឯង ទាំងមានឥស្សរៈផុតចាកសម្រេក ដើម្បីប្រាថ្នាឱ្យខ្លួនក្លាយទៅជាយ៉ាងនេះ ឬយ៉ាងនោះបានហើយ ។

## មិនមានអ្វីនៅនានិព្វាន

និរវាណៈស្ថិតនៅលើពាក្យពេចន៍ភាសា ដែលមានលក្ខណៈជាទ្វិភាវៈ(គូ២) ហើយដែលត្រូវបានប្រើសម្រាប់ធ្វើការប្រៀបធៀបទាំងឡាយ ។ ដូចនេះទើបជាការពិតដែលថា និរវាណៈគឺស្ថិតនៅលើអ្វី ដែលយើងនាំគ្នាបញ្ញត្តថាជាអំពើល្អ អំពើអាក្រក់ ភាពត្រឹមត្រូវ ភាពខុសឆ្គង ការតាំងនៅ ការមិនតាំងនៅ សូម្បីតែពាក្យថា"សេចក្តីសុខ" ដែលយើងនាំយកមកប្រើ ដើម្បីអធិប្បាយនូវនិរវាណៈ ក៏មានលក្ខណៈខុសគ្នាស្រឡះ ទៅនឹងសេចក្តីសុខនៅក្នុងលោកនេះ ។ គ្រាមួយព្រះសារីបុត្របានពោលយ៉ាងដូច្នេះថា"ម្នាលអាវុសោ! និរវាណៈគឺជាសុខ និរវាណៈគឺជាសុខ" ហេតុនោះឯងទើបធ្វើឱ្យព្រះឧទាយី សួរបញ្ជោក់ទៅកាន់លោកថា "ម្នាលសម្លាញ់សារីបុត្រ! និរវាណៈនឹងជាសុខម្តេចកើត បើគ្មានវេទនាផងនោះ" ព្រះសារីបុត្របានតបសំនួរនេះក្នុងលក្ខណៈជាបរមត្ថ ហើយដែលហួសពីវិស័យរបស់មនុស្សធម្មតាគប្បីយល់បានថា "ការមិនមានវេទនានេះឯងគឺជាសុខ" ។

និរវាណៈស្ថិតនៅលើសូម្បីការពិចារណាខាងផ្នែកតក្កសាស្ត្រ និងការឱ្យហេតុផល(អតក្កាវចរៈ) យើងកាន់តែនាំគ្នាវិភាគវែកញែក និងសន្និដ្ឋានរឿងទាក់ទងទៅនឹងនិរវាណៈ ដែលជាបរមត្ថសច្ចៈនេះច្រើនប៉ុណ្ណា ក៏កាន់តែនាំឱ្យខាតបង់ពេលវេលា ដោយឥតប្រយោជន៍ប៉ុណ្ណោះដែរ ព្រោះថាយើងនឹងមិនអាចយល់ច្បាស់អំពីនិរវាណៈដោយវិធីនេះបានឡើយ ដូចគ្នាទៅនឹងក្មេងដែលកំពុងរៀននៅថ្នាក់មត្តេយ្យ នឹងឱ្យគេទៅវិភាគវែកញែក រឿងដែលទាក់ទងទៅនឹងទ្រឹស្តីគណិតវិទ្យាថ្នាក់ទី១២នោះ គឺប្រាកដជាមិនអាចធ្វើទៅបានឡើយ។ ប៉ុន្តែផ្ទុយមកវិញប្រសិនបើគេបានសិក្សារៀនសូត្រ ដោយក្តីឧស្សាហ៍ព្យាយាម ទៅតាមលំដាប់លំដោយនោះ ថ្ងៃណាមួយគេប្រាកដជាអាចយល់បាន នូវរឿងទាំងនោះជាក់ជាមិនខាន។

និរវាណៈបុគ្គលអាចនឹង "ដឹងច្បាស់ឃើញច្បាស់បាន ដោយបញ្ញារបស់ខ្លួនឯងផ្ទាល់ប៉ុណ្ណោះ" (បច្ចត្តំ វេទិតព្វោ វិញ្ញូហិ)។ ប្រសិនបើយើងធ្វើដំណើរ(បដិបត្តិ)តាមអរិយមគ្គ ដែលព្រះពុទ្ធអង្គទ្រង់បានសម្តែងទុកមក ប្រកបដោយការប្រឹងប្រែងព្យាយាម ធ្វើការហ្វឹកហាត់ដុសខាត់ជម្រះចិត្តរបស់ខ្លួន ឱ្យបានស្អាតបរិសុទ្ធយ៉ាងពិតប្រាកដ ទាំងអាចឱ្យសម្រេចបានដល់ការចម្រើនអប់រំផ្លូវចិត្តដ៏ក្រៃលែង ឥតឈប់ឈរឡើងថែមទៀតនោះ ថ្ងៃណាមួយយើងក៏អាចនឹងដឹងច្បាស់ដោយខ្លួនឯងថា

និរវាណៈគឺមានពិតនៅក្នុងខ្លួនរបស់យើងនេះផ្ទាល់តែម្តង ដោយមិនចាំបាច់ចំណាយកម្លាំងនិងពេលវេលា ទៅជាមួយនឹងការជជែកតវ៉ាគ្នាដោយពាក្យពេចន៍ ដែលកាន់តែនិយាយក៏កាន់តែធ្វើឱ្យឆ្ងល់ខ្លាំងឡើងថែមទៀតនោះឡើយ ។

បន្ទាប់ទៅនេះក៏នឹងពោលទៅដល់មគ្គ( ផ្លូវឬមាគ៌ា) ដែលនាំបុគ្គលអ្នកបដិបត្តិតាម ឆ្ពោះទៅកាន់ការយល់និងឃើញច្បាស់នូវនិរវាណៈ ។

ឲឲឲ✵ៜៜៜ

# ជំពូក ៥

# អរិយសច្ចៈ ប្រការទី៤

# មគ្គ : ផ្លូវនាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ

# អរិយមគ្គមានអង្គ៨

អរិយសច្ចៈប្រការទី៤ គឺមាគ៌ាដែលនាំឆ្ពោះទៅកាន់ការរំលត់ទុក្ខ (ទុក្ខនិរោធ គាមិនី បដិបទា អរិយសច្ច) ផ្លូវនេះមានឈ្មោះថាជា "ផ្លូវកណ្ដាល"(មជ្ឈិមាបដិបទា) ព្រោះវៀរចាកអំពីឧបដិបត្តិដ៏ផ្សៀងបំផុត២ប្រការ។ ឧបដិបត្តិដ៏ផ្សៀងបំផុតប្រការដំបូងនោះ បានដល់ការស្វែងរកសេចក្ដីសុខនៅក្នុងកាមគុណ ដែលជាការបដិបត្តិមិនប្រពៃ(ថោកទាប) មិនជាប្រយោជន៍ ហើយជាផ្លូវបដិបត្តិរបស់សាមញ្ញជន។ ចំណែកឯឧបដិបត្តិដ៏ផ្សៀងបំផុតប្រការទីពីរនោះ គឺការស្វែងរកនូវសេចក្ដីសុខ ដោយការធ្វើនូវទារុណកម្មចំពោះខ្លួនឯង ឱ្យបានដល់នូវសេចក្ដីលំបាកក្ដៅក្រហាយ តាមរយៈការបំពេញនូវទុក្ករកិរិយាទៅតាមរូបភាពផ្សេងៗ ដែលជាការធ្វើបាបរាងកាយ ជាការបដិបត្តិដែលមិនមានតម្លៃ ហើយជារឿងឥតប្រយោជន៍។ ដើមឡើយព្រះពុទ្ធជាម្ចាស់ទ្រង់បានសាកល្បងនូវវិធីបដិបត្តិដ៏ផ្សៀងបំផុតទាំង២ប្រការនេះរួចមកហើយដោយព្រះអង្គផ្ទាល់ ក្រោយមកទើបទ្រង់ប្រទះឃើញថាជាផ្លូវដែលមិនមានប្រយោជន៍

ពោលគឺមិនអាចនាំសត្វឱ្យរួចចាកផុតអំពីសេចក្តីទុក្ខ ដែលមាននៅក្នុងសង្សារវដ្តនេះបានឡើយ ទើបទ្រង់ងាកមកបដិបត្តិទៅតាមមជ្ឈិមាបដិបទា ដែលជាផ្លូវកណ្តាល( មិនតឹងពេក មិនធូរពេក) ជាផ្លូវដែលអាចនាំឆ្ពោះទៅកាន់ការត្រាស់ដឹងនូវសច្ចធម៌ ដើម្បីភាពស្ងប់រម្ងាប់ ដើម្បីរំលត់បង់នូវកិលេស ដើម្បីការឃើញច្បាស់យ៉ាងប្រត្យក្ស និងដើម្បីធ្វើឱ្យដល់ទីបំផុតនៃសេចក្តីទុក្ខពោលគឺព្រះនិព្វាន។ មជ្ឈិមាបដិបទាដែលជាផ្លូវកណ្តាល ពោលគឺប្រាសចាកនូវផ្លូវបដិបត្តិដ៏ផ្សៀងបំផុតទាំងពីរប្រការនោះ សំដៅដល់អរិយមគ្គដែលប្រកបដោយអង្គ៨( អរិយអដ្ឋង្គិកមគ្គ)រួមមាន

១. ការយល់ឃើញត្រូវ ( សម្មាទិដ្ឋិ)

២. ការត្រិះរិះត្រូវ ( សម្មាសង្កប្បៈ)

៣. វាចាត្រូវ ( សម្មាវាចា)

៤. ការងារត្រូវ ( សម្មាកម្មន្តៈ)

៥. ការចិញ្ចឹមជីវិតត្រូវ ( សម្មាអាជីវៈ)

៦. ការព្យាយាមត្រូវ ( សម្មាវាយាមៈ)

៧. ការរឭកត្រូវ ( សម្មាសតិ)

៨. ការតម្កល់ចិត្តត្រូវ ( សម្មាសមាធិ)

អង្គមគ្គទាំង៨ប្រការខាងលើនេះ គឺជាខ្លឹមសាររួមនៃឱវាទទូន្មាន

របស់អង្គព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ហើយដែលព្រះអង្គទ្រង់បានឧទ្ទិសរយៈពេល៤៥ព្រះវស្សានៃព្រះជន្មាយុរបស់ព្រះអង្គ ប្រយោជន៍ដើម្បីទេសនាទូន្មានប្រៀនប្រដៅសត្វលោក ឱ្យធ្វើដំណើរតាមមាគ៌ាដ៏ប្រសើរ ពោលគឺអរិយមគ្គប្រកបដោយអង្គ៨ ដែលព្រះអង្គទ្រង់បានត្រាស់ដឹងហើយនេះ ដោយព្រះបំណងស្រោចស្រង់សត្វលោក ឱ្យបានរួចចាកផុតអំពីសេចក្ដីទុក្ខ។ ព្រះអង្គទ្រង់បានអធិប្បាយនូវអរិយមគ្គទាំង៨ប្រការនេះ ទៅតាមវិធីនិងពាក្យពេចន៍ផ្សេងៗគ្នាទៅកាន់បុគ្គលផ្សេងៗគ្នា អាស្រ័យទៅតាមសតិបញ្ញានិងការយល់ដឹងរបស់បុគ្គលនោះៗ[៨]។ ការបដិបត្តិតាមមគ្គទាំង៨ប្រការនេះ មានការពាក់ព័ន្ធគ្នាទៅវិញទៅមកចំណុចនិមួយៗជាផ្លូវបដិបត្តិ អនុគ្រោះឱ្យដល់ចំណុចមួយដទៃផ្សេងទៀតដោយមានគោលដៅដើម្បីការអប់រំ ហ្វឹកហាត់ទូន្មានខ្លួនឯងទៅតាម

---

[៨] ជាទំនៀមរបស់ព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ កាលបើនឹងសម្ដែងនូវព្រះធម៌ ទ្រង់រមែងប្រមើលមើលនូវឧបនិស្ស័យនិងសតិបញ្ញារបស់សត្វជាមុនសិនថា តើសត្វលោកនោះៗមានចរិត ឧបនិស្ស័យ ចំណង់ចំណូលចិត្តនិងអធ្យាស្រ័យយ៉ាងណាៗជាដើម។ បន្ទាប់មកទើបទ្រង់រំពឹងនៅក្នុងព្រះទ័យថា គួរសម្ដែងនូវព្រះធម៌បែបណា ដើម្បីឱ្យស្របទៅនឹងចរិតអធ្យាស្រ័យរបស់បុគ្គលនោះបាន។ ហេតុដូច្នេះហើយ ទើបយើងសង្កេតឃើញនៅក្នុងទីជាច្រើន ដែលព្រះអង្គទ្រង់បានអធិប្បាយនូវអរិយមគ្គទាំង៨ប្រការនេះ ទៅកាន់បុគ្គលផ្សេងៗគ្នា ដោយវិធីនិងពាក្យពេចន៍ផ្សេងៗគ្នា តែនៅរក្សាគោលការណ៍ដើមទាំងស្រុង មិនខុសអ្វីទៅនឹងការធ្វើដំណើរលើផ្លូវ២ដែលមានគោលដៅតែមួយនោះឡើយ ពោលគឺប្រព្រឹត្តទៅដើម្បីការកម្ចាត់បង់នូវសេចក្ដីទុក្ខនៅក្នុងសង្សារវដ្ដនេះប៉ុណ្ណោះ។

គោលការណ៍របស់ព្រះពុទ្ធសាសនា ដោយអាចបែងចែកចេញជា៣ប្រការធំៗគឺ:

១. ការប្រព្រឹត្តខ្លួនឱ្យតាំងនៅក្នុងគន្លងសីលធម៌ដ៏ល្អប្រពៃ

២. ការអប់រំចិត្ត

៣. ការចម្រើនបញ្ញា

ព្រោះហេតុដូច្នេះ ការយល់ច្បាស់ទាក់ទងទៅនឹងការបែងចែកមគ្គទាំង៨ប្រការ អាចចាត់ទុកបានថាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះអាចធ្វើឱ្យយើងយល់ច្បាស់នូវមាគ៌ាដែលព្រះពុទ្ធអង្គ ទ្រង់បានឧទ្ទិសព្រះកាយរបស់ព្រះអង្គអស់រយៈពេល៤៥ព្រះវស្សា ក្នុងការប្រទានឱវាទទូន្មានរបស់ព្រះអង្គទុកក៏ "ដើម្បីប្រយោជន៏ និងសេចក្តីសុខរបស់មនុស្សទាំងឡាយ ដើម្បីអនុគ្រោះដល់សត្វលោក" (ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ)។

## គុណសម្បត្តិរបស់មនុស្សដែលគ្រប់លក្ខណៈ

ក្នុងផ្លូវព្រះពុទ្ធសាសនា ការដែលបុគ្គលនឹងអាចក្លាយជាមនុស្សដែលមានលក្ខណសម្បត្តិល្អឥតខ្ចោះបាននោះ ចាំបាច់ទាមទារឱ្យមានការចម្រើននូវគុណសម្បត្តិ២ប្រការឱ្យបានស្មើៗគ្នា គឺផ្នែកករុណានិងបញ្ញា។ សេចក្តីករុណាដែលពោលនៅក្នុងទីនេះ គឺសំដៅដល់សេចក្តីមេត្តា ការ

អាណិតអាសូរ សេចក្តីអើពើ ការអត់ធន់ និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ក៏ដូចជាគុណសម្បត្តិដ៏ប្រសើរខាងផ្នែកអារម្មណ៍ ឬគុណសម្បត្តិខាងផ្នែកចិត្តគំនិតផ្សេងៗឯទៀត។ ចំណែកឯបញ្ញាគឺបានដល់ពុទ្ធិ(ចំណេះដឹង) ឬគុណសម្បត្តិខាងផ្នែកផ្លូវចិត្ត។ ប្រសិនបើបុគ្គលណាមួយធ្វើឱ្យចម្រើនតែខាងផ្នែកករុណា ដោយមិនបានធ្វើឱ្យចម្រើនខាងផ្នែកពុទ្ធិបញ្ញា បុគ្គលនោះអាចនឹងក្លាយជាមនុស្សល្ងង់តែមានចិត្តល្អ។ ផ្ទុយទៅវិញ បុគ្គលណាដែលចម្រើនតែពុទ្ធិបញ្ញា ដោយខ្វះខាតការធ្វើឱ្យចម្រើននូវផ្នែកករុណាធម៌។ គេម្នាក់នោះអាចនឹងក្លាយជាមនុស្សឆ្លាត ប៉ុន្តែមានចិត្តគំនិតកោងកាច មិនមានទឹកចិត្តចំពោះអ្នកដទៃ។ ព្រោះអាស្រ័យហេតុដូចនេះ ការដែលបុគ្គលមានបំណងប្រាថ្នា ចង់ឱ្យខ្លួនក្លាយជាមនុស្ស ដែលមានលក្ខណសម្បត្តិពេញលេញបាននោះ តោងតែចម្រើននូវផ្នែកទាំងពីរនេះឱ្យបានស្មើៗគ្នា។ ទាំងនេះឯងគឺជាគោលដៅនៃដំណើរជីវិត តាមបែបពុទ្ធសាសនិកជន ពោលគឺជាវិថីជីវិតដែលប្រកបព្រមទៅដោយបញ្ញា និងសេចក្តីករុណា ដែលសម្ព័ន្ធគ្នាទៅវិញទៅមក មិនអាចកាត់ផ្តាច់ចេញពីគ្នាបាន ហើយដែលនឹងត្រូវលើកយកមកបកស្រាយជាខាងក្រោយទៀត។

# អង្គប្រកបផ្នែកសីល

តាមលំនាំនៃការប្រព្រឹត្តផ្នែកចរិយសាស្រ្ត(សីល) ដែលតាំងនៅលើមូលដ្ឋាននៃក្តីមេត្តានិងក្តីករុណានោះ មានអង្គប្រកបរបស់អរិយអដ្ឋង្គិកមគ្គចំនួន៣ប្រការគឺ សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ (បានដល់ខទី ៣, ៤ និង ៥)។

សម្មាវាចា(វាចាត្រូវ)សំដៅដល់

(១) ការវៀរចាកនូវការនិយាយកុហក។

(២) ការវៀរចាកនូវរាល់សម្តីញុះញង់ចាក់ដោត ឬសម្តីទាំងឡាយណាដែលបង្កឱ្យមានទំនាស់ ក៏ដូចជាការបែកបាក់នូវសាមគ្គីភាព។

(៣) ការវៀរចាកការនិយាយនូវសម្តីគ្រោតគ្រាត(ពាក្យអាសអាភាស) អសុរស(ពាក្យជេរឬប្រមាថមាក់ងាយ) និងពាក្យចងអាឃាតជាដើម។

(៤) ការវៀរចាកនូវការនិយាយ ពាក្យរោយរាយឥតបានការ ពាក្យដែលមិនញ៉ាំងប្រយោជន៍ឱ្យសម្រេច ឬពាក្យនិន្ទាឈ្នានីសជាដើម។

ពេលដែលអាចលះបង់បាននូវរាល់វាចាដ៏ខ្លាំក្លង និងប្រកបដោយទោសទាំងនេះបានហើយនោះ បុគ្គលក៏នឹងពោលតែពាក្យពិត ប្រើពាក្យសម្តីដែលសម្តែងនូវមេត្រីភាព ពាក្យសម្តីដែលមានប្រយោជន៍ ពាក្យសម្តីដែលពិរោះ សុភាពរាបសា ហើយនឹងមិននិយាយដោយការ

ប្រមាថ ពោលគឺនិយាយស្របទៅតាមកាលៈទេសៈ ដរាបណាដែលមិនអាចនិយាយនូវអ្វីដែលមានប្រយោជន៍ គេក៏រមែងស្ងាត់ស្ងៀមទៅ មិននិយាយអ្វីចេញមកឡើយ ។

សម្មាកម្មន្តៈ( ការងារត្រូវ) ចំណុចនេះមានគោលបំណងដើម្បីផ្ដួងផ្ដើម ការប្រព្រឹត្តដែលមានសីលធម៌ មានសេចក្ដីថ្លៃថ្នូរ និងដែលប្រកបទៅដោយសន្តិ ។ ជាការបង្រៀនឱ្យយើងលះបង់ចាកការបំផ្លាញជីវិត ចាកការលួច ការឆបោក ឬកេងប្រវ័ញ្ចអ្នកដទៃ ចាកការប្រព្រឹត្តខុសនៅក្នុងផ្លូវកាម ទាំងបានបង្រៀនឱ្យយើងចេះជួយដល់អ្នកដទៃដើម្បីឱ្យគេអាចមានជីវិតយ៉ាងសុខស្ងប់ និងប្រកបដោយកិត្តិយសទៅតាមគន្លងដ៏ល្អប្រពៃ ។

សម្មាអាជីវៈ( ការចិញ្ចឹមជីវិតត្រូវ) បានដល់ការវៀរចាកនូវការចិញ្ចឹមជីវិតដោយអាជីព ដែលនាំការក្ដៅក្រហាយឱ្យដល់អ្នកដទៃ ដូចជាការជួញដូរអាវុធដែលប្រើសម្រាប់ការប្រហារគ្នា ការជួញដូរគ្រឿងស្រវឹងគ្រប់ប្រភេទ( រួមទាំងថ្នាំញៀនផងដែរ) ការជួញដូរសត្វ ការជួញដូរមនុស្ស ការបោកប្រាស់អ្នកដទៃ និងការបើកបនល្បែងស៊ីសងជាដើម ហើយឱ្យចិញ្ចឹមជីវិតប្រកបដោយសេចក្ដីថ្លៃថ្នូរ មិនផ្ទុយទៅនឹងក្រមសីលធម៌ និងមិនបៀតបៀនចំពោះអ្នកដទៃ( សត្វដទៃ) ។ ក្នុងទីនេះយើងប្រហែលជាយល់បានយ៉ាងច្បាស់ហើយថា ព្រះពុទ្ធសាសនាប្រឆាំងយ៉ាង

ដាច់ខាត ចំពោះសង្គ្រាមគ្រប់រូបភាព(រួមទាំងសង្គ្រាមដែលគេហៅថាជាសង្គ្រាមដើម្បីការពារសាសនា ឬដើម្បីផ្សព្វផ្សាយសាសនារបស់ខ្លួននោះផងដែរ...) ត្បិតបានកំណត់គោលការណ៍ ក្នុងការបដិបត្តិទុកយ៉ាងដូច្នេះថា ការជួញដូរអាវុធសង្គ្រាម និងអាវុធសម្រាប់ប្រហារគ្នានោះជាទង្វើដ៏អាក្រក់និងជាដំណើរជីវិតដែលមិនសុចរិត។

អង្គប្រកបទាំង៣របស់មគ្គ៨ប្រការខាងលើនេះ (សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ) ជាអង្គប្រកបនៃការប្រព្រឹត្តខាងផ្នែកចរិយសាស្ត្រ។ គប្បីយល់ឱ្យបានច្បាស់ថា ការប្រព្រឹត្តខាងផ្នែកចរិយសាស្ត្រនិងខាងផ្នែកសីលធម៌របស់ពុទ្ធសាសនិកជននេះ គោលដៅសំខាន់គឺដើម្បីញ៉ាំងជីវិត ឱ្យមានសេចក្ដីសុខនិងពេញទៅដោយសាមគ្គីភាព ទាំងចំពោះបច្ចេកបុគ្គល(individual) ក៏ដូចជាចំពោះសង្គមមនុស្សទាំងមូល។ ការប្រព្រឹត្តខាងផ្នែកសីលធម៌នេះ ចាត់ទុកបានថាជាឫសគល់យ៉ាងសំខាន់ដើម្បីសម្រេចបាននូវគុណធម៌ខាងផ្នែកចិត្តគំនិត ដែលមានលក្ខណៈប្រសើរខ្ពង់ខ្ពស់ខ្លាំងឡើងថែមទៀត។ ការអប់រំចម្រើនផ្លូវចិត្ត ពិតជាមិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើប្រាសចាកមូលដ្ឋានខាងផ្នែកសីលធម៌នេះ។

# អង្គប្រកបផ្នែកសមាធិ

ប្រការបន្ទាប់មកគឺការគ្រប់គ្រងផ្លូវចិត្ត( សមាធិ) ។ ក្នុងចំណុចនេះរួមមាន អង្គប្រកបរបស់មគ្គទាំង៨ចំនួន៣ប្រការគឺ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ( ប្រការទី ៦,៧ និង ៨) ។

សម្មាវាយាមៈ( ព្យាយាមត្រូវ) ជាការពុះពារព្យាយាមយ៉ាងដូច្នេះគឺ

( ១) ព្យាយាមការពាររារាំងអំពើអាក្រក់ និងអកុសលធម៌ទាំងឡាយមិនឱ្យកើតឡើងបានក្នុងចិត្តគំនិត ។

( ២) ព្យាយាមកំចាត់អកុសលធម៌ ដែលកើតឡើងហើយនៅក្នុងចិត្តគំនិតឱ្យវិនាសសាបសូន្យទៅ ។

( ៣) ព្យាយាមសាងឬប្រព្រឹត្តនូវអំពើល្អនិងធម៌ជាកុសលទាំងឡាយដែលនៅមិនទាន់កើតក្នុងចិត្តឱ្យកើតឡើង ។

( ៤) ព្យាយាមរក្សាក៏ដូចជាធ្វើឱ្យចម្រើនឡើង នូវកុសលធម៌ទាំងឡាយណា ដែលមាននៅក្នុងចិត្តស្រាប់ហើយនោះ មិនឱ្យវិនាសបង់ទៅ ។

សម្មាសតិ( ការរឭកត្រូវ) គឺការឃ្លាំកំណត់មើលយកចិត្តទុកដាក់និងចាប់អារម្មណ៍ចំពោះរឿងទាំងនេះគឺ

(១) តាំងសតិកំណត់ព្រឹត្តិកម្មខាងផ្នែករាងកាយ(កាយានុបស្សនា)។

(២) តាំងសតិកំណត់វេទនាឬអារម្មណ៏ផ្សេងៗ(វេទនានុបស្សនា)។

(៣) តាំងសតិកំណត់ព្រឹត្តិកម្មផ្លូវចិត្ត(ចិត្តានុបស្សនា)។

(៤) តាំងសតិកំណត់ផ្នត់គំនិត ទ្រឹស្ដីនិងសភាវធម៌គ្រប់បែបយ៉ាងទាំងអស់(ធម្មានុបស្សនា)។

ការបដិបត្តិសមាធិដោយការកំណត់ខ្យល់ ដង្ហើមចេញចូល (អានាបាណស្សតិ) ជាលំនាំនៃការបដិបត្តិមួយដែលទទួលបាននូវការពេញនិយមជាទូទៅ ជាការបដិបត្តិក្នុងបំណងអប់រំចម្រើនផ្នែកផ្លូវចិត្តដោយផ្សារភ្ជាប់ទៅនឹងរាងកាយ ហើយនៅមានវិធីក្នុងការអប់រំចម្រើនផ្នែកផ្លូវចិត្ត ដោយផ្សារភ្ជាប់ទៅនឹងរាងកាយជាច្រើនយ៉ាងផ្សេងទៀតញែកទៅតាមប្រភេទរបស់សមាធិ។

ក្នុងចំណែកដែលទាក់ទងទៅនឹងអារម្មណ៏ឬវេទនានោះ គឺការដែលបុគ្គលកំណត់ដឹងនូវអារម្មណ៏និងវេទនាគ្រប់រូបបែប ទាំងវេទនាដែលជាសុខ វេទនាដែលជាទុក្ខ និងវេទនាដែលជាឧបេក្ខា(មិនសុខមិនទុក្ខ)ថា វាកើតឡើងបានយ៉ាងដូចម្ដេច ហើយនឹងរលត់ទៅវិញបានយ៉ាងដូចម្ដេច?

ចំណែកឯផ្នែកដែលពាក់ព័ន្ធជាមួយនឹងចិត្តានុបស្សនានោះ គឺការ

ដែលបុគ្គលកំណត់ដឹងថា ចិត្តរបស់ខ្លួនមានតម្រេកឬទេ ធ្លាក់ទៅក្នុងអំណាចនៃសេចក្តីវង្វេងឬយ៉ាងណា មានភាពរវើរវាយ ឬថាមានការតម្កល់នៅមាំឬទេជាដើម ។

ក្នុងផ្នែកដែលទាក់ទងទៅនឹងផ្នត់គំនិតនិងទ្រឹស្តី ក៏ដូចជាសភាវធម៌គ្រប់បែបយ៉ាងទាំងអស់( ធម្មានុបស្សនា)វិញនោះ បុគ្គលគប្បីសិក្សាឱ្យបានយល់ច្បាស់ នូវដំណើរនៃសភាវៈទាំងនោះថា វាកើតឡើងនិងរលត់ទៅវិញបានយ៉ាងដូចម្តេច? វាចម្រើនឡើងបានយ៉ាងដូចម្តេច? អាចគ្រប់គ្រងបានយ៉ាងដូចម្តេច? ឬថានឹងអាចកម្ចាត់បង់ទៅវិញបានយ៉ាងដូចម្តេចជាដើម ។

សមាធិទាំង៤រូបបែបនេះ មានសេចក្តីអត្ថាធិប្បាយយ៉ាងពិស្តារនៅក្នុងសតិបដ្ឋានសូត្រ( ការតាំងសតិ) ។

អង្គប្រកបប្រការទី៣ ដែលជាប្រការចុងក្រោយនៃការគ្រប់គ្រងផ្លូវចិត្ត( សមាធិ)គឺសម្មាសមាធិ ដែលនឹងនាំឆ្ពោះទៅកាន់ធ្យាន( ឈាន)៤ ដែលត្រូវបានគេស្គាល់ជាទូទៅ នៅក្នុងភាសាអង់គ្លេសថា trance ឬ recueillement ។

នៅក្នុងធ្យាន( ឈាន)ទី១( បឋមជ្ឈាន) អាចកំចាត់កាមតណ្ហានិងអកុសលចិត្តប្រភេទខ្លះបានដូចជា តម្រេក សេចក្តីព្យាបាទ ការសោកសៅ ការខ្វាយខ្វល់ ចិត្តរវើរវាយ និងសេចក្តីសង្ស័យបាន ធ្វើឱ្យមានបីតិ

( សេចក្ដីឆ្អែតចិត្ត) និងសេចក្ដីសុខរហូតដល់ព្រឹត្តិកម្មផ្លូវចិត្តផ្សេងៗថែមទៀតផង ។

ក្នុងឈ្យាន( ឈាន) ទី២( ទុតិយជ្ឈាន) ចិត្តត្រូវបានចម្រើនឡើងរហូតដល់ថ្នាក់ស្ងប់ស្ងៀម មានដំណើរចិត្តមូលស្ពុងទៅក្នុងអារម្មណ៍តែមួយ( ឯកគ្គតា) ប្រកបជាមួយបីតិនិងសេចក្ដីសុខ ។

ក្នុងឈ្យាន( ឈាន) ទី៣( តតិយជ្ឈាន) សេចក្ដីឆ្អែតចិត្ត( បីតិ) ដែលជាវេទនាម្យ៉ាងដែរនោះបានរលត់ទៅ ដោយបន្សល់ទុកនៅត្រឹមសេចក្ដីសុខនិងឯកគ្គតាប៉ុណ្ណោះ ។

ក្នុងឈ្យាន( ឈាន) ទី៤( ចតុត្ថជ្ឈាន) ដែលជាឈ្យានចុងក្រោយសេចក្ដីដឹងនូវអារម្មណ៍ទាំងឡាយ ទាំងដែលជាសុខនិងជាទុក្ខ មិនថាជាបីតិឬសេចក្ដីសោកសៅផ្សេងៗបានរលត់ទៅទាំងអស់ មានត្រឹមឯកគ្គតាជាមួយនិងសម្បជញ្ញៈប៉ុណ្ណោះដែលបន្សល់នៅ ។

ដោយអាស្រ័យហេតុដូចបានរៀបរាប់មកនេះ យើងសង្កេតឃើញថា ចិត្តជាសភាវៈដែលបុគ្គលអាចហ្វឹកហាត់ គ្រប់គ្រងនិងធ្វើឱ្យចម្រើនឡើងបាន ដោយអាស្រ័យសម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ។

# អង្គប្រកបផ្នែកបញ្ញា

អង្គប្រកបចំនួន២ផ្សេងទៀតនៃមគ្គទាំង៨ដែលនៅសល់គឺ សម្មាសង្កប្បៈ(សេចក្តីត្រិះរិះត្រូវ) និងសម្មាទិដ្ឋិ (សេចក្តីយល់ឃើញត្រូវ) ប្រកបគ្នាជា"តួបញ្ញា"។

សម្មាសង្កប្បៈ(សេចក្តីត្រិះរិះត្រូវ) សំដៅដល់សេចក្តីត្រិះរិះក្នុងការលះលោកចេញបួស សេចក្តីត្រិះរិះក្នុងការកម្ចាត់បង់នូវតម្រេក សេចក្តីត្រិះរិះក្នុងការធ្វើចិត្តឱ្យមានមេត្តា សេចក្តីត្រិះរិះដែលនឹងមិនប្រើនូវអំពើហិង្សា ដោយព្យាយាមផ្សាយចិត្តមេត្តាគ្របដណ្តប់ទៅដល់សព្វសត្វទាំងពួង។

ជាប្រការគួរឱ្យកត់សម្គាល់ យើងសង្កេតឃើញថា ការត្រិះរិះដែលនឹងលះលោកចេញបួសក្តី ការត្រិះរិះដែលនឹងមានមេត្តាក្តី ក៏ដូចជាការត្រិះរិះដែលនឹងមិនប្រើនូវអំពើហិង្សាក្តី ត្រូវបានរាប់បញ្ចូលទៅក្នុងផ្នែករបស់បញ្ញា។ ខនេះបានបង្ហាញឱ្យយើងឃើញយ៉ាងច្បាស់ថា បញ្ញាដ៏ពិតប្រាកដ ចាំបាច់ត្រូវប្រកបដោយគុណសម្បត្តិដ៏ប្រសើរទាំងនេះ។ រីឯការត្រិះរិះក្នុងផ្លូវតណ្ហាដែលប្រកាន់មាំនៅក្នុងតួខ្លួន ការត្រិះរិះនៅក្នុងការចងអាឃាតព្យាបាទ ការត្រិះរិះដែលនាំទៅដល់ការប្រើនូវអំពើហិង្សាជាលទ្ធផលស្តែងចេញពីការខ្វះខាតបញ្ញា ហើយប្រការដ៏សំខាន់នេះ យើង

អាចនាំទៅប្រើជាមួយនឹងជីវិតគ្រប់រូបបែប មិនថាជាជីវិតរបស់បច្ចេកបុគ្គល ក៏ដូចជាសង្គមជាតិទាំងមូលបានផងដែរ ។

សម្មាទិដ្ឋិ(សេចក្តីយល់ឃើញត្រូវ) គឺការយល់នូវសភាវធម៌ទាំងឡាយទៅតាមសេចក្តីពិត ។ សម្មាទិដ្ឋិតាមពិតទៅក៏គឺការយល់នូវអរិយសច្ចៈ៤ ដែលអធិប្បាយនូវសភាវធម៌ទាំងអស់ទៅតាមសេចក្តីពិត ។ ដូច្នេះសម្មាទិដ្ឋិនេះ នៅទីបំផុតក៏នឹងធ្វើឱ្យបុគ្គលបានយល់ច្បាស់នូវអរិយសច្ចៈ៤ ។ ក្នុងផ្លូវព្រះពុទ្ធសាសនា ការយល់មាន២ប្រភេទគឺ (១)ការយល់គឺការដឹង ភាពជាពហុស្សូត ការមានសតិបញ្ញា អាចដឹងនិងយល់ច្បាស់នូវអ្វីមួយដែលខ្លួនបានរៀនមក ការយល់ប្រភេទនេះហៅថា "អនុពោធិ" ជាការយល់ដែលនៅមិនទាន់ដល់នូវទីបំផុតនៅឡើយ ។ (២)ការយល់ដ៏ជ្រាលជ្រៅ ដែលជា"ការយល់ច្បាស់ទៅតាមសភាពពិតនៃបរមត្ថធម៌"(បដិវេធ) សំដៅដល់ការឃើញនូវសភាវធម៌ទាំងឡាយទៅតាមសេចក្តីពិត ដោយមិនជាប់ជំពាក់ទៅនឹងឈ្មោះឬសន្មតិណាមួយឡើយ ។ ការដឹងច្បាស់ទៅតាមសភាវៈពិតយ៉ាងដូច្នេះ នឹងអាចកើតឡើងបាន លុះណាតែចិត្តប្រាសចាកអាសវៈ(កិលេស)ទាំងឡាយ ហើយអាចធ្វើឱ្យចម្រើនពេញលេញទៅបាន ក៏អាស្រ័យដោយការបដិបត្តិសមាធិប៉ុណ្ណោះ ។

តាមដែលបានអធិប្បាយអំពីមគ្គ(ផ្លូវនាំឆ្ពោះទៅកាន់ការរំលត់

ទុក្ខ) មកដោយសង្ខេបយ៉ាងដូច្នេះ ក៏ប្រហែលជាល្មមអាចធ្វើឱ្យយើងយល់បានថា មគ្គគឺជាវិធីជីវិត ដែលបុគ្គលម្នាក់ៗអាចនាំយកទៅប្រព្រឹត្តបដិបត្តិ ដើម្បីការគ្រប់គ្រងខ្លួនឯង ទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត ជាការអភិវឌ្ឍខ្លួនឯង និងជាការជម្រះចិត្តរបស់ខ្លួនឱ្យបានស្អាតបរិសុទ្ធ ដោយមិនមានការពាក់ព័ន្ធទៅជាមួយនឹងរឿងជំនឿ ការបន់ស្រន់ ការបូជា ភក្តិភាព(ចំពោះព្រះជាម្ចាស់) ឬពិធីកម្មណាមួយនោះឡើយ។ ដោយន័យនេះ ទើបមិនមានការពាក់ព័ន្ធទៅនឹងអ្វី ដែលមនុស្សនិយមនាំគ្នាហៅថា"សាសនា" ជាផ្លូវដែលនាំទៅកាន់ការត្រាស់ដឹងនូវឧត្តមសច្ចៈ (បរមត្ថសច្ចៈ) ជាការមានឥស្សរភាពយ៉ាងពេញលេញ មានសេចក្តីសុខ និងសន្តិភាព ដោយអាស្រ័យការបំពេញនូវសីល សមាធិ បញ្ញា យ៉ាងពេញលេញបរិបូរ។

ក្នុងប្រទេសដែលគោរពនូវព្រះពុទ្ធសាសនាទាំងឡាយ នៅមានប្រពៃណីនិងពិធីកម្មខាងផ្នែកសាសនា ដែលនិយមនាំគ្នាធ្វើឡើងបែបសាមញ្ញៗទៅតាមឱកាសផ្សេងៗ ប៉ុន្តែប្រពៃណីនិងពិធីកម្មទាំងនោះ មិនបានពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងអរិយមគ្គនេះឡើយ។ វាមានតម្លៃត្រឹមតែជាការស្នងសទ្ធានិងសេចក្តីត្រូវការមួយចំនួន របស់អ្នកដែលមានសតិបញ្ញាទន់ខ្សោយនៅឡើយ ដើម្បីជួយឱ្យអ្នកទាំងនោះបានជម្រះផ្លូវសម្រាប់ធ្វើដំណើរទៅកាន់អរិយមគ្គបានយ៉ាងសន្សឹមៗប៉ុណ្ណោះ។

# សរុបអរិយសច្ចៈ៤

ចំពោះអ្វីដែលទាក់ទងទៅនឹងអរិយសច្ចៈ៤ប្រការនេះ យើងមានតួនាទីដែលគប្បីបដិបត្តិ៤ប្រការដូចគ្នាគឺ៖

១. អរិយសច្ចៈប្រការទី១គឺទុក្ខ បានដល់សភាវៈរបស់ជីវិត សេចក្តីទុក្ខរបស់ជីវិត សេចក្តីសោកសៅ និងសេចក្តីរីករាយរបស់ជីវិត ភាពខ្វះខាត ការមិនបានសមតាមបំណង ភាពមិនទៀតទាត់ និងភាពមិនមានខ្លឹមសាររបស់ជីវិត។ ក្នុងខនេះយើងមានតួនាទីដែលចាំបាច់ត្រូវយល់ទៅតាមសេចក្តីពិតឱ្យបានជាក់ច្បាស់(បរិញ្ញេយ្យ)។

២. អរិយសច្ចៈខទី២គឺប្រភពកើតឡើងនៃសេចក្តីទុក្ខ ដែលសំដៅដល់តណ្ហាព្រមជាមួយកិលេសអាសវៈ និងសាសវៈទាំងឡាយដទៃទៀត ហើយយើងមានតួនាទីមិនត្រឹមតែតម្រង់ការយល់ឃើញ របស់ខ្លួនទៅតាមសេចក្តីពិត នៃដំណើរប្រព្រឹត្តទៅរបស់តណ្ហានេះប៉ុណ្ណោះទេ ពោលគឺត្រូវលះបង់ចោល កម្ចាត់ ឬបំផ្លាញនូវតណ្ហាទាំងនោះផងដែរ(បហានតព្វៈ)។

៣. អរិយសច្ចៈខទី៣គឺការរំលត់ទុក្ខ ពោលគឺព្រះនិព្វានជាបរមសច្ចៈ។ ក្នុងខនេះ យើងមានតួនាទីចាំបាច់ត្រូវតម្រង់នូវការយល់ឃើញរបស់ខ្លួនឱ្យប្រព្រឹត្តទៅតាមសេចក្តីពិត(សច្ឆិកាតព្វៈ)។

៤. អរិយសច្ចៈខទី៤គឺមគ្គ ជាផ្លូវដែលនាំឆ្ពោះទៅកាន់ការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាទីអស់ទៅនៃសេចក្តីទុក្ខ ហើយយើងមានតួនាទីមិនគ្រាន់តែសិក្សាឱ្យបានដឹងនិងយល់ច្បាស់នូវរឿងមគ្គនេះប៉ុណ្ណោះទេ តែត្រូវធ្វើដំណើរតាមនិងបដិបត្តិតាមមគ្គនេះផងដែរ (ភាវេតព្វៈ) ។

ឲឲឲ✶៩៩៩

# ជំពូកទី៦

## ធម្មៈដែលសម្តែងអំពីការមិនមានតួខ្លួន "អនត្តា"

## ជំនឿរឿងអត្តា

អ្វីដែលមនុស្សទូទៅនាំគ្នាយល់ថាជា "វិញ្ញាណ" "អត្តា" ឬដែលភាសាសំស្ក្រឹតហៅថា "អាត្ម័ន" នោះ គឺពួកគេនាំគ្នាសំដៅទៅដល់អ្វីដែលមាននៅក្នុងខ្លួនមនុស្ស ថាជាសភាវៈគង់វង្ស ឋិតថេរនិងមានលក្ខណៈពេញលេញ ជាសភាវៈដែលមិនប្រែប្រួល ហើយស្ថិតនៅពីក្រោយលោកទាំងមូល ជាអ្នកសម្តែងចេញនូវការផ្លាស់ប្តូរប្រែប្រួល។ សាសនាមួយចំនួនមានជំនឿថា មនុស្សម្នាក់ៗមានវិញ្ញាណដែលព្រះជាម្ចាស់បានបង្កើតមក ហើយបន្ទាប់អំពីការស្លាប់ វិញ្ញាណនេះក៏នឹងទៅស្ថិតជានិច្ចនិរន្តរ៍ក្នុងនរកឬសួគ៌តាមជតាកម្មរបស់វិញ្ញាណ ដោយអាស្រ័យទៅលើការជំនុំជម្រះរបស់ព្រះជាម្ចាស់។ ចំណែកនៅក្នុងសាសនាមួយចំនួនទៀតមានជំនឿថា វិញ្ញាណឆ្លងកាត់ការមានជីវិតមកជាច្រើនគ្រា រហូតដល់ត្រូវបានជម្រះឱ្យបរិសុទ្ធផូរផង់ ហើយនៅទីបំផុតក៏នឹងចូលទៅរួមជាមួយនឹងព្រះជាម្ចាស់ឬព្រះព្រហ្ម ពោលគឺវិញ្ញាណនៃចក្រវាលឬអាត្ម័ន ដែលជាប្រភពកំណើតរបស់ខ្លួន។ ពួកគេនៅមានជំនឿទៀតថា វិញ្ញាណឬអត្តាជាអ្នកគិត ជាអ្នកទទួលដឹងនូវអារម្មណ៍ និងជាអ្នកទទួលគុណនិងទោសពី

កម្មល្អនិងអាក្រក់របស់ខ្លួន។ ជំនឿដូច្នេះហៅថា ជំនឿដែលជឿថាមានតួខ្លួន( អត្តវាទ) ។

## ប្រភពនៃក្តីទុក្ខសោកក្នុងលោក

ព្រះពុទ្ធសាសនាមានលក្ខណៈពិសេសម្យ៉ាង ក្នុងដំណើរប្រវត្តិសាស្ត្រនៃការគិតរបស់មនុស្ស ថាជាសាសនាដែលបដិសេធការមានប្រាកដនៃវិញ្ញាណ អត្តា ឬតួខ្លួន។ តាមពាក្យទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ជំនឿដែលថាមានតួខ្លួននេះជាជំនឿដែលខុស កើតចេញពីការស្រមើស្រមៃ ដែលមិនត្រូវជាមួយនឹងការពិត និងបង្កឱ្យកើតការយល់ខុសថា "ខ្លួនយើង"និង"របស់យើង" បង្កឱ្យកើតចំណង់ដែលឃើញដល់ប្រយោជន៍ផ្ទាល់ខ្លួន សេចក្តីស្រេកឃ្លាន ការប្រកាន់មាំ ការខឹងក្រោធ ការព្យាបាទ ការតម្កើងខ្លួន ការប្រកាន់ខ្លួន ការឈ្លក់វង្វេងនឹងតួខ្លួន រហូតដល់កិលេសាសវៈទាំងឡាយទាំងពួងនៅក្នុងលោក រាប់តាំងពីទំនាស់រវាងបុគ្គល រហូតដល់សង្គ្រាមរវាងជាតិនិមួយៗ។ សរុបមកថា អំពើអាក្រក់ទាំងឡាយទាំងពួងនៅក្នុងលោក សុទ្ធសឹងមានប្រភពកើតចេញមកពីការយល់ខុសនេះឯង។

# មនុស្សបង្កើតព្រះជាម្ចាស់

ក្នុងចិត្តរបស់មនុស្សមានការគិតដែលកប់ជ្រៅ(រហូតយើងមិនទាំងដឹងថាវាមានថែមទៀតផង)២ប្រការគឺៈ

១. គំនិតដែលត្រូវការការពារខ្លួនឯង

២. គំនិតដែលចង់រក្សាខ្លួនឯង។

តាមរយៈការគិតចង់ការពារខ្លួនឯងនេះ ទើបមនុស្សបានបង្កើតព្រះឡើងមក ដើម្បីឱ្យខ្លួនបានពឹងពាក់អាស្រ័យនិងជួយការពារខ្លួន ឱ្យរួចចាកផុតពីទុក្ខភ័យ និងដើម្បីភាពរឹងមាំរបស់ខ្លួនផ្ទាល់ ប្រដូចទៅនឹងទារកដែលត្រូវពឹងពាក់អាស្រ័យមាតាបិតារបស់ខ្លួនដូច្នោះដែរ។ រីឯគំនិតនៅក្នុងប្រការទីពីរដែលគិតចង់រក្សាខ្លួនឯងនោះ មនុស្សបានបង្កើតនូវផ្នត់គំនិតថាមានវិញ្ញាណឬអាត្ម័នដែលមិនចេះស្លាប់(អមតៈ) មានជីវិតនៅអស់កាលជានិច្ច ដោយអាស្រ័យហេតុមានអវិជ្ជា ភាពទន់ជ្រាយ ការភ័យខ្លាច និងចំណង់នេះឯង ទើបមនុស្សត្រូវការវត្ថុទាំង២យ៉ាងនេះ មកជួយលួងលោមចិត្ត និងបានចងចិត្តជាប់ជាមួយនឹងវត្ថុទាំង២នេះ យ៉ាងរឹងមាំរហូតងើបមុខលែងរួច។

ឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ មិនគាំទ្រឱ្យមានអវិជ្ជា ភាពទន់ជ្រាយ ការភ័យខ្លាច និងចំណង់ទាំងនេះឡើយ ប៉ុន្តែផ្ទុយទៅវិញ

គឺមានគោលបំណងដើម្បីដឹកនាំមនុស្ស ឱ្យបានយល់ច្បាស់នូវសេចក្តីពិត ដោយការកម្ចាត់និងបំផ្លាញនូវសភាវៈទាំងនេះ ប្រភេទជីកឫសដកគល់ចោលតែម្តង។ តាមគោលការណ៍របស់ព្រះពុទ្ធសាសនា គំនិតដែលថាមានព្រះជាម្ចាស់និងមានអត្តានេះ ជាគំនិតដែលខុស( មិច្ឆាទិដ្ឋិ) និងសោះសូន្យទទេឥតប្រយោជន៍ ទោះបីថាផ្នត់គំនិតទាំងនេះ បានវិវឌ្ឍក្លាយមកជាទ្រឹស្តីហើយក្តី តែក៏សុទ្ធតែជាការស្រមើស្រមៃដែលល្អិតសុខុម និងពិបាកក្នុងការកែប្រែ។ ផ្នត់គំនិតទាំងនេះ បានកប់ជ្រៅទៅក្នុងចិត្តរបស់មនុស្ស ជាអ្វីដែលមនុស្សមានភាពស្និទស្នាលជាមួយ រហូតលែងត្រូវការចង់ដឹង ចង់ឮ និងចង់យល់នូវទ្រឹស្តីទាំងឡាយណា ដែលផ្ទុយទៅនឹងគំនិតទាំងនេះ។

## ធម៌បញ្ច្រាសលោកិយ

ព្រះពុទ្ធជាម្ចាស់ទ្រង់បានជ្រាបនូវរឿងទាំងនេះយ៉ាងច្បាស់ ហេតុដូច្នេះហើយទើបបានជាព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ព្រះធម៌គឺពាក្យទូន្មានរបស់ព្រះអង្គមានលក្ខណៈ "បញ្ច្រាសចរន្តលោកិយ" (បដិសោតគាមិ) ពោលគឺផ្ទុយទៅនឹងចរន្តនៃការប្រាថ្នាចង់បាន ដែលប្រារព្ធចំពោះតួខ្លួនរបស់មនុស្ស។ ជាឧទាហរណ៍ជាក់ស្តែង នៅក្នុងគម្ពីរដែលនិយាយអំពីព្រះរាជជីវប្រវត្តិរបស់ព្រះបរមសាស្តាចារ្យបានបញ្ជាក់ថា នៅរយៈពេល

៤សប្តាហ៍បន្ទាប់អំពីការត្រាស់ដឹងរបស់ព្រះអង្គ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់គង់នៅក្រោមដើមជ្រៃមួយដើម ហើយទ្រង់រំពឹងនៅក្នុងព្រះទ័យរបស់ព្រះអង្គថា "យើងបានត្រាស់ដឹងនូវសច្ចធម៌នេះហើយ ដែលជាសច្ចធម៌ដ៏ជ្រាលជ្រៅ ល្អិតសុខុម ពិបាកក្នុងការឃើញច្បាស់ ពិបាកក្នុងការស្វែងយល់... ជនជាបណ្ឌិតប៉ុណ្ណោះទើបអាចយល់បាន... មនុស្សទាំងឡាយ ដែលមានកិលេសគ្របសង្កត់ និងត្រូវរួបរឹតទៅដោយភាពងងឹតគឺអវិជ្ជា នឹងមិនអាចមើលឃើញនូវសច្ចធម៌ ដែលជាធម៌បញ្ច្រាសចរន្តលោក មានភាពឧត្តុងឧត្តម ជ្រាលជ្រៅ ប្រណីតសុខុម និងពិបាកក្នុងការយល់ច្បាស់នេះបានឡើយ"។ បន្ទាប់ពីនោះ ព្រះអង្គបានទ្រង់ប្រៀបធៀបលោកទាំងមូលទៅនឹងស្រះឈូកថា នៅក្នុងស្រះឈូកមួយ មានផ្កាឈូកខ្លះស្ថិតនៅក្រោមទឹក ផ្កាឈូកខ្លះស្ថិតនៅស្មើទឹក ហើយផ្កាឈូកខ្លះទៀតផុសឡើងមកផុតអំពីផ្ទៃទឹក ក្នុងលំនាំដូចគ្នានេះដែរ លើលោកនេះមានមនុស្សដែលមានបញ្ញាស្មារតី ការយល់ដឹងនិងមានការអប់រំមកខុសៗគ្នា។ ហេតុដូច្នេះ ក៏ប្រហែលជានឹងមានខ្លះដែលអាចយល់នូវសច្ចធម៌នេះបាន។ ក្រោយពីទ្រង់មានព្រះតម្រិះយ៉ាងដូច្នេះហើយ ទើបទ្រង់សម្រេចព្រះទ័យដែលនឹងសម្តែងនូវសច្ចធម៌នោះ។

ធម៌ដែលនិយាយអំពីអនត្តា និងការមិនមានតួខ្លួននេះមានការពាក់ព័ន្ធទៅនឹងការវិភាគនូវបញ្ចក្ខន្ធ( ខន្ធ៥) និងសភាវៈដែលអាស្រ័យនូវគ្នានឹងគ្នាកើតឡើង( បដិច្ចសមុប្បាទ) ។

## វិភាគខន្ធ៥

ដូចដែលបានរៀបរាប់មកនៅខាងដើម ក្នុងជំពូកដែលនិយាយទាក់ទងទៅនឹងអរិយសច្ចៈប្រការទី១( ទុក្ខ) នោះរួចមកហើយថា អ្វីដែលយើងនាំគ្នាហៅថាជាសត្វបុគ្គល ធាតុពិតគឺគ្រាន់តែជាការរួមបញ្ចូលគ្នានៃខន្ធ៥ប៉ុណ្ណោះ ។ ប្រសិនបើនាំខន្ធ៥នេះមកវិភាគ និងត្រួតពិនិត្យឱ្យបានល្អិតល្អន់ ក៏មិនមានអ្វីផ្សេងដែលល្មមអាចឱ្យប្រកាន់មាំបានថាជា "យើង" "អាត្មន" "តួខ្លួន" ឬថាជាខ្លឹមសារដែលឋិតថេរ មិនមានការប្រែប្រួលនោះឡើយ ហើយនេះជាវិធីអធិប្បាយតាមបែបវិភាគ ដែលអាចយកមកប្រើជាមួយនឹងគោលធម៌បដិច្ចសមុប្បាទ ដែលជាការប្រើវិធីអធិប្បាយតាមបែបវិភាគ ។ ដូច្នេះអាស្រ័យតាមគោលការណ៍នេះក៏មិនមានអ្វីនៅក្នុងលោកដែលមានលក្ខណៈពេញលេញបរិបូរ ។ អ្វីៗគ្រប់យ៉ាងគ្រាន់តែជាហេតុនិងបច្ច័យ ដែលអាស្រ័យនូវគ្នាទៅវិញទៅមកតែប៉ុណ្ណោះ នេះគឺទ្រឹស្តីសម្ព័ន្ធភាពរបស់ព្រះពុទ្ធសាសនា ។

# សភាវៈដែលកើតព្រោះហេតុ(បដិច្ចសមុប្បាទ)

មុនដែលយើងនឹងឈានចូលទៅដល់ការអធិប្បាយវែកញែកអំពីរឿង"អនត្តា"យ៉ាងពិតប្រាកដនោះ ក៏អាចនឹងជាប្រយោជន៍ ប្រសិនបើយើងបានដឹងនូវគោលធម៌ខ្លះៗទាក់ទងទៅនឹងបដិច្ចសមុប្បាទ។ គោលធម៌ទាក់ទងទៅនឹងបដិច្ចសមុប្បាទនេះ មានពាក្យអធិប្បាយដោយសង្ខេបចំនួន៤បន្ទាត់ដូចខាងក្រោមនេះ

- ពេលមានសភាវៈនេះ ទើបបណ្ដាលឱ្យមានសភាវៈនោះ (ឥមស្មឹ សតិ ឥទំ ហោតិ)។

- ពេលសភាវៈនេះកើត ទើបបណ្ដាលឱ្យសភាវៈនោះកើត (ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ)។

- ពេលសភាវៈនេះមិនមាន សភាវៈនោះក៏មិនមាន(ឥមស្មឹ អសតិ ឥទំ ន ហោតិ)។

- ពេលសភាវៈនេះរលត់ សភាវៈនោះក៏រលត់(ឥមស្ស និរោធា ឥទំ និរុជ្ឈតិ)។

ដោយអាស្រ័យគោលការណ៍នៃហេតុនិងបច្ច័យ មានសម្ព័ន្ធភាពរវាងគ្នានឹងគ្នា និងអាស្រ័យនូវគ្នានឹងគ្នាទៅវិញទៅមក និងការបន្តភ្ជាប់របស់ជីវិតទាំងអស់ រួមទាំងការរលត់ទៅនៃសភាវៈទាំងនោះ ទើបមាន

ពាក្យអធិប្បាយរំលែកញែកព្រះសូត្រសង្ខេបហៅថា បដិច្ចសមុប្បាទ (ការអាស្រ័យនូវគ្នានឹងគ្នាកើតឡើង) ដែលប្រកបទៅដោយអង្គ១២ ប្រការគឺៈ

១. ព្រោះមានអវិជ្ជា(ការមិនដឹង)ជាហេតុបច្ច័យ ទើបមានកម្ម (ការប្រព្រឹត្តធ្វើនូវអំពើផ្សេងៗ)ដែលប្រកបដោយចេតនា ឬសង្ខារ (អវិជ្ជាបច្ចយា សង្ខារា)

២. ព្រោះមានកម្មដែលប្រកបដោយចេតនាជាហេតុបច្ច័យ ទើបមានវិញ្ញាណ(សង្ខារបច្ចយា វិញ្ញាណំ)

៣. ព្រោះមានវិញ្ញាណជាហេតុបច្ច័យ ទើបមាននាម និង រូប (វិញ្ញាណបច្ចយា នាមរូបំ)

៤. ព្រោះមាននាមរូបជាហេតុបច្ច័យ ទើបមានអាយតនៈទាំង៦ (គឺអាយតនៈទាំងដែលជារូបធម៌និងនាមធម៌) (នាមរូបបច្ចយាសឡាយតនំ)

៥. ព្រោះមានអាយតនៈជាហេតុបច្ច័យ ទើបមានសម្ផស្ស(ការពាល់ត្រូវ) (សឡាយតនបច្ចយា ផស្សោ)

៦. ព្រោះមានសម្ផស្សជាហេតុបច្ច័យ ទើបមានការទទួលដឹងនូវអារម្មណ៍ផ្សេងៗ(វេទនា) (សម្ផស្សបច្ចយា វេទនា)

៧. ព្រោះមានការទទួលដឹងនូវអារម្មណ៍ជាហេតុបច្ច័យ ទើបមានតណ្ហា(សេចក្តីប្រាថ្នាចង់បាន) (វេទនាបច្ចយា តណ្ហា)

៨. ព្រោះមានតណ្ហា(សេចក្តីប្រាថ្នាចង់បាន)ជាហេតុបច្ច័យ ទើបមានការប្រកាន់មាំ(ឧបាទាន) (តណ្ហាបច្ចយា ឧបាទានំ)

៩. ព្រោះមានការប្រកាន់មាំជាហេតុបច្ច័យ ទើបមានភព(ភាពជានេះជានោះ) (ឧបាទានបច្ចយា ភវោ)

១០. ព្រោះមានភពជាហេតុបច្ច័យ ទើបមានការកើត(ជាតិ) (ភវបច្ចយា ជាតិ)

១១. ព្រោះមានការកើតជាហេតុបច្ច័យ ទើបមានការចាស់(ជរា) និងការស្លាប់(មរណៈ) (ជាតិបច្ចយា ជរាមរណំ)

១២. ព្រោះមានការចាស់និងការស្លាប់ជាហេតុបច្ច័យ ទើបមានសេចក្តីសោកសៅ ខ្សឹកខ្សួល និងសេចក្តីទុក្ខ ។ល។

នេះគឺចម្លើយដែលថា ជីវិតកើតឡើងតាំងនៅ និងប្រព្រឹត្តទៅបានយ៉ាងដូចម្តេច ប្រសិនបើយើងនាំគ្នាមកពិចារណា ទៅដល់ព្រះសូត្រនេះដោយបដិលោម(បញ្ច្រាស) ក៏នឹងមកដល់ចំណុច ដែលជាទីរលត់ទៅនៃសម្ព័ន្ធភាពរបស់សភាវធម៌ទាំងនេះគឺៈ ព្រោះអវិជ្ជារលត់ទៅដោយមិនសេសសល់ ទើបកម្មដែលប្រកបដោយចេតនាឬសង្ខាររលត់ ព្រោះកម្មដែលប្រកបដោយចេតនាឬសង្ខាររលត់ ទើបវិញ្ញាណរលត់..... ព្រោះការ

កើតរលត់ទៅ(មិនមានការកើត) ទើបការចាស់ ការឈឺ ការស្លាប់ និងសេចក្តីទុក្ខសោកផ្សេងៗ។ល។ មិនមាន។

## គន្លងនៃវដ្តៈ

គប្បីចងចាំទុកថា អង្គប្រកបនិមួយៗនៃបដិច្ចសមុប្បាទ សុទ្ធសឹងជាបច្ច័យ(បដិច្ចសមុប្បន្ន) និងជាហេតុ(បដិច្ចសមុប្បាទ) រវាងគ្នានឹងគ្នា មានការទាក់ទងគ្នា និងអាស្រ័យនូវគ្នាទៅវិញទៅមក គ្មានអង្គប្រកបណាមួយមានលក្ខណៈពេញលេញឬជាឥស្សរៈឡើយ។ ដោយអាស្រ័យហេតុនេះ ទើបព្រះពុទ្ធសាសនាមិនព្រមទទួលស្គាល់ថាមានបឋមហេតុ(ហេតុដំបូងបំផុត) ដូចដែលបានអធិប្បាយរួចមកហើយនៅខាងដើម។ បដិច្ចសមុប្បាទនេះ បុគ្គលគប្បីយល់ឱ្យបានច្បាស់ថា មានលក្ខណៈជាវដ្តចក្រ នឹងថាមានលក្ខណៈប្រទាក់គ្នាដូចជាច្រវាក់នោះ គឺមិនមែនឡើយ។

បញ្ហាទាក់ទងទៅនឹង"ឥស្សរភាពនៃការប៉ងប្រាថ្នា"(Free Will) ជំនឿដែលថាគ្រប់គ្នាមានអំណាចដែលនឹងសម្រេចចិត្តបានយ៉ាងឥស្សរៈទង្វើផ្សេងៗរបស់មនុស្ស គឺមិនបានត្រូវកំណត់ទុកជាមុនដោយព្រះជាម្ចាស់នោះឡើយ ជាចំណុចសំខាន់មួយ៉ាងនៅក្នុងផ្នត់គំនិតនិងទ្រឹស្តីផ្នែកទស្សនវិជ្ជារបស់លោកខាងលិច។ តែបើនិយាយតាមគោលការណ៍របស់

បដិច្ចសមុប្បាទវិញនោះ បញ្ហានេះមិនធ្លាប់កើតឡើងហើយនឹងមិនអាចកើតឡើងបានឡើយ ព្រោះនៅពេលដែលគ្រប់សភាវៈទាំងអស់មានទំនាក់ទំនងគ្នា ជាហេតុជាបច្ច័យអោយដល់គ្នានឹងគ្នា ហើយពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកយ៉ាងដូច្នេះ តើការប្រាថ្នាតែមួយ៉ាងនឹងមានឥស្សរៈបានយ៉ាងដូចម្តេច? ការប្រាថ្នានេះរួមនៅក្នុងខន្ធទី៤(សង្ខារក្ខន្ធ) ដែលដូចគ្នាទៅនឹងការគិតផ្សេងៗផងដែរ គឺជាសភាវៈដែលមានហេតុមានបច្ច័យ(បដិច្ចសមុប្បាទ)។ អ្វីដែលយើងហៅថាជា"ឥស្សរភាព" នៅក្នុងលោកនេះ តាមពិតទៅក៏គឺជាអ្វីដែលមិនមានឥស្សរៈយ៉ាងពេញលេញនោះឡើយ ព្រោះជាសភាវៈដែលមានហេតុបច្ច័យ និងពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក។ មានការប្រាថ្នាដែលជាហេតុជាបច្ច័យ និងមានសម្ព័ន្ធភាពរវាងគ្នានឹងគ្នា តែមិនមានការប្រាថ្នាដែលមិនមានហេតុបច្ច័យ និងមានលក្ខណៈពេញលេញបរិបូរដោយខ្លួនឯងនោះឡើយ។ ដោយសេចក្តីពិតទៅ គឺមិនមានអ្វីដែលមានលក្ខណៈពេញលេញបរិបូរនៅក្នុងលោកយើងនេះឡើយ មិនថាទាំងខាងផ្នែករាងកាយនិងចិត្តគំនិត(រូបធម៌ និងនាមធម៌) ព្រោះថាអ្វីៗគ្រប់យ៉ាងសុទ្ធសឹងមានហេតុបច្ច័យ និងអាស្រ័យនូវគ្នាទៅវិញទៅមក។ ប្រសិនបើ"ការប្រាថ្នាដោយឥស្សរៈ" សំដៅដល់ការប្រាថ្នាដែលមានឥស្សរៈពីហេតុបច្ច័យ(មិនមានហេតុបច្ច័យ) ការប្រាថ្នាបែបនេះប្រាកដណាស់ គឺមិនអាចកើតមានបានឡើយ ត្បិតថាគ្រប់

សភាវធម៌ទាំងអស់ រមែងកើតឡើងដោយមានហេតុបច្ច័យ និងអាស្រ័យនូវគ្នាទៅវិញទៅមក។ ហេតុដូច្នេះ តើការប្រាថ្នាដែលយើងគិតថាមានឥស្សរៈពីហេតុនិងបច្ច័យ នឹងកើតឡើងបានយ៉ាងដូចម្ដេច?។ ផ្នត់គំនិតរឿង"ឥស្សរភាពនៃការប៉ងប្រាថ្នា"នេះក៏ដូចគ្នា ជារឿងដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគំនិតដែលថាមានព្រះជាម្ចាស់ វិញ្ញាណឬតួខ្លួន។ មិនត្រឹមតែអ្វីដែលយើងហៅថា"ឥស្សរភាពនៃការប៉ងប្រាថ្នា"នេះប៉ុណ្ណោះទេ ដែលមិនមានឥស្សរភាព សូម្បីតែផ្នត់គំនិតគ្រប់យ៉ាងដែលជឿថា "មានការប៉ងប្រាថ្នាដោយឥស្សរៈ" ក៏សុទ្ធតែមិនមានឥស្សរៈពីហេតុបច្ច័យដូចគ្នាទាំងអស់។

ផ្អែកទៅតាមគោលការណ៍នៃបដិច្ចសមុប្បាទ គំនិតថាមានខ្លឹមសារដែលគង់វង្សឋិតថេរជាអមតៈ នៅក្នុងខ្លួនមនុស្សឬនៅខាងក្រៅខ្លួនមនុស្ស មិនថាជាអ្វីដែលយើងហៅថា "អាត្មន" "ខ្លួនយើង" "វិញ្ញាណ" ឬ "អត្តា"ក្ដី ចាត់ថាជាការយល់ឃើញខុស។ វាគ្រាន់តែជាការប្រើនូវអារម្មណ៍ស្រមើស្រមៃនឹកគិតដោយមនុស្សខ្លួនឯងប៉ុណ្ណោះ។ អ្វីដែលបានពោលរៀបរាប់មកទាំងប៉ុន្មាននេះ គឺជាគោលការណ៍របស់ព្រះពុទ្ធសាសនា ដែលនិយាយស្ដីអំពី"អនត្តា" ការមិនមានវិញ្ញាណ ឬមិនមានតួខ្លួន។

# សច្ចៈ២ប្រការ

ដើម្បីជៀសវាងនូវការសង្ស័យ ទើបសូមលើកយកមកបង្ហាញនៅក្នុងទីនេះតែម្តងថាសច្ចៈមាន២ប្រការគឺ ការពិតដោយសន្មតិ(សម្មតិសច្ច) និងការពិតដោយបរមត្ថ(បរមត្ថសច្ច សំស្ក្រឹតថា បរមាថិសត្យ)។ ខណៈពេលយើងប្រើពាក្យសម្រាប់និយាយនៅក្នុងជីវិតប្រចាំថ្ងៃដូចជា "ខ្ញុំ" "អ្នក" "សត្វ" "បុគ្គល"។ល។ យើងឈ្មោះថាមិនបាននិយាយកុហកព្រោះហេតុមិនមានតួខ្លួនឬសត្វបុគ្គលនោះឡើយ ប៉ុន្តែយើងគឺនិយាយទៅតាមការពិតនៃការសន្មតរបស់មនុស្សលោក។ ដោយឡែកសម្រាប់ផ្លូវបរមត្ថវិញនោះគឺមិនមាន "យើង" ឬ "សត្វ" អ្វីទាំងអស់។ គ្រប់យ៉ាងគ្រាន់តែជាការសន្មត ដូចដែលមានសម្តែងទុកមកនៅក្នុងមហាយានសូត្រាលង្ការថា"បុគ្គល(សំ.បុទ្គល)ចាត់ថាមាន ក៏អាស្រ័យតែដោយបញ្ញត្តិប៉ុណ្ណោះ(ដោយសន្មតិថាមាននៅ) តែតាមការពិត មិនមានបុគ្គលនោះឡើយ"។

ការបដិសេធនូវការមានប្រាកដនៃអាត្មននេះ ជាគោលការណ៍រួមដែលមាននៅក្នុងជំនឿតាំងតែគ្រាដំបូង ទាំងខាងផ្នែកហីនយាននិងមហាយាន ដូច្នេះទើបមិនមានហេតុផលណាមួយដែលនឹងបដិសេធបានថា ជំនឿរបស់ពុទ្ធសាសនិកទាំង២ពួក ដែលមានលក្ខណៈដូចគ្នានៅ

ត្រង់ចំណុចនេះ ជាជំនឿដែលភ្លាំងភ្លាត់ចេញអំពីឱវាទទូន្មានដ៏ពិតប្រាកដរបស់អង្គព្រះសម្មាសម្ពុទ្ធនោះឡើយ ។

## អ្នកស្វែងរក

មានរឿងដែលគួរឱ្យយើងចាប់អារម្មណ៍ថា ក្នុងរយៈពេលកន្លងទៅមិនយូរប៉ុន្មាននេះ មានអ្នកប្រាជ្ញមួយចំនួនបានទទួលបរាជ័យ ពេលដែលពួកគេព្យាយាមដើម្បីបញ្ចូលនូវគំនិតដែលយល់ថា "មានតួខ្លួន"នេះចូលទៅក្នុងពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ទាំងដែលវាគឺជារឿងផ្ទុយទៅនឹងខ្លឹមសារដ៏ពិតប្រាកដរបស់ព្រះពុទ្ធសាសនា។ ពួកអ្នកប្រាជ្ញទាំងនោះសុទ្ធសឹងជាអ្នកមានការគោរព ស្ងើចសរសើរចំពោះព្រះពុទ្ធជាម្ចាស់និងឱវាទទូន្មានរបស់ព្រះអង្គ ទើបបានងាកមកគោរពរាប់អានព្រះពុទ្ធសាសនា ប៉ុន្តែអ្វីដែលគួរអោយឆ្ងល់នោះគឺថា លោកទាំងនោះត្រលប់ជាមិនព្រមគិតថា ព្រះពុទ្ធជាម្ចាស់ដែលពួកខ្លួនចាត់ទុកថាជាអ្នកមានការប្រព្រឹត្តដ៏បរិសុទ្ធនិងប្រសើរខ្ពង់ខ្ពស់បំផុតនោះ ទ្រង់បានបដិសេធថាមានអាត្មន(ប៉ុន្តែជាអ្វីដែលពួកខ្លួនត្រូវការបំផុតនោះ)។ ហេតុដូច្នេះហើយ ទើបមនុស្សទាំងនោះព្យាយាមរកអំណះអំណាងពីឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ដើម្បីនាំមកគាំទ្រនូវតម្រូវការដែលថាមានសភាវៈជាអមតៈ ហើយអ្វីដែលជាអមតៈដែលពួកគេបានបង្កើត

ឡើងមកដោយខ្លួនឯងនេះទៀតសោត គឺមិនមែនអត្តាតូចៗដែលមាននៅក្នុងសត្វ បុគ្គលនោះឡើយ តែគឺអត្តាធំ ។

អ្នកដែលជឿថាមានអាត្ម័នឬតួខ្លួននេះ ការពិតទៅគួរតែនិយាយចេញមកដោយត្រង់ៗថា ខ្លួនមានជំនឿយ៉ាងដូច្នោះ ឬបើមិនដូច្នោះទេក៏អាចនឹងនិយាយតែម្តងទៅថា ព្រះពុទ្ធជាម្ចាស់ពិតជាមានកំហុសយ៉ាងធំ ដែលទ្រង់បានបដិសេធថាមិនមានអាត្ម័ន តែជាការមិនសមគួរសោះឡើយ ដែលនរណាម្នាក់នឹងនាំយកនូវអ្វី ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានបដិសេធហើយនោះ មកបញ្ចូលទុកនៅក្នុងព្រះពុទ្ធសាសនា។ ទាំងនេះក៏សុទ្ធសឹងជាព្រឹត្តិការណ៍ ដែលធ្លាប់កើតមានមកជាហូរហែ នៅក្នុងប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ព្រះពុទ្ធសាសនា និងដែលមានចារឹកទុកនៅក្នុងគម្ពីរជាន់ដើមមួយចំនួន។

សាសនាផ្សេងៗដែលជឿថាមានព្រះជាម្ចាស់ និងមានវិញ្ញាណនោះ នឹងមិនបិទបាំងនូវរឿងទាំងពីរយ៉ាងនេះ ទុកជាអាថិកំបាំងឡើយផ្ទុយទៅវិញពួកគេបានប្រកាសចេញមកយ៉ាងត្រង់ៗ និងម្តងហើយម្តងទៀត ដោយការប្រើនូវពាក្យពេចន៍យ៉ាងពិរោះរណ្តំ។ ដូចគ្នានេះដែរប្រសិនបើព្រះពុទ្ធជាម្ចាស់ទ្រង់ព្រមទទួលស្គាល់នូវផ្នត់គំនិតដែលថា មានព្រះជាម្ចាស់ឬមានវិញ្ញាណទាំងពីរយ៉ាងនេះ ដូចដែលគ្រប់សាសនាបានទទួលស្គាល់ និងចាត់ទុកថាមានសារៈសំខាន់បំផុតនោះ ព្រះអង្គប្រាកដជា

ទ្រង់ប្រកាសចេញមកឱ្យសាធារណជនបានដឹង ដូចដែលទ្រង់បានត្រាស់ទៅដល់អ្វីៗផ្សេងដទៃទៀត។ ព្រះអង្គច្បាស់ជាមិនទ្រង់ទុកឱ្យនៅជាអាថិកំបាំង ដើម្បីឱ្យអ្នកដទៃមកស្រាវជ្រាវឃើញ បន្ទាប់ពីទ្រង់បរិនិព្វានទៅជាង២៥០០ឆ្នាំហើយនោះឡើយ។

## ខ្លាចនូវអ្វីដែលមិនគួរខ្លាច

មនុស្សទាំងឡាយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ជាមួយនឹងឱវាទទូន្មានរឿង"អនត្តា"របស់ព្រះពុទ្ធជាម្ចាស់ ទាំងនេះដោយអាស្រ័យគំនិតដែលថា អត្តាដែលខ្លួនកំពុងស្រមើស្រមៃថាខ្លួនឯងមាននៅនេះ កំពុងត្រូវបានបំផ្លាញ ហើយព្រះពុទ្ធអង្គទ្រង់ជ្រាបច្បាស់ណាស់អំពីខនេះ។

សម័យមួយ មានភិក្ខុមួយរូបបានទូលសួរព្រះពុទ្ធអង្គថា "បពិត្រព្រះអង្គដ៏ចម្រើន! មានករណីរបស់បុគ្គលណាខ្លះដែរឬទេ នៅពេលដែលមិនប្រទះឃើញថា មានសភាវៈដែលឋិតថេរនៅក្នុងតួខ្លួនហើយ កើតនូវសេចក្ដីទុក្ខទោមនស្សនោះ?"

"ម្នាលភិក្ខុ! ករណីដូច្នេះពិតជាមាន"។ បន្ទាប់មកទ្រង់ត្រាស់ថា "គឺមានបុរសម្នាក់មានការយល់ឃើញយ៉ាងដូច្នេះថា "ចក្រវាលគឺអាត្មន ហេតុដូច្នេះយើងនឹងក្លាយទៅជាអាត្មនបន្ទាប់អំពីការស្លាប់ អាត្មនជាសភាវៈគង់វង្ស ឋិតថេរជានិរន្តរ៍ និងមិនមានការផ្លាស់ប្ដូរប្រែប្រួល

ហើយខ្លួនយើងក៏នឹងតាំងនៅយ៉ាងដូច្នោះ អស់កាលជានិរន្តរ៍"។ តមក បុរសម្នាក់នោះបានឮថា តថាគតឬសាវ័កទាំងឡាយបង្រៀនអំពីការមិនមានតួខ្លួន ដែលសំដៅកម្ចាត់បង់នូវការយល់ឃើញ ដែលកើតចេញពីការស្រមើស្រមៃទាំងឡាយប្រភេទជីកឫសដកគល់... បង្រៀនគោលការណ៍ដែលសំដៅរំលត់បង់នូវតណ្ហា... សំដៅស្រាយចេញនូវតម្រេក និងធ្វើឱ្យជាក់ច្បាស់នូវទីបំផុតនៃសេចក្ដីទុក្ខ(និព្វាន) ទើបបុរសម្នាក់នោះគិតថា "យើងនឹងត្រូវបានបំផ្លាញ យើងនឹងត្រូវបានកម្ចាត់ ហើយនឹងមិនមានយើងតទៅទៀតឡើយ"។ ដោយហេតុនេះ បុរសនោះក៏ដល់នូវសេចក្ដីសោកសៅ ព្រួយបារម្ភ ខ្វាយខ្វល់ ស្រក់ទឹកភ្នែក ទះដើមទ្រូង និងវង្វេងវង្វាយ។ ម្នាលភិក្ខុ! នេះឯងគឺករណីរបស់អ្នកដែលបានទទួលនូវសេចក្ដីទុក្ខទោមនស្សនៅពេលដែលមិនប្រទះឃើញថា មានសភាវៈដែលឋិតថេរនៅក្នុងតួខ្លួន"។

ក្នុងទីឯទៀត ព្រះពុទ្ធជាម្ចាស់បានទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! គំនិតដែលថា"យើងនឹងមិនមាន"នេះ គឺបាននាំមកនូវភាពតក់ស្លុតសម្រាប់សត្វលោកទាំងឡាយ ដែលមិនទាន់យល់ច្បាស់នូវសច្ចធម៌"។

មានអ្នកដែលព្យាយាមស្វែងរក"អត្តា" នៅក្នុងព្រះពុទ្ធសាសនាបានពោលជំទាស់ថា ព្រះពុទ្ធជាម្ចាស់ទ្រង់ពិតជាបានត្រាស់ថា រូប វេទនា

សញ្ញា សង្ខារ និងវិញ្ញាណមានពិត និងបានត្រាស់បន្ថែមទៀតថាសភាវៈទាំងឡាយនេះ មិនមានសភាវៈណាមួយដែលមានតួខ្លួនក៏ពិតមែន ប៉ុន្តែព្រះអង្គមិនបានទ្រង់ត្រាស់ឡើយថា មិនមានអត្តានៅក្នុងខ្លួនមនុស្សឬនៅក្នុងទីឯទៀតក្រៅអំពីខន្ធ៥។

ការពោលជំទាស់នេះស្តាប់ទៅមិនគួរទទួលយកបាន ដោយហេតុផល២ប្រការគឺ

១. ហេតុផលប្រការទីមួយ នៅក្នុងព្រះធម៌ដែលជាឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ មនុស្សប្រកបឡើងដោយខន្ធ៥ និងមិនមានអ្វីផ្សេងទេក្រៅពីនេះ។ ព្រះអង្គមិនធ្លាប់ទ្រង់ត្រាស់ឡើយថា នៅក្នុងមនុស្សឬសត្វ មានអ្វីដែលផ្សេងក្រៅអំពីខន្ធ៥។

២. ហេតុផលប្រការទី២ ព្រះពុទ្ធជាម្ចាស់ជានិច្ចជាកាល ទ្រង់បដិសេធយ៉ាងដាច់ខាតទៅនឹងទស្សនៈថាមានអាត្មន វិញ្ញាណ អត្តា ឬតួខ្លួននៅក្នុងសត្វបុគ្គល ក្រៅពីសត្វបុគ្គល ឬនាទីណាមួយនៅក្នុងចក្រវាល ក្រៅចក្រវាល ដូចឧទាហរណ៍ដែលនឹងលើកយកមកសម្តែងបញ្ជាក់នៅខាងក្រោមនេះ។

# វិភាគន័យក្នុងព្រះធម្មបទ

ក្នុងព្រះធម្មបទមានគាថាចំនួន៣គាថា ដែលមានសារៈសំខាន់យ៉ាងក្រៃលែង និងជាគោលនៃឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ គឺគាថាទី៥ គាថាទី៦ និងគាថាទី៧ បទទី២០ (ឬគាថាទី ២៧៧, ២៧៨,និង ២៧៩)។ ពីរគាថាដំបូងថា "សង្ខារទាំងពួងមិនទៀង (សព្វេ សង្ខារា អនិច្ចា)" និង "សង្ខារទាំងពួងជាទុក្ខ (សព្វេ សង្ខារា ទុក្ខា)"។ គាថាទី៣ ថា "ធម៌ទាំងពួងមិនមានតួខ្លួន (សព្វេ ធម្មា អនត្តា)"។

នៅក្នុងទីនេះ គប្បីសង្កេតឱ្យបានល្អិតល្អន់ថា ក្នុងពីរគាថាដំបូងនោះទ្រង់ប្រើពាក្យថា"សង្ខារា" (សភាវៈទាំងឡាយដែលមានបច្ច័យតាក់តែង)។ ដោយឡែកនៅក្នុងគាថាទី៣នេះ ព្រះអង្គទ្រង់បានប្រើពាក្យថា "ធម្មា"ជំនួសអោយពាក្យថា"សង្ខារា" ហើយព្រោះហេតុអ្វីទើបនៅក្នុងគាថាទី៣នេះទ្រង់មិនប្រើពាក្យថា"សង្ខារា" ដូចនៅក្នុងពីរគាថាដំបូង? ប៉ុន្តែទ្រង់បែជាប្រើពាក្យ"ធម្មា"ជំនួសទៅវិញ?។ ត្រង់នេះឯងគឺជាចំណុចដ៏សំខាន់នៃរឿងទាំងនេះ។

ពាក្យថា"សង្ខារា"សំដៅដល់ខន្ធ៥ គឺសភាវៈទាំងពួងដែលមានបច្ច័យតាក់តែង(កើតឡើងដោយអាស្រ័យហេតុនិងបច្ច័យ) មានការទាក់ទងគ្នា មានសម្ព័ន្ធភាពទៅវិញទៅមក មិនថាសភាវៈនោះជារូប

កាយ(រូបធម៌)ក្តី ឬចិត្ត(នាមធម៌)ក្តី។ ប្រសិនបើព្រះគាថាទី៣ទ្រង់ប្រើពាក្យថា "សង្ខារទាំងពួង(សភាវៈទាំងឡាយដែលមានបច្ច័យតាក់តែង)" ដែរនោះ ម្ល៉េះសមមនុស្សទាំងឡាយប្រហែលជាគិតថា ទុកណាជាសភាវៈដែលមានបច្ច័យតាក់តែងនឹងមិនមានអត្តាក៏ពិតមែន ប៉ុន្តែក៏គង់មានអត្តាដទៃពីសភាវៈដែលមានបច្ច័យតាក់តែង(គឺក្រៅអំពីខន្ធ៥)។ ហេតុដូច្នេះដើម្បីជៀសវាងនូវការយល់ខុសយ៉ាងដូច្នេះ ទើបបានជាទ្រង់ប្រើពាក្យថា "ធម្មា" នៅក្នុងព្រះគាថាទី៣។

ពាក្យថា"ធម្ម" មានអត្ថន័យជ្រាលជ្រៅជាងពាក្យថា"សង្ខារា" ហើយមិនមានស័ព្ទនៅក្នុងព្រះពុទ្ធសាសនាណាមួយ ដែលមានអត្ថន័យជ្រាលជ្រៅនិងទូលំទូលាយជាងស័ព្ទ"ធម្ម"នេះឡើយ។ ពាក្យថា"ធម្ម" មានអត្ថន័យមិនមែនសំដៅត្រឹមតែ សភាវៈដែលមានបច្ច័យតាក់តែងប៉ុណ្ណោះទេ តែនៅរួមទៅដល់ព្រះនិព្វាន ដែលមិនមានបច្ច័យតាក់តែង (ដែលបច្ច័យតាក់តែងមិនបាន) ហើយថែមទាំងជាសភាវៈពេញលេញថែមទៀតផង។ គ្មានសភាវៈណាមួយទោះក្នុងឬក្រៅចក្កវាឡ មិនថាល្អឬអាក្រក់ មានបច្ច័យតាក់តែងឬមិនមានបច្ច័យតាក់តែង ជាសភាវៈដែលមានសម្ព័ន្ធភាពរវាងគ្នានឹងគ្នា ឬមានឥស្សរៈពេញលេញ ដែលមិនរួមនៅក្នុងពាក្យ"ធម្ម"នេះឡើយ។ ដូច្នេះទើបមិនមានអ្វីដែលគួរឱ្យសង្ស័យសម្រាប់ព្រះគាថាដែលថា "ធម៌ទាំងពួងមិនមានតួខ្លួន (សព្វេ ធម្មា

អនត្តា)” គឺមានន័យថា មិនមានតួខ្លួន មិនមានអាត្មន មិនចំពោះតែនៅក្នុងខន្ធ៥ប៉ុណ្ណោះទេ តែនៅសំដៅដល់ការមិនមានទោះនៅក្នុងទីដទៃណាក្រៅអំពីខន្ធ៥ថែមទៀតផង។

បើនិយាយតាមឱវាទទូន្មានផ្នែកខាងថេរវាទ(ហីនយាន) ខនេះមានន័យថា មិនមានអត្តាទាំងនៅក្នុងបុគ្គលឬក្នុងធម៌ទាំងឡាយ។ ព្រះពុទ្ធសាសនាខាងផ្នែកមហាយាន ក៏មានគោលជំហរដូចគ្នាចំពោះចំណុចនេះ ដោយមិនមានភាពខុសប្លែកគ្នាសូម្បីតែបន្តិចណាឡើយ ដូចដែលផ្នែកមហាយានបានគូសបញ្ជាក់ទុកយ៉ាងច្បាស់ថា“ធម្មនៃរាតមយៈ” និង “បុទ្គល-នៃរាតមយៈ”។

## អលគទ្ទូបមសូត្រ

ក្នុងអលគទ្ទូបមសូត្រនៃមជ្ឈិមនិកាយ ព្រះពុទ្ធជាម្ចាស់បានទ្រង់ត្រាស់ដល់បណ្ដាសាវ័កទាំងឡាយរបស់ព្រះអង្គថា “ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរនាំគ្នាទទួលយកទ្រឹស្ដីអត្តា(អត្តាវាទ)ចុះ ប្រសិនបើនៅក្នុងការទទួលស្គាល់នោះមិនបង្កឱ្យកើតការសោកសៅ សេចក្ដីទុក្ខ សេចក្ដីទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត។ ម្នាលភិក្ខុទាំងឡាយ! តែថាអ្នកទាំងឡាយធ្លាប់ឃើញទ្រឹស្ដីអត្តាណា ដែលនៅពេលបុគ្គលទទួល

ស្គាល់ហើយ នឹងមិនបង្កឱ្យកើតទុក្ខ សេចក្ដីសោកសៅ សេចក្ដីទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តខ្លះទេ?"

"មិនធ្លាប់ឃើញឡើយក្រាបទូល"

"ត្រឹមត្រូវហើយភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ! តថាគតផ្ទាល់ក៏ដូចគ្នា គឺមិនធ្លាប់ឃើញនូវទ្រឹស្ដីអត្តាណាមួយ ដែលនៅពេលបុគ្គលទទួលស្គាល់ហើយ នឹងមិនបង្កឱ្យកើតទុក្ខ សេចក្ដីសោកសៅ សេចក្ដីទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្តនោះឡើយ" ។

ប្រសិនបើមានទ្រឹស្ដីអត្តាណាមួយ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ព្រមទទួលស្គាល់ ព្រះអង្គក៏ប្រហែលជាទ្រង់អធិប្បាយទុកមកយ៉ាងពិតប្រាកដ ព្រោះថាព្រះអង្គក៏បានទ្រង់សំណូមពរឱ្យភិក្ខុទាំងឡាយ ព្រមទទួលស្គាល់ទ្រឹស្ដីអត្តាដែលមិនបង្កឱ្យកើតទុក្ខនោះបាន ប៉ុន្តែព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា មិនមានទ្រឹស្ដីអត្តាដូច្នោះ ហើយទ្រឹស្ដីអត្តានេះមិនថាជាទ្រឹស្ដីណាមួយ ទោះមានភាពល្អិតល្អន់ហ្មត់ចត់ប៉ុណ្ណាក៏ដោយចុះ គឺសុទ្ធតែជាទ្រឹស្ដីដែលខុសឆ្គង ហើយកើតចេញពីការស្រមើស្រមៃប៉ុណ្ណោះ ដែលបង្កឱ្យកើតបញ្ហាគ្រប់ប្រភេទ បង្កឱ្យកើតសេចក្ដីសោកសៅ សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខ សេចក្ដីទោមនស្ស សេចក្ដីចង្អៀតចង្អល់ចិត្ត និងសេចក្ដីក្ដៅក្រហាយ ។

នៅក្នុងព្រះសូត្រដដែលនោះ ព្រះពុទ្ធអង្គទ្រង់បានមានព្រះពុទ្ធដីការបន្ថែមទៀតថា "ម្នាលភិក្ខុទាំងឡាយ! ពេលមិនមានអត្តា និងមិនមានសភាវៈអ្វីដែលមានអត្តា ដែលអាចរកឃើញបានយ៉ាងពិតប្រាកដ ទស្សនៈដែលកើតចេញពីសន្និដ្ឋានដែលថា "ចក្កវាឡគឺអាត្ម័ន(វិញ្ញាណ)។ បន្ទាប់អំពីស្លាប់ហើយ យើងនឹងក្លាយជាអាត្ម័នហើយអាត្ម័ននោះ នឹងឋិតថេរគង់វង្ស រឹងមាំ មិនប្រែប្រួល ចំណែកយើងក៏នឹងតាំងនៅយ៉ាងដូច្នោះអស់កាលជានិច្ចនិរន្តរ៍" ទស្សនៈបែបនេះមិនអង្គឹជាទស្សនៈដទៃ ក្រៅតែពីជាទស្សនៈដែលឆោតល្ងង់ទៅហើយមែនទេ?"។

ត្រង់នេះឯងដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សង្កត់យ៉ាងច្បាស់ថា អាត្ម័ន វិញ្ញាណ ឬតួខ្លួនដែលពិតប្រាកដ បុគ្គលមិនអាចជួបប្រទះបានទោះនៅក្នុងទីណាក៏ដោយ ហើយជាភាពឆោតល្ងង់ដែលជឿថា មានសភាវៈយ៉ាងដូច្នោះ។

## អធិប្បាយអំពី "ខ្លួនជាទីពឹងរបស់ខ្លួន"

បណ្តាអ្នកដែលព្យាយាមស្វែងរកអត្តា នៅក្នុងឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ បានអះអាងទៅដល់ឧទាហរណ៍មួយចំនួន ដែលបាននាំគ្នាបកប្រែខុសតាំងពីដំបូង ហើយក្រោយមកក៏បាននាំគ្នាពន្យល់សេចក្តីខុសតាមទៅផងដែរ។ ឧទាហរណ៍មួយដែលគេស្គាល់ច្បាស់គឺបានមកពី

គាថាធម្មបទ(បទទី១២ គាថាទី៤ ឬគាថាទី១០៦) ដែលថា "អត្តា ហិ អត្តនោ នាថោ" ដែលគេបានប្រែថា "ខ្លួនជាម្ចាស់របស់ខ្លួន" ហើយក៏វិភាគន័យថា "អត្តាធំជាម្ចាស់របស់អត្តាតូច"។

ប្រការដំបូង គឺការបកប្រែនេះមានលក្ខណៈមិនត្រឹមត្រូវ "អត្តា" នៅក្នុងទីនេះ មិនបានសំដៅដល់អត្តា ក្នុងន័យដែលជាវិញ្ញាណនោះទេ។ ក្នុងភាសាបាលីពាក្យថា"អត្តា" ជាទូទៅត្រូវបានប្រើជាបុរិសសព្វនាម ឬវិសេសនសព្វនាម អាចនឹងមានការលើកលែងខ្លះ ក៏ចំពោះតែការប្រើនៅក្នុងករណីពិសេស ដូចជាក្នុងលំនាំបកស្រាយអំពីគោលការណ៍ទស្សនវិជ្ជាសម្រាប់ផ្នែកដែលទាក់ទងទៅនឹងទ្រឹស្តីរឿងអត្តា ដូចដែលបានរៀបរាប់រួចមកហើយនៅខាងដើម តែដែលប្រើជាទូទៅដូចនៅក្នុងគាថាព្រះធម្មបទបទទី១២ ក្នុងគាថាដែលលើកមកជាឧទាហរណ៍ខាងដើម និងនៅក្នុងទីដទៃជាច្រើនទៀត "អត្តា"ត្រូវបានប្រើជាបុរិសសព្វនាម ឬវិសេសនសព្វនាម ដែលសំដៅដល់"ខ្លួនខ្ញុំ" "ខ្លួនអ្នក" "ខ្លួនគេ" "បុគ្គល" "បុគ្គលនោះឯង"។

ប្រការបន្ទាប់មកគឺពាក្យថា "នាថោ"។ ពាក្យនេះមិនបានសំដៅដល់"នាយ" ឬ "ម្ចាស់"នោះឡើយ តែគឺសំដៅដល់"ទីពឹង" "គាំទ្រ" "អនុគ្រោះ" "គ្រប់គ្រង"។ ដូចនេះ "អត្តា ហិ អត្តនោ នាថោ" មានន័យយ៉ាងពិតប្រាកដថា "ខ្លួនជាទីពឹងរបស់ខ្លួន" "ខ្លួនត្រូវជួយខ្លួន" ឬ "ខ្លួនត្រូវ

គាំទ្រខ្លួនដោយខ្លួនឯង"។ ទាំងនេះគឺចង់បញ្ជាក់ថា "អ្នកត្រូវពឹងខ្លួនឯងផ្ទាល់ កុំពឹង(ឬអាង)អ្នកដទៃ"។

## មហាបរិនិព្វានសូត្រ

មានតួយ៉ាងមួយផ្សេងទៀត ដែលបានសម្ដែងឱ្យឃើញថា មានការព្យាយាមដែលនឹងនាំយកអត្តា មកជ្រែកបញ្ចូលនៅក្នុងឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ គឺព្រះពុទ្ធដីការមួយឃ្លាថា "អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា" ដែលបានដកស្រង់ចេញមកពីព្រះសូត្រមួយមានឈ្មោះថាមហាបរិនិព្វានសូត្រ ហើយប្រែតាមរូបស័ព្ទ(ន័យត្រង់) ថា "អ្នកទាំងឡាយចូរនៅដោយធ្វើខ្លួនឱ្យជាកោះធ្វើខ្លួនឱ្យជាទីពឹង កុំយកវត្ថុដទៃជាទីពឹងឡើយ"។ ព្រោះឃ្លានេះឯង ទើបធ្វើឱ្យបណ្ដាអ្នកដែលប្រាថ្នាចង់ឱ្យមានអត្តានៅក្នុងព្រះពុទ្ធសាសនា នាំគ្នាវិភាគពាក្យ"អត្តទីបា" និងពាក្យ"អត្តសរណា"ថា "ប្រកាន់យកអត្តាជាប្រទីប" និង "ប្រកាន់យកអត្តាជាទីពឹង"។

យើងនឹងមិនអាចយល់ច្បាស់នូវអត្ថន័យនិងខ្លឹមសារដ៏ពិតប្រាកដនៃព្រះពុទ្ធឱវាទ ដែលទ្រង់ប្រទានដល់ព្រះអានន្ទនេះបានឡើយ ប្រសិនបើមិនពិចារណាទៅដល់ប្រវត្តិរឿងរ៉ាវ ដែលនាំឱ្យព្រះអង្គទ្រង់ត្រាស់នូវព្រះពុទ្ធដីការនេះទេនោះ។

ពេលទ្រង់ប្រទាននូវព្រះពុទ្ធឱវាទទាំងនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់គង់នៅនាភូមិមួយមានឈ្មោះថា"វេឡុវគ្រាម" ក្នុងអំលុងរយៈពេល៣ខែមុនបរិនិព្វាន។ ខណៈនោះព្រះអង្គទ្រង់មានព្រះជន្មាយុ៨០ព្រះវស្សា និងកំពុងប្រឈួនដោយព្រះរោគាពាធយ៉ាងធ្ងន់ធ្ងរ រហូតស្ទើរអស់ព្រះជន្ម តែដោយព្រះអង្គទ្រង់ព្រះតម្រិះថា មិនទាន់ដល់ពេលវេលាដ៏សមគួរដែលទ្រង់នឹងបរិនិព្វាន លុះណាតែបានផ្សព្វផ្សាយដំណឹងស្តីអំពីការបរិនិព្វាន ទៅដល់បណ្តាសាវ័កទាំងឡាយរបស់ព្រះអង្គជាមុនសិន។ ម្ល៉ោះហើយទើបទ្រង់អត់សង្កត់នូវទុក្ខវេទនានោះ ដោយព្រះទ័យអង់អាចក្លាហាន(អធិវាសនខន្តិគុណ) និងបានជាពីព្រះប្រឈួននោះនៅទីបំផុត បើទុកណាជាព្រះរាជសុខភាពរបស់ព្រះអង្គ មិនទាន់រឹងប៉ឹងនៅឡើយក៏ពិតមែន។ ថ្ងៃមួយបន្ទាប់អំពីទ្រង់បានជាសះស្បើយ អំពីព្រះរោគាពាធហើយនោះ ព្រះអង្គទ្រង់បានប្រថាប់គង់នៅក្រោមដើមឈើមួយដើម។ តមកព្រះអានន្ទដែលជាពុទ្ធុបដ្ឋាក បានចូលទៅគាល់ព្រះបិយបរមគ្រូ ថ្វាយអភិវាទនមស្សការ ហើយអង្គុយនៅក្នុងទីដ៏សមគួរ រួចទើបក្រាបបង្គំទូលថា

"បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គបានឃើញសេចក្តីផាសុកនៃព្រះដ៏មានព្រះភាគហើយ ទាំងសេចក្តីអត់ធន់នៃព្រះដ៏មានបុណ្យ ខ្ញុំព្រះអង្គក៏បានឃើញហើយដែរ តែពេលខ្ញុំព្រះអង្គបានឃើញព្រះជរាពាធ

របស់ព្រះដ៏មានព្រះភាគ ទិសទាំងឡាយហាក់ប្រាកដនូវភាពងងឹតសូន្យសុងដល់ខ្ញុំព្រះអង្គ ឥន្ទ្រិយទាំងឡាយរបស់ខ្ញុំព្រះអង្គក៏មិនជ្រះស្រលះ។ ទុកជាយ៉ាងណាក្តីខ្ញុំព្រះអង្គ ក៏នៅមានសេចក្តីស្បើយក្នុងចិត្តដោយគំនិតថា ព្រះដ៏មានព្រះភាគនឹងមិនទាន់ទ្រង់បរិនិព្វានឡើយ ដរាបណាទ្រង់មិនទាន់ប្រទានឱវាទដល់ភិក្ខុសង្ឃ"។

លំដាប់នោះ ព្រះសក្យមុនីដែលទ្រង់ប្រកបដោយព្រះមហាករុណាទិគុណ និងក្តីសន្តោសប្រោសប្រណី បានត្រាស់ទៅកាន់ព្រះអានន្ទដែលជាពុទ្ធុបដ្ឋាក ដោយព្រះបិយវាចាយ៉ាងរាបសាទន់ភ្លន់ថា "ម្នាលអានន្ទ! ភិក្ខុសង្ឃនៅសង្ឃឹមអ្វីចំពោះតថាគតទៀត? ធម៌(សច្ចធម៌)ទាំងឡាយ តថាគតក៏បានសម្តែងទុកហើយ ដោយមិនធ្វើឱ្យមានភាពខុសប្លែកគ្នា រវាងអ្វីដែលជាអាថ៌កំបាំង និងអ្វីដែលជាការបើកចំហនោះឡើយ ការលាក់បាំងនូវធម៌ទាំងឡាយមិនមានដល់តថាគតឡើយ។ តថាគតមិនមានអ្វីដែលដូចទៅនឹងកណ្តាប់ដៃរបស់អាចារ្យ(អាចរិយមុដ្ឋិ)។ ម្នាលអានន្ទ! ឥលូវនេះតថាគតមានវ័យជរាណាស់ហើយ ជាមនុស្សចាស់ដែលមានវ័យកន្លងហើយ ជន្មាយុកាលរបស់តថាគត ឈានចូលដល់គម្រប់៨០ឆ្នាំហើយ។ រទេះចាស់នឹងអាចនៅប្រើការតទៅទៀតបាន ដោយអាស្រ័យការជួសជុលយ៉ាងណាមិញ រាងកាយរបស់តថាគតក៏យ៉ាងនោះដែរ នឹងអាចប្រព្រឹត្តទៅបាន ក៏ដោយអាស្រ័យតែការព្យាបាលថែទាំ

ប៉ុណ្ណោះ។ ម្នាលអានន្ទ! ព្រោះអាស្រ័យហេតុដូច្នេះ អ្នកទាំងឡាយចូរមានខ្លួនជាកោះ មានខ្លួនជាទីពឹង កុំយកវត្ថុដទៃ(សភាវៈដទៃ) ជាទីពឹងឡើយ ពោលគឺចូរមានធម៌ជាទីពឹងនៅគ្រប់ឥរិយាបថចុះ”។

អ្វីដែលព្រះពុទ្ធជាម្ចាស់ត្រូវការសម្តែងដល់ព្រះអានន្ទនោះ គឺយើងអាចសង្កេតឃើញបានយ៉ាងច្បាស់ថា ព្រះអានន្ទមានសេចក្តីសោកសៅខ្លួចចិត្ត ព្រោះគិតថាព្រះភិក្ខុសង្ឃនឹងត្រូវឯកោ មិនមានទីពឹង ទីពំនាក់ មិនមានអ្នកដឹកនាំ បន្ទាប់ពីព្រះបរមគ្រូរបស់ពួកខ្លួនទ្រង់បរិនិព្វានទៅហើយនោះ។ អាស្រ័យហេតុដូច្នេះឯង ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទាននូវព្រះឱវាទដើម្បីផ្តល់ជាកម្លាំងចិត្ត និងភាពជឿជាក់ដល់ព្រះអានន្ទដោយទ្រង់ត្រាស់ថា ភិក្ខុសង្ឃគប្បីពឹងខ្លួនឯង ពឹងព្រះធម៌ ដែលទ្រង់បានសម្តែងទុកមក ហើយមិនគប្បីពឹងបុគ្គលណាមួយ ឬព្រះជាម្ចាស់អង្គណាឡើយ។ ដូច្នេះបញ្ហាក្នុងរឿងអាត្មនឬតួខ្លួន ដែលចាត់ថាជារឿងទស្សនវិជ្ជា(គ្រាន់តែជាការយល់ឃើញ) ទើបមិនត្រូវបានចាត់ចូលនៅក្នុងករណីនេះ។

ក្រៅពីនោះព្រះពុទ្ធជាម្ចាស់ ទ្រង់នៅបានអធិប្បាយដល់ព្រះអានន្ទ អំពីវិធីដែលនឹងធ្វើឱ្យមនុស្សយើង អាចមានខ្លួនជាកោះ ជាទីពឹងបានដោយអាស្រ័យការចម្រើននូវសតិបដ្ឋាន៤ គឺកាយានុបស្សនា វេទនា

នុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា ដោយទ្រង់មិនបានត្រាស់ទៅដល់អត្តានៅក្នុងទីនេះឡើយ ។

## អត្តានៅឯណា?

ភ័ស្តុតាងមួយផ្សេងទៀតដែលបង្ហាញថា បណ្តាអ្នកដែលបានព្យាយាមស្វែងរកអាត្ម័ន នៅក្នុងឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ បាននាំយកមកអាងជាញឹកញាប់ ក៏គឺរឿងដូចតទៅនេះ:

គ្រាមួយព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់ នៅក្រោមដើមឈើមួយដើម នៅតាមផ្លូវដែលព្រះអង្គស្តេចយាងត្រលប់មកពីនគរពារាណសីទៅកាន់ឧរុវេលាសេនានិគម ។ ក្នុងថ្ងៃនោះ មានព្រះអង្គម្ចាស់ដែលជាមិត្តសម្លាញ់នឹងគ្នាចំនួន៣០អង្គព្រមដោយព្រះជាយា បាននាំគ្នាចេញទៅដើរកម្សាន្ត(ទៅទទួលទានអាហារនៅទីវាល) នៅក្នុងព្រៃដែលព្រះពុទ្ធអង្គទ្រង់កំពុងគង់ប្រថាប់នៅនោះ ។ ក្នុងចំណោមព្រះអង្គម្ចាស់ទាំងនោះមានព្រះអង្គម្ចាស់មួយព្រះអង្គ ទ្រង់នៅកំលោះនៅឡើយ ហើយព្រះអង្គម្ចាស់អង្គនេះឯងទ្រង់បាននាំយកនាងសោភិនីម្នាក់ទៅជាមួយផងដែរ ។ ក្នុងខណៈដែលអ្នកដទៃ កំពុងតែលេងសប្បាយជាមួយគ្នា នាងសោភិនីម្នាក់នោះបានលួចយករបស់មានតម្លៃផ្សេងៗរត់គេចខ្លួនបាត់ទៅ ។ ព្រះអង្គម្ចាស់ទាំងនោះបាននាំគ្នាចេញតាមស្វែងរកនាងសោភិនីម្នាក់នោះ

រហូតបានទៅជួបនឹងព្រះពុទ្ធជាម្ចាស់ កំពុងប្រថាប់គង់នៅក្រោមដើមឈើនោះឯង ទើបនាំគ្នាក្រាបបង្គំទូលសួរថា ព្រះអង្គទ្រង់បានឃើញស្រីម្នាក់នោះដែរឬទេ? ។ គ្រានោះឯង ព្រះពុទ្ធជាម្ចាស់ទ្រង់បានសាកសួរអំពីដំណើរដើមទងនៃរឿងរ៉ាវនោះ ពេលព្រះអង្គម្ចាស់ទាំងនោះ បានក្រាបទូលឱ្យទ្រង់ជ្រាបហើយ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរទៅកាន់ម្ចាស់ក្សត្រាទាំងនោះថា "ម្នាលមាណពទាំងឡាយ! អ្នកទាំងឡាយមានការយល់ឃើញយ៉ាងដូចម្ដេច? អ្វីទៅដែលប្រសើរជាង រវាងការស្វែងរកមនុស្សស្រីម្នាក់នោះ ជាមួយនឹងការស្វែងរកខ្លួនឯង?" ។

ក្នុងករណីនេះក៏ដូចគ្នា ជាការចោទសួរនូវបញ្ហាយ៉ាងសាមញ្ញ គ្មានហេតុផលណាមួយ ដែលអាចនឹងនាំមកអាងបានថា ព្រះពុទ្ធអង្គទ្រង់ត្រាស់សំដៅទៅដល់ផ្នត់គំនិតរឿងអត្តាឬអាត្មននោះឡើយ ។ ពេលព្រះអង្គម្ចាស់ទាំងនោះក្រាបទូលថា "ការស្វែងរកខ្លួនឯងប្រសើរជាង" ។ ព្រះពុទ្ធអង្គបានទ្រង់ណែនាំឱ្យព្រះអង្គម្ចាស់ទាំងនោះអង្គុយចុះ ហើយទ្រង់សម្ដែងធម៌ដល់ព្រះអង្គម្ចាស់ទាំងនោះ ។ តាមដំណើររឿងនេះ អ្វីដែលព្រះអង្គទ្រង់បានត្រាស់សម្ដែងដល់ព្រះអង្គម្ចាស់ទាំងនោះ តាមដែលប្រាកដនៅក្នុងគម្ពីរដាន់ដើម មិនមានពាក្យណាមួយដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់ទៅដល់រឿងអាត្មននោះឡើយ ។

រឿងដែលគេនាំគ្នាសរសេរច្រើនបំផុតនោះ គឺរឿងដែលព្រះអង្គទ្រង់នៅស្ងៀម ពេលដែលបរិញ្វាជកឈ្មោះវច្ឆគោត្របានទូលសួរព្រះអង្គថាមានអាត្មនឬទេ? ដូចមានសេចក្តីនៅក្នុងព្រះគម្ពីរថា:

វច្ឆគោត្របានចូលគាល់ព្រះពុទ្ធជាម្ចាស់ ហើយក្រាបទូលសួរថា "បពិត្រព្រះគោតមដ៏ចម្រើន អាត្មនមានឬទេ?"។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់គង់នៅស្ងៀម ដោយមិនទ្រង់មានព្រះវាចាអ្វីឡើយ។

"បពិត្រព្រះគោតមដ៏ចម្រើន អាត្មនមិនមានឬ?"។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់គង់នៅស្ងៀមដូចដើម។ វច្ឆគោត្របានក្រោកឈររួចហើយដើរចាកចេញទៅ។

បន្ទាប់អំពីវច្ឆគោត្របានចាកចេញទៅផុតហើយនោះ ព្រះអានន្ទបានទូលសួរព្រះពុទ្ធអង្គថា ហេតុអ្វីទើបទ្រង់មិនឆ្លើយទៅនឹងសំណួររបស់វច្ឆគោត្រ? ព្រះពុទ្ធជាម្ចាស់បានទ្រង់អធិប្បាយ នូវគោលជំហររបស់ព្រះអង្គថា "ម្នាលអានន្ទ! ពេលវច្ឆគោត្របរិញ្វាជកសួរថា "អត្តាពិតជាមានមែនឬ?" ប្រសិនបើយើងឆ្លើយថា "អត្តាពិតជាមានមែន"។ ម្នាលអានន្ទ! វាក៏នឹងជាការលម្អៀងទៅរកសមណៈឬព្រាហ្មណ៍ទាំងឡាយ ពួកដែលប្រកាន់យកនូវទ្រឹស្តីថាទៀង(សស្សតវាទៈ)"។

"ម្នាលអានន្ទ! ពេលវច្ឆគោត្របរិញ្វាជកសួរថា "អត្តាពិតជាមិនមានឬ?" ប្រសិនបើយើងតបថា"មិនមានអត្តា" ម្នាលអានន្ទ! វាក៏នឹង

ជាការលម្អៀងទៅរកសមណៈឬព្រាហ្មណ៍ទាំងឡាយ ពួកដែលប្រកាន់យកនូវទ្រឹស្តីដែលថាសោះសូន្យ(ឧច្ឆេទវាទៈ)"។

"ម្នាលអានន្ទ! ក៏នៅពេលដែលវច្ឆគោត្របរិព្វាជកសួរថា "អត្តាពិតជាមានឬ?" ប្រសិនបើយើងឆ្លើយថា "អត្តាពិតជាមានមែន" វានឹងស្របជាមួយអ្វីដែលយើងដឹងមកថា ធម៌ទាំងឡាយមិនមានអត្តានោះហើយឬ?"។ "មិនស្របទេក្រាបទូល"។

"ម្នាលអានន្ទ! ក៏នៅពេលដែលវច្ឆគោត្របរិព្វាជកសួរថា "អត្តាមិនមានឬ?" ប្រសិនបើយើងឆ្លើយថា "អត្តាមិនមាន" វាក៏នឹងធ្វើឱ្យវច្ឆគោត្រដែលមានចម្ងល់ស្រាប់ទៅហើយនោះ កាន់តែមានចម្ងល់ខ្លាំងឡើងថែមទៀត ព្រោះគេគិតថា "កាលពីមុនយើងមានអាត្ម័ន(អត្តា) តែពេលនេះយើងលែងមានអាត្ម័នទៀតហើយ"។

## វិធីឆ្លើយសំនួររបស់ព្រះពុទ្ធជាម្ចាស់

មកដល់ត្រង់ចំណុចនេះ ប្រហែលជាមិនមានអ្វីដែលគួរឱ្យសង្ស័យទៀតនោះទេថា ហេតុអ្វីទើបព្រះពុទ្ធជាម្ចាស់ទ្រង់នៅស្ងៀម តែរឿងនេះយើងនឹងយល់បានកាន់តែច្បាស់ថែមទៀត បើប្រសិនណាជាយើងបានពិចារណាទៅដល់គោលជំហរ និងវិធីដែលព្រះអង្គទ្រង់បដិបត្តិចំពោះសំណួរក៏ដូចជាអ្នកសួរសំណួរផ្សេងៗ ដែលចំណុចនេះមើលទៅ

ហាក់ទំនងជាបណ្តាអ្នកដែលនាំយកនូវបញ្ហាអត្តាមកបកស្រាយ មិនសូវជាបានជ្រាបច្បាស់ប៉ុន្មានឡើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់មិនមែនជាបុគ្គល ដែលរង់ចាំឆ្លើយនូវគ្រប់បញ្ហាដែលគេបានចោទសួរ ដោយមិនបានទ្រង់ព្រះតម្រិះជាមុននោះឡើយ ។ ព្រះអង្គទ្រង់ជាសាស្តាអ្នកបដិបត្តិ(Practical Teacher) ទ្រង់ប្រកបព្រមទៅដោយព្រះមហាករុណាទិគុណ(Compassion) និងព្រះបញ្ញាគុណ(Wisdom) ។ ព្រះអង្គមិនទ្រង់ឆ្លើយបញ្ហាក្នុងលក្ខណៈដើម្បីអួតអាងអំពីសមត្ថភាព ប៉ុន្តែគឺព្រះអង្គទ្រង់ឆ្លើយបញ្ហាដើម្បីជួយឱ្យអ្នកចោទសួរនោះៗ បានយល់និងជ្រាបច្បាស់( ឃើញច្បាស់នូវការពិត) ។ ព្រះអង្គទ្រង់ត្រាស់ដល់បុគ្គលទាំងឡាយ ដោយផ្តោតព្រះទ័យយកចិត្តទុកដាក់ទៅដល់ការអភិវឌ្ឍ ចរិត ឧបនិស្ស័យ លក្ខណៈ និងសក្តានុភាពដែលបុគ្គលនោះៗនឹងអាចយល់បាននូវបញ្ហាទាំងនោះ ។

ក្នុងការបដិបត្តិចំពោះសំណួរផ្សេងៗនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់មានវិធី៤យ៉ាងគឺៈ

១. បញ្ហាខ្លះព្រះអង្គនឹងឆ្លើយភ្លាមបន្ទាប់អំពីការសួរ

២. បញ្ហាខ្លះព្រះអង្គនឹងឆ្លើយ បន្ទាប់ពីទ្រង់បានវិភាគ នូវបញ្ហាទាំងនោះហើយ

៣. បញ្ហាខ្លះព្រះអង្គនឹងឆ្លើយដោយការសួរបកត្រលប់ទៅវិញ

៤. បញ្ហាខ្លះទៀតព្រះអង្គនឹងជៀសវាងមិនឆ្លើយតបឡើយ (ប្រសិនបើមិនធ្វើឱ្យកើតប្រយោជន៍ដល់អ្នកសួរ)

ការជៀសវាងមិនឆ្លើយនូវបញ្ហានេះ គឺព្រះអង្គទ្រង់ធ្វើដោយវិធីជាច្រើន។ វិធីទីមួយគឺទ្រង់ប្រាប់ថា បញ្ហានោះៗឆ្លើយមិនបាន ឬថាអធិប្បាយមិនបាន ដូចដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ប្រាប់ដល់វច្ឆគោត្របរិព្វាជកម្នាក់នេះជាច្រើនលើកច្រើនសា ពេលវច្ឆគោត្រទូលសួរបញ្ហាផ្សេងៗថា ចក្រវាលទៀងឬទេ?ជាដើម។ ដូចគ្នានេះដែរព្រះអង្គទ្រង់ក៏ធ្លាប់ប្រើនូវវិធីនេះ ឆ្លើយបញ្ហារបស់មាលុងក្យបុត្រនិងអ្នកឯទៀតៗរួចមកហើយដែរ ប៉ុន្តែព្រះអង្គមិនត្រាស់ដូចគ្នានេះជាមួយបញ្ហាដែលសួរថាមានអាត្មន(អត្តា)ឬទេ? ព្រោះថាព្រះអង្គទ្រង់តែងបានអធិប្បាយពន្យល់ទាក់ទងនឹងបញ្ហានេះជានិច្ចថា ព្រះអង្គទ្រង់មិនអាចត្រាស់ថា"មានអត្តា" ព្រោះវានឹងក្លាយទៅជាការជំទាស់ទៅនឹងអ្វី ដែលព្រះអង្គទ្រង់ជ្រាបមកថា "ធម៌ទាំងឡាយមិនមានអត្តា" ហើយព្រះអង្គក៏មិនមានព្រះរាជបំណងត្រាស់ថា "មិនមានអត្តា" ព្រោះវានឹងបង្កឱ្យកើតមន្ទិលសង្ស័យនិងសេចក្តីក្តៅក្រហាយដោយមិនចាំបាច់ដល់វច្ឆគោត្របរិព្វាជក ដែលកើតមាននូវមន្ទិលសង្ស័យជាមួយនឹងបញ្ហាបែបនេះស្រាប់ទៅហើយ ត្បិតថាវច្ឆគោត្រផ្ទាល់ តាំងពីដើមរៀងមក គឺជាអ្នកដែលទទួលស្គាល់នូវទស្សនៈរឿងអត្តា ម្ល៉ោះហើយគេប្រាកដជាមិនស្ថិតនៅ

ក្នុងឋានៈ ដែលនឹងយល់ច្បាស់នូវរឿងស្ដីអំពី"អនត្តា"នេះបានឡើយ។ ដូច្នេះការជៀសវាងមិនឆ្លើយនូវបញ្ហាខនេះដោយវិធីនៅស្ងៀម ទើបជាដំណោះស្រាយដ៏ល្អបំផុតនៅក្នុងករណីនេះ។

## គោលជំហរដ៏ត្រឹមត្រូវ

តាមទ្រឹស្ដីរបស់ព្រះពុទ្ធជាម្ចាស់ វាជាការខុសឆ្គងប្រសិនបើមានការប្រកាន់មាំថា "យើងមិនមានតួខ្លួន"(គឺជា ឧច្ឆេទទិដ្ឋិ) ដូចគ្នាទៅនឹងការប្រកាន់មាំថា "យើងមានតួខ្លួន" ក៏ជាមិច្ឆាទិដ្ឋិ(គឺជាសស្សតទិដ្ឋិ) ព្រោះការយល់ឃើញទាំងពីរយ៉ាងនេះជាសំយោជន៍ ជាទស្សនះដែលកើតពីការគិតមិនត្រឹមត្រូវដែលថា "មានខ្លួនយើង"។ គោលជំហរដ៏ត្រឹមត្រូវទាក់ទងទៅនឹងរឿង"អនត្តា"នេះ គឺការមិនប្រកាន់មាំនូវទិដ្ឋិណាមួយ ហើយឱ្យពិចារណាឃើញសភាវៈទាំងឡាយទៅតាមសេចក្ដីពិត ដោយមិនឱ្យចិត្តចូលទៅតាក់តែង ឱ្យពិចារណាឃើញថា អ្វីដែលយើងនាំគ្នាហៅថា"ជាខ្លួនយើង" ឬ "ជាសត្វបុគ្គល" គឺគ្រាន់តែជាការរួមបញ្ចូលគ្នានៃខន្ធទាំងឡាយ ទាំងដែលជារូបនិងជានាម ជាសភាវៈដែលមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក អាស្រ័យនូវគ្នានិងគ្នា ស្ថិតនៅក្នុងសភាពនៃការប្រែប្រួលគ្រប់ខណៈ ប្រព្រឹត្តទៅតាមច្បាប់ហេតុនិងផល(ច្បាប់ធម្មជាតិ)

ព្រមទាំងបង្ហាញឱ្យឃើញថា មិនមានសភាវៈណាមួយ ទៀងទាត់ឋិតថេរ មិនប្រែប្រួល និងស្ថិតនៅជាអមតៈនោះឡើយ ។

មានបញ្ហាមួយត្រូវបានគេចោទសួរឡើងថា ប្រសិនបើមិនមាន "អាត្ម័ន" ចុះតើនរណាទៅដែលជាអ្នកទទួលវិបាក (ផល) របស់កម្ម? ។ គ្មាននរណាម្នាក់ឆ្លើយសំណួរនេះ បានល្អជាងព្រះពុទ្ធជាម្ចាស់នោះឡើយ ។ ពេលភិក្ខុកំលោះមួយអង្គទូលសួរបញ្ហានេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា "ម្នាលភិក្ខុ! តថាគតបង្រៀនអ្នកឱ្យមើលឃើញភាវៈជាហេតុជាបច្ច័យ នៅក្នុងសភាវៈទាំងឡាយនិងនៅក្នុងទីទាំងពួង " ។

ឱវាទទូន្មានក្នុងរឿង "អនត្តា" "មិនមានវិញ្ញាណ" ឬ "មិនមានតួខ្លួន" នេះ បុគ្គលមិនគប្បីយល់ថា ជាឱវាទទូន្មានក្នុងផ្លូវអវិជ្ជមាន ឬជាឧច្ឆេទទិដ្ឋិ ។ អនត្តានេះដូចគ្នាទៅនឹងព្រះនិព្វានដែរ គឺជាសច្ចធម៌ ជាការពិតនៃសភាវធម៌ទាំងអស់ ហើយការពិតនឹងប្រព្រឹត្តទៅនៅក្នុងផ្លូវអវិជ្ជមាននោះគឺមិនមានឡើយ ។ ជំនឿខុសឆ្គងនៅក្នុងរឿង "អត្តា" ដែលកើតចេញពីក្តីស្រមើស្រមៃ ទៅលើអ្វីដែលមិនមានថាជារបស់ដែលមាននោះទេវិញទេ ដែលជាជំនឿនៅក្នុងផ្លូវអវិជ្ជមាន ។ ឱវាទទូន្មាននៅក្នុងរឿងអនត្តានេះ ជាឱវាទទូន្មានដែលបន្ទោរបង់នូវភាពងងឹត គឺជំនឿបែបខុសឆ្គងទាំងឡាយ និងជំនួសមកវិញដោយពន្លឺភ្លឺស្វាងគឺបញ្ញា ។ ដូច្នេះទើបមិនអាចនិយាយបានថា ជាជំនឿនៅក្នុងផ្លូវអវិជ្ជមាន ដូចដែលព្រះ

ថេរៈអសង្គៈធ្លាប់បានពោលទុកមក    មានសេចក្តីពិរោះគួរឱ្យចាប់ចិត្តថា "រឿងពិតស្តីអំពីអនត្តាពិតជាមានយ៉ាងប្រាកដ "( នៃរាតមយាសតិតា) ។

ឈឈឈ✵ឥឥឥ

# ជំពូកទី៧

# កម្មដ្ឋាន ឬ ការអប់រំចិត្ត(ភាវនា)

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ! សេចក្ដីទុក្ខមាន២ប្រការ។ ចុះតើសេចក្ដីទុក្ខ២ប្រការនោះ មានអ្វីខ្លះ? គឺសេចក្ដីទុក្ខផ្លូវកាយនិងសេចក្ដីទុក្ខផ្លូវចិត្ត។ មនុស្សទាំងឡាយមើលទៅហាក់រួចផុតពីសេចក្ដីទុក្ខផ្លូវកាយ ដោយរយៈវេលាមួយឆ្នាំខ្លះ ពីរឆ្នាំខ្លះ ដប់ឆ្នាំខ្លះ ឬរាប់សិបឆ្នាំខ្លះ... ឬច្រើនជាងនេះទៀតក៏សឹងមាន តែភិក្ខុទាំងឡាយនៅក្នុងលោកនេះ បុគ្គលដែលរួចចាកផុតពីសេចក្ដីទុក្ខផ្លូវចិត្ត សូម្បីត្រឹមមួយខណៈ គឺមានតិចតួចបំផុត ក្រៅតែពីបុគ្គលដែលរួចចាកផុតពីកិលេសទាំងឡាយហើយប៉ុណ្ណោះ( ព្រះអរហន្ត)"។

ឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ជាពិសេសគឺវិធីបដិបត្តិ"កម្មដ្ឋាន" មានគោលបំណងដើម្បីធ្វើឱ្យកើត នូវសុខភាពផ្លូវចិត្តយ៉ាងពេញលេញ មាននូវតុល្យភាពនិងសេចក្ដីស្ងប់ តែជាការគួរឱ្យសោកស្ដាយព្រោះថា មិនមានឱវាទទូន្មានទាំងឡាយណារបស់ព្រះពុទ្ធជាម្ចាស់ ដែលទាំងពុទ្ធសាសនិកជននិងសាសនិកសាសនាដទៃៗ មានការយល់ខុសស្មើនឹងរឿង"កម្មដ្ឋាន"នេះឡើយ។ ភ្លាមពេលដែលបានឮពាក្យថា"កម្មដ្ឋាន" មនុស្សក៏នាំគ្នាគិតទៅដល់ការបញ្ចៀសខ្លួនចេញពីភារកិច្ចប្រចាំថ្ងៃ រួចទៅ

អង្គុយនៅក្នុងឥរិយាបថណាមួយដូចជារូបសំណាកក្នុងល្អាង ឬនៅក្នុងវត្ត ក្នុងកន្លែងស្ងប់ស្ងាត់ ដោយកាត់ផ្តាច់ខ្លួនចេញពីសង្គម ពីការសប្បាយ ហ៊ឺហា ឬអង្គុយស្ងៀមនឹកគិតទៅដល់រឿងអស្ចារ្យ(អាថ៌កំបាំង) ឬចូល ឈាន។ "កម្មដ្ឋាន"ដ៏ពិតប្រាកដនៅក្នុងផ្លូវព្រះពុទ្ធសាសនានោះ គឺមិន មែនសុទ្ធតែត្រូវគេចខ្លួនចេញពីសង្គមនោះឡើយ។ ឱវាទទូន្មានរបស់ព្រះ ពុទ្ធជាម្ចាស់ស្តីអំពីរឿងកម្មដ្ឋាននេះ គឺមានមនុស្សជាច្រើនមានការយល់ ខុស រហូតធ្វើឱ្យសម័យត១មកការបដិបត្តិ"កម្មដ្ឋាន" មានការថមថយចុះ ជាលំដាប់ ហើយបានក្លាយទៅជាប្រពៃណីឬពិធីកម្មម្យ៉ាង ដែលត្រូវ បដិបត្តិនៅក្នុងឱកាសពិសេសណាមួយប៉ុណ្ណោះ។

## ការចម្រើនកម្មដ្ឋាន

មានមនុស្សមិនតិចទេ ដែលចាប់អារម្មណ៍នៅក្នុងការចម្រើនកម្ម ដ្ឋានឬយោគៈ ដើម្បីឱ្យបានសម្រេចថាមពលផ្លូវចិត្តឬអំណាចដ៏ពិសេស អស្ចារ្យ(ធ្លាប់មានដូនជីដែលជាពុទ្ធសាសនិកម្នាក់នៅក្នុងប្រទេសឥណ្ឌា បានព្យាយាមសាងនូវថាមពលពិសេស ឱ្យខ្លួនអាចឃើញអ្វីបានតាម ត្រចៀក ក្នុងខណៈពេលជាមួយគ្នាដូនជីម្នាក់នោះ ក៏បានសម្រេចនូវទិព្វ ចក្ខុ(ភ្នែកទិព្វ)ផងដែរ)។ គំនិតដូច្នេះគឺគ្មានអ្វីផ្សេងក្រៅតែពីការស្រេក ឃ្លាននៅក្នុងរឿងអំណាចអស្ចារ្យប៉ុណ្ណោះ។

ពាក្យថា"កម្មដ្ឋាន"នេះ ប្រើជំនួសពាក្យដើមថា"ភាវនា" ដែលមានន័យថា"ការចម្រើន" ឬ "ការអភិវឌ្ឍ" សំដៅដល់ការចម្រើន ឬការអភិវឌ្ឍផ្លូវចិត្ត។ បើនិយាយឱ្យត្រឹមត្រូវទៅតាមអត្ថន័យដ៏ពិតប្រាកដរបស់ស័ព្ទវិញនោះ "ការភាវនា"ក្នុងផ្លូវព្រះពុទ្ធសាសនា គឺការចម្រើនចិត្ត។ ការភាវនាមានគោលបំណងដើម្បីជម្រះចិត្តឱ្យស្អាតបរិសុទ្ធ ប្រាសចាកកិលេសជាគ្រឿងសៅហ្មង និងបាបអកុសលទាំងឡាយដូចជា រាគៈ ទោសៈ មោហៈ ព្យាបាទ គំនុំគុំកួន សេចក្ដីរាយមាយផ្លូវចិត្ត(ឧទ្ធច្ចកុក្កុច្ចៈ) សេចក្ដីសង្ស័យ(វិចិកិច្ឆា) ហើយដើម្បីបណ្ដុះនូវគុណសម្បត្តិផ្សេងៗដូចជា សមាធិ សតិ បញ្ញា និងសេចក្ដីអំណត់ព្យាយាម កម្លាំងនិងសមត្ថភាពនៅក្នុងការដោះស្រាយបញ្ហា(បញ្ហាជីវិត) ភាពជឿជាក់ បីតិ សេចក្ដីស្ងប់ ដែលនឹងនាំឱ្យបានសម្រេចនូវបញ្ញាជាន់ខ្ពស់ អាចមើលឃើញសភាវៈទាំងឡាយទៅតាមសេចក្ដីពិត និងយល់ច្បាស់នូវបរមសច្ចៈ គឺព្រះនិព្វាននៅទីបំផុត។

## ប្រភេទនៃកម្មដ្ឋាន

កម្មដ្ឋានមាន២ប្រភេទគឺ ការចម្រើនចិត្តឱ្យមានដំណើរតាំងស៊ប់មាំនៅក្នុងអារម្មណ៍(សមថៈឬសមាធិ) ជាការចម្រើនចិត្តឱ្យស្ងប់នៅក្នុងអារម្មណ៍តែមួយ(បាលីថា ចិត្តេកគ្គតា សំស្ក្រឹតថា ចិត្តៃកាគ្រតា) ដោយ

ការប្រើវិធីផ្សេងៗ តាមដែលមានកំណត់ទុកនៅក្នុងព្រះគម្ពីរ ហើយដែលអាចនាំទៅដល់សភាវៈ ដែលជ្រាលជ្រៅខ្ពង់ខ្ពស់និងអាថ៌កំបាំងដូចជាអាកិញ្ចញ្ញាយតនៈ(ភពដែលកំណត់នូវសភាវៈមិនមានអ្វីជាអារម្មណ៍) ឬនេវសញ្ញានាសញ្ញាយតនៈ(ភពដែលបដិសេធចោលទាំងការមាននិងមិនមាននូវសញ្ញាទាំងពួង)។ ក្នុងផ្លូវព្រះពុទ្ធសាសនា សភាវៈអាថ៌កំបាំងទាំងឡាយនេះកើតឡើងមកអំពីចិត្ត មានចិត្តជាអ្នកសាង មានហេតុនិងបច្ច័យជាអ្នកតាក់តែង(សង្ខារ) ដោយមិនបានពាក់ព័ន្ធទៅនឹងសច្ចធម៌គឺព្រះនិព្វាននោះឡើយ។ កម្មដ្ឋានបែបនេះមានតាំងអំពីមុនសម័យរបស់ព្រះពុទ្ធជាម្ចាស់មកម្ល៉េះ ហេតុដូច្នេះទើបមិនមែនជារបស់ផ្ដាច់មុខរបស់ព្រះពុទ្ធសាសនាឡើយ ប៉ុន្តែក៏មិនបានស្ថិតនៅក្រៅក្របខ័ណ្ឌកម្មដ្ឋានតាមបែបព្រះពុទ្ធសាសនាដែរ។ ទោះជាយ៉ាងណាក្តី កម្មដ្ឋានបែបនេះមិនមានភាពចាំបាច់ សម្រាប់ការត្រាស់ដឹងនូវសច្ចធម៌គឺព្រះនិព្វានឡើយ។ មុនព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនោះ ព្រះអង្គផ្ទាល់ទ្រង់ធ្លាប់បានសិក្សានូវវិធីបដិបត្តិយោគៈទាំងនេះជាមួយអាចារ្យផ្សេងៗ រហូតបានសម្រេចនូវសភាវៈដ៏ប្រសើរខ្ពង់ខ្ពស់ខាងផ្នែកផ្លូវចិត្ត(សមាបត្តិទាំង៨) តែព្រះអង្គក៏ទ្រង់នៅមិនទាន់ពេញព្រះទ័យ ដោយទ្រង់យល់ថាវិធីបដិបត្តិយោគៈទាំងនោះ មិនអាចជួយបុគ្គលឱ្យរលាស់ខ្លួនចេញចាកទុក្ខទាំងស្រុងបាន មិនមែនជាវិធីដែលអាចនាំឱ្យត្រាស់ដឹងនូវសច្ចធម៌(ព្រះនិព្វាន)

ទើបព្រះអង្គទ្រង់ព្រះតម្រិះថា សភាវៈអាចកំបាំងខាងផ្នែកផ្លូវចិត្តទាំងនេះ គ្រាន់តែជា"ធមិជាគ្រឿងនៅដោយសុខនៅក្នុងលោក(ទិដ្ឋធម្មសុខវិហារ)" ឬជា"ធមិជាគ្រឿងនៅដោយស្ងប់(សន្តិវិហារ)" មិនមានអ្វីប្រសើរទៅជាងនេះឡើយ។

ដូច្នេះទើបព្រះពុទ្ធអង្គទ្រង់ស្វែងរកឃើញ នូវ"កម្មដ្ឋាន"មួយបែបផ្សេងទៀតហៅថា"វិបស្សនា"(សំស្ក្រឹតថា វិបស្យនា ឬ វិទ្រសនា) គឺ"ការឃើញច្បាស់" នូវធាតុពិតនៃសភាវៈទាំងឡាយ ដែលនាំឆ្ពោះទៅកាន់ការត្រាស់ដឹងនូវសច្ចធមិគឺព្រះនិព្វាន។ ហើយនេះឯងគឺ"កម្មដ្ឋាន"តាមបែបព្រះពុទ្ធសាសនា ដែលជាការអប់រំចម្រើនចិត្តយ៉ាងពិតប្រាកដមានមូលដ្ឋាននៅលើសតិសម្បជញ្ញៈ និងការសង្កេតពិចារណាយ៉ាងយកចិត្តទុកដាក់។

វាប្រហែលជាមិនអាចទៅរួចឡើយ ដែលនឹងសម្តែងឱ្យអស់សេចក្តីអំពីគុណប្រយោជន៍របស់"កម្មដ្ឋាន" នៅក្នុងជំពូកដែលមានកម្រាស់មិនប៉ុន្មានទំព័រនេះ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងទីនេះនឹងព្យាយាមអធិប្បាយអំពីវិធីបដិបត្តិ"កម្មដ្ឋាន" ការអប់រំចម្រើនចិត្ត ឬការអភិវឌ្ឍចិត្តតាមបែបព្រះពុទ្ធសាសនា តែដោយសេចក្តីសង្ខេបប៉ុណ្ណោះ។

# សតិបដ្ឋានសូត្រ

ព្រះសូត្រដ៏សំខាន់បំផុត ដែលព្រះពុទ្ធអង្គទ្រង់បានសម្ដែងទាក់ទងទៅនឹងការអប់រំចម្រើនចិត្ត(កម្មដ្ឋាន)គឺសតិបដ្ឋានសូត្រ "ការតម្កល់សតិ" ឬ "ការតាំងចិត្ត" (សូត្រទី២២ ក្នុងគម្ពីរទីឃនិកាយ ឬសូត្រទី១០ នៅក្នុងគម្ពីរមជ្ឈិមនិកាយ)។ ព្រះសូត្រនេះមនុស្សសម័យបុរាណ មានការនិយមចូលចិត្តខ្លាំងណាស់ រហូតដល់ត្រូវបានគេនាំយកមកសូត្រមិនចំពោះតែនៅក្នុងវត្តប៉ុណ្ណោះទេ តែថែមទាំងត្រូវបាននាំយកមកសូត្រនៅតាមផ្ទះរបស់ពុទ្ធសាសនិកជនទៀតផង ដោយឱ្យសមាជិកនៅក្នុងក្រុមគ្រួសារមកអង្គុយនាំគ្នាស្ដាប់ ប្រកបដោយសទ្ធាជ្រះថ្លា។ ជាញឹកញាប់ដែលព្រះភិក្ខុនាំយកនូវព្រះសូត្រនេះ ទៅសូត្រឱ្យមនុស្សដែលជិតស្លាប់បានស្ដាប់ ដើម្បីដុសខាត់ជម្រះចិត្តរបស់ខ្លួនជាគ្រាចុងក្រោយ ឱ្យបានស្អាតបរិសុទ្ធ។

វិធីបដិបត្តិ "កម្មដ្ឋាន" ដូចដែលបានអធិប្បាយនៅក្នុងព្រះសូត្រនេះ មិនបានកាត់ផ្ដាច់ជីវិតរបស់យើងចេញពីជីវិតប្រចាំថ្ងៃឡើយ។ ផ្ទុយទៅវិញ គឺជារឿងដែលពាក់ព័ន្ធទៅនឹងជីវិតនិងភារកិច្ចប្រចាំថ្ងៃរបស់យើង ទាក់ទិនទៅនឹងសេចក្ដីទុក្ខ សេចក្ដីសុខ ការនិយាយ ការគិត រួមទាំងការប្រកបអាជីពដោយសុចរិត ក៏ដូចជាការប្រើប្រាស់នូវសតិ

បញ្ញារបស់យើង សម្រាប់ត្រិះរិះនូវរឿងរ៉ាវផ្សេងៗផងដែរ ។

សតិបដ្ឋានសូត្រនេះបែងចេញជា៤ក្រុមធំៗគឺ:

១. ក្រុមដែលពាក់ព័ន្ធជាមួយនឹងរាងកាយរបស់យើង( កាយានុបស្សនា)

២. ក្រុមដែលពាក់ព័ន្ធជាមួយនឹងអារម្មណ៍ ឬវេទនារបស់យើង ( វេទនានុបស្សនា)

៣. ក្រុមដែលពាក់ព័ន្ធទៅនឹងចិត្ត( ចិត្តានុបស្សនា)

៤. ក្រុមដែលពាក់ព័ន្ធជាមួយនឹងសីលធម៌ និងពុទ្ធិបញ្ញាផ្សេងៗ ( ធម្មានុបស្សនា)

គប្បីចងចាំទុកនៅក្នុងចិត្តថា មិនថាជា"កម្មដ្ឋាន"បែបណាក៏ដោយ សារៈសំខាន់បំផុតគឺស្ថិតនៅត្រង់ការរឭកដឹង ឬសតិ ការដាក់ចិត្តការឃ្លាំសង្កេត( អនុបស្សនា) ។

## អានាបាណស្សតិកម្មដ្ឋាន

កម្មដ្ឋានដែលទាក់ទងទៅនឹងរាងកាយ ហើយដែលគេនិយមបដិបត្តិច្រើនជាងគេនោះគឺ "ការតាំងសតិកំណត់ខ្យល់ដង្ហើមចេញចូល" ( អានាបាណស្សតិ) ។ អានាបាណស្សតិនេះប៉ុណ្ណោះ ដែលនៅក្នុងព្រះគម្ពីរបានកំណត់នូវឥរិយាបថដ៏ជាក់លាក់មួយទាក់ទងទៅនឹងការអង្គុយ ។

ដោយឡែកសម្រាប់"កម្មដ្ឋាន"ប្រភេទផ្សេងៗ ដូចដែលបានអធិប្បាយទុកមកនៅក្នុងព្រះគម្ពីរ យើងអាចនឹងអង្គុយ ឈរ ដើរ ឬគេងក៏បានតាមតែការងាយស្រួល។ សម្រាប់ការហ្វឹកហាត់កំណត់ខ្យល់ដង្ហើមចេញចូលវិញ ក្នុងគម្ពីរបានបញ្ជាក់ប្រាប់ថាអ្នកបដិបត្តិចាំបាច់ត្រូវ "អង្គុយពែនភ្នែន តាំងខ្លួនឱ្យត្រង់និងតម្កល់សតិឱ្យមាំ"។ ពិតមែនហើយថាការអង្គុយពែនភ្នែននេះ គឺមិនងាយសោះឡើយសម្រាប់មនុស្សនៅក្នុងប្រទេសផ្សេងៗ ជាពិសេសប្រទេសប៉ែកលោកខាងលិច។ ហេតុដូច្នេះ សម្រាប់អ្នកដែលយល់ថា ការអង្គុយពែនភ្នែនមានការលំបាកនោះ ក៏អាចនឹងអង្គុយនៅលើកៅអីដោយ "តាំងខ្លួនឱ្យត្រង់និងតម្កល់សតិឱ្យមាំ" ក៏បាន។ ក្នុងការបដិបត្តិអានាបាណស្សតិនេះ អ្វីដែលចាំបាច់បំផុតនោះគឺថា អ្នកបដិបត្តិគួរអង្គុយខ្លួនឱ្យត្រង់ដោយមិនចាំបាច់ប្រឹង ដៃទាំងពីរដាក់នៅលើភ្នែនតាមសម្រួល។ លុះអង្គុយបានយ៉ាងដូច្នេះហើយ ក៏អាចប្រើវិធីបិទភ្នែក ឬសម្លឹងទៅកាន់ចុងច្រមុះរបស់ខ្លួនក៏បាន ទៅតាមការចូលចិត្តរបស់ខ្លួន។

មនុស្សយើងដកដង្ហើមចេញចូលគ្រប់វិនាទី តែមិនធ្លាប់មានសតិកំណត់នូវខ្យល់ដង្ហើមរបស់ខ្លួនសោះឡើយ មិនធ្លាប់យកចិត្តទៅផ្ដោតនៅត្រង់ខ្យល់ដង្ហើមនោះ។ ឧទាហរណ៍ថាពេលនេះ អ្នកកំពុងបដិបត្តិអានាបាណស្សតិកម្មដ្ឋាន សូមឱ្យដកដង្ហើមចេញចូលតាមធម្មតា កុំព្យាយាម

ទៅបង្គាប់វា នាំចិត្តរបស់អ្នកទៅផ្តោតនៅត្រង់ខ្យល់ដង្ហើមចេញចូលនោះ ឱ្យចិត្តពិនិត្យសង្កេតមើលខ្យល់ដង្ហើមចេញចូលនោះ។ ពេលដែលមនុស្សយើងដកដង្ហើម ជួនកាលដកដង្ហើមវែង ជួនកាលដកដង្ហើមខ្លី ប្រការនេះមិនសំខាន់អ្វីឡើយ គឺឱ្យដកដង្ហើមទៅតាមធម្មតា ប៉ុន្តែអ្វីដែលសំខាន់នោះ គឺពេលដកដង្ហើមវែងក៏ឱ្យមានសតិរឭកដឹងថា ដកដង្ហើមវែង ពេលដកដង្ហើមខ្លីក៏ឱ្យមានសតិរឭកដឹងថា ដកដង្ហើមខ្លីយ៉ាងនេះជាដើម។ ពោលដោយន័យម្យ៉ាងទៀតថា ត្រូវតាំងស្មារតីកំណត់ដឹងនូវគ្រប់ខ្យល់ដង្ហើមចេញចូល រហូតដឹងអំពីការផ្លាស់ប្តូរប្រែប្រួលរបស់វា។ អ្នកបដិបត្តិចាំបាច់ត្រូវបំភ្លេចនូវអ្វីៗគ្រប់យ៉ាង មិនថាជាអ្វីដែលនៅជុំវិញខ្លួន (បរិយាកាសជុំវិញ) មិនងាកភ្នែកសម្លឹងមើលអ្វីទាំងអស់ដែលនៅជុំវិញខ្លួន។ ត្រូវបដិបត្តិយ៉ាងដូច្នេះឱ្យបានខ្ជាប់ខ្ជួន ដោយប្រើរយៈពេល៥ទៅ ១០នាទី។

ក្នុងដំណាក់កាលដំបូង អ្នកបដិបត្តិអាចនឹងមានអារម្មណ៍ថា មានការលំបាកក្នុងការនាំចិត្តទៅផ្តោតនៅត្រង់ខ្យល់ដង្ហើមចេញចូល និងមានអារម្មណ៍ថាចិត្តគឺមិននៅស្ងៀម ទៅតាមការបង្គាប់បញ្ជារបស់ខ្លួន ដោយចេះតែគិតទៅដល់រឿងរ៉ាវផ្សេងៗ ជាពិសេសពេលបានឮសំឡេងខាងក្រៅ ចិត្តក៏ចាប់ផ្តើមញាប់ញ័រ ហើយព្រោះប្រការនេះឯង អាចនឹងធ្វើឱ្យអ្នកបដិបត្តិមានអារម្មណ៍រួញរាក្នុងការបដិបត្តិបន្តទៅទៀត ប៉ុន្តែប្រសិន

បើព្យាយាមដូចដែលបានរៀបរាប់មកនេះ ឱ្យបានរឿយៗមួយថ្ងៃ២ដង គឺព្រឹកម្តង ល្ងាចម្តង ដោយប្រើរយៈពេលប្រមាណពី៥ទៅ១០នាទី (យ៉ាងតិច) អ្នកបដិបត្តិនឹងទទួលអារម្មណ៍ថាអាចគ្រប់គ្រងចិត្តរបស់ខ្លួនបានបន្តិចម្តងៗ។ បន្ទាប់ពីឆ្លងផុតទៅមួយរយៈ អ្នកបដិបត្តិក៏អាចនឹងពើបប្រទះនូវរយៈពេលដ៏ខ្លីណាមួយ ដែលចិត្តរបស់គេត្រូវបានប្រមូលផ្តុំទាំងស្រុងនៅត្រង់ខ្យល់ដង្ហើមចេញចូល ហើយវាក៏ជាអំឡុងពេលដែលអ្នកបដិបត្តិ មិនបានឮនូវសំឡេងខាងក្រៅ ជាពេលដែលខ្លួនគេត្រូវបានកាត់ផ្តាច់ចេញទាំងស្រុងពីលោកខាងក្រៅ ក្នុងរយៈពេលដ៏ខ្លីនេះឯងដែលអ្នកបដិបត្តិបានជួបប្រទះ នូវសេចក្តីសុខនិងសេចក្តីស្ងប់យ៉ាងក្រៃលែងរហូតដល់ធ្វើឱ្យខ្លួនគេចង់បដិបត្តិបន្តទៅទៀត តែក៏មិនអាចនឹងធ្វើទៅបាន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបដិបត្តិព្យាយាមបដិបត្តិឱ្យបានជាប់ជាប្រចាំ ក៏នឹងបានជួបប្រទះនូវសេចក្តីសុខបែបនោះជាញយៗហើយយូរជាងមុន ក្នុងអំឡុងពេលនោះជាអំឡុងពេលដែលអ្នកបដិបត្តិភ្លេចនឹកអំពីខ្លួនឯង ដោយនាំសតិទៅកំណត់នៅត្រង់ខ្យល់ដង្ហើមតែម្យ៉ាង។ ដរាបណាមនុស្សយើងនៅគិតដល់ខ្លួនឯងនៅឡើយ គេក៏នឹងមិនអាចធ្វើចិត្តរបស់គេឱ្យជាចិត្តដែលស្ងប់រម្ងាប់បានឡើយ។

ការបដិបត្តិនូវអានាបាណស្សតិនេះ ជាការបដិបត្តិបែបសាមញ្ញនិងងាយស្រួល មានគោលដៅធ្វើឱ្យសមាធិមានការចម្រើនឡើង ដែល

ជូនកាលអាចនឹងនាំទៅដល់ការបានសម្រេច នូវគុណវិសេសដ៏អស្ចារ្យ (ឫទ្ធិ ឬ អំណាចផ្លូវចិត្ត)។ ក្រៅពីនោះ កម្លាំងរបស់សមាធិនេះ ក៏អាចជាបច្ច័យនាំឱ្យកើតការយល់ច្បាស់នូវសភាវៈអាថ៌កំបាំង និងយល់ចាក់ធ្លុះនូវធម្មជាតិនៃសភាវៈផ្សេងៗ រហូតធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានបាន។

ក្រៅពីអ្វីដែលបានរៀបរាប់មកនេះ ការបដិបត្តិអានាបាណស្សតិនៅផ្តល់ផលជាច្រើនផ្សេងទៀតដល់អ្នកបដិបត្តិ ដូចជាធ្វើឱ្យមានសុខភាពរាងកាយល្អ ជួយបន្ធូរបន្ថយភាពតានតឹង ធ្វើឱ្យគេងលក់ស្រួល និងមានប្រសិទ្ធភាពនៅក្នុងការអនុវត្តកិច្ចការងារប្រចាំថ្ងៃ ធ្វើឱ្យអ្នកបដិបត្តិមានសភាពស្ងប់និងត្រជាក់ សូម្បីពេលដែលគួរកើតអាការៈភ័យភ្ញាក់ផ្អើល។ ប្រសិនបើបានបដិបត្តិអានាបាណស្សតិប្រហែលពី៥ទៅ១០នាទី ក៏នឹងដឹងច្បាស់នៅរំពេចនៃខណៈនោះឯងថា ខ្លួនឯងមានសេចក្តីស្ងប់ ទាំងមានអារម្មណ៍ហាក់បីដូចជាទើបនឹងភ្ញាក់ពីដំណេក។

"កម្មដ្ឋាន"ដែលនឹងពោលបន្ទាប់ទៅទៀតនេះ ទាក់ទងទៅនឹងចិត្តរបស់យើងផ្ទាល់តែម្តង ដោយយើងចាំបាច់ត្រូវមានសតិកំណត់ដឹងនៅគ្រប់ខណៈថា ចិត្តស្រលាញ់ឬស្អប់ ចិត្តត្រូវសេចក្តីខឹងក្រោធ សេចក្តីព្យាបាទ ភាពច្រណែនឈ្នានីសគ្របសង្កត់ឬយ៉ាងណា ឬថាចិត្តមានសេចក្តីមេត្តាករុណា ចិត្តមានសេចក្តីវង្វេង(មោហៈ) ឬមានការយល់ច្បាស់និងត្រឹមត្រូវជាដើម។ យើងត្រូវទទួលស្គាល់ថា ជាញយៗដែល

យើងខ្លាចឬមានការខ្មាសអៀន ក្នុងការត្រួតពិនិត្យនូវចិត្តរបស់ខ្លួនឯងម៉្លោះហើយទើបចេះតែគេចវេះជាញឹកញាប់ ។ មនុស្សយើងតោងត្រូវមានសេចក្ដីក្លាហាននិងស្មោះត្រង់ ដោយការឃ្លាំសង្កេតពិនិត្យចិត្តរបស់ខ្លួនឯង ដូចទៅនឹងការដែលយើងឆ្លុះកញ្ចក់មើលមុខខ្លួនឯង យ៉ាងដូច្នោះដែរ ។

## វិធីរំលត់កំហឹង

ក្នុងការត្រួតពិនិត្យចិត្តរបស់ខ្លួន ចាំបាច់គឺយើងមិនត្រូវស្ថិតនៅក្នុងគោលជំហរវិភាគ រើកញែកឬជំនុំជម្រះកាត់ក្ដីអ្វីនោះឡើយ ។ យើងមិនចាំបាច់បែងចែកថាខុសឬត្រូវ ល្អឬអាក្រក់ ដោយគ្រាន់តែឃ្លាំសង្កេតនិងត្រួតពិនិត្យប៉ុណ្ណោះ ។ កុំគប្បីធ្វើខ្លួនជាអ្នកជំនុំជម្រះ តែសូមធ្វើខ្លួនឱ្យដូចជាអ្នកវិទ្យាសាស្ត្រ( ដែលកំពុងធ្វើការពិសោធទៅលើអ្វីមួយ៉ាង) ។ ពេលដែលបានធ្វើការសង្កេតចិត្ត និងអាចមើលដឹងនូវធម្មជាតិដ៏ពិតប្រាកដរបស់ចិត្តបានយ៉ាងជាក់ច្បាស់ហើយនោះ អ្នកក៏នឹងរំសាយបង់នូវការប្រកាន់មាំក្នុងអារម្មណ៍ ក៏ដូចជាសភាវៈទាំងឡាយផ្សេងៗ ហើយដោយអាស្រ័យវិធីនេះ អ្នកក៏អាចនឹងកាត់ផ្ដាច់បាននូវឧបាទាន( ការប្រកាន់មាំនៅក្នុងសភាវៈផ្សេងៗ) មានឥស្សរភាព និងអាចមើលឃើញសភាវៈទាំងឡាយទៅតាមសេចក្ដីពិត ។

មួយវិញទៀត នៅពេលដែលអ្នកមានការខឹងក្រោធ អ្នកនឹងត្រូវការទាស់ចិត្ត សេចក្ដីថ្នាំងថ្នាក់ ការចងអាឃាតព្យាបាទ ការស្អប់ខ្ពើមជាដើមគ្របសង្កត់ ហើយជាលទ្ធផលជាក់ស្ដែង ដែលយើងអាចនឹងឃើញច្បាស់បាននៅក្នុងអំឡុងពេលនោះ គឺចិត្តនឹងពេញទៅដោយសេចក្ដីមួម៉ៅក្ដៅក្រហាយ ជាការដុតកម្ដៅខ្លួនឯងដោយខ្លួនឯង ត្បិតថាមិនមានបុគ្គលណាអាចនឹងធ្វើឱ្យអ្នកខឹងក្រោធបានឡើយ ប្រសិនបើខ្លួនអ្នកផ្ទាល់មិនចង់ខឹង។ ចំណុចនេះវាមិនខុសអ្វីទៅនឹងការស្រលាញ់ ដែលគ្មាននរណាម្នាក់អាចបង្គាប់អ្នកបានឡើយ ប្រសិនណាជាចិត្តរបស់អ្នកមិនស្រលាញ់ទេនោះ។ បុគ្គលដែលត្រូវសេចក្ដីខឹងក្រោធ គ្របសង្កត់បានហើយនោះ រមែងនៅជាទុក្ខ ហើយរាល់កិច្ចការងារទាំងឡាយ ដែលគេសម្រេចចិត្តធ្វើនៅក្នុងអំឡុងពេលនៃការខឹងក្រោធនោះ តែងហុចមកវិញនូវលទ្ធផលមិនគួរជាទីប្រាថ្នា មិនតែប៉ុណ្ណោះគេរមែងធ្វើឱ្យបាត់បង់នូវសម្រស់របស់ខ្លួនឯង ព្រោះថាមនុស្សទាំងឡាយ ពិតជាមិនចង់ឃើញនូវទឹកមុខរបស់បុគ្គល ដែលកំពុងពោរពេញទៅដោយការខឹងក្រោធនោះឡើយ។ ហេតុដូច្នេះ បុគ្គលគប្បីកំណត់ដឹងនូវទោសនៃការខឹងក្រោធ និងព្យាយាមរិះរកវិធីកម្ចាត់បង់ចោលនូវការខឹងក្រោធ(បើមិនបានទាំងស្រុងទេ ក៏គួរតែអាចធ្វើបានភាគច្រើនដែរ) ដោយការត្រួតពិនិត្យនូវសភាពនៃការខឹងក្រោធនោះថា វាកើតឡើងមកបានយ៉ាងដូចម្ដេច

ហើយរលត់ទៅវិញយ៉ាងដូចម្ដេច ហើយអ្វីដែលមិនអាចបំភ្លេចបាននោះ គឺចាំបាច់ត្រូវតែកុំគិតថា "យើងជាអ្នកខឹង" ឬ "កំហឹងនេះជារបស់យើង" ដោយគ្រាន់តែឱ្យសតិទៅកំណត់ដឹង នូវសភាវៈនៃចិត្តដែលកំពុងខឹងនោះ ធ្វើការសង្កេតនិងត្រួតពិនិត្យចិត្តដែលកំពុងខឹងនោះយ៉ាងយកចិត្តទុកដាក់ទៅតាមសភាពពិតរបស់វា បន្ទាប់មកយើងក៏នឹងបានដឹងច្បាស់ថា ធាតុពិតវាគ្រាន់តែជាសភាពនៃចិត្តមួយប្រភេទ ដែលកើតឡើងហើយនឹងរលត់ទៅវិញប៉ុណ្ណោះ ពោលគឺមិនមានអ្វីដែលអាចឱ្យយើងប្រកាន់មាំបានថា ជារបស់យើងនោះឡើយ។ វិធីនេះអាចនាំទៅប្រើជាមួយនឹងអារម្មណ៍ និងសភាវៈផ្លូវចិត្តដទៃផ្សេងៗទៀតបានទាំងអស់។

## ឧបសគ្គរារាំងផ្លូវចិត្ត

ដើម្បីនឹងឱ្យការបដិបត្តិ "កម្មដ្ឋាន" របស់អ្នក ទទួលបាននូវលទ្ធផលគួរជាទីប្រាថ្នានោះ អ្នកចាំបាច់ត្រូវសិក្សាស្វែងយល់ឱ្យបានជ្រាបច្បាស់ អំពីធម៌ដែលចាត់ថាជាឧបសគ្គ ឬថាជាគ្រឿងរារាំងចិត្តមិនឱ្យងាកទៅរកអំពើជាកុសលបានចំនួន៥យ៉ាងគឺៈ

១. កាមច្ឆន្ទៈ សេចក្ដីប្រាថ្នាឬការពេញចិត្តនៅក្នុងកាម។

២. ព្យាបាទៈ គំនុំ ការចងអាឃាត ឬការប្រាថ្នាចង់ឱ្យអ្នកដទៃវិនាស។

៣. ថីនមិទ្ធៈ ការច្រអូស ធុញទ្រាន់ និងការងងុយដេក ។

៤. ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីរាយមាយ និងសេចក្តីរសាប់រសល់ ឬក្តៅក្រហាយក្នុងចិត្ត ។

៥. វិចិកិច្ឆា សេចក្តីស្ទាក់ស្ទើរ សង្ស័យមិនដាច់ស្រេចនៅក្នុងចិត្ត ។

នីវរណធម៌ទាំង៥យ៉ាងនេះ ចាត់ថាជាឧបសគ្គចំពោះការយល់ច្បាស់នូវសច្ចធម៌ ហើយបើពោលដោយរួមទៅ គឺវាជាឧបសគ្គរារាំងនូវរាល់ការចម្រើនឡើងគ្រប់យ៉ាងផ្នែកផ្លូវចិត្ត ។ ពេលដែលបុគ្គលណាម្នាក់ត្រូវនីវរណៈទាំងនេះគ្របសង្កត់ ហើយគេមិនដឹងនូវវិធីដើម្បីកម្ចាត់វាចេញទៅ ក៏នឹងធ្វើឱ្យបុគ្គលនោះ មិនអាចយល់បានថាអ្វីខុសអ្វីត្រូវ អ្វីល្អអ្វីអាក្រក់ជាដើម ។

## អង្គបញ្ញាជាគ្រឿងត្រាស់ដឹង

បុគ្គលនៅអាចបដិបត្តិ"កម្មដ្ឋាន" តាមគន្លងធម៌ដែលជា "អង្គនៃការត្រាស់ដឹង៧ប្រការ"(ពោជ្ឈង្គ៧)គឺៈ

១. សតិ សេចក្តីរឭកដឹង បានដល់ការរឭកដឹងនូវគ្រប់ភារកិច្ចនិងគ្រប់ឥរិយាបថទាំងខាងផ្នែករាងកាយនិងចិត្តគំនិត ដូចដែលបានអធិប្បាយរួចមកហើយនៅខាងដើម ។

២. ធម្មវិចយៈ ការពិចារណានិងវិភាគនូវបញ្ហា ក៏ដូចជាសាស្ត្រផ្សេងៗ ហើយដែលរួមបញ្ចូលទាំងការសិក្សាខាងផ្នែកសាសនា ចរិយសាស្ត្រនិងទស្សនវិជ្ជា ការអាន ការវិភាគវែកញែក ការដេញដោលការសន្ទនា ព្រមទាំងការចូលរួមស្តាប់ការបកស្រាយពន្យល់ទាក់ទងទៅនឹងគោលការណ៍ច្បាប់ផ្សេងៗ ។

៣. វិរិយៈ សេចក្តីព្យាយាម ពោលគឺធ្វើដោយការពុះពារ រហូតបានសម្រេចដូចការតាំងចិត្ត ។

៤. បីតិ សេចក្តីឆ្អែតចិត្តប្រកបដោយអំណរ ជាគុណសម្បត្តិផ្ទុយទៅនឹងសភាពនៃចិត្ត ដែលរមែងមើលលោកក្នុងផ្លូវអាក្រក់ និងសេចក្តីសោកសៅ ។

**៥. បស្សទ្ធិ ភាវៈនៃចិត្តដែលស្ងប់រម្ងាប់ ។**

៦. សមាធិ ការមានចិត្តតម្កល់មាំ ដូចដែលបានអធិប្បាយហើយនៅខាងដើម ។

៧. ឧបេក្ខា ភាវៈនៃបុគ្គលមានចិត្តជាកណ្តាល ។ ខនេះសំដៅដល់ការដែលអាចមានជីវិតប្រឈមទៅនឹងការផ្លាស់ប្តូរឡើងចុះៗ ដោយចិត្តដែលស្ងប់ ត្រជាក់និងមិនញាប់ញ័រ ។

ការដែលបុគ្គលនឹងអាចបណ្តុះនូវគុណសម្បត្តិទាំងនេះ ឱ្យកើតមានឡើងនៅក្នុងខន្ធសន្តានបាននោះ ចាំបាច់ត្រូវមានសេចក្តីប្រាថ្នា ការ

តាំងចិត្តយ៉ាងមុតមាំ និងការស្ម័គ្រចិត្តយ៉ាងពិតប្រាកដ។ ចំពោះល័ក្ខខ័ណ្ឌទាំងខាងផ្នែកវត្ថុ(រូបធម៌) និងខាងផ្នែកផ្លូវចិត្ត(នាមធម៌) ជាច្រើនផ្សេងទៀត ដែលនឹងអនុគ្រោះឱ្យដល់ការចម្រើននូវគុណសម្បត្តិទាំងនេះ សុទ្ធសឹងមានសេចក្តីអធិប្បាយយ៉ាងពិស្តារនៅក្នុងគម្ពីរផ្សេងៗ។

ក្រៅពីនេះហើយនោះ បុគ្គលនៅអាចបដិបត្តិ"កម្មដ្ឋាន" ដោយការពិចារណានូវរឿងរ៉ាវផ្សេងៗដូចជាខន្ធ៥ ដោយការវិភាគរាវរកថា "អ្វីជាសត្វ ជាបុគ្គល?" ឬថា "អ្វីដែលជាខ្លឹមសារដ៏ពិតប្រាកដនៃជីវិតនេះ" ឬពិចារណានូវអរិយសច្ចៈ៤ តាមដែលបានអធិប្បាយមកហើយនៅខាងដើម។ ការសិក្សានិងពិចារណារាវរករឿងរ៉ាវទាំងនេះ ត្រូវបានចាត់បញ្ចូលទៅក្នុងកម្មដ្ឋានបែបទី៤(ធម្មានុបស្សនា) ដែលអាចនាំទៅដល់ការយល់ច្បាស់នូវបរមសច្ចៈ។

ដោយឡែកពីអ្វីដែលបានអធិប្បាយមកនេះ ក៏នៅមានអារម្មណ៍របស់កម្មដ្ឋានផ្សេងៗជាច្រើនទៀត សរុបទាំងអស់៤០ប្រភេទ ហើយនៅក្នុង៤០ប្រភេទនេះ នឹងលើកយកមកពោលចំពោះតែព្រហ្មវិហារ៤ប្រការប៉ុណ្ណោះគឺ:

១. មេត្តា ការផ្សាយនូវសេចក្តីស្រលាញ់ និងបំណងប្រាថ្នាចង់ឱ្យអ្នកដទៃបានសុខ ដល់មនុស្សសត្វផងទាំងឡាយ ដោយមិនមានទីបំផុត

និងមិនរើសមុខ មិនដូច"មាតាដែលស្រលាញ់ចំពោះតែកូនខ្លួននោះឡើយ"។

២.ករុណា គឺអាណិតអាសូរ និងការជួយសង្គ្រោះចំពោះមនុស្សសត្វផងទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ ដោយប្រាថ្នាចង់ឱ្យគេរួចចាកទុក្ខ។

៣. មុទិតា ការត្រេកអរតាម គឺត្រេកអរនៅពេលដែលដឹងថាអ្នកដទៃ(ទោះជានរណាក៏ដោយ) មានទ្រព្យធន បុណ្យសក្តិ ទទួលបានជោគជ័យក្នុងកិច្ចការងារ ឬថាមានសេចក្តីសុខ សេចក្តីចម្រើនជាដើម ក៏មានចិត្តជួយអរគេ មិនច្រណែននិន្ទាឈ្នានីស(មុទិតានេះជាធម៌ដ៏ប្រសើរបំផុតមួយសម្រាប់មនុស្សគ្រប់ៗរូប)។

៤. ឧបេក្ខា ភាវៈនៃបុគ្គលមានចិត្តជាកណ្តាល គឺដំណើរមិនលំអៀងទៅខាងណា និងមិនរំភើបញាប់ញ័រទៅតាមការផ្លាស់ប្តូរប្រែប្រួលផ្សេងៗនៅក្នុងជីវិត។

ឲឲឲ✲ឲឲឲ

# ជំពូកទី៨

# ព្រះពុទ្ធសាសនាជាមួយលោកបច្ចុប្បន្ន

មានមនុស្សមួយចំនួនគិតថា ព្រះពុទ្ធសាសនាជាសាសនាដែលមានគន្លងបែបផែនដ៏ប្រសើរខ្ពង់ខ្ពស់ ហួសវិស័យដែលសាមញ្ញជនទាំងបុរសនិងស្ត្រីនឹងអាចបដិបត្តិតាមបាន ក្នុងជីវិតតាមបែបលោកិយរបស់យើងទាំងអស់គ្នានេះ ហើយយល់ថាប្រសិនបើនរណាម្នាក់ មានបំណងប្រាថ្នាចង់ឱ្យខ្លួនក្លាយទៅជាពុទ្ធសាសនិកជនយ៉ាងពិតប្រាកដនោះ ចាំបាច់ត្រូវដកខ្លួនចេញពីសង្គមមនុស្ស ទៅរស់នៅតាមវត្តអារាមឬទីកន្លែងស្ងប់ស្ងាត់ផ្សេងៗ។

ខនេះជាការយល់ខុសយ៉ាងគួរឱ្យសោកស្តាយ ដែលបណ្តាលមកពីកង្វះខាតការយល់ដឹងយ៉ាងត្រឹមត្រូវ នៅក្នុងឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់នេះឯង ទើបធ្វើឱ្យមនុស្សទាំងនោះប្រញាប់ធ្វើការវាយតម្លៃយ៉ាងខុសឆ្គងដូច្នេះ មូលហេតុមកពីការដែលខ្លួនគ្រាន់តែបានស្តាប់ឬអានត្រួសៗ ទាក់ទងទៅនឹងជ្រុងតូចមួយនៃព្រះពុទ្ធសាសនា សរសេរឡើងដោយអ្នកនិពន្ធមួយចំនួន ដែលមិនទាន់យល់ច្បាស់នូវព្រះពុទ្ធសាសនាឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ តាមរយៈការផ្តល់នូវទស្សនៈតូចចង្អៀតនិងមានអគតិចំពោះរឿងទាំងនេះ។ ឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់

មិនបានសំដៅតែទៅលើព្រះភិក្ខុសង្ឃនៅក្នុងវត្តប៉ុណ្ណោះទេ តែគឺសម្រាប់សាមញ្ញជនប្រុសស្រី ដែលជាអ្នកគ្រប់គ្រងផ្ទះសម្បែងក្រុមគ្រួសារផងដែរ។ អរិយមគ្គអង្គ៨ គឺជាលំនាំនៃដំណើរជីវិតរបស់ពុទ្ធសាសនិកជនទូទៅ ជាផ្លូវដ៏ស័ក្តិសមសម្រាប់មនុស្សទូទៅ ដោយមិនរើសមុខនោះឡើយ។

## ធម្មៈសម្រាប់មនុស្សគ្រប់ឋានៈ

មនុស្សភាគច្រើននៅលើលោកនេះ ប្រហែលជាមិនអាចបួសជាព្រះសង្ឃ ឬសូម្បីតែគេចខ្លួនទៅរស់នៅតាមល្អាង ឬព្រៃទាំងអស់គ្នាបាននោះឡើយ។ ព្រះពុទ្ធសាសនាដ៏ប្រសើរបរិសុទ្ធផូរផង់ ច្បាស់ជាមិនមានប្រយោជន៏សម្រាប់មនុស្សជាតិឡើយ ប្រសិនបើពួកគេមិនអាចនាំយកមកប្រព្រឹត្តបដិបត្តិ នៅក្នុងជីវិតប្រចាំថ្ងៃក្នុងសង្គមបច្ចុប្បន្នបាន។ ផ្ទុយមកវិញ ប្រសិនបើអ្នកយល់ច្បាស់នូវខ្លឹមសាររបស់ព្រះពុទ្ធសាសនា បានយ៉ាងត្រឹមត្រូវហើយនោះ( មិនមែនគ្រាន់តែដឹងតាមការនិយាយតៗគ្នា) ពិតណាស់អ្នកប្រាកដជាអាចនាំយកមកបដិបត្តិតាមបាន សូម្បីនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នក។

មនុស្សខ្លះអាចនឹងគិតថា វាជាការងាយស្រួលក្នុងការបដិបត្តិនូវពុទ្ធធម៌ ប្រសិនបើគេមានជីវិតរស់នៅក្នុងទីកន្លែងដែលស្ងប់ស្ងាត់ កាត់

ផ្តាច់ចេញពីសង្គម។ ផ្ទុយទៅវិញ មនុស្សមួយចំនួនទៀតអាចនឹងមានការយល់ឃើញថា ការគេចខ្លួនចេញទៅយ៉ាងដូច្នោះ ធ្វើឱ្យជីវិតមានភាពស្ងិតស្រពោន ទទួលរងនូវសម្ពាធ ទាំងខាងផ្លូវកាយនិងផ្លូវចិត្ត ហើយដោយអាស្រ័យវិធីនេះ នឹងមិនអាចប្រព្រឹត្តទៅដើម្បីការលើកកម្ពស់គុណភាពជីវិត ទាំងខាងផ្នែកចិត្តគំនិតក៏ដូចជាពុទ្ធិបញ្ញា។

ការលះបង់(លោក)ដ៏ពិតប្រាកដមិនបានសំដៅតែទៅដល់ ការគេចចេញពីសង្គមមនុស្សដោយផ្លូវកាយនោះឡើយ។ ព្រះសារីបុត្រអគ្គសាវ័ករបស់ព្រះពុទ្ធជាម្ចាស់បានពោលថា បុគ្គលឯណានិមួយអាចនឹងចូលទៅនៅក្នុងព្រៃ ឧទ្ទិសខ្លួនបំពេញនូវតប(តះប៉ះ)ធម៌ ប៉ុន្តែមានចិត្តមិនបរិសុទ្ធ ពេញទៅដោយកិលេសនិងអាសវៈទាំងឡាយ។ រីឯបុគ្គលម្នាក់ផ្សេងទៀតអាចនឹងរស់នៅជាមួយក្រុមមនុស្ស ឬនៅទីប្រជុំជនណាមួយ ដោយមិនបានអនុវត្តតាមបែបផែនរបស់អ្នកបួស ដែលចូលទៅនៅក្នុងព្រៃនោះឡើយ ប៉ុន្តែចិត្តរបស់គេមានសភាពស្អាតបរិសុទ្ធ រួចចាកផុតពីកិលេសជាគ្រឿងសៅហ្មងទាំងឡាយ។ ព្រះសារីបុត្រពោលថា បណ្តាបុគ្គលទាំងពីរពួកនេះ អ្នកដែលមានជីវិតរស់នៅយ៉ាងបរិសុទ្ធជាមួយនឹងសង្គមមនុស្ស រមែងប្រសើរថ្លៃថ្លាជាងបុគ្គលដែលចូលទៅនៅក្នុងព្រៃ (តែចិត្តពេញដោយកិលេស)ជាអនេក។

គំនិតដែលយល់ថា ការបដិបត្តិតាមឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់បាននោះ ចាំបាច់ត្រូវបញ្ចៀសខ្លួនចេញពីសង្គមមនុស្ស ជាគំនិតដែលមិនត្រឹមត្រូវ ចាត់ថាជាគំនិតដែលជាបដិបក្ខចំពោះការបដិបត្តិធម៌ ដោយខ្វះខាតការថ្លឹងថ្លែងពិចារណាឱ្យបានល្អិតល្អន់ជាមុន។ មានឧទាហរណ៍ជាច្រើននៅក្នុងព្រះពុទ្ធសាសនា បានបញ្ជាក់អះអាងអំពីបុគ្គលមួយចំនួនទាំងបុរសនិងស្ត្រី ដែលមានជីវិតរស់នៅតាមបែបសាមញ្ញជន ប៉ុន្តែអាចបដិបត្តិតាមឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ដោយទទួលបានលទ្ធផលល្អ ទាំងនៅអាចធ្វើឱ្យជាក់ច្បាស់បាននៅព្រះនិព្វានថែមទៀតផង។ គ្រាមួយវច្ឆគោត្របរិព្វាជក(ដែលបានពោលនៅក្នុងបទស្តីពីអនត្តា) ធ្លាប់ទូលសួរព្រះពុទ្ធជាម្ចាស់ដោយត្រង់ៗថា "បពិត្រព្រះអង្គដ៏ចម្រើន! តើមានដែរឬទេ ឧបាសក ឧបាសិកាដែលនៅគ្រប់គ្រងផ្ទះសម្បែង បដិបត្តិតាមពាក្យទូន្មានរបស់ព្រះអង្គហើយទទួលបានលទ្ធផលល្អ ដោយសម្រេចបាននូវសភាវៈដ៏ប្រសើរខ្ពង់ខ្ពស់ខាងផ្នែកផ្លូវចិត្តនោះ?"។ ព្រះពុទ្ធអង្គទ្រង់បានសង្កត់យ៉ាងជាក់ច្បាស់ថា "មិនមែនមានត្រឹមតែបុគ្គលម្នាក់ឬពីនាក់ត្រឹមមួយរយឬពីររយនាក់ប៉ុណ្ណោះទេ តែគឺនៅមានឧបាសក ឧបាសិកាច្រើនជាងនេះទៅទៀត ដែលរស់នៅតាមបែបឃរាវាសវិស័យ បដិបត្តិតាមធម្មៈរបស់ព្រះអង្គ ដោយទទួលបាននូវលទ្ធផលល្អ សម្រេចបាននូវសភាវៈដ៏ប្រសើរខ្ពង់ខ្ពស់ខាងផ្នែកផ្លូវចិត្តនោះច្រើនមកហើយ"។

ពិតជាគួរឱ្យអនុមោទនាខ្លាំងណាស់ សម្រាប់លោកដែលមានជីវិតរស់នៅដាច់ចេញឆ្ងាយពីសង្គម នៅតាមទីកន្លែងស្ងប់ស្ងាត់ផ្សេងៗ ប៉ុន្តែគឺពិតជារឹតតែគួរឱ្យអនុមោទនាខ្លាំងជាងនេះទៅទៀតនោះ ប្រសិនបើបដិបត្តិធម៌នៅក្នុងមជ្ឈដ្ឋាន ដែលពោរពេញទៅដោយសភាវៈជាគ្រឿងរំខានចិត្តនៅក្នុងសង្គមមនុស្ស ផ្តល់ការជួយសង្គ្រោះនិងអនុគ្រោះប្រយោជន៍ ឱ្យដល់សង្គមមនុស្សទាំងមូល។ ក្នុងករណីខ្លះវាអាចជាប្រយោជន៍យ៉ាងខ្លាំងសម្រាប់មនុស្សយើង ដែលនឹងបញ្ចៀសខ្លួនចេញទៅបដិបត្តិធម៌មួងម្កាល ដើម្បីជម្រះចិត្តនិងនិស្ស័យរបស់ខ្លួន ដោយការហ្វឹកហាត់សីល សមាធិ និងបញ្ញាឱ្យបានល្អរឹងមាំចាស់ក្លាជាមុនសិន មុននឹងចេញមកដើម្បីបំពេញប្រយោជន៍ឱ្យដល់សង្គមជាក្រោយ។ ដោយឡែកប្រសិនបើបុគ្គលណាមួយ បញ្ចៀសខ្លួនទៅនៅទីស្ងប់ស្ងាត់រហូតមួយជីវិត ប្រាថ្នាតែចំពោះសេចក្តីសុខផ្ទាល់ខ្លួន ដោយមិនគិតទៅដល់មនុស្សដទៃសោះនោះ ពិតណាស់គឺមិនមែនជាការបំពេញខ្លួន ទៅតាមឱវាទទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ដែលមានក្តីមេត្តា ក្តីករុណា និងការអនុគ្រោះប្រយោជន៍ឱ្យដល់សត្វលោកជាមូលដ្ឋាននោះឡើយ។

មានសំនួរមួយបានចោទសួរថា "ប្រសិនបើបុគ្គលអាចបដិបត្តិតាមព្រះពុទ្ធសាសនាខណៈដែលមានជីវិតរស់នៅ បែបឃរាវាសវិស័យបាននោះ ហេតុអ្វីទើបព្រះពុទ្ធជាម្ចាស់ទ្រង់បង្កើតឱ្យមានព្រះសង្ឃ? "។

ព្រះសង្ឃផ្តល់ឱកាសឱ្យបណ្តាជន ដែលពេញចិត្តនឹងឧទ្ទិសជីវិតរបស់ខ្លួន ដោយមិនគ្រាន់តែដើម្បីហ្វឹកហាត់ជម្រះចិត្តនិងចម្រើនពុទ្ធិបញ្ញារបស់ខ្លួនឯងប៉ុណ្ណោះទេ តែគឺដើម្បីអនុគ្រោះប្រយោជន៍ឱ្យដល់ជនដទៃផងដែរ។ គ្រហស្ថដែលនៅគ្រប់គ្រងក្រុមគ្រួសារនិងផ្ទះសម្បែងរមែងមិនអាចឧទ្ទិសជីវិតទាំងមូលរបស់ខ្លួន ដើម្បីប្រយោជន៍របស់អ្នកដទៃបាននោះឡើយ ចំណែកព្រះសង្ឃមិនមានភារៈនិងការទទួលខុសត្រូវចំពោះក្រុមគ្រួសារ មិនមានចំណងនៅក្នុងលោកិយវិស័យ ទើបស្ថិតនៅក្នុងឋានៈដែលអាចឧទ្ទិសជីវិតទាំងមូល **"ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីគុណ ដើម្បីសេចក្តីសុខដល់សព្វសត្វផងទាំងឡាយ"** ដូចដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់ណែនាំទុកមក។

## គោលធម៌សម្រាប់ភាពជាពុទ្ធសាសនិកបុគ្គល

ប្រសិនបើមានសេចក្តីប្រាថ្នាចង់ក្លាយជាពុទ្ធសាសនិកជន ក៏មិនចាំបាច់ត្រូវធ្វើនូវពិធីកម្មអ្វីនោះឡើយ( វៀរលែងតែករណីដែលប្រាថ្នាចង់បួសជាភិក្ខុ ពោលគឺចង់ក្លាយទៅជាសមាជិករបស់គណៈសង្ឃប៉ុណ្ណោះ ដែលអ្នកបួសគប្បីត្រូវឆ្លងកាត់ការសិក្សាហ្វឹកហាត់ខាងផ្នែកវិន័យជាមុនសិន) ។ បើបុគ្គលណាមួយមានការយល់ចូលចិត្ត នូវព្រះធម៌ដែលជាឱវាទ

ទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ មានការជឿជាក់ថាឱវាទទូន្មានរបស់ព្រះអង្គគឺជាមាគ៌ាដ៏ត្រឹមត្រូវ ដែលអាចនាំសត្វឱ្យចាកផុតអំពីសេចក្តីទុក្ខបាន ហើយព្យាយាមប្រព្រឹត្តបដិបត្តិតាមឱវាទទូន្មាននោះ ត្រឹមប៉ុណ្ណោះបុគ្គលម្នាក់នោះគឺមានឈ្មោះថា ជាពុទ្ធសាសនិកជនរួចជាស្រេចទៅហើយ ។ ប៉ុន្តែយោងទៅតាមប្រពៃណីដែលមានការប្រព្រឹត្តតៗគ្នាមក នៅក្នុងប្រទេសដែលគោរពតម្កើងព្រះពុទ្ធសាសនានោះ បុគ្គលនឹងត្រូវគេចាត់ថាជាពុទ្ធសាសនិកជនបាន លុះណាតែបានបង្អោនកាយវាចាចិត្ត សូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដែលយើងនិយមនាំគ្នាហៅជាទូទៅថា "ព្រះរតនត្រ័យ"នោះថាជាទីពឹង ជាទីរលឹក បន្ទាប់មកទើបសមាទានសីល៥(បញ្ចសីល) ដែលជាប្រការសម្រាប់ពុទ្ធសាសនិកបុគ្គលគប្បីវៀរចាកគឺ:

១. វៀរចាករាល់ការសម្លាប់នូវសត្វមានជីវិតគ្រប់ប្រភេទ ។

២. វៀរចាកនូវការកាន់យករបស់ ដែលអ្នកដទៃគេមិនបានឱ្យ (ដោយ កាយ វាចា ឬដោយចិត្ត) ។

៣. វៀរចាកការប្រព្រឹត្តខុសនៅក្នុងផ្លូវកាម(បុត្រ ភរិយា ឬស្វាមីអ្នកដទៃ) ។

៤. វៀរចាកនូវការនិយាយសម្តីមិនពិត (ពាក្យកុហក ញុះញង់ អាសគ្រាម និងពាក្យឥតបានការ) ។

៥. វៀរចាកការសេព(ផឹក ជក់ ចាក់) គ្រឿងស្រវឹងគ្រប់ប្រភេទ(រួមទាំងគ្រឿងញៀនផ្សេងៗផងដែរ)។

តាមរយៈការពោលនូវពាក្យសមាទានទាំងនេះ ដូចដែលមានប្រាកដមកនៅក្នុងគម្ពីរតាំងពីបុរាណ នៅក្នុងពិធីខាងផ្នែកសាសនានៅនាឱកាសផ្សេងៗ ដែលពុទ្ធបរិស័ទនឹងមកប្រជុំគ្នា ហើយពោលនូវពាក្យសមាទានសីល៥នេះទៅតាមព្រះភិក្ខុសង្ឃ។

តាមពិតទៅគឺមិនមានពិធីកម្មឯណានិមួយ ដែលពុទ្ធសាសនិកជនចាំបាច់ត្រូវតែធ្វើដោយខានមិនបាន ដូចដែលយើងធ្លាប់ឃើញនៅក្នុងសាសនាមួយចំនួននោះឡើយ **ត្បិតថាព្រះពុទ្ធសាសនាគឺមិនមែនជាសាសនានៃពិធីកម្ម(សាសនាដែលសម្បូរទៅដោយពិធីផ្សេងៗ) ឬថាជាសាសនានៃការបន់ស្រន់នោះឡើយ**។ ប៉ុន្តែផ្ទុយទៅវិញ ព្រះពុទ្ធសាសនាគឺជាសាសនា ដែលសង្កត់ធ្ងន់ទៅលើការប្រព្រឹត្តបដិបត្តិដោយផ្ទាល់របស់បុគ្គលម្នាក់ៗ ក្នុងបំណងកម្ចាត់បង់នូវបាបអកុសលឱ្យអស់ពីចិត្តប៉ុណ្ណោះ(គ្មានព្រះជាម្ចាស់ណា អាចកម្ចាត់នូវអំពើអាក្រក់ចេញពីក្នុងចិត្តរបស់អ្នកបានឡើយ ប្រសិនបើខ្លួនអ្នកមិនកម្ចាត់វាដោយខ្លួនឯងទេនោះ)។ ពិតហើយថានៅគ្រប់ប្រទេសដែលគោរពព្រះពុទ្ធសាសនា សុទ្ធតែមានពិធីកម្មតាមបែបសាមញ្ញៗនិងគួរឱ្យចាប់អារម្មណ៍នៅក្នុងឱកាសដ៏សំខាន់ផ្សេងៗ ដែលពុទ្ធបរិស័ទនាំគ្នាធ្វើនូវការគោរពបូជា ដោយគ្រឿងសក្ការៈ

មានទៀន ធូប ផ្កាភ្ញីឬប្រទីបជាដើម នៅតាមទីកន្លែងសក្ការៈទាំងឡាយ ដូចជាព្រះសថូប ព្រះសក្យមុនីចេតិយ ព្រះពោធិព្រឹក្ស ឬព្រះពុទ្ធបដិមាជាដើម ប៉ុន្តែខនេះមិនគប្បីយកទៅប្រៀបធៀបជាមួយនឹងអ្នកដែលសូត្រមន្តបន់ស្រន់ បួងសួង នៅក្នុងសាសនាប្រភេទទេវនិយម(សាសនាដែលមានជំនឿថាព្រះអាទិទេព ឬព្រះជាម្ចាស់ជាអ្នកបង្កើតអ្វីៗគ្រប់យ៉ាង) នោះឡើយ ពោលគឺវាគ្រាន់តែជាការថ្វាយនូវការគោរពស្រលាញ់ចំពោះព្រះបរមសាស្តា ដែលទ្រង់ជាអ្នកចង្អុលបង្ហាញផ្លូវឱ្យដល់សត្វលោកប៉ុណ្ណោះ។ មួយវិញទៀត ការបដិបត្តិទៅតាមប្រពៃណីទាំងនេះបើទោះមិនមែនជាខ្លឹមសារដ៏ពិតប្រាកដរបស់ព្រះពុទ្ធសាសនា តែក៏មានប្រយោជន៏សម្រាប់ជាការតបស្នងនូវអារម្មណ៏និងសទ្ធាខាងផ្នែកសាសនាដល់បុគ្គលដែលមានសតិបញ្ញាទន់ខ្សោយនៅឡើយ ហើយថែមទាំងជាការជួយឱ្យគេ បានធ្វើដំណើរទៅតាមផ្លូវនៃអរិយមគ្គបន្តិចម្តងៗ។

## សង្គ្រាមនិងសន្តិភាព

ព្រះពុទ្ធជាម្ចាស់ទ្រង់មានគោលជំហរច្បាស់លាស់របស់ព្រះអង្គទាក់ទងទៅនឹងរឿងនយោបាយ សង្គ្រាមក៏ដូចជាសន្តិភាព។ ឧទាហរណ៏ជាក់ស្តែងដែលយើងរាល់គ្នាបានដឹងច្បាស់ ហើយគួរត្រូវបានលើកយកមកបញ្ជាក់នៅក្នុងទីនេះនោះគឺថា ព្រះពុទ្ធសាសនាប្រកាសផ្សព្វផ្សាយ

នូវអហិង្សធម៌និងសន្តិភាព ក្នុងឋានៈជាសាសន៍សកល និងជាសាសនាដែលជំទាស់ទាំងស្រុងទាក់ទងទៅនឹងការប្រើអំពើហិង្សា ឬការប្រល័យផ្តាច់ផ្តិលជីវិតមិនថាជាប្រភេទណាក៏ដោយចុះ( ក្នុងករណីណាក៏ដោយ) ។

តាមទស្សនៈរបស់ព្រះពុទ្ធសាសនា មិនមានសង្គ្រាមណាមួយដែលអាចហៅបានថាជា"សង្គ្រាមផ្នែកធម្មៈ" ដែលជាពាក្យមួយត្រូវបានគេបញ្ញត្តឡើងមកយ៉ាងខុសឆ្គង ហើយធ្វើការផ្សព្វផ្សាយវាចេញទៅដោយគ្រាន់តែដើម្បីទាមទាររកភាពត្រឹមត្រូវ ក៏ដូចជាដើម្បីដោះសាឱ្យដល់កំហឹង ភាពសាហាវយង់ឃ្នង់ អំពើហិង្សា និងការសម្លាប់រង្គាលរបស់ខ្លួនប៉ុណ្ណោះ ។ តើនរណានឹងជាអ្នកកាត់សេចក្តីបានថា ប៉ែកខាងណាជា"ពួកធម៌" ប៉ែកខាងណាជា"ពួកអធម៌"? អ្នកដែលមានកម្លាំងខ្លាំងហើយជាអ្នកឈ្នះគឺជា"ពួកធម៌" រីឯអ្នកដែលទន់ខ្សោយហើយជាអ្នកចាញ់គឺជា"ពួកអធម៌" ។ សង្គ្រាមរបស់យើងជាសង្គ្រាម"ផ្នែកធម្មៈ"ជានិច្ច ចំណែកសង្គ្រាមរបស់អ្នកឯងជាសង្គ្រាម"ផ្នែកអធម្មៈ"ជានិច្ច ។ ហេតុដូច្នេះហើយ ទើបព្រះពុទ្ធសាសនាមិនព្រមទទួលយកនូវទស្សនៈបែបនេះឡើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់មិនគ្រាន់តែបង្រៀន នូវគោលការណ៍នៃអហិង្សធម៌និងសន្តិធម៌ប៉ុណ្ណោះទេ តែព្រះអង្គផ្ទាល់ក៏ធ្លាប់ស្តេចយាងចូលទៅកាន់សមរភូមិប្រយុទ្ធ ដោយទ្រង់ចូលទៅប្រថាប់គង់នៅចំកណ្តាល

កងទ័ពនៃគូបដិបក្ខ ដើម្បីបញ្ចៀសមិនឱ្យមានសង្គ្រាមកើតឡើង តួយ៉ាង ដូចជានៅក្នុងករណីទំនាស់រវាងពួកនគរសាក្យនិងពួកនគរកោលិយ ដែលកំពុងត្រៀមខ្លួនច្បាំងគ្នា ដោយអាស្រ័យមូលហេតុចេញមកពីការដណ្ដើមទឹកនៅក្នុងស្ទឹងរោហិណី ហើយគ្រាមួយព្រះពុទ្ធដីការបស់ព្រះអង្គក៏បានជួយការពារមិនឱ្យព្រះបាទអជាតសត្រូវ ទ្រង់ប្រើកម្លាំងចូលវាយលុកដែនវជ្ជី(ក្រុងវេសាលី និងមិថិលា)។

## ផ្លូវនៃសន្តិភាព

ការនិយាយទៅដល់ការទ្រទ្រង់សន្តិភាពដោយអាស្រ័យការប្រើកម្លាំងទ័ពក្ដី ឬដោយការគំរាមកំហែងដោយអាវុធយុទ្ធោបករណ៍ក្ដី សុទ្ធសឹងតែជារឿងល្ងង់ខ្លៅ។ អានុភាពនៃអាវុធយុទ្ធោបករណ៍ មានតែបង្កនូវការភ័យខ្លាច ពោលគឺវាមិនអាចសាងនូវសន្តិភាពបាននោះឡើយ។ ហេតុដូច្នេះទើបមិនមែនជាហេតុផល ដែលថាសន្តិភាពដ៏ពិតប្រាកដនិងជាស្ថាពរមួយ នឹងអាចកើតឡើងទៅបាន ទាំងដែលមនុស្សគ្រប់គ្នានៅមានការភ័យខ្លាច ហើយដែលការភ័យខ្លាចនោះមិនយូរមិនឆាប់ ក៏នឹងក្លាយទៅជាកំហឹង ការព្យាបាទ និងអរិភាព(ភាពជាសត្រូវនឹងគ្នា) ដែលពេលខ្លះរឿងទាំងអស់នេះអាចនឹងត្រូវបៀមទុក នៅក្នុងចិត្តបានត្រឹមមួយរយៈពេលខ្លីប៉ុណ្ណោះ តែវាក៏អាចនឹងផ្ទុះចេញជាអំពើហិង្សាបានគ្រប់

ពេល។ សន្តិភាពយ៉ាងពេញលេញនិងពិតប្រាកដ នឹងអាចកើតឡើងបាន ក៏តែក្នុងបរិយាកាសនៃមេត្តា មិត្តភាព ប្រាសចាកការភ័យខ្លាច ការមិនទុកចិត្តគ្នា និងការចងអាឃាតព្យាបាទប៉ុណ្ណោះ។

ព្រះពុទ្ធសាសនាមានគោលដៅសាងសង្គម ដែលប្រឆាំងទៅនឹងការប្រើកម្លាំងមកដោះស្រាយបញ្ហា ក៏ដូចជាដើម្បីដណ្តើមអំណាច ជាសង្គមដែលពោរពេញទៅដោយភាពស្ងប់សុខ(សន្តិភាព) ប្រាសចាកការប្រជែងយកឈ្នះចាញ់ សង្គមដែលមានការប្រឆាំងតវ៉ាទៅនឹងការធ្វើទុក្ខទោសចំពោះមនុស្សបរិសុទ្ធ សង្គមដែលអ្នកឈ្នះខ្លួនឯង ត្រូវបានទទួលនូវការលើកសរសើរខ្លាំងជាង អ្នកដែលឈ្នះមនុស្សរាប់លាននាក់ ដោយការធ្វើសង្គ្រាមផ្នែកយោធានិងសង្គ្រាមសេដ្ឋកិច្ច សង្គមដែលការខឹងក្រោធត្រូវបានយកឈ្នះដោយទឹកចិត្តមេត្តា និងអំពើអាក្រក់ឈ្នះបានដោយអំពើល្អ សង្គមដែលភាពជាសត្រូវ ការច្រណែនឈ្នានីស ការចងគំនុំ សេចក្តីលោភលន់ មិនចូលទៅជំពាក់ជំពិននៅក្នុងទឹកចិត្តរបស់មនុស្ស សង្គមដែលមានភាពករុណាជាកម្លាំង រុញច្រាននូវរាល់កិច្ចការងារទាំងឡាយ សង្គមដែលមានតែសាមគ្គីភាពនិងការស្រលាញ់រាប់អានគ្នា។ គ្រប់គ្នារស់នៅក្នុងលោកនៃការប្រាថ្នាតិច សន្តោសតាមមានតាមបាន មិនធ្លាក់ទៅក្នុងអំណាចនៃវត្ថុនិយម មានគោលដៅតម្រង់ឆ្ពោះ

ទៅរកប្រយោជន៏ដ៏ប្រសើរខ្ពង់ខ្ពស់បំផុត គឺការធ្វើឱ្យជាក់ច្បាស់នូវទីបំផុតនៃសេចក្តីទុក្ខ **ពោលគឺព្រះនិព្វាន** ។

ឈឈឈ✴ឆឆឆ

អាទិត្យ, ៥កើត ខែស្រាពណ៍

ឆ្នាំច ២៥៥០

នាវស្សានរដូវ ១១.៤៩ថ្ងៃត្រង់

# បទានុក្រម

**កណ្ឌ**-អានថា កាន់ (**ន**) ព្រួញ; គ្រាប់កាំភ្លើង; ទង; ដើម; កំណាត់; បរិច្ឆេទ; វគ្គ; ខ្សែ : សាស្ត្រាមួយកណ្ឌ។

**កាមសុខ** (**ន**) សុខក្នុងកាមឬសេចក្តីសប្បាយដែលកើតឡើងអំពីកាម។

**កុសិនារា** (**ន**) ឈ្មោះក្រុងជាទីនៅនៃស្តេចមល្លរាជ ក្នុងមជ្ឈិមប្រទេស ក្នុងជាន់ពុទ្ធសម័យ, ព្រះសក្យមុនីគោតមទ្រង់ចូលបរិនិព្វានក្នុងឧទ្យាន ជិតក្រុងនេះ។

**គណាចារ្យ**-អានថា គៈ ណា ចា (**ន**) ក្រុមគ្រូបង្រៀន។

**គ្រហស្ថ**-អានថា គ្រ ហ៊ាស់ (**ន**) អ្នកមានផ្ទះ, អ្នកគ្រប់គ្រងផ្ទះ គឺអ្នកមានគ្រួសារ។

**ចេតសិកធម៌**-អានថា ចេ តៈ សិ កៈ ធ័រ (**ន**) សភាវៈដែលប្រកបផ្សំនឹងចិត្ត កើតរលត់ព្រមជាមួយនឹងចិត្ត។

**ញាណ** (**ន**) សេចក្តីដឹង, ប្រាជ្ញា : ទ្រង់ញាណ(ព្រះពុទ្ធ) ទ្រង់ជ្រាបច្បាស់នូវកិច្ចការអាថិកំបាំងជ្រាលជ្រៅផ្សេងៗដោយព្រះប្រាជ្ញា ។

**តក្កវិទ្យា** (**ន**) វិជ្ជាត្រិះរិះ គឺចំណេះខាងការពិចារណារិះរកហេតុផលដែលប្លែក អោយឃើញប្រាកដដោយគំនិតខ្លួនឯង, វិជ្ជាសម្រាប់ត្រិះរិះ

រាវរកខាងរបៀបបែបបទក្នុងការនិយាយស្តីឬក្នុងកិច្ចការផ្សេងៗ អោយបានត្រឹមត្រូវសមរម្យទៅតាមលក្ខណៈនៃហេតុផល ។

**តណ្ហាសវៈ**-អានថា តន់ ហា ស: វ: (**ន**) កិលេសជាគ្រឿងត្រាំគឺតណ្ហាដែលញ៉ាំងសត្វទាំងឡាយឱ្យសៅហ្មង ។

**តថាគត**-អានថា ត: ថា គត់ (**ន**) ព្រះនាមវិសេសនៃព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គ ។ ប្រើជាបុរិសសព្វនាមផ្ទាល់ព្រះអង្គ ជាជំនួសពាក្យថា "ខ្ញុំ" ។

**តបធម៌**-អានថា ត: ប៉: ធ័រ (**ន**) ធម៌សម្រាប់ប្រព្រឹត្តដើម្បីដុតបំផ្លាញកិលេស ដែលជាគ្រឿងសៅហ្មងនៅក្នុងចិត្ត ។

**ថេរៈ** (**ន**) ភិក្ខុអ្នកមានចិត្តខ្ជាប់ខ្ជួន គឺភិក្ខុដែលបានបួសយូរឆ្នាំហើយយ៉ាងតិចត្រឹម១០ឆ្នាំឡើងទៅ ហៅថាបួសបាន១០វស្សាហើយ : គួរគោរពព្រះថេរៈ , ព្រះថេរៈនិមន្តមក ។ បើជាភិក្ខុនីហៅថា **ថេរី** ។

**ទស្សនវិជ្ជា** (**ន**) វិជ្ជាដែលកើតឡើងដោយទស្សនៈ , វិទ្យាសាស្ត្រថែងអំពីគោលការណ៍សំខាន់ៗ និងបុព្វហេតុផ្សេងៗ ឬអំពីជីវិតនៃមនុស្សនិងសត្វ ។

**ទស្សនវិទូ** (**ន**) អ្នកប្រាជ្ញខាងទស្សនវិជ្ជា : ព្រះពុទ្ធជាទស្សនវិទូឯកក្នុងលោក ។

**ទុទិដ្ឋិនិយម** (ន) ការនិយមចំពោះទុទិដ្ឋិ, សេចក្តីចូលចិត្តក្នុងទ្រឹស្តីថាអាក្រក់, សេចក្តីប្រកាន់ខ្ជាប់ក្នុងទ្រឹស្តីថាលំបាក, ការចូលចិត្តឬការយល់ឃើញថារបស់អ្វីក្នុងលោកសុទ្ធតែអាក្រក់, សុទ្ធតែប្រកបដោយទុក្ខលំបាក ។

**ធ្យាន** (ន) សភាវៈដ៏ប្រសើរខ្ពង់ខ្ពស់ខាងផ្នែកផ្លូវចិត្ត ដែលសម្រេចបានតាមរយៈការបដិបត្តនូវសមាធិ, ឈាន ។

**និក្ខេបបទ**-អានថា និក ខេ ប៉ះ បត់ (ន) បទឬមាតិការឿងដែលលើកយកមកដាក់ជាគោល ដើម្បីអធិប្បាយពង្រីកសេចក្តីអោយសមល្មមស្តាប់បាន ។ ពាក្យនេះសព្វថ្ងៃប្រើសំដៅយកសៀវភៅដែលបេក្ខជនតែងឡើង ហើយដាក់អោយគណៈមេប្រយោគពិនិត្យ ក្នុងការប្រលងយកថ្នាក់បណ្ឌិតផ្នែកវិជ្ជាណាមួយ ។

**និគ្រន្ថ**-អានថា និ គ្រន់ (ន) បព្វជិតពួកមួយបួសក្រៅពុទ្ធសាសនាប្រកាន់លិទ្ធថា ខ្លួនជាមនុស្សក្សាត់កិលេសដែលចាក់ស្រេះនៅក្នុងសន្តាន អោយជ្រះអស់ហើយ ។

**និវេទនកថា**-អានថា និ វេ ទៈ នៈ កៈ ថា (ន) ពាក្យជូនដំណឹង, ឱ្យដំណឹង, ប្រាប់ដំណឹងពីកិច្ចការឬពីស្ថានការណ៍ផ្សេងៗ ដែលគួរឱ្យដឹងឱ្យយល់ : និវេទនកថាក្នុងខាងដើមសៀវភៅ... ។

**នីវរណៈ**-អានថា នី វ: រ: ណ: (ន) ធម៌រារាំង, ឃាត់ឃាំងទប់ចិត្តមិនឱ្យងាកទៅរកអំពើជាកុសល, មាន៥យ៉ាងគឺ ១. កាមច្ឆន្ទៈ សេចក្តីប្រាថ្នា ឬការពេញចិត្តចំពោះកាម; ២. ព្យាបាទៈ គំនុំ ឬសេចក្តីគុំកួនធ្វើឱ្យអ្នកដទៃវិនាស; ៣. ថីនមិទ្ធៈ ការច្រអូសធុញទ្រាន់ និងការងងុយដេក; ៤. ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីរាមមាយនិងសេចក្តីរសាប់រសល់ ឬក្តៅក្រហាយក្នុងចិត្ត; ៥. វិចិកិច្ឆា សេចក្តីសង្ស័យមិនដាច់ស្រេចនៅក្នុងចិត្ត។

**បរមសាស្តា**-អានថា ប រ៉ុម ម៉: សា ស្តា (ន) គ្រូដ៏ប្រសើរក្រៃលែង, ព្រះនាមនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ។

**បញ្ចវគ្គីយ**-អានថា ប៉ុញ ច: វ័ក គី (ន) ក្រុមអ្នកបួស៥នាក់ដែលបានចេញបួសក្នុងបំណងតាមបំរើព្រះពុទ្ធជាម្ចាស់ និងដែលបានទទួលស្តាប់នូវព្រះធម៌មុនដំបូងគេបង្អស់។

**បរមត្ថធម៌** (ន) សច្ចធម៌មានអត្ថដ៏ឧត្តម ឬក្រៃលែង(ព្រះអភិធម្ម)។

**បសាទសម្ផស្ស**-អានថា ប៉: សាត សំ ភាស់ (ន) អាយតនៈសម្រាប់ទទួលសម្ផស្សដឹងអារម្មណ៍ គឺគ្រឿងពិសេសដែលមានប្រចាំតាមធម្មជាតិនៅក្នុងរូបកាយមនុស្ស សត្វ សម្រាប់ទទួលដឹងនូវអារម្មណ៍ពីខាងក្រៅដែលមកប៉ះពាល់។

**បុរិសសព្វនាម**-អានថា ប៉ុ រិ ស: សប់ ព: នាម (ន) ស័ព្ទប្រើជំនួសឈ្មោះមនុស្ស; សត្វ; ឬវត្ថុនានាដោយចំពោះ ប៉ុន្តែមិនចេញចំឈ្មោះ

នោះទេ ដោយយកពាក្យដទៃផ្សេងពីនោះមកជំនួសវិញមានពាក្យថា ព្រះអង្គ , លោក , អ្នក , គេ , គាត់ , វា , ឯ , អា , ហង , ខ្ញុំ , ព្រះអង្គ , ខ្ញុំព្រះករុណា , ខ្ញុំបាទ , គេ , ខ្ញុំឯង , អញខ្ញុំ , ខ្ញុំម្ចាស់ , អាត្មាភាព , អាត្មាអញ , យើង , យើងខ្ញុំ ...។

**ប្រត្យក្សភាព**-អានថា ប្រ ត្យ័ក ភាព (**គុ**) ឬ (**កិ.វិ**) ដែលជាក់, ប្រាកដ, ច្បាស់, មែន, ពិត។

**ព្រហ្មចរិយធម៌**-អានថា ព្រះ ហ្មះ ចៈ រ៉ិ យ៉ះ ធ័រ (**ន**) បែបបទ ឬសណ្ដាប់ធ្នាប់របស់ព្រហ្មចារីឬព្រហ្មចារិនី; ការប្រព្រឹត្តធម៌ដ៏ប្រសើរ។ តាមន័យខាងពុទ្ធសាសនាថា ការឱ្យទាន, ការខ្វល់ខ្វាយឬខ្នះខ្នែងចំពោះអំពើជាអកុសល, ការរក្សាសីល៥, ការចំរើនព្រហ្មវិហារ៤, ការសំដែងធម៌ឬណែនាំពន្យល់ឱ្យអ្នកដទៃកាន់អំពើសុចរិត, ការវៀចាកមេថុនធម្ម, សេចក្ដីសន្ដោសចំពោះភរិយារបស់ខ្លួន, សេចក្ដីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការកុសល, ការរក្សាឧបោសថសីលតាមកាលកំណត់, អរិយមគ្គ, ព្រះពុទ្ធសាសនាទាំងមូល, អធ្យាស្រ័យ(ទាំង១២យ៉ាងនេះ)ហៅថាព្រហ្មចរិយ ឬព្រហ្មចារ្យ(ហៅថាព្រហ្មចរិយធម៌ក៏បាន)។

**ព្រះដ៏មានព្រះភាគ** (**ន**) ព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ។

**ភិក្ខុ**-អានថា ភិក ខុ (**ន**) សមណៈអ្នកសូម, សមណៈអ្នកខ្លាចភ័យក្នុងវដ្ដសង្សារ,អ្នកខ្លាចបាបជានិច្ច, អ្នកមានព្យាយាមដុតបំផ្លាញអំពើអាក្រក់

ខាងពុទ្ធសាសនាហៅចំពោះតែបុរសអ្នកបួស ដែលមានភេទឧត្តមជាងសាមណេរ ៖ ភិក្ខុច្រើនរូប, បួសភិក្ខុ, លោកភិក្ខុ ។ ភិក្ខុភាព, ភិក្ខុភាវ ឬភិក្ខុភាវៈ ដំណើរបានទទួលឧបសម្បទាជាភិក្ខុ គឺការបានភេទជាលោកភិក្ខុ ។ ភិក្ខុសង្ឃ ប្រជុំភិក្ខុច្រើនតាំងពី៤រូបឡើងទៅ ។

**ភិយ្យោភាព**-អានថា ភី យោ ភាប (ន) ដំណើរច្រើនក្រៃលែង, ភាវៈលើសលែង ។

**មជ្ឈិមនិកាយ**-អានថា ម័ច ឈិ មៈ និ កាយ (ន) ឈ្មោះគម្ពីរព្រះសុត្តន្តបិដកមួយពួក តបន្ទាប់ពីគម្ពីរទីឃនិកាយមក ។

**មហាយាន** (ន) យានធំ ។ ឈ្មោះពួកពុទ្ធសាសនិកដែលបែកលទ្ធិចេញផ្សេងច្រើនអន្លើ ឃ្លាតពីលទ្ធិដើមដូចយ៉ាងពួក អ្នកកាន់ពុទ្ធសាសនានៅប្រទេសចិន , ជប៉ុន , វៀតណាមជាដើម ហៅថាពួកមហាយាន ឬលទ្ធិមហាយាន សំដៅសេចក្ដីថា "ពួកឬលទ្ធិមានធម៌ជាយានដ៏ប្រសើរ" (ជាគូគ្នានឹងហីនយាន ; ហៅថាអាចរិយវាទី "អ្នកពោលតាមលទ្ធិអាចារ្យ (របស់ខ្លួន)" ក៏បាន(ជាគូគ្នានឹងថេរវាទ ឬថេរវាទី) ហៅថាឧត្តរនិកាយ "ពួកខាងជើង" ក៏បាន(ជាគូគ្នានឹងទក្ខិណនិកាយ) ។ ពួកឬលទ្ធិទាំងនេះកើតមានឡើង(មុនដំបូងក្នុងមជ្ឈិមប្រទេស) តាំងពីក្នុងខាងដើមសតវត្សរ៍ទី២នៃពុទ្ធសករាជតរៀងមក ។

**មិច្ឆាទិដ្ឋិ** (**ន**) សេចក្តីយល់ឃើញខុស គឺដំណើរយល់ខុសអំពីសេចក្តីពិត ដូចយ៉ាងយល់ឃើញថា មាតាបិតាគ្មានគុណ , សត្វទាំងអស់ស្លាប់ហើយ លែងកើតទៀតជាដើម ។

**យសោធរាពិម្ពា**-អានថា យៈ សោ ធៈ រា ពិម ពា (**ន**) ស្ត្រីអ្នកទ្រទ្រង់យស ; ព្រះនាមក្សត្រីមួយអង្គជាកន្សែសពេជ្ជនៃព្រះសក្យមុនីគោតម (ព្រះនាងពិម្ពា) ។

**លោកុត្តរធម៌**-អានថា លោ កុត តៈ រ៉ៈ ធ័រ (**ន**) ធម៌ចម្លងសត្វអោយចេញផុតចាកលោក គឺមគ្គ៤ , ផល៤ , និព្វាន១ ។

**វិញ្ញាណ** (**ន**) ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ កើតឡើងក៏តែអាស្រ័យដោយការប៉ះទង្គិច រវាងអាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅប៉ុណ្ណោះ(នឹងកើតឡើងចំពោះមនុស្សស្លាប់នោះគឺពុំមានឡើយ) ។

**សក្យមុនី**-អានថា ស័ក ក្យ៉ៈ មុ នី (**ន**) អ្នកប្រាជ្ញរបស់ពួកសាក្យ(ព្រះសមណគោតមបរមគ្រូ) ។

**សង្សារវដ្ត**-អានថា សង់ សា រៈ វ៉ៃត (**ន**)ដំណើរវិលកើតវិលស្លាប់(គ្មានទីបញ្ចប់) ។

**សម្មាសម្ពុទ្ធ** (**ន**) លោកអ្នកត្រាស់ដឹងឯងដោយប្រពៃ(ព្រះពុទ្ធអង្គ) ។

**សាយ័ណ្ហសម័យ**-អានថា សា យ៉ុន ហះ សៈ ម៉ៃ (ន) វេលារសៀល, ពេលល្ងាច : វេលាសាយ័ណ្ហ ; ហៅសាយ័ណ្ហកាល ឬ សាយ័ណ្ហសម័យក៏បាន ។

**សាស្ដា**-អានថា សា ស្ដា (ន) គ្រូ, គ្រូប្រៀនប្រដៅ, គ្រូប្រដៅសាសនា ; ព្រះសព្វញ្ញុពុទ្ធ ។ ខ្មែរហៅចំពោះព្រះពុទ្ធថាព្រះសាស្ដាចារ្យ ។

**សិរិមហាមាយា**-អានថា សិ រិ ម ហា មា យា (ន) ព្រះនាមរបស់ព្រះអគ្គមហេសីនៃព្រះបាទសិរីសុទ្ធោទនៈ( ព្រះមាតានៃព្រះសម្មាសម្ពុទ្ធ) ។

**សុទិដ្ឋិនិយម** (ន) ការនិយមចំពោះសុទិដ្ឋិ, ការនិយមដោយទិដ្ឋិត្រូវ, ការចូលចិត្តឬការយល់ឃើញថារបស់អ្វីក្នុងលោកសុទ្ធតែល្អ, សុទ្ធតែប្រសើរសុខស្រួល ។

**សុទ្ធោទនៈ**-អានថា សុត ធោ ទៈ នៈ (ន) បាយសុទ្ធ ឬ បាយ-ស ។ ព្រះនាមព្រះវរបិតានៃព្រះសក្យមុនីគោតម : ព្រះបាទសុទ្ធោទនៈពុទ្ធបិតា ឬ ព្រះបាទស្រីសុទ្ធោទនក្សត្រិយ៍ក្រុងកបិលពស្ដុ ។

**សុន្ទរភាព**-អានថា សុន ទៈ រៈ ភាព (ន) ភាពល្អ, សេចក្ដីល្អ ។

**សំយោជន**-អានថា ស័ង យោ ជៈ នៈ (ន) កិលេសជាគ្រឿងប្រកបចិត្ត គឺកិលេសរឹងត្អឹងជាគ្រឿងទាក់ឆ្វាក់រួបរឹត ដែលអាស្រ័យនៅនឹងចិត្ត ។

**អដ្ឋកថាចារ្យ**-អានថា អ័ត ថៈ កៈ ថា ចា (ន) គ្រូផ្នែកគម្ពីរអដ្ឋកថា ។

**អនាគាមិផល** (ន) លោកុត្តរផលរបស់អនាគាមិបុគ្គល ។

**អនុត្តរសម្មាសម្ពោធិញ្ញាណ**-អានថា អៈ នុត តៈ រ៉ៈ ស័ម ម៉ា ស័ម ពោ ធិ ញាណ (**ន**) ប្រាជ្ញាជាគ្រឿងធ្វើអោយត្រាស់ដឹង(នូវសច្ចធម៌) ដោយខ្លួនឯងនិងដោយប្រពៃរកការដឹងដទៃប្រដូចស្មើគ្មាន ; ប្រាជ្ញានៃព្រះពុទ្ធ ។

**អនេកបរិយាយ** (**ន**) បរិយាយច្រើន , ដែលមានបរិយាយច្រើន ។

**អភិវាទន៏**-អានថា អៈ ភិ វាត (**ន**) កិរិយាថ្វាយបង្គំ , ការគំនាប់ , ការសំពះ ឬ ការក្រាបសំពះដោយគោរព ។

**អរហន្ត** (**ន**) អ្នកឆ្ងាយចាកកិលេស គឺអ្នកដែលបានសំរេចលោកុត្តធម៌ផុតថ្នាក់ : អរហន្តគឺអ្នកដែលសំរេចអរហត្ត(បើស្រ្តីជា **អរហន្តី**) ។

**អវតារ**-អានថា អៈ វៈ តា (**ន**) ដំណើរឆ្លងចុះ(ពីមួយទៅមួយជាលំដាប់គ្នា) , លំដាប់ត១គ្នា , ការបែងភាគ ។

**អវិជ្ជា** (**ន**) ការមិនដឹងច្បាស់ , សេចក្តីល្ងង់ , មោហៈ ឬ មោហោ ។

**អសោក**-អានថា អៈ សោក (**គុ**) ដែលឥតសោក , ឥតស្តាយស្រណោះ (**ន**) ព្រះនាមព្រះរាជាមួយព្រះអង្គក្នុងប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទី៣នៃពុទ្ធសករាជ ជាក្សត្រមានតេជានុភាពច្រើន ជាពុទ្ធសាសនូបត្ថម្ភកៈទ្រង់បានទំនុកបំរុងព្រះពុទ្ធសាសនាដោយពេញព្រះសមត្ថភាព ។

**អាមិស** (**ន**) សាច់(ដែលប្រើជាអាហារ) ; នុយ ; របស់ជាគ្រឿងទាក់ចិត្ត ឬជាគ្រឿងជន្លជន្លេញចិត្ត ; លាភៈ ; សក្ការៈ ឬលាភសក្ការៈ ; ទាន ; ទេយ្យទាន ឬទេយ្យវត្ថុ ; ចតុប្បច្ច័យ ; អាហារ ។ល។

**អាយតនៈ (ន)** លំនៅនៃអារម្មណ៍ ; ទីប្រជុំនៃអារម្មណ៍មានពីរប្រភេទ គឺ អាយតនៈខាងក្នុង( ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត) និង អាយតនៈខាងក្រៅ( រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍) ។

**អាវុសោ (ន)** អាលបនទិបាត មានសេចក្តីថា "អ្នកមានអាយុ" សម្រាប់ភិក្ខុចាស់វស្សានិយាយទៅរកភិក្ខុខ្ចីវស្សាជាង ឬនិយាយទៅរកសាមណេរ ( ប្រើបានទាំងឯក. ទាំងពហុ.) ។

**ឥន្ទ្រិយវត្ថុ (ន)** អាយតនៈខាងក្នុងទាំង៦ រួមមាន : ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត ។

**ឥសិបតនៈ**-អានថា ឥ សិ ប៉ះ តះ នះ **(ន)** ឈ្មោះភូមិប្រទេសមួយ កន្លែងនៅក្នុងប្រទេសឥណ្ឌាប៉ែកកណ្តាល ជាទីដែលព្រះសព្វញ្ញុពុទ្ធទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រជាបឋមទេសនារបស់ព្រះអង្គ( ទីនោះសម័យបច្ចុប្បន្ននេះហៅសានាថ នៅជិតក្រុងពារាណសី) ។

**ឧបសម្បទា**-អានថា អ៊ុ ប៉ះ ស័ម ប៉ះ ទា **(ន)** ការដល់នូវភាពជាភិក្ខុ ឬ ការបានជាភិក្ខុភាព គឺការបួសជាភិក្ខុ( ដោយញត្តិចតុត្ថកម្មវាចា តាមលក្ខណប្បញ្ញត្តិក្នុងវិន័យពុទ្ធសាសនា) ។

**ឧបាសក (ន)** សិស្សសាសនា , អ្នកដល់ព្រះរត្នត្រ័យជាទីពឹង ឬជាទីរឭក គឺគ្រហស្ថដែលចូលកាន់ពុទ្ធសាសនាស៊ប់ ហើយកាន់សីល- ធម៌ខ្ជាប់ខ្ជួន តាមច្បាប់ពុទ្ធសាសនិកជនជាគ្រហស្ថ( បើជាស្ត្រីហៅថា**ឧបាសិកា** ) ។

**ឧបេក្ខា** (ន) ការតាំងចិត្តជាកណ្ដាល , សេចក្ដីព្រងើយកន្ដើយ , ដំណើរមិនលម្អៀងទៅខាងណា ។

**ឯកគ្គតា**-អានថា អេ ក័ក គៈ តា (ន) ដំណើរតាំងនៅមូលស្ងួនក្នុងអារម្មណ៍តែមួយ ; ដំណើរមូលចិត្តស្លួងក្នុងអារម្មណ៍តែមួយ ។

☞☞☞🕮☜☜☜

"ម្នាលព្រាហ្មណ៍! វាប្រៀបដូចទឹកដែលហូរធ្លាក់ពីលើភ្នំ ហូរឆ្ងាយហើយលឿន នាំយកអ្វីៗគ្រប់យ៉ាងទៅព្រមគ្នាជាមួយនឹងទឹកនោះ មិនមានខណៈ(មិនមានការឈប់ជាបណ្តោះអាសន្នណាមួយ ក្នុងខណៈកំពុងហូរធ្លាក់មកនោះ) មិនមានច្រំដែល មិនមានជាលើកទីពីរនៅពេលដែលវាឈប់ហូរ ប៉ុន្តែវាហូរទៅនិងហូរបន្តទៅរឿយៗ។ ព្រាហ្មណ៍! ជីវិតមនុស្សក៏ដូច្នោះដែរ ប្រៀបដូចទឹកដែលហូរធ្លាក់ពីលើភ្នំ"


ព្រះពុទ្ធទ្រង់បង្រៀនអ្វី?
ធម្មទាន
ព.ស ២៥៥៥
ជីន គុសល
គេហទំព័រ៥០០០ឆ្នាំ
www.5000-years.org